

# ធនធានទន្លេ គឺជាអាយុជីវិតរបស់យើង

"ការស្រាវជ្រាវដោយអ្នកភូមិ គឺជាចំនុចគន្លឹះ ដ៏សំខាន់មួយសំរាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព"




អាស័យដ្ឋាន : ផ្ទះលេខ ៥៩ ផ្លូវលេខ ១៥៦ ស,ង ផ្សារដេប៉ូ១ ខណ្ឌទួលគោក ភ្នំពេញ

ទូរស័ព្ទ និងទូរសារ : ០២៣ ៨៨១ ៦១៣ និង ០២៣ ៣៦៩ ១៧៦

ទូរស័ព្ទចល័ត : ០១២ ៧៩៣ ៤៨៩ និង ០១២ ៨៩៥ ៦២៤

ប្រអប់សំបុត្រ : P.O.Box: 1486, CCC Box: 357

សារអេឡិចត្រូនិច : tek@cepa-cambodia.org

cepa@cepa-cambodia.org



ISBN-9789995092337


ធនធានទន្លេ គឺជាអាយុជីវិតរបស់យើង

# អន្លង់ និងធនធានទន្លេ សេសាន សេកុង និងស្រែពក ខេត្តស្ទឹងត្រែង

# *Pools and River Resources of SeSan, Sekong and Srepok Rivers, Stung Treng province*



ការផ្សាយរបស់សមាគមថែរក្សាបរិស្ថាន និងវប្បធម៌

**សមាគមថែរក្សាបរិស្ថាន និង វប្បធម៌ (សេប៉ា_CEPA)** បានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដោយនិស្សិតមួយក្រុម ជាអង្គការមិនមែនរដ្ឋាភិបាល មិនរកកំរៃ មិនពាក់ព័ន្ធនឹងគណបក្សនយោបាយ ឬក្រុមនយោបាយណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃនៅឆ្នាំ១៩៩៦។

**ទស្សនៈវិស័យ**

សេប៉ាប្រាថ្នាចង់បាននូវ : សង្គមឯករាជ្យមួយដែលថែរក្សាបាននូវវប្បធម៌ និងបរិស្ថានដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ស្ថិរភាព និងសុវត្ថិភាពសំរាប់កូនខ្មែរជំនាន់ក្រោយ។

**គោលដៅ**

ធានាអោយបាននូវការថែទាំ និងការពារបរិស្ថាន និងធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយសមធម៌ឆ្ពោះទៅរកនិរន្តរភាពនៃការប្រើប្រាស់ និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និងកូនខ្មែរជំនាន់ក្រោយ ។

**បេសកកម្មរបស់សេប៉ា គឺ**

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយថ្នាក់មូលដ្ឋាន និងរាជរដ្ឋាភិបាលដើម្បីលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាពលរដ្ឋ និងជំរុញអោយមានការការពារបរិស្ថាន និងវប្បធម៌របស់ខ្លួនតាមរយៈការស្រាវជ្រាវ ការអប់រំ ការផ្លាស់ប្តូរ ព័ត៌មាន-បទពិសោធន៍ និងការបណ្តុះបណ្តាលសកម្មជន។
- បង្កើននូវឱកាសសំរាប់សហគមន៍ក្នុងការលើកស្ទួយជីវភាពរបស់ពួកគាត់ និងអនុវត្តនូវគោលការណ៍សមភាព និងសមធម៌រវាងបុរស និងនារីដើម្បីធានាបាននូវការថែរក្សាប្រពៃណី វប្បធម៌ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។
- ពង្រឹងនូវសិទ្ធិរបស់ប្រជាជនមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយសមភាព និងសមធម៌។
- ជំរុញការងារបណ្តាញក្នុងការទំនាក់ទំនងជាមួយនឹងអ្នកពាក់ព័ន្ធដើម្បីធានាបាននូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងថែរក្សានូវវប្បធម៌អន្តោគ្រាម ។

**សកម្មភាព និងយុទ្ធសាស្រ្ត**

- កម្មវិធីការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (គម្រោងសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ)
- កម្មវិធីតស៊ូមតិដើម្បីការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព (គម្រោងគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព គម្រោងតស៊ូមតិថ្នាក់ជាតិ-អន្តរជាតិ និងគម្រោងផ្សព្វផ្សាយ និងគេហទំព័រ)
- កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស (គម្រោងបណ្តុះបណ្តាលសកម្មជនបរិស្ថាន សហគមន៍ និងបុគ្គលិក)





**កែសម្រួលអត្ថបទ និងរៀបចំ**

លោក តឹក វណ្ណារ៉ា
លោក វង្ស គង្គា
លោក ពាក្យ សាវ៉ែន
លោក ស៊ិន ឆាំ
លោក ហុង ឆាយ
ក. ជ័យ សូនីរ៉ា
ក. ធីម បុប្ផា
ក. សូផាន កញ្ចនា
ក. អ៊ុម សុផាណារី
ក. អ៊ិត ចាន់ធឿន

**គណៈកម្មការត្រួតពិនិត្យ**

លោក ទេព ប៊ុណ្ណារិទ្ធ
លោក ប៊ូ សារឿន
លោក តឹក វណ្ណារ៉ា
លោក ហាក់ វិមាន
លោក យេន រុន
លោកស្រី លុយ រស្មី

**រចនាទំព័រ និងថតរូប**

លោក តឹក វណ្ណារ៉ា
លោក ហុង ឆាយ
ក. អ៊ុម សុផាណារី
ក. អ៊ិត ចាន់ធឿន

**ស្រាវជ្រាវដោយៈ**

អ្នកភូមិតាមដងទន្លេសេសាន សេកុង និងស្រែពក ក្រោមការសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសពីបុគ្គលិកសមាគមថែរក្សាបរិស្ថាន និងវប្បធម៌, មន្ទីរបរិស្ថាន និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តស្ទឹងត្រែង( សូមមើលក្នុងឧបសម្ព័ន្ធ២ ខាងក្រោយ)

# តារាងមាតិកា

**ទំព័រ**


សេចក្តីថ្លែងអំណរគុណ...... .......... X

បុព្វកថា.......... XII

បញ្ជីអក្សរកាត់ .......... XVI

**ជំពូក ១ : សេចក្តីផ្តើម**

១.១ សេចក្តីផ្តើម.......... ១

១.២ ស្ថានភាពទូទៅ.......... ២

១.៣ គោលបំណងនៃការសិក្សា.......... ៣

១.៤ ទំហំនៃការសិក្សា .......... ៣

**ជំពូក ២ : វិធីសាស្ត្រសិក្សាស្រាវជ្រាវ**

២.១ វិធីសាស្ត្រក្នុងការវាស់វែង.......... ៥

២.២ វិធីសាស្ត្រក្នុងការពិភាក្សាក្រុម .......... ៥

២.៣ សម្ភារៈប្រើប្រាស់ .......... ៧

**ជំពូក ៣ : លទ្ធផលនៃការសិក្សាស្រាវជ្រាវ**

***អន្លង់នៅតាមបណ្តោយ ទន្លេសេកុង***

៣ .១ ភូមិញ៉ាងស៊ុំ ឃុំថ្មកែវ.......... ១០

៣.១.១ អន្លង់ ហ៊ុលម៉ាន ឬអូរល្វា .......... ១២

៣.១.២ អន្លង់ អូរតានេល.......... ១៥

៣.១.៣ អន្លង់ ជួរខាន់ម៉ាកហ្មឿង (វ៉ឺនតាឡើក) អន្លង់ជួរស្តី.......... ១៧





៣.១.៤ អន្លង់ អន្លង់ថ្មដា (វ៉ឺនហ៊ីនឡាត) .......... ២០

៣.១.៥ អន្លង់ អូរកាន់លឿង ( ដើមក្តុល) .......... ២២

៣.១.៦ អន្លង់ អូរតូច(វ៉ឺនហួយណយ) .......... ២៥

៣.១.៧ អន្លង់ តាភីឡា.......... ២៧

៣.១.៨ អន្លង់ អូរទុងលុង.......... ២៩

៣.២ ភូមិអូរចាយ ឃុំសន្តិភាព .......... .......... ៣១

៣.២.១ អន្លង់ វ៉ាយាំ.......... ៣៣

៣.៣ ភូមិសៀមប៉ាង ឃុំសេកុង .......... ៣៦

៣.៣.១ អន្លង់ តាកាឡាំង .......... ៣៧

៣.៣.២ អន្លង់ អូរសៃ.......... ៤០

៣.៤ ភូមិបានមួង ឃុំសេកុង .......... .......... ៤២

៣.៥ ភូមិកែងញៀ ឃុំសេកុង .......... ៤២

៣.៥.១ អន្លង់ គគីរ .......... ៤៤

៣.៥.២ អន្លង់ ជួរធំ (វ៉ឺនកែងញៀ) .......... ៤៧

៣.៥.៣ អន្លង់ ខាន់នីមួន( ជួរខាន់នីមួន) .......... ៤៩

៣.៥.៤ អន្លង់ រន្ទះបាញ់( តែង ហ្វាកផា) .......... ៥២

៣.៦ ភូមិពាមខិៈ ឃុំស្រែសំបូរ.......... ៥៤

៣.៦.១ អន្លង់ ជួរពាមខិៈ ( តែងប៉ាខិៈ) .......... ៥៦

៣.៧ ភូមិកេតមឿង ឃុំស្រែសំបូរ .......... ៥៨

៣.៧.១.អន្លង់ អូរតាឡួន.......... ៦០

៣.៧.២ អន្លង់ អូរក្រឡាក់ រឺ អន្លង់អូរកាឡាក់.......... ៦៣

៣.៨ ភូមិកញ្ចោញទឹក ឃុំស្រែសំបូរ.......... ៦៦

៣.៨.១ អន្លង់ កំពង់ថ្ម ( ថាហ៊ីន) .......... ៦៦

៣.៨.២ អន្លង់ ប៉ាតង(ត្រីក្រាយ)..........................................................................៧០

៣.៨.៣ អន្លង់ គែ(សង្កែ).......................................................................................៧២

៣.៨.៤ អន្លង់ ហ៊ីនដាង(ថ្មពាល)...............................................................................៧៤

៣.៨.៥ អន្លង់ អូរគៀន(អូររទេះ)...............................................................................៧៧

៣.៨.៦ អន្លង់ ខាន់ដាយនាងនាគ(ជណ្តើរនាងនាគ)......................................................៧៩.

៣.៨.៧ អន្លង់ វ៉ឺនតាញ៉ូង......................................................................................៨១

**អន្លង់នៅតាមបណ្តោយ ទន្លេស្រែពក**

៣.៩ ភូមិស្រែស្រណុក ឃុំក្បាលរមាស..................................................................៨៤

៣.៩.១ អន្លង់កោះអណ្តែត.....................................................................................៨៦

៣.៩.២ អន្លង់ កំពង់ជ្រៃ.......................................................................................៨៩

៣.៩.៣ អន្លង់ ពាមអូរស្វូ......................................................................................៩២

៣.៩.៤ អន្លង់កំពង់ទឹក.........................................................................................៩៤

៣.១០ ភូមិក្បាលរមាស ឃុំក្បាលរមាស...................................................................៩៧

៣.១០.១ អន្លង់ ពក.............................................................................................៩៩

៣.១០.២ អន្លង់ក្បាលភូមិ.....................................................................................១០១

៣.១០.៣ អន្លង់កណ្តាលភូមិ..................................................................................១០៤

៣.១០.៤ អន្លង់ កុតប៊ូ(អន្លង់ត្រីជីរ)........................................................................១០៧

៣.១១ ភូមិក្របីជ្រុំ ឃុំក្បាលរមាស.......................................................................១១០

៣.១១.១ អន្លង់ កាងតាយោក.................................................................................១១២

៣.១១.២ អន្លង់លុងម៉ាតាយ (អន្លង់ធ្លាក់ភ្លែងាប់)..........................................................១១៤

៣.១១.៣ អន្លង់ហ៊ីនឡាត(អន្លង់ថ្មលាត)...................................................................១១៦



**អន្លង់នៅតាមបណ្តោយទន្លេសេសាន**

៣.១២ ភូមិសាមឃួយ ឃុំសាមឃួយ...........................................................................១១៩

៣.១២.១ អន្លង់ សាម៉ាខយតូច(អន្លង់ជំរាលថ្មតូច)...................................................១២១

៣.១២.២ អន្លង់ សាម៉ាខយធំ(អន្លង់ជំរាលថ្មធំ)........................................................១២៣

៣.១២.៣ អន្លង់ តាហិង.......................................................................................១២៥

៣.១២.៤ អន្លង់ យាយសាត់...................................................................................១២៦

៣.១២.៥ អន្លង់ យាយផានី...................................................................................១២៧

៣.១៣ ភូមិបាដើម ឃុំសាមឃួយ .........................................................................១២៨

៣.១៣.១ អន្លង់ ហ៊ីនឡាត(អន្លង់ថ្មលាត).................................................................១២៨

៣.១៣.២ អន្លង់ កំពង់វត្តបាឌើម...........................................................................១៣១

៣.១៤ ភូមិហាងសាវ៉ាត ឃុំសាមឃួយ .................................................................១៣២

៣.១៤.១ អន្លង់ ចឹកស៊ី .....................................................................................១៣២

៣.១៤.២ អន្លង់ ណាយ៉ាក់ ..................................................................................១៣៤

៣.១៤.៣ អន្លង់ ហ៊ីនស៊ូងក្រោម(ថ្មខ្ពស់ក្រោម)..........................................................១៣៥

៣.១៤.៤ អន្លង់ ហ៊ីនស៊ូងលើ(ថ្មខ្ពស់លើ)................................................................១៣៧

៣.១៥ ភូមិសេសាន ឃុំកំភុន ............................................................................១៣៩

៣.១៥.១ អន្លង់ ខាន់ថានី....................................................................................១៣៩

៣.១៥.២ អន្លង់ ហ៊ីនខែ(អន្លង់ថ្មក្រពើ)..................................................................១៤២

៣.១៥.៣ អន្លង់ ហ៊ីនស៊ូង(អន្លង់ថ្មខ្ពស់).................................................................១៤៤

៣.១៦ ភូមិបានម៉ៃ ឃុំកំភុន ............................................................................១៤៦

៣.១៦.១ អន្លង់ យាយមីត ឬ អន្លង់តាឡិក..............................................................១៤៦

៣.១៦.២ អន្លង់ យាយហៅ.......................................................................១៥០

៣.១៦.៣ អន្លង់ សាលា....... ...................................................................១៥២

៣.១៧ ភូមិកំភុន ឃុំកំភុន ...............................................................................១៥៣

៣.១៧.១ អន្លង់ កំពង់ចំឡង(ថាខាម)..........................................................១៥៥

៣.១៧.២ អន្លង់ យាយលិក...........................................................................១៥៧

៣.១៧.៣ អន្លង់ តាម៉ៅ...............................................................................១៥៩

៣.១៧.៣ អន្លង់ អូរចាប...............................................................................១៦១

៣.១៨ ភូមិបានប៊ុង ឃុំភ្លុក ...............................................................................១៦៣

៣.១៨.១ អន្លង់ ផ្តៅ(ប៊ុងវាយ)......................................................................១៦៣

៣.១៨.២ អន្លង់ ថ្មពុះ..................................................................................១៦៦

៣.១៨.៣ អន្លង់ អ្នកតា.................................................................................១៦៨

៣.១៨.៤ អន្លង់ សាមផាន់ឬក្លែងព័រ ..........................................................១៧១

៣.១៩ ភូមិភ្លុក ឃុំភ្លុក ...............................................................................១៧៣

៣.១៩.១ អន្លង់ ខកម៉ាធំ ខកម៉ាខាងជើង អន្លង់ក្រោលសេះខាងជើង...........១៧៣

៣.១៩.២ អន្លង់ ខកម៉ាតូច រឺខកម៉ាខាងត្បូង ក្រោលសេះខាងត្បូង..............១៧៨

៣.១៩.៣ អន្លង់ វ៉ឺនស្អីក..............................................................................១៨០

៣.១៩.៤ អន្លង់ប៉ាពេ(ផាផៃ) .....................................................................១៨២

៣.១៩.៥ អន្លង់ កោះព្រឹត .........................................................................១៨៤

៣.១៩.៦ អន្លង់ វ៉ឺនចាន់.បាពីត.......................................................................១៨៦

៣.១៩.៧ អន្លង់ ហាតខាវ(ឆ្នេរខ្សាច់សរ)......................................................១៨៨

៣.១៩.៨ អន្លង់ ហាងឡម អន្លង់កន្ទុយរួម........ .......................................១៩០

៣.១៩.៩ អន្លង់ ហ្សឿឡាវ៉ឿ .......................................................................១៩២

៣.១៩.១០ អន្លង់ ហ៊ីនខៀវ(អន្លង់ថ្មខៀវ)....... ...........................................១៩៤



៣.១៩.១១ អន្លង់ វ៉ឺនតាប៉ិត..........................................................................១៩៦

៣.១៩.១២ អន្លង់ ខនតែ...............................................................................១៩៩

៣.១៩.១៣ អន្លង់ ជួអ្នកតា(អន្លង់ថាជា)....................................................២០១

៣.១៩.១៤ អន្លង់ ប៊ុងថាក់ឡាំង......................................................................២០៣

៣.២០ ភូមិស្រែគរ១ ឃុំស្រែគរ...........................................................................២០៧

៣.២០.១ អន្លង់វ៉ឺនហ៊ៃ....... .......................................................................២០៩

៣.២០.២ អន្លង់កន្ទួត....................................................................................២១១

៣.២០.៣ អន្លង់ ផាសាលុះ... ........................................................................២១៣

៣.២០.៤ អន្លង់តាលី.....................................................................................២១៥

៣.២០.៥ អន្លង់សាលា...................................................................................២១៧

៣.២០.៦ អន្លង់ ប៉ាកាន់................................................................................២២០

៣.២០.៧ អន្លង់ ផាស៊ី...................................................................................២២២

៣.២១ ភូមិស្រែគរ២ ឃុំស្រែគរ...........................................................................២២៤

៣.២១.១ អន្លង់ ត្រី(អន្លង់ប៉ា)......................................................................២២៦

៣.២១.២ អន្លង់ ឃ្មួន....................................................................................២២៨

៣.២១.៣ អន្លង់ ពោន...................................................................................២៣០

៣.២១.៤ អន្លង់ ហាតសែង .........................................................................២៣២

៣.២១.៥ អន្លង់ ពន្លាក....... .........................................................................២៣៤

៣.២២ ភូមិខ្សាច់ថ្មី ឃុំតាឡាត ...........................................................................២៣៦

៣.២២.១ អន្លង់ កន្ទក់....... .........................................................................២៣៨

៣.២២.២ អន្លង់ ជជួរ...................................................................................២៤០

៣.២២.៣ អន្លង់ តាសួស................................................................................២៤២

៣.២២.៤ អន្លង់ ក្រពើ..................................................................................២៤៤

៣.២២.៥ អន្លង់ អង់កូរ.................................................................................២៤៦

៣.២២.៦ អន្លង់កំបោរ..................................................................................២៤៨

៣.២៣ ភូមិក្រឡាពុះ ឃុំតាឡាត....... ..................................................................២៥១

៣.២៣.១ អន្លង់ គែន ...................................................................................២៥៣

៣.២៣.២ អន្លង់ ស្វាយ........................................................................២៥៥
៣.២៣.៣ អន្លង់ អូរក្រឡាពុះ..................................................................២៥៧
៣.២៤ ភូមិស្វាយរៀង ឃុំតាឡាត ..........................................................២៦០
៣.២៤.១ អន្លង់ កោះព្រៅ.......................................................................២៦០
៣.២៤.២ អន្លង់ ស្នំ................................................................................២៦៤
៣.២៤.៣ អន្លង់ យាយសាត.......................................................................២៦៦
៣.២៤.៤ អន្លង់ អូរឫស្សី ( អន្លង់អាខាំ)......................................................២៦៩
៣.២៥ ភូមិរំពាត់ ឃុំតាឡាត ..................................................................២៧២
៣.២៥.១ អន្លង់ យក្សប្រាយ ....................................................................២៧២
៣.២៥.២ អន្លង់ ខ្ទួច..............................................................................២៧៦
៣.២៥.៣ អន្លង់ កំប៉ូតធំ..........................................................................២៧៨
៣.២៦ ភូមិតាឡាត ឃុំតាឡាត.................................................................២៨១
៣.២៦.១ អន្លង់ កំពង់ព្រះ.......................................................................២៨១
៣.២៦.២ អន្លង់ ស្រែគល់........................................................................២៨៥
៣.២៦.៣ អន្លង់ គោល.............................................................................២៨៧

**ជំពូក ៤ សន្និដ្ឋាន និង អនុសាសន៍**

៤.១ សេចក្តីសន្និដ្ឋាន..............................................................................២៩០
៤.២ អនុសាសន៍ ....................................................................................២៩១
៤.៣ ឯកសារយោង...................................................................................២៩១

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១ .......................................................................................២៩២
ឧបសម្ព័ន្ធ ២ .......................................................................................២៩៤



# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកស្រាវជ្រាវយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះមន្ទីរធនធានទឹក និងឧត្តុនិយមខេត្តស្ទឹងត្រែង អភិបាលស្រុកសេសាន អភិបាលស្រុកសៀមប៉ាង មេឃុំនិងក្រុមប្រឹក្សា ឃុំថ្មកែវ ឃុំសន្តិភាព ឃុំសេកុង ឃុំស្រែសំបូរ ឃុំតាឡាត ឃុំស្រែគរ ឃុំភ្លុក ឃុំកំភុន ឃុំសាមឃួយ និងឃុំក្បាលរមាស ព្រមទាំងមេភូមិចំនួន ២៦ភូមិនៅតាមបណ្តោយដងទន្លេសេសាន សេកុង និង ស្រែពក ដែលបានគាំទ្រ និងជំរុញលើកទឹកចិត្តដល់ប្រជាជនតាមមូលដ្ឋាន ជាពិសេសដល់ការសិក្សាស្រាវជ្រាវដែលរៀបចំឡើងដោយក្រុមអ្នកភូមិ ក្នុងការប្រមូលព័ត៌មានពីអន្លង់ និងធនធានទន្លេសេសាន សេកុង និងស្រែពក ដើម្បីចូលរួមចំណែកលើកកម្ពស់ចំណេះដឹងរបស់សហគមន៍ក្នុងការអភិរក្ស និងប្រើប្រាស់ធនធានទន្លេប្រកបដោយនិរន្តរភាព។

ជាមួយគ្នានេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក **ទេព ប៊ុណ្ណារិទ្ធ** នាយកប្រតិបត្តិសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ និងលោក **តឹក វណ្ណារ៉ា** មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងតស៊ូមតិនៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ដែលបានផ្តួចផ្តើមគំនិតបង្កើតឱ្យមានការសិក្សាស្រាវជ្រាវអំពីអន្លង់ និងធនធានទន្លេ តាមដងទន្លេសេសាន សេកុង និងស្រែពកដោយអ្នកភូមិនេះឡើង និងផ្តល់នូវប្រឹក្សាល្អៗដល់ដំណើរការសិក្សាស្រាវជ្រាវទាំងមូល ព្រមទាំងត្រួតពិនិត្យលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ រចនាទំព័រ និងការបោះពុម្ពផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវដោយអ្នកភូមិនេះឡើង។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក **ម៉ូ សារឿន** មន្ត្រីឯកទេសទំនាក់ទំនងព័ត៌មាននៃធនាគារពិភពលោក លោក **ហាក់ វិមាន** អនុប្រធានមន្ទីរបរិស្ថាន និងជា-នាយកតំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង កញ្ញា **សុផាន គព្វនា** អ្នកសម្របសម្រួលសហគមន៍ដើម្បីឱ្យមានការផ្លាស់ប្រែនៃអង្គការទស្សនៈពិភពលោក (World Vision) កញ្ញា **ជា សីលា**

អ្នកសម្របសម្រួលសហគមន៍នៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC) កញ្ញា អ៊ុម សុផាណារី កញ្ញា អ៊ិត ចាន់ធឿន និងលោក ហុង ឆាយ ដែលជាបុគ្គលិកស្ម័គ្រចិត្តនៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ដែលបានចូលរួមវិភាគទានដ៏មានតំលៃក្នុងការត្រួតពិនិត្យលើលទ្ធផលនៃការសិក្សាស្រាវជ្រាវដោយអ្នកភូមិអំពីអន្លង់ និងធនធានទន្លេសេសាន សេកុង និងស្រែពក ខេត្តស្ទឹងត្រែង ដើម្បីសំរេចបានសមិទ្ធិផលជាសៀវភៅដ៏សំខាន់ នេះ។

ទន្ទឹមនឹងនេះ ក្រុមការងារស្រាវជ្រាវយើងខ្ញុំ ក៏មិនភ្លេចថ្លែងអំណរគុណជាពិសេស ចំពោះលោក **ខង្ស គន្ធា** មន្រ្តីគំរោងគ្រប់គ្រងធនធានទឹក លោក **ពាក្យ សារ៉េន** មន្រ្តីជំនួយការគំរោងគ្រប់គ្រងធនធានទឹក កញ្ញា **ជ័យ សុនីរ៉ា** មន្រ្តីជំនួយការគំរោងសហគមន៍ព្រៃឈើ កញ្ញា **ឆឹម បុប្ផា** មន្រ្តីជំនួយគំរោងសហគមន៍ទេសចរណ៍ធម្មជាតិភូមិរ៉ើនសៀននៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ហៅកាត់ថា អង្គការសេប៉ា និងលោក **ស៊ិន ឆាំ** អនុប្រធានការិយាល័យជលសាស្ត្រនៃមន្ទីរធនធានទឹក និងឧតុនិយមខេត្តស្ទឹងត្រែង ដែលបានគាំទ្រផ្នែកបច្ចេកទេស ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការប្រមូលព័ត៌មានអំពីរុក្ខជាតិ ប្រភេទត្រី អន្លង់ និងធនធានទន្លេ ព្រមទាំងជួយសម្របសម្រួលដល់ដំណើរការស្រាវជ្រាវជាមួយក្រុមអ្នកស្រាវជ្រាវតាំងពីដើមរហូតដល់ចប់ ហើយទទួលបានលទ្ធផលជាផ្លែផ្កាដ៏ល្អប្រសើរ ជាទីមោទនភាពបំផុតសំរាប់អ្នកភូមិតាមបណ្តោយដងទន្លេសេសាន សេកុង និងស្រែពក និង សមាគមថែរក្សា-បរិស្ថាន និងវប្បធម៌ (CEPA) ក្នុងការចូលរួមចំណែកអភិរក្ស និងអភិវឌ្ឍន៍ធនធានទន្លេប្រកបដោយនិរន្តរភាព និងសង្គមជាតិយើង។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរ ដល់ម្ចាស់ជំនួយដូចជាអង្គការ FORUM-SYD, OXFAM AMERICA, SWEDISH SOCIETY FOR NATURE CONCERVATION រាជរដ្ឋាភិបាល និងគ្រប់ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ចំពោះការគាំទ្រគ្រប់បែបយ៉ាងដល់សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) ក្នុងការឈានទៅសំរេចទស្សនៈវិស័យដ៏យូរអង្វែងរបស់សមាគម។



# បុព្វកថា

ទន្លេមេគង្គបានហូរកាត់ខេត្តស្ទឹងត្រែងពីជើងទៅត្បូង ។ នៅទីរួមខេត្តទន្លេមេគង្គបានជួបប្រសព្វជាមួយទន្លេសេកុង ដែលបានភ្ជាប់ដៃទន្លេចំនួនពីរទៀត គឺទន្លេសេសាន និងស្រែពក។ ទន្លេទាំងអស់ស្ថិតនៅភាគខាងលើដែលមានអន្លង់ជ្រៅៗ តំបន់ទឹកជួរ និងព្រៃលិចទឹកជាច្រើន។ ការជួបប្រសព្វនេះ មិនត្រឹមតែផ្តល់នូវផ្លូវនាវាចរទេ គឺថែមទាំងផ្តល់នូវសារៈសំខាន់ជាជម្រកត្រីពងកូន និងផ្លូវធ្វើបំលាស់ទីរបស់វា។ ធនធានទាំងអស់នេះ ត្រូវការការពារព្រោះវាជាជម្រកសំរាប់ប្រភេទត្រី ពិសេសមួយចំនួនដូចជា ត្រីត្រសក់ ត្រីរាជ ត្រីគល់រាំង និងត្រីប៉ាស៊ីអ៊ីជាដើម។ មានប្រជាជនប្រមាណ៩0%បានរស់នៅតាមបណ្តោយទន្លេទាំងបួន ហើយបានពឹងអាស្រ័យលើការនេសាទសំរាប់បរិភោគប្រចាំថ្ងៃ និងបង្កើតប្រាក់ចំណូល។ ការជួបគ្នារវាងទន្លេមេគង្គ និងដៃនានារបស់វានៅទីរួមខេត្ត គឺមិនត្រឹមតែបានផ្តល់នូវធនធានធម្មជាតិដ៏មហាសាលនោះទេ វាថែមទាំងបានបង្កើតនូវចំនុចយុទ្ធសាស្ត្រចម្បងមួយសំរាប់ការតាំងទីលំនៅរបស់ប្រជាជន និងការធ្វើពាណិជ្ជកម្មផងដែរ។

ទន្លេនីមួយៗ តែងតែមានលក្ខណៈពិសេសរបស់វា សំរាប់អោយសត្វមានជីវិតនានារស់នៅបានស្រួលដូចជា មានអន្លង់ជ្រៅៗ ព្រៃលិចទឹក ផ្ទាំងថ្មធំៗ ជួរថ្ម ជួរទឹក ធនធានជលផលកោះ ប្រព័ន្ធជីវចំរុះ និងប្រព័ន្ធបរិស្ថានជាដើម ដែលជាទីជម្រក និងប្រភពធនធានចំណីអាហារសំរាប់ទ្រទ្រង់សត្វមានជីវិតទាំងនោះ និងជីវភាពរស់នៅរបស់ប្រជាជនដែលកំពុងមានវត្តមានតាមបណ្តោយដងទន្លេសេសាន សេកុង និងស្រែពក។

ដើម្បីលើកកម្ពស់ និងបង្កើនការយល់ដឹងដល់អ្នកភូមិតាមដងទន្លេសេសាន សេកុង និងស្រែពកអំពីសារៈសំខាន់នៃធនធានទន្លេ អន្លង់ និងប្រព័ន្ធជីវចំរុះ ដែលមាននៅក្នុងទន្លេទាំងនេះ ក្នុងគោលបំណងជំរុញឱ្យប្រជាជនយល់ដឹងកាន់តែច្បាស់ពីធនធានទាំងនេះ ដើម្បីចូលរួមក្នុងការអភិរក្ស និងអភិវឌ្ឍន៍ធនធានទន្លេសំរាប់ធ្វើការប្រើប្រាស់ប្រកបដោយនិរន្តរភាព ទាំងពេលបច្ចុប្បន្ន និងអនាគត។ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ហៅកាត់ថា អង្គការសេប៉ា បាន

ធ្វើការលើកទឹកចិត្តដល់អ្នកភូមិចំនួន១៥៩នាក់ (ស្រី៥១នាក់)នៅក្នុងភូមិចំនួន២៦ ឃុំចំនួន ១០ តាមដងទន្លេសេសាន សេកុង និងស្រែពក ក្នុងស្រុកសេសាន និងសៀមប៉ាង នៃខេត្តស្ទឹងត្រែង ដែលក្នុងនោះមានចំនួន១៥ភូមិ និង ៥ឃុំ តាមដងទន្លេសេសាន ៨ភូមិ និង៤ឃុំតាមដងទន្លេសេកុង ព្រមទាំង៣ភូមិ និង១ឃុំ នៅតាមដងទន្លេស្រែពក ធ្វើការសិក្សាស្រាវជ្រាវអំពីអន្លង់ និងធនធានទន្លេសេសាន សេកុង និងស្រែពក។ ចំពោះការសិក្សាស្រាវជ្រាវនេះក្រុមយើងខ្ញុំបានចំណាយពេលវេលាអស់ចំនួន៤០ថ្ងៃ សំរាប់ធ្វើការស្រង់ព័ត៌មាននៅក្នុងភូមិ ចំនួន ២៦ នៅតាមដងទន្លេទាំងបី ហើយចំណាយពេលវេលាចំនួន៣ខែ បន្ថែមទៀតសំរាប់ធ្វើការវិភាគព័ត៌មាន និង សរសេររបាយការណ៏លទ្ធផលនៃការសិក្សាស្រាវជ្រាវ។ ដូច្នេះយើងខ្ញុំបានប្រើប្រាស់ពេលវេលាសរុប ចំនួន៤ខែ ១០ថ្ងៃ សំរាប់ការងារសិក្សាទាំងមូល។

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដើម្បីចងក្រងព័ត៌មានទុកជាឯកសារស្រាវជ្រាវបន្ត សំរាប់កូនចៅជំនាន់ក្រោយៗអោយបានដឹង និងប្រើប្រាស់ ហើយចេះធ្វើការប្រៀបធៀបគ្នាអំពីធនធានទន្លេ និងអន្លង់ដែលមាននាពេលអតីតកាល បច្ចុប្បន្ន និងសំរាប់ទៅអនាគត ។

ការសិក្សានេះ បានដំណើរការទៅបានទទួលលទ្ធផលល្អក៏ដោយសារតែ មានការជួយជ្រោមជ្រែងអស់ពីកំលាំងកាយ កំលាំងចិត្តពីសំណាក់អាជ្ញាធរមូលដ្ឋាន (លោកអភិបាលស្រុក លោកមេឃុំ មេភូមិ) និងជាពិសេសក្រុមការងារសហគមន៏គ្រប់គ្រងធនធានទឹកនៅតាមភូមិនីមួយៗ ព្រមទាំងចាស់ទុំដែលរស់នៅក្នុងភូមិទាំងនោះ។

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដោយអ្នកភូមិ ដូច្នេះរាល់ព័ត៌មានទាំងអស់ដែលជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ គឺវាមានអត្ថន័យស៊ីជំរៅទៅលើបែបគុណភាព និងសង្គមច្រើនជាងផ្នែកវិទ្យាសាស្ត្រ។ ហើយលទ្ធផលនៃការស្រាវជ្រាវនេះ គឺជាការបើកផ្លូវដំបូងមួយសំរាប់បរិបទខេត្តស្ទឹងត្រែង ដើម្បីនាំផ្លូវឱ្យអ្នកឯកទេសសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រធ្វើការសិក្សាស្រាវជ្រាវបន្តទៀត ក្នុងការស្វែងរកព័ត៌មានពិតប្រាកដបែបវិទ្យាសាស្ត្រ ដើម្បីចូលរួមអភិរក្ស និងអភិវឌ្ឍន៏អន្លង់ និងធនធានទន្លេសេសាន សេកុង និងស្រែពកប្រកបដោយនិរន្តរភាព។



# *Preface*

*The Mekong River's water flow across the Stung Treng province from the south to the north. At the Stung Treng provincial town, Mekong River intersects Sekong River with other two tributaries are SeSan and Srepok Rivers. The intersection of these rivers provides not only navigation but also a lot of important sources of fish species and fish's habitats. These resources have to protect many kinds of fish such as TreyTrasak, Trey Reach, Trey Kolrang and Trey Pase-e etc.*

*90% of people live along these four rivers depend on fishing for their food security and general income. The intersection of these rivers at Stung Treng town provides huge natural resources and creates keys strategic points for settlement of people and do business.*

*Each river has also special characteristic for many species living. For example, deep pools, flooded forest, rocks, waterfalls, islands, ecological systems, and environmental systems etc are the habitats and food sources to support living of these species and livelihood of people live along the Mekong, SeSan, Sekong and Srepok Rivers.*

*we promote and increase people's awareness along the SeSan, Sekong and Srepok rivers about river resources in deep pools and ecological systems in these rivers in order to help villagers understand clearly about these valuable resources. After they have knowledge, they must participate in conservation and development of these important natural resources for sustainability.*

*The objectives of research study to collect information about deep pools and river resources along the SeSan, Sekong and Srepok rivers to make a basic document for villagers, readers and researchers understand and sustainable use of these resources in the present and the future.*

*To achieve these objectives, Culture and Environment Preservation Association (CEPA) has encouraged 159 villagers (women:51) in 26 villages and 10 communes along the SeSan, Sekong and Srepok Rivers in the SeSan district and Siem Pang district of Stung Treng Province which has 15 villages, 5 communes along the SeSan river, 8 villages, 4 communes along the Sekong river and 3 villages in 1 commune along the Srepok river to do research on deep pools river resources of SeSan, Sekong and Srepok rivers. In this research study, research team has spent*

*40 days for information collecting in 26 villages along these three rivers and other three months for information analysis and report writing of research results. So, our team spent 4 months and 10 days for whole research study.*

*The research study received very good result because we have been full supported by the chief of villages, commune chiefs, commune council, SeSan district chief and Siem Pang district chief, especially water resource community working group in each village and elders in these villages.*

*This research study was done by villagers, so, all the information of research result has deeply meaningful qualitative and social rather than scientific research. The result of this research is the first opening way of Stung Treng context in order to guide to other researchers continue to do scientific research for contributing in sustainable conservation and development of deep pools and river resources along the SeSan, Sekong and Srepok Rivers.*



## បញ្ជីអក្សរកាត់

- **គ.ម** : **គីឡូម៉ែត្រ**
- **ម** : **ម៉ែត្រ**
- **ស.ម** : **សង់ទីម៉ែត្រ**
- GPS : Geography Position System

## ឧបករណ៍ប្រើប្រាស់ដើម្បីសិក្សាស្រាវជ្រាវ

- បញ្ជីសំណួរ
- ម៉ែត្រវាស់
- ខ្សែវាស់
- GPS
- ទូកម៉ាស៊ីន និង ទូកចែវ

# សេចក្តីផ្តើម

ស្ទឹងត្រែងជាខេត្តមួយដែលស្ថិតនៅភូមិភាគឦសាននៃប្រទេសកម្ពុជា ដែលមានទីតាំងនៅដាច់ឆ្ងាយពីរាជធានីភ្នំពេញ ហើយយើងអាចធ្វើដំណើរទៅកាន់ខេត្តនេះបានតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។ ខេត្តនេះមានទេសភាពយ៉ាងស្រស់ត្រកាល បើធៀបទៅនឹងបណ្តាខេត្តផ្សេងៗទៀត ដោយសារវាមានទន្លេបួនគឺ ទន្លេមេគង្គ សេសាន សេកុង និងស្រែពក ដែលសំបូរទៅដោយព្រៃឈើ ព្រៃលិចទឹក អន្លង់ និងកោះតូចៗនៅតាមដងទន្លេ។ ធនធានធម្មជាតិទាំងនេះ គឺជាកំលាំងចលករជួយលើកសម្រស់ខេត្តឱ្យកាន់តែស្រស់តាមបែបធម្មជាតិបន្ថែមទៀត ដោយពុំសូវមានការបំពុលបរិស្ថាន[១] ។

ទន្លេមេគង្គមានប្រភពមកពីភាគខាងកើតនៃខ្ពង់រាបទីបេ ប្រទេសចិន, ទន្លេសេសាន មានប្រភពមកពីតំបន់ខ្ពង់រាបកន្ទុំ និងចាក់ឡាយនៃប្រទេសវៀតណាម, ទន្លេសេកុង មានប្រភពមកពីខ្ពង់រាបប្រទេសវៀតណាម ហើយហូរកាត់ប្រទេសឡាវមុននឹងហូរចាក់ចូលខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា, និងទន្លេស្រែពក មានប្រភពមកពីខ្ពង់រាបដាឡាត់នៃប្រទេសវៀតណាម។

ជារួមខេត្តស្ទឹងត្រែងចែកជា៥ស្រុករួមមានៈ ស្រុកសេសាន សៀមបូក សៀមប៉ាង ស្ទឹងត្រែង និងថាឡាបរិវ៉ាត់ ហើយមានឃុំសរុបចំនួន៣៤ឃុំ និងភូមិចំនួន១២៧ នៅទូទាំង ខេត្តមានប្រជាជនសរុបចំនួន ១៤.៩៦0គ្រួសារ ស្មើនឹង ៧៧.៣៧២នាក់ ។

ខេត្តស្ទឹងត្រែងនាពេលបច្ចុប្បន្ន កំពុងចាប់ផ្តើមធ្វើសមាហរណកម្មទាំងផ្នែកសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធទៅក្នុងសង្គម និងតំបន់ (ឡាវ និងវៀតណាម)។ នេះគឺជាឱកាសដ៏ល្អមួយសំរាប់

១. តឹក វណ្ណារ៉ា (២០០៦), សក្តានុពលនៃការអភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិបែបសហគមន៍តាមដងទន្លេមេគង្គភាគខាងលើនៃប្រទេសកម្ពុជា ករណីសិក្សា ស្រុក ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង, និក្ខេបបទបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកការអភិវឌ្ឍសេដ្ឋកិច្ចកសិកម្ម បោះពុម្ពដោយសាកលវិទ្យាល័យភូមិន្ទកសិកម្ម ឆ្នាំ ២០០៦ ទំព័រ ២



ធ្វើការផ្លាស់ប្តូរ និងលើកកំរិតជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទន្លេទាំងបួន ដែលមានជនជាតិដើមរស់នៅចំរុះគ្នារហូតដល់ទៅមានចំនួន ១៤ជនជាតិ។ អនាគតដ៏ថ្មីស្រឡាងក្នុងយុគសកលភាវូបនីយកម្ម ឯកជនភាវូបនីយកម្មនេះ ខេត្តស្ទឹងត្រែងនឹងមានឈ្មោះបោះសំលេងក្នុងតំបន់ក៏ដូចជាពិភពលោកដែរ។ ទន្ទឹមនឹងការផ្លាស់ប្តូរដ៏ធំធេងនេះ កត្តាហានិភ័យមួយចំនួនទាក់ទងនឹងការផ្លាស់ប្តូរផ្នែកបរិស្ថាន និងធនធានធម្មជាតិនៅក្នុងខេត្តនេះ ក៏កំពុងចាប់ផ្តើមកើតមានឡើងយ៉ាងក្តៅគគុកផងដែរ។

ជីវភាពរបស់ប្រជាជនដែលរស់នៅក្នុងអាងទន្លេទាំងបួននៃខេត្តស្ទឹងត្រែង គឺមិនផ្តោតលើសកម្មភាពមុខរបរតែមួយមុខនោះទេ គឺផ្តោតសំខាន់ទៅលើសកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃផងដែរ។ សកម្មភាពចិញ្ចឹមជីវិតទាំងនោះរួមមានការធ្វើស្រែចំការ នេសាទ ចិញ្ចឹមសត្វ ប្រមូលផល និងអនុផលព្រៃឈើ បរបាញ់សត្វ ដាំបន្លែតាម ច្រាំងទន្លេ ដាំដំណាំចម្រុះ បើកទូកដ និងធ្វើពាណិជ្ជកម្មខ្នាតតូចជាដើម[២] ។

## ១.២ ស្ថានភាពទូទៅ

នាពេលបច្ចុប្បន្ននេះទាំងធម្មជាតិ និងសកម្មភាពមនុស្ស បានធ្វើអោយគុណភាពទឹក និងធនធាននៅក្នុងទន្លេប្រែប្រួលដូចជា ទឹកមានគុណភាពល្អក្លាយទៅជាកខ្វក់ពេលប្រើប្រាស់បង្កអោយកើតជាជំងឺផ្សេងៗដល់ប្រជាពលរដ្ឋ ច្រាំងទន្លេបាក់ធ្លាក់ចុះទាំងគំហុក ដោយសារទឹកហូរបុក និងល្បឿនទឹកហូរខ្លាំងនៅពេលមានទឹកជំនន់ ដីខ្សាច់ដុះលប់អន្លង់ ត្រីថយចុះ និងធនធានជាច្រើនទៀតនៅក្នុងទឹកត្រូវបាត់បង់ជាបណ្តើរៗ។ ដោយសារតែការអភិវឌ្ឍ និងការទាញយកផលប្រយោជន៍ពីទន្លេ និងទឹកទន្លេបានធ្វើអោយមានផលប៉ះពាល់ជាអវិជ្ជមានជាក់ស្តែងដូចជាទំនប់វារីអគ្គិសនី យ៉ាលី នៅប្រទេសវៀតណាម ។ ដោយសារតែហេតុនេះទើប

២. តឹក វណ្ណារ៉ា (២០០៧), និរន្តរភាពនៃសហគមន៍នេសាទ ករណីសិក្សា ភូមិកោះស្នែង ឃុំ កោះស្នែង ស្រុក ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា, និក្ខេបបទបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកការសិក្សាស្តីពីការអភិវឌ្ឍឯកទេសៈ សកលភាវូបនីយកម្ម បោះពុម្ពវិទ្យាស្ថានក្រោយឧត្តមសិក្សា (IUED) នៃប្រទេសស្វីស ឆ្នាំ ២០០៧ ទំព័រ ១៧

ប្រជាជននៅតាមដងទន្លេសេកុង និង ស្រែពកមានការព្រួយបារម្ភ ហើយរៀបចំការសិក្សាស្រាវជ្រាវ និងចងក្រង ដើម្បីធ្វើការតាមដាន និងកត់សំគាល់នូវបម្រែបម្រួលធនធានក្នុងទឹកដែលតែងតែរាក់ទៅៗ និងខ្សត់ទៅៗ ដោយមានការជួយសម្របសម្រួលពីបុគ្គលិកអង្គការសេប៉ា។ ការសិក្សានេះបានប្រព្រឹត្តទៅដោយសហគមន៍នៅតាមមូលដ្ឋានផ្ទាល់ និងធ្វើការរៀបចំចងក្រងព័ត៌មានដែលបានមកពីការសិក្សាទុកជាឯកសារសំរាប់កូនចៅជំនាន់ក្រោយប្រើប្រាស់ ហើយនឹងធ្វើការសិក្សាស្រាវជ្រាវបន្ត និងជាគំរូសំរាប់ការអភិវឌ្ឍដទៃទៀតចាំបាច់ត្រូវតែធ្វើការសិក្សាពីផលប៉ះពាល់ អោយបានស៊ីជំរៅ និងមានភាពច្បាស់លាស់។

## ១.៣ គោលបំណងនៃការសិក្សា

១. ស្រាវជ្រាវពីធនធានក្នុងទឹកនៅតាមបណ្តោយដងទន្លេដែលផ្តោតសំខាន់ទៅលើអន្លង់ត្រីប្រភេទធនធាននៅក្នុងអន្លង់ និង ប្រភេទរុក្ខជាតិនៅក្នុងទឹក។

២. សិក្សាពីបម្រែបម្រួលនៃធនធានក្នុងទឹក ជាពិសេសចំពោះជម្រៅអន្លង់ ប្រភេទពូជត្រី និង រុក្ខជាតិ រវាងពេលមុន និង ពេលបច្ចុប្បន្ន ។

៣. ចងក្រងនូវព័ត៌មានដែលបានសិក្សាឃើញសំរាប់តំកល់ទុកជាឯកសារ នៅក្នុងតំបន់អាជ្ញាធរមូលដ្ឋាន អង្គការដៃគូ និង អ្នកពាក់ព័ន្ធដទៃទៀត។

## ១.៤ ទំហំនៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះបានប្រព្រឹត្តទៅនៅក្នុងទន្លេចំនួនបីគឺៈទន្លេ សេសាន សេកុង និង ទន្លេស្រែពក ដោយនៅតាមទន្លេសេសាន បានសិក្សាចំនួន១៥ភូមិគឺ ភូមិរំពាត់ ភូមិក្រឡាពុះ ភូមិតាឡាត ភូមិស្វាយរៀង ភូមិខ្សាច់ថ្មី (ក្នុងឃុំតាឡាត) ភូមិស្រែគរ១ ភូមិស្រែគរ២ (ក្នុងឃុំ ស្រែគរ) ភូមិភ្លុក ភូមិបានប៊ុង (ក្នុងឃុំភ្លុក) ភូមិបានម៉ៃ ភូមិកំភុន ភូមិសេសាន (ក្នុងឃុំកំភុន) ភូមិហាង្សាវ៉ាត ភូមិបាដើម និងភូមិសាមឃួយ (ក្នុងឃុំសាមឃួយ) ហើយទន្លេសេកុងបានសិក្សាចំនួន ៨ភូមិមានៈ ភូមិញ៉ាងស៊ុំ(ឃុំថ្មកែវ) ភូមិអូរចាយ (ឃុំសន្តិភាព)



ភូមិសៀមប៉ាង ភូមិបានមួង ភូមិកែងញ៉ៅ(ឃុំសេកុង) ភូមិពាមខិៈ ភូមិកេតមឿង និងភូមិកញ្ចោញទឹក (ឃុំស្រែសំបូរ) ក្នុងស្រុកសៀមប៉ាង និង នៅតាមទន្លេស្រែពកមានភូមិចំនួន៣គឺៈ ភូមិស្រែស្រណុក ភូមិក្បាលរមាស ភូមិក្របីជ្រុំ (ឃុំក្បាលរមាស) ស្រុកសេសាន ។

ក្នុងការសិក្សាស្រាវជ្រាវពីអន្លង់ និង ធនធានក្នុងទឹកនេះដោយមានការចូលរួមពីសហគមន៍ចាស់ទុំ ប្រជាជន មេភូមិ និង មេឃុំ នៅតាមភូមិឃុំនីមួយៗ។ ដោយមានការជួយសម្របសម្រួលការសិក្សាស្រាវជ្រាវពីបុគ្គលិកអង្គការសេប៉ា សហការជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្តស្ទឹងត្រែង ។

ពេលវេលានៃការសិក្សាស្រាវជ្រាវតាមភូមិនីមួយៗ ចំនួន ២ថ្ងៃ និងភូមិដែលមានអន្លង់ច្រើនត្រូវចំណាយពេល ៣ថ្ងៃ ដែលក្នុងនោះថ្ងៃទី ១ ប្រមូលព័ត៌មាន ប្រវត្តិអន្លង់ និងធនធានដែលមាននៅក្នុងអន្លង់តាមរយៈការពិភាក្សាក្រុមសហគមន៍ ប្រជាជននេសាទ និងក្រុមចាស់ទុំនៅក្នុងភូមិ ហើយនៅថ្ងៃបន្ទាប់ ក្រុមអ្នកសិក្សាស្រាវជ្រាវ បានចុះទៅធ្វើការវាស់វែងនៅតាមអន្លង់ផ្ទាល់តែម្តង ។

# ជំពូក ២
# វិធីសាស្ត្រសិក្សាស្រាវជ្រាវ

## ២.១ វិធីសាស្ត្រក្នុងការវាស់វែង

វិធីសាស្ត្រដែលប្រើប្រាស់ដើម្បីសិក្សាស្រាវជ្រាវមាន ៣ ដំណាក់កាលគឺ ១-ប្រជុំពិភាក្សារកឈ្មោះ និងប្រវត្តិរបស់អន្លង់, ២-ធ្វើការវាស់វែង និង អង្កេតមើលព័ត៌មានជុំវិញអន្លង់ ៣-ធ្វើការផ្ទៀងផ្ទាត់នូវលទ្ធផលដែលបានសិក្សាឃើញ ។ ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដោយសហគមន៍ និង អាជ្ញាធរភូមិឃុំ ជាអ្នកចុះវាស់វែង និង ប្រមូលព័ត៌មាន ដោយមានការជួយសម្របសម្រួល និង ចងក្រងជាឯកសារដោយបុគ្គលិកគម្រោង ។

## ២.២ វិធីសាស្ត្រក្នុងការពិភាក្សាក្រុម

### ប្រជុំពិភាក្សារកឈ្មោះ និង ប្រវត្តិរបស់អន្លង់:

មុននឹងធ្វើការសិក្សាពីអន្លង់តាមភូមិនីមួយៗ ត្រូវធ្វើការប្រជុំពិភាក្សារកឈ្មោះអន្លង់ និង ប្រវត្តិរបស់អន្លង់ជាមុនសិន ។ ការពិភាក្សានេះ ដោយមានការចូលរួមពីចាស់ព្រឹទ្ធាចារ្យ អ្នកនេសាទ មេភូមិ និង គណៈកម្មការ សហគមន៍គ្រប់គ្រងធនធានទឹកនៅក្នុងភូមិ ។ ការពិភាក្សានេះគឺ ធ្វើឡើងដើម្បីអោយដឹងពីចំនួន និង ឈ្មោះអន្លង់ ដែលមាននៅក្នុងភូមិទាំងឈ្មោះពីមុន និង ពេលបច្ចុប្បន្ន ជាភាសាខ្មែរ និង ភាសាឡាវ ដែលប្រជាជននិយមហៅនៅក្នុងភូមិ ។ ការពិភាក្សាមុនធ្វើការចុះវាស់វែងនេះ គឺដើម្បីអោយដឹងផងដែរនូវបម្រែបម្រួលរវាងព័ត៌មានអន្លង់ពីមុន និងស្ថានភាពពេលបច្ចុប្បន្ន ជាមួយគ្នានឹងប្រវត្តិរឿងរ៉ាវដែលមានចំពោះអន្លង់នីមួយៗផងដែរ ។

### ពេលចុះធ្វើការវាស់វែង និង អង្កេតផ្ទាល់

បន្ទាប់ពីធ្វើការប្រមូលព័ត៌មាន ប្រវត្តិ និង ឈ្មោះអន្លង់នីមួយៗរួចមក ទើបធ្វើការចុះវាស់វែងអន្លង់នោះ។ ក្នុងការវាស់វែងមានការចូលរួមពីគណៈកម្មការសហគមន៍គ្រប់គ្រងធនធាន



ទឹក អ្នកនេសាទនៅក្នុងភូមិ និង អាជ្ញាធរភូមិឃុំ ។ វិធីសាស្ត្រដែលសហគមន៍វាស់វែងតាមបែបសាមញ្ញគឺ ដោយជិះទូកទៅបរិវេណអន្លង់ហើយយកខ្សែជ័រ ទំហំប្រមាណ ០,២- ០,៣ ស.ម ចងដុំថ្មដោយគួចជាខ្នាត (១ម, ២ម, ៥ម,១០ម និង ១៥ម) ហើយទំលាក់ចូលទៅក្នុងអន្លង់ ។

ដើម្បីអោយដឹងពីជំរៅអន្លង់នីមួយៗ ពិតប្រាកដនោះក្នុងការវាស់វែង ធ្វើឡើងដោយរកតែជំរៅពីបាតទន្លេទៅបាតអន្លង់ប៉ុណ្ណោះ ដោយដកប្រវែងកំពស់ទឹកពីបាតទន្លេចេញ ។

ក្នុងការចងខ្សែទំលាក់ សំរាប់វាស់ជំរៅអន្លង់នីមួយៗនោះ គឺធ្វើឡើងច្រើនដង ច្រើនកន្លែងដើម្បីអោយដឹងថា តើក្នុងចំណោមកន្លែងដែលទំលាក់ខ្សែវាស់នោះកន្លែងណាដែលជ្រៅជាងគេ បន្ទាប់ពីដឹងកន្លែងដែលជ្រៅជាងគេហើយទើបយកមកដកប្រវែងដែលវាស់ពីលើផ្ទៃទឹកមកបាតទន្លេ ។ ប៉ុន្តែបើក្នុងករណីដែលទឹកទន្លេហូរវិញនោះ ការវាស់វែងធ្វើដូចគ្នា ដោយគ្រាន់តែកាត់ប្រវែងដែលជំរេលខ្សែទេរ នៅពេលទឹកហូរ (កាច់ដកប្រវែងដែលខ្សែទ្រេត) ។ ការកាច់ដកប្រវែងខ្សែទ្រេតចេញនេះប្រែប្រួលទៅតាមល្បឿនទឹកដែលហូរខ្លាំង ឬ ហូរតិច ប្រសិនបើល្បឿនទឹកហូរខ្លាំងនោះវាស់គិតដកប្រវែងខ្សែទ្រេតច្រើន ។ នៅពេលធ្វើការវាស់វែងអន្លង់របស់គណៈកម្មការសហគមន៍នេះមានការចុះសម្របសម្រួល និង ជួយចុចចំណុចទីតាំងភូមិសាស្ត្រ (Geography Position System (GPS) )ដើម្បីអោយដឹងពីចំណុចអាប់ស៊ីស និង អរដោនេ នៅលើផែនដីសំរាប់ដៅចំណុចនៅលើផែនទី ។

### ផ្ទៀងផ្ទាត់លទ្ធផលដែលបានសិក្សា និង អង្កេតឃើញ

បន្ទាប់ពីធ្វើការវាស់វែងនូវជំរៅ និង អង្កេតឃើញស្ថានភាពអន្លង់ និង ជុំវិញអន្លង់រួចមក យើងក៏បានធ្វើការបង្ហាញនូវលទ្ធផលដែលបានរកឃើញ ដល់ប្រជាជននៅក្នុងសហគមន៍ទាំងអស់ ដើម្បីធ្វើការផ្ទៀងផ្ទាត់អោយកាន់តែច្បាស់ និង ធ្វើការកែតំរូវនូវព័ត៌មានណាដែលមិនត្រឹមត្រូវដោយមានការចូលរួមពីចាស់ព្រឹទ្ធាចារ្យ អាជ្ញាធរភូមិឃុំ សហគមន៍ និង អ្នកនេសាទ

នៅក្នុងភូមិដែលជាអ្នកដឹងនូវព័ត៌មានច្បាស់ ។ ចំពោះព័ត៌មានមួយចំនួនត្រូវធ្វើការ សំរេចជាក្រុមដោយសំរេចយកតាមសំលេងគាំទ្រភាគច្រើន ។

## ២.៣ សម្ភារៈប្រើប្រាស់

- ក្រដាស និង ប៊ិចសំរាប់កត់ត្រានូវព័ត៌មាន
- ក្រដាសផ្ទាំងធំសំរាប់ពិភាក្សាក្រុម
- ហ្វឺតសរសេរក្រដាស
- ម៉ាស៊ីនថតរូប
- ម៉ែត្រវាស់
- ខ្សែជ័រសំរាប់វាស់
- ដុំថ្ម - ទូក



ស្ថានភាពទន្លេសេសាននារដូវប្រាំង





ការប្រើប្រាស់ខ្សែសន្ទូច សំរាប់វាស់ជំរៅ បណ្តោយ និងទទឹងរបស់អន្លង់



# ជំពូក ៣
# លទ្ធផលសិក្សាស្រាវជ្រាវ

ទន្លេទាំងបី សេសាន សេកុង និងស្រែពក ជាប្រភពធនធានមួយយ៉ាងសំខាន់ក្នុងការលើកស្ទួយកំរិតជីវភាព និង ការប្រកបមុខរបររបស់ប្រជាជនដែលរស់នៅតាមដងទន្លេ ដែលភាគច្រើនបានពឹងផ្អែកទៅលើធនធានធម្មជាតិស្ទើរតែទាំងស្រុង។ ការប្រកបមុខរបររបស់ប្រជាជននៅតាមដងទន្លេសំខាន់ៗរួមមាន : ការនេសាទត្រី ធ្វើស្រែចំការ បរបាញ់សត្វ និង ការចូលព្រៃដើម្បីរកផល និង អនុផលព្រៃឈើ ។ ការប្រកបមុខរបរដែលពឹងផ្អែកទៅលើធនធានទន្លេរបស់ប្រជាជននៅតាមដងទន្លេចាប់ផ្តើមានការព្រួយបារម្ភជាបន្តបន្ទាប់ចាប់ពីឆ្នាំ ២០០០ ព្រោះថា ធនធានទាំងនេះត្រូវបានថយចុះជារៀងរាល់ឆ្នាំ ដោយសារការបំផ្លាញដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់ និង ដោយសារការអភិវឌ្ឍនៅតាមដងទន្លេផ្នែកខាងលើ ដោយមិនបានធ្វើការសិក្សាពីផលប៉ះពាល់អោយបានដិតដល់ និង ត្រឹមត្រូវតាមបច្ចេកទេស ។ បញ្ហាដែលប្រជាជនបាននិងកំពុងជួបប្រទះ ហើយមានការព្រួយបារម្ភទៅថ្ងៃមុខនោះរួមមានទាំងការប្រកបមុខរបរសំរាប់ចិញ្ចឹមគ្រួសារ ការប៉ះពាល់សុខភាព ការអប់រំរបស់កូនចៅ វប្បធម៌ប្រពៃណី ទំនៀមទំលាប់ និងមធ្យោបាយធ្វើដំណើរ ព្រោះថាទាំងទន្លេ និងធនធាននៅក្នុងទន្លេកំពុងត្រូវបានរងនូវការបំផ្លិចបំផ្លាញ និងគំរាមកំហែងយ៉ាងខ្លាំង ដូចជាការសាងសង់ទំនប់វារីអគ្គិសនី ការរែងមាស ការកាប់ព្រៃតាមដងទន្លេ និងការផ្តល់ដីព្រៃទៅអោយក្រុមហ៊ុនដីសម្បទាន ។

ទន្លេសេកុង ស្ថិតនៅក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ហើយទន្លេនេះបានហូរចេញមកពីតំបន់ខ្ពង់រាប ប្រទេសវៀតណាម ហើយហូរកាត់ខេត្តអត្តពឺប្រទេសឡាវ និងខេត្តស្ទឹងត្រែងប្រទេសកម្ពុជា។ នៅក្នុងប្រទេសកម្ពុជា ទន្លេសេកុងហូរកាត់ស្រុកចំនួន ២ គឺស្រុកសៀមប៉ាង និងស្រុកសេសាន មានភូមិចំនួន ៣២ភូមិ។

ការសិក្សានៅតាមដងទន្លេសេកុងមានចំនួន ៨ភូមិ ក្នុងឃុំចំនួន ៤ប៉ុណ្ណោះ ។ មូលហេតុការសិក្សានេះមានចំនួនត្រឹមតែ ៨ភូមិ ដោយសារការសិក្សានេះជាការសិក្សារបស់សហគមន៍នៅតាមដងទន្លេ ។ ចំពោះភូមិដែលអង្គការសេប៉ានៅមិនទាន់បានជួយសម្របសម្រួលធ្វើការសិក្សាទេនោះ ក៏នៅមិនទាន់បានសិក្សានៅឡើយ។ ភូមិទាំង ៨ រួមមាន ភូមិញ៉ាងស៊ុំ ឃុំថ្មកែវ, ភូមិអូរចាយ ឃុំសន្តិភាព, ភូមិសៀមប៉ាង, បានមួង, កែងញ៉ៃ ឃុំសេកុង, ភូមិពាមខិះ កេតមឿង និង កញ្ចាញទឹក ក្នុងឃុំស្រែសំបូរ ។

ចំណែកឯទន្លេសេសាន មានប្រភពមកពីតំបន់ខ្ពង់រាបកន្ទុំ និងចាឡាយនៃប្រទេសវៀតណាម ទន្លេសេសានហូរកាត់ខេត្តចំនួនពីរនៃប្រទេសកម្ពុជា គឺខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។ សំរាប់ខេត្តស្ទឹងត្រែងទន្លេសេសានហូរកាត់ឃុំចំនួន៥ ក្នុងស្រុកសេសាន ដែលមានភូមិសរុបចំនួន១៥។ ការសិក្សាធនធានអន្លង់ និងធនធានទន្លេតាមដងទន្លេសេសាន បានធ្វើឡើងក្នុងភូមិចំនួន១៥ គឺ ភូមិកំភុន បានម៉ៃ សេសាន បានប៊ុង ភ្លុក បាឌើម សាមឃួយ ហាង្សាវ៉ាត ស្រែគរ១ ស្រែគរ២ ស្វាយរៀង ខ្សាច់ថ្មី វំពាត់ តាឡាត និង ភូមិក្រឡាពុះ នៃស្រុកសេសាន ខេត្តស្ទឹងត្រែង។

ទន្លេស្រែពក ដែលជាទន្លេមានប្រភពមកពីខ្ពង់រាបប្រទេសវៀតណាម ហើយហូរកាត់ខេត្តមណ្ឌលគិរី រតនគិរី និង បញ្ចប់នៅក្នុងខេត្តស្ទឹងត្រែង ជាមួយនឹងទន្លេសេសាន ត្រង់ឃុំភ្លុក ស្រុកសេសាននោះ ការសិក្សាបានធ្វើឡើងទៅលើតែក្នុងឃុំក្បាលរមាស ដែលមានភូមិចំនួន ៣ គឺ ភូមិក្របីជ្រុំ ក្បាលរមាស និង ភូមិស្រែស្រណុកប៉ុណ្ណោះ ។

## *អន្លង់តាមបណ្តោយទន្លេសេកុង*

### ៣.១ ភូមិញ៉ាងស៊ុំ ឃុំថ្មកែវ

ភូមិញ៉ាងស៊ុំ ស្ថិតនៅក្នុងឃុំថ្មកែវ ស្រុកសៀមប៉ាង តាមបណ្តោយដងទន្លេសេកុង ដែលមានចំងាយប្រមាណ១៥គ.ម ភាគខាងជើងនៃទីរួមស្រុក (ស្ថិតនៅផ្នែកខាងលើនៃខ្សែទឹក)។ ប្រជាជនដែលរស់នៅក្នុងតំបន់នេះការធ្វើដំណើរសំខាន់ គឺផ្លូវទឹកដែលមានទូកជាមធ្យោបាយ និងនៅរដូវប្រាំងអាចធ្វើដំណើរតាមផ្លូវគោកក៏បាន ព្រោះទឹកអូរស្រកផុតអស់ ។ ប្រជាជននៅ

ក្នុងភូមិសរុបចំនួន ១៥៧គ្រួសារ មានប្រជាជនសរុបចំនួន ៨៧០ នាក់ ស្រី ៤៣៨នាក់

**តារាង១ ឈ្មោះ អន្លង់នៅក្នុងភូមិញ៉ាងស៊ុំ ឃុំថ្មកែវ**

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំពីមុន(ម) | | ទំហំ ២០០៦ (ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | ហ៊ុលម៉ានបូអូរល្វា | ១០ | ១០ | ២០ | ២០ | ២០ | ២០ | ១៥៧៤៣៦៨ | ០៦៤៥១៣៥ |
| ២ | អូរតានេល | ១១ | ៩ | ៣០ | ២០ | ៣០ | ២០ | ១៥៧២៩១២ | ០៦៤៥៤០០ |
| ៣ | ជួរខាន់ម៉ាក់ហឿង | ១០ | ៩ | ១៥ | ១៥ | ១៥ | ១៥ | ១៥៧២៦៤៦ | ០៦៤៥៨៥៥ |
| ៤ | ហ៊ិនឡាត | ១០ | ៧ | ១៥ | ១៥ | ១៥ | ១៥ | ១៥៧២១១៧ | ០៦៤៧២៦១ |
| ៥ | អូរកាន់លឿង | ៣០ | ១៣ | ១០០ | ៥០ | ១០០ | ៥០ | ១៥៧២១១៧ | ០៦៤៨១៥០ |
| ៦ | អូរហួយណយ | ៦ | ៥ | ១០ | ១០ | ១០ | ១០ | ១៥៧០៨០៦ | ០៦៤៨៧២៨ |
| ៧ | អន្លង់តាភីឡា | ៦ | ៥ | ១០ | ១០ | ១០ | ១០ | ១៥៧០៨០៦ | ០៦៤៨៧២៨ |
| ៨ | អន្លង់អូរទុងលុង | ៦ | ៥ | ១០ | ១០ | ១០ | ១០ | ១៥៧០៨០៦ | ០៦៤៨៧២៨ |



(ទិន្នន័យភូមិ ២០០៦)តែប្រជាជននៅតំបន់នេះគាត់អាចនិយាយបានពីរភាសា គឺភាសាខ្មែរ និងភាសាឡាវ ។ ភូមិនេះមានអន្លង់សរុបចំនួន ៨ គឺ : អន្លង់អូរល្វា អន្លង់អូរតានេល អន្លង់ជួរខាន់ម៉ាកហឿង អន្លង់ហ៊ិនឡាត អន្លង់អូរកាន់លឿង អន្លង់អូរណយ អន្លង់តាភីឡា និង អន្លង់អូរទូងលុង ។ អន្លង់ទាំងនេះមានជំរៅមិនស្មើគ្នាទេ ក្នុងនោះអន្លង់ដែលមានជំរៅជ្រៅជាងគេ គឺអន្លង់អូរកាន់លឿង(១៣ម) និងអន្លង់ដែលមានជំរៅរាក់ជាងគេ គឺអន្លង់អូរណយ (៥ម) ។

**៣.១.១ អន្លង់ហ៊ុលម៉ាន បូអូរល្វា**

**ក. ទីតាំង**

អន្លង់ហ៊ុលម៉ាន មានចំងាយ ៥គ.ម ពីភូមិញ៉ាងស៊ុំស្ថិតនៅភាគខាងលើនៃខ្សែទឹក[១] ។ ឈ្មោះហ៊ុលម៉ាន នេះមានតាំងពីយូរលង់ណាស់មកហើយ ដែលត្រូវបានប្រជាជនក្នុងភូមិហៅតាមចាស់បុរាណត១គ្នារហូតមកដល់សព្វថ្ងៃនេះ។ អន្លង់នេះស្ថិតនៅជាប់នឹងច្រាំងទន្លេខាងលិច គឺនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើងលើ។ កាលពីមុនចំណុចនេះជាភូមិចាស់ របស់ប្រជាពលរដ្ឋគាត់ធ្លាប់រស់នៅចាប់តាំងពីដំបូងរហូតមកម្ល៉េះ ។ ចំណែកក្បាលអន្លង់ផ្នែកខាងលើមានអូរមួយហូរចាក់ហៅថា អូរល្វា (ហួយឌឿ) ចំងាយ ៣០០ម ពីអន្លង់។ ប្រជាពលរដ្ឋមួយចំនួនបានហៅអន្លង់នេះតាមឈ្មោះអូរ និងខ្លះទៀតហៅតាមជួរ ព្រោះនៅខាងក្រោមអូរចំងាយ ៥០០ម មានជួរមួយហៅថា ជួរហ៊ុលម៉ាន ដូចនេះគេក៏នាំគ្នាហៅឈ្មោះទៅតាមជួរនោះ (អន្លង់នេះសំបូរ ត្រីឆ្លាំងជាងអន្លង់ដទៃៗ ទៀត) ។

**<u>ចំណុចនៅលើ GPS :</u>**

-អាប់ស៊ីស = ០៦៤៥១៣៥

- អរដោនេ =១៥៧៤៣៦៨

- រយៈកំពស់ =៦៥ ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ១០ម

- ទំហំ : មុនឆ្នាំ ១៩៩៥ = ២០ម X ២០ម ឆ្នាំ ២០០៦ = ២០ម X ២០ម

### គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : មានថ្មធំៗនៅខាងក្រោមជាប់នឹងមាត់អន្លង់ និងមានថ្មប៉ប្រះទឹកនៅជិតៗ អន្លង់ នៅផ្នែកខាងកើតអន្លង់មានខ្សាច់គ្រួស និងមានកោះមួយតូចបណ្តោយប្រវែង ១៥០មនិងទទឹង៥០ម នៅរដូវប្រាំង ប្រជាពលរដ្ឋតែងតែទៅវែងមាសនៅទីនោះ ជារៀងរាល់ឆ្នាំរហូតមកដល់សព្វថ្ងៃនេះ។ ចាប់ពីខែកុម្ភៈឬខែមីនាទឹកស្រក គឺចាប់ផ្តើមមើលឃើញថ្មប៉ប្រះទឹក និង ខ្សាច់ គ្រួសនៅតាមមាត់អន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើល ឃើញផ្ទាំងថ្ម និង ខ្សាច់ឡើយ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើង រហូតដល់ ១១ម ទៅ ១៥ម ប្រែប្រួលទៅតាមឆ្នាំ ។

### ឃ. ប្រភេទសត្វ

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវវិផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីត្រសក់, ប៉ាវ៉ា, ប៉ាស៊ីអ៊ី, ត្រីផ្ទក់, ត្រីឆ្ដោ, ត្រីខ្យា, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីក្រពើ, ត្រីឆ្កោក, ត្រីត្រនេល, ត្រីសន្ទាយ, ត្រីប្រា, ត្រីថ្ម, ត្រីបបែល, ត្រីស្លឹកឫស្សី, ត្រីអាចម៍កុក, ត្រីផ្កាគរ, ត្រីក្លាំងហាយ,ត្រីក្រាយ, ត្រីខ្ញឹង, ត្រីស្រកាក្អាម, ត្រីល្មិច=ប៉ាប្លូ, ត្រីកែសជំរៅ, កញ្ជ្រូក ។

- ប្រភេទល្មូន : ពស់, ត្រកួត, កន្ទ្រង, អន្សង, អណ្តើក, ក្រពើ និង កន្ធាយ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ប្រវឹក, មាន់ទឹក, អាអូដ, មាន់ព្រៃ, សត្វអក, ទីទុយ, មៀម និង ក្អែក ។

- ប្រភេទសត្វផ្សេងៗ : គោ, ជ្រូកព្រៃ, ឈ្លូស, ប្រើស និង ខ្ទង ។



### ង. ប្រភេទរុក្ខជាតិ

ដើមរៃ ដើមផ្កាអណ្តែងដុះតាមថ្មក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមឈើទាល , ដើមត្រស់, ដើមឫស្សី, ដើមពង្រ, ដើមរាំងទឹក, ដើមល្វា, ដើមក្តុល, ដើមស្រឡៅ, ដើមទន្លា (ស្រគុំ), ដើមក្របៅ និង ដើមត្រែង ។

### ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការុក្ខជាតិជាបន្លែមួយចំនួន ។

- ការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជន ដែលមកពីភូមិខាងក្រៅដូចជា : បានមួង អូរឡាក់កាយ ផាបាំង កែងញៀ សៀមប៉ាង អូរចាយ ភូមិដីក្រហម ញ៉ាងស៊ុំ ចន្ទតូច។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ទៅ ១២ស.ម នេសាទនៅរដូវប្រាំង
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ១ ទៅលេខ១៤ (នេសាទបានគ្រប់រដូវ) ។
  - មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡា ២ហ៊ុន-១៤ហ៊ុន ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ
  - តុំ : នេសាទជាប្រចាំ
  - ប៉ោង : ដាក់ពី ខែ មិថុនា ដល់ ខែ កក្កដា

### ៣.១.២ អន្លង់អូរតានេល

**ក. ទីតាំង**

អន្លង់អូរតានេល មានចំងាយ ៣គ.ម ពីភូមិញ៉ាងស៊ុំ ស្ថិតនៅភាគខាងលើនៃខ្សែទឹក[១] ។ ឈ្មោះអូរតានេល មានតាំងពីយូរលង់មកហើយដែលត្រូវបានប្រជាជននៅក្នុងភូមិហៅតាមចាស់បុរាណៗគ្នារហូតមកដល់សព្វថ្ងៃនេះ ។ អន្លង់នេះស្ថិតនៅជាប់ច្រាំងទន្លេខាងលិច គឺនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើងលើ ។

នៅក្បាលអន្លង់ផ្នែកខាងលើមានអូរមួយហូរចាក់ហៅថា អូរតានេល ស្ថិតនៅចំអន្លង់តែម្តង ដូចនេះគេក៏នាំគ្នាហៅឈ្មោះអន្លង់នេះតាមអូរនោះទៅ ( អន្លង់នេះសំបូរត្រីឆ្លាំងជាងគេ ) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៥៤០០
- អរដោនេ =១៥៧២៩១២
- រយៈកំពស់ =៥៩ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១១ម ឆ្នាំ ២០០៦ = ៩ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៣០ម X ២០ម ឆ្នាំ ២០០៦ = ៣០ម X ២០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : យើងអាចមើលឃើញមានថ្មប៉ប្រះទឹកនៅជិតៗអន្លង់ខ្លះៗនិងនៅក្បាលអន្លង់ផ្នែកខាងកើត មានខ្សាច់ដុះបណ្តោយប្រវែង ៣០០ម និង ទទឹង ១០០ម ។

♦ រដូវវស្សា :នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញថ្មប៉ប្រះទឹក និងខ្សាច់បានឡើយ ។ នៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១១ម ទៅ ១៥ម ដោយវាប្រែប្រួលទៅតាមឆ្នាំ ។

**ឃ. ប្រភេទសត្វ**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប លូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

-ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីគ្រសក់, ប៉ាវ៉ា, ប៉ាស៊ីអ៊ី, ត្រីឆ្តោ,ត្រីខ្យា, ត្រីផ្ទក់, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីក្រពើ, ត្រីឆ្កោក, ត្រីត្រនេល, ត្រីសន្ទាយ, ត្រីថ្ម, ត្រីបំបែល, ត្រីស្លឹកឫស្សី, ត្រីអាចម៍កុក, ត្រីផ្កាគរ, ត្រីក្លាំងហាយ, ត្រីក្រាយ, ត្រីខ្ញឹង, ត្រីស្រកាក្តាម, ត្រី លិ្ទច= ប៉ាប្លួ, ត្រីកែសជំរៅ, និងត្រីកញ្រ្ជូក ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ប្រវឹក, មាន់ទឹក, អាអូដ, មាន់ព្រៃ, សត្វអក, ទីទុយ, មៀម និង ក្អែក ។

- ប្រភេទលូន : ពស់, ត្រកួត, កន្ធ្លង, អន្សង, អណ្តើក, ក្រពើ និង កន្ធាយ ។

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ប្រើស និង ខ្ទង ។

**ង. ប្រភេទរុក្ខជាតិ**

ដើមរៃ ដើមផ្កាអណ្តែងដុះតាមថ្មក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមឈើទាល, ដើមត្រស់, ដើមឫស្សី, ដើមពង្រ, ដើមរាំងទឹក, ដើមល្វា, ដើមក្តុល, ដើមក្របៅ, ដើម-ស្រឡៅ, ដើមទន្លា ( ស្រគុំ) និង ដើមគ្រែង ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និង ផ្ការុក្ខជាតិ-ជាបន្លែ។

- ការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និងប្រជាជនដែលមកពីភូមិខាងក្រៅដូចជា : អូរឡាក់កាយ, ផាបាំង, កែងញ៉ៃ, ដនឡូង, សៀមប៉ាង, អូរចាយ, ភូមិដីក្រហម, បានមូង, ញ៉ាងស៊ុំ និង ចន្ទតូច ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា៧ ហ៊ុនទៅ ១២ហ៊ុន នេសាទនៅរដូវប្រាំង
- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែ លេខ ១

ទៅលេខ១៤( នេសាទគ្រប់រដូវ) ។

- មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡា លេខ ២-១៤ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ

- តុំ : ដាក់ជាប្រចាំ

- លប : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ

### ៣.១.៣ អន្លង់ជួរខាន់ម៉ាក់ហ្សឿង (ឌុីន តាឌៀត) អន្លង់ជួរស្តី

**ក. ទីតាំង**

អន្លង់ជួរខាន់ម៉ាក់ហ្សឿង មានចំងាយ ២គ.មពីភូមិញ៉ាងស៊ី ស្ថិតនៅភាគខាងលើនៃខ្សែទឹក[១] ។ ឈ្មោះជួរខាន់ម៉ាក់ហ្សឿង នេះមានតាំងពីយូរលង់មកដែលត្រូវបានប្រជាជននៅក្នុងភូមិហៅតាមចាស់បុរាណតៗគ្នា រហូតមកដល់សព្វថ្ងៃនេះ ។ អន្លង់នេះស្ថិតនៅជាប់ច្រាំងទន្លេខាងលិច គឺនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើងលើ។ នៅក្បាលអន្លង់មានជួរថ្មមួយចំងាយ ២០ម ពីអន្លង់នៅត្រើយខាងកើតមានអូរមួយឈ្មោះថា អូរការធីន (ដើមកាធុមធេត) ។ គេនាំគ្នាហៅអន្លង់នេះទៅតាមជួរខាន់ម៉ាក់ហ្សឿង ហើយការដែលហៅដូចនេះ ដោយកាលពីមុនមានដើមស្តីច្រើន (កុកម៉ាក់ហ្សឿង) នៅចំណុចនោះទើបគេហៅតាមដើមនោះទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៥៨៩៥
- អរដោនេ =១៥៧២៦៤៦
- រយៈកំពស់ =៥៧ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៩ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១៥ម X ១៥ម ឆ្នាំ ២០០៦ = ១៥ម X ១៥ម



**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : មានជួរថ្មអមសងខាងអន្លង់ និងនៅជិតៗអន្លង់មានថ្មប៉ប្រះទឹក ចំណុចអន្លង់ផ្នែកខាងកើតក៏មានថ្មប៉ប្រះទឹកច្រើនដែរ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញជួរថ្ម ដែលនៅអមសងខាងអន្លង់ និងថ្មប៉ប្រះទឹកជុំវិញមាត់អន្លង់បានឡើយ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១១ម ទៅ ១៥ម ។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប ល្មូន និង សត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

-ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីត្រសក់, ប៉ាវ៉ា, ប៉ាស៊ីអ៊ី, ត្រីឆ្តោ, ត្រីខ្យា, ត្រីថ្ពក់, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីក្រពើ, ត្រីឆ្កោក, ត្រីត្រនេលត្រីសន្ទាយ, ត្រីថ្ម, ត្រីបបែល, ល្អិច=ប៉ាបួ, ត្រីស្លឹកឫស្សី,ត្រីអាចម៍កុក, ត្រីផ្កាគរ, ត្រីខ្ទីង, ត្រីក្លាំងហាយ, ត្រីក្រាយ, ត្រីស្រកាក្តាម, ត្រីកែសជំរៅ, និងត្រីកញ្ជក ។

-ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ប្រវឹក, មាន់ទឹក, អាអូដ, មាន់ព្រៃ, សត្វអក, ទិទុយ, មៀម និង ក្អែក ។

- ប្រភេទល្មូន : កន្ធាយ, ពស់, ត្រកួត, កន្ទ្រង ,អន្សង, អណ្តើក, ក្រពើ និង កន្ធាយ ។

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ប្រើស, ខ្ទង, គោ និង ក្របី ។

**ង. ប្រភេទរុក្ខជាតិ :**

ដើមរៃ ដើមផ្កាអណ្តែងដុះតាមថ្មក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមឈើទាល , ដើមត្រស់, ដើមឫស្សី, ដើមពង្រ, ដើមរាំងទឹក, ដើមល្វា និង ដើមក្តុល ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ។

- ការនេសាទអន្លង់នេះមានអ្នកមកនេសាទពីរប្រភេទ គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា : អូរឡាក់កាយ, ផាបាំង, កែងញ៉ៃ, ដនឡូង, សៀមប៉ាង, អូរចាយ, ភូមិដីក្រហម, បានមួង, ញ៉ាំងសុំ, ចន្ទុតូច ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ទៅ ១២ស.ម នេសាទនៅរដូវប្រាំង
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ១ ទៅ ១៤ ( នេសាទគ្រប់រដូវ) ។
  - មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលាដោយប្រើក្រឡាលេខ ២- ១៤ហ៊ុន ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ
  - តុំ :នេសាទជាប្រចាំ
  - ប៉ោង : ដាក់ខែ មិថុនា ដល់ខែ កក្កដា



**៣.១.៤ អន្លង់ថ្មដា (ខ្ទឹនហ៊ិនឡាត)**

**ក. ទីតាំង**

អន្លង់ថ្មដា មានចំងាយ ១គ.មពីភូមិញ៉ាំងសុំ ស្ថិតនៅភាគខាងលើនៃខ្សែទឹក ។ ឈ្មោះថ្មដា មានតាំងពីយូរលង់មកហើយដែលត្រូវបាន ប្រជាជនក្នុងភូមិហៅតាមចាស់បុរាណត។គ្នារហូតមកដល់សព្វថ្ងៃនេះ ។ អន្លង់នេះស្ថិតនៅជាប់ច្រាំងទន្លេខាងកើត គឺនៅខាងស្តាំដៃ បើនិយាយតាមខ្សែទឹកឡើងលើ ។ កាលពីមុន អន្លង់នេះមានសត្វក្រពើច្រើនឡើងដេកនៅលើថ្មដេកហាមាត់ចាំត្របាក់រុយ ហើយប្រជាជនគាត់មិនហ៊ានចុះទៅបង់សំណាញ់ទេ ប៉ុន្តែក្រពើទាំងនេះត្រូវបានយួនចាប់យកកាលពីឆ្នាំ១៩៣០អស់មួយចំនួនធំទៅហើយ ។ នៅជិតអន្លង់មានផ្ទាំងថ្មធំមួយដែលគេនាំគ្នា ហៅថាហ៊ិនឡាត អន្លង់នេះទៅតាមសណ្ឋាននៃថ្មនោះទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៧២៦១
- អរដោនេ = ១៥៧២១១៧
- រយៈកំពស់ = ៦១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៧ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១៥ម x ១៥ម ឆ្នាំ ២០០៦ = ១៥ម x ១៥ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅជាប់នឹងមាត់អន្លង់ ជ្រុងខាងកើតផ្នែកខាងលើមាត់អន្លង់មានថ្មដាដែលមានទំហំប្រវែង ១០ម x ៤ ជ្រុង ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញផ្ទាំងថ្ម ។ រដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០ម ទៅ ១៤ម ។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប ល្មូន និង សត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីត្រសក់, ប៉ាវ៉ា, ប៉ាស៊ីអុី, ត្រីឆ្តោ, ត្រីខ្យា, ត្រីផ្ទក់, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីក្រពើ, ត្រីឆ្អោក, ត្រីត្រនេល, ត្រីសន្ទាយ, ត្រីថ្មុ, ត្រីបបែល, ល្មិច(ប៉ាប្លូ ), ត្រីស្លឹកឬស្សី, ត្រីអាចម៍កុក, ត្រីផ្កាគរ, ត្រីខ្ទីង, ត្រីក្លាំងហាយ, ត្រីក្រាយ, ត្រីស្រកាក្តាម, ត្រីកែសជំរៅ , និងត្រីកញ្ជ្រូក ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ប្រវឹក, មាន់ទឹក, អាអូដ, មាន់ព្រៃ, សត្វអក, ទីទុយ, មៀម និង ក្អែក ។

- ប្រភេទល្មូន : កន្ធាយ, ពស់, ត្រកួត, កន្ទ្រង, អន្សង, អណ្តើក និង ក្រពើ ។

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ប្រើស និង ស្វា ។

**ង. ប្រភេទរុក្ខជាតិ :**

ដើមរៃ ដើមផ្កាអណ្តែងដុះតាមថ្មក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមពង្រ , ដើមត្រស់, ដើមល្ហា , ដើមឬស្សី , ដើមរាំងទឹក, ដើមឈើទាល , ដើមក្តុល, ដើមស្រឡៅ, ដើមទន្លា ( ស្រគុំ), ដើមក្របៅ និង ដើមត្រែង ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយការរស់នៅជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ។

- ការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា អូរឡាក់កាយ, ផាបាំង, កែងញ៉ៅ, ដនឡូង, សៀម-ប៉ាង, អូរចាយ, ភូមិដីក្រហម, បានមួង, ញ៉ាងស៊ុំ, ចន្ទតូច ។



- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម ទៅ ១២ស.ម នេសាទនៅរដូវប្រាំង ។

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែ លេខ ១ ទៅ១៤ ។

- មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡា២ហ៊ុន-១៤ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ

- តុំ : នេសាទជាប្រចាំ

- ប៉ោង : ដាក់ពីខែ មិថុនា ដល់ខែ កក្កដា

**៣.១.៥ អន្លង់អូរកាន់លឿង (ដើមក្តុល)**

**ក. ទីតាំង :**

អន្លង់អូរកាន់លឿង ស្ថិតនៅខាងលើភូមិញ៉ាងស៊ុំនៃខ្សែទឹកនៅចំណុចកណ្តាលទន្លេបញ្ចិតខាងកើតអន្លង់នេះ កាលពីមុនមានដើមឈើទាលធំមនុស្សអង្គុយជុំវិញដើមចំនួន ១៥អ្នក ទើបជុំនៅខាងលើអន្លង់បន្តិច កាលពីដើមនៅចំណុចនោះមើលឃើញថ្មមានទ្វារបិទបើកនៅរដូវប្រាំង រៀងរាល់ថ្ងៃសីល ហើយពេលដែលទ្វារបើកត្រូវតែបាត់មនុស្សក្នុងភូមិ បច្ចុប្បន្នថ្មនេះជួនឃើញជួនមិនឃើញ ។ នៅថ្ងៃមួយគេទៅបង់សំណាញ់នៅជិតនោះក៏បានឃើញព្រះមួយអង្គធំធ្វើអំពីមាសនៅក្បែរមាត់អន្លង់ប្រវែង ៣ម នៅក្នុងទឹក និងមានទ្រុងទាដែលធ្វើអំពីមាសនៅលើច្រាំងតែក្រោយមកក៏បានឃើញទ្រុងនោះនៅក្នុងទឹកទៅវិញ ប៉ុន្តែឃើញតែថ្ងៃសីលប៉ុណ្ណោះ ( កាលពីមុន ) ។

កាលពីឆ្នាំ ២០០១ ប្រជាពលរដ្ឋបានឃើញ ក្របីក្លៀចមួយក្បាល ផុសឡើងលេងទឹកនៅថ្ងៃសីល ហើយក៏មុជចុះបាត់ទៅអន្លង់នេះបច្ចុប្បន្ននៅប្រកាន់ណាស់តែនិយាយខុសមាត់ គឺមានបញ្ហាកើតឡើងហើយ ។ ដោយនៅចំណុចអន្លង់មានដើមក្តុលច្រើននៅទីនោះ ហើយមានអូរមួយទៀតហូរចាក់ឈ្មោះថា អូរកាន់លឿង នៅត្រើយខាងលិច ទើបគេហៅឈ្មោះ អន្លង់ទៅតាមនោះតៗគ្នាមកដល់សព្វថ្ងៃនេះ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៨១៩០
- អរដោនេ =១៩៧២១១៧
- រយៈកំពស់ =៩៧ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៣០ម ឆ្នាំ ២០០៦ = ១៣ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០០ម x ៥០មឆ្នាំ ២០០៦ = ១០០ម x ៥០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : មើលឃើញ ផ្ទាំងថ្មនៅទល់មុខអន្លង់ និង ខ្សាច់ដុះ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិន-អាចមើលឃើញផ្ទាំងថ្ម និងខ្សាច់នៅជិតអន្លង់ទេ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០-១២ម ។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប លូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល , ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីត្រសក់, ប៉ាវ៉ា, ប៉ាស៊ីអ៊ី,ត្រីឆ្តោ, ត្រីខ្យា, ត្រីផ្ទក់, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីក្រពើ, ត្រីឆ្កោក, ត្រីត្រនេល, ត្រីសន្ទាយ, ត្រីថ្ម,



ត្រីបបែល, ល្ពិច (ប៉ាប្លូ), ត្រីស្លឹកឫស្សី, ត្រីអាចម៍កុក, ត្រីផ្កាគរ, ត្រីខ្ជឹង, ត្រីក្លាំងហាយ, ត្រីក្រាយ, ត្រីស្រកាក្តាម, ត្រីកែសជំរៅ, ត្រីកញ្ច្រូក និង ត្រីផ្ទក់ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, មាន់ស្រុក ។
- ប្រភេទលូន : ពស់, ត្រកួត, កន្ធែង, កន្ធាយ, អន្សង ,អណ្តើក និង ក្រពើ ។
- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ស្វា, ក្របី, គោ និងជ្រូកស្រុក ។

**ង. ប្រភេទរុក្ខជាតិ :**

ដើមរៃ ដុះតាមថ្មក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមឈើទាល, ដើមត្រស់, ដើមឫស្សី, ដើមពង្រ, ដើមរាំងទឹក, ដើមល្វា, ដើមក្តុល, ដើមស្រឡៅ, ដើមទន្លា (ស្រគុំ), ដើមក្របៅ និង ដើមត្រែង ។

**ច.ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និង ផ្ការុក្ខជាតិជាបន្លែមួយចំនួន ។ ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និងប្រជាជនដែលមកពីភូមិខាងក្រៅដូចជា អូរឡាក់កាយ ផាបាំង កែងញ៉ៃ ដនឡូង សៀមប៉ាង អូរចាយ ភូមិដីក្រហម បានមួង ញ៉ាងស៊ុំ ចន្ទតូច ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ទៅ ១២ស.ម នេសាទនៅរដូវប្រាំង
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែ លេខ ១ ទៅ លេខ ១៤ ។
  - មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡា២ហ៊ុន-១៤ហ៊ុន
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ
  - តុំ : ដាក់ជាប្រចាំ
  - ប៉ោង : ដាក់ពីខែ មិថុនា ដល់ខែ កក្កដា

### ៣.១.៦ អន្លង់អួរតូច (ទ្វីនហួយណយ)

**ក. ទីតាំង :**

អន្លង់អួរតូច ស្ថិតនៅទល់មុខភូមិញ៉ាំងស៊ុំ នៅជិតច្រាំងខាងលិចបើនិយាយតាមខ្សែទឹកមកលើ ហើយនៅច្រាំងទន្លេមានល្បាក់ថ្ម ។ អន្លង់នេះមានឈ្មោះតាំងពីយូរលង់មកហើយ ដែលនៅចំណុចនោះមានអូរតូចមួយ ហូរចាក់ហៅថា (ហួយណយ) ចំងាយ១០មពីអន្លង់ប្រជាជន - បានហៅឈ្មោះអន្លង់នេះទៅតាមអូរនោះ ( អន្លង់នេះ មិនសូវមានត្រីដូចជាអន្លង់ដទៃៗទេ ) ។

**<u>ចំណុចនៅលើ GPS :</u>**

-អាប់ស៊ីស = ០៦៤៨៧២៨

- អរដោនេ = ១៥៧០៨០៦

- រយៈកំពស់ =៦១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៦ម ឆ្នាំ ២០០៦ = ៥ម

- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០ម x ១០ម ឆ្នាំ ២០០៦ = ១០ម x ១០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : យើងអាចមើលឃើញមានល្បាក់ថ្មដែលនៅជាប់ច្រាំងទន្លេ ជិតអន្លង់តែប៉ុណ្ណោះ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ រដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០មទៅ ១៤ម ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។



- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្អិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីឆ្កោក, ត្រីព្រួល,ខ្ទៅ ( បច្ចុប្បន្នសំបូរ ) ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ស្រុក

- ប្រភេទល្មូន : ពស់ បង្កួយ

- ប្រភេទសត្វផ្សេងៗ : ជ្រូក គោ

**ង. ប្រភេទរុក្ខជាតិ :**

ដើមរំ មានដុះនៅតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី, ដើមរាំងទឹក, ដើមល្វា, ដើមក្តុល និង ដើមជន្លា ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និងប្រជាជនដែលមកពីភូមិខាងក្រៅដូចជា ញ៉ាំងស៊ុំ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ទៅ ១២ស.ម នេសាទនៅរដូវប្រាំង

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែ លេខ ១ ទៅ លេខ១៤ ។

- មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលាដោយប្រើក្រឡា ២ហ៊ុន-១៤ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ

- តុំ : នេសាទជាប្រចាំ

- ប៉ោង : ដាក់ពីខែ មិថុនា ដល់ខែ កក្កដា

### ៣.១.៧ អន្លង់តាភីឡា

អន្លង់តាភីឡា ស្ថិតនៅទល់មុខភូមិខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកមកលើ[១] ហើយនៅច្រាំងទន្លេមានល្បាក់ថ្ម និងមានអូរតូចមួយហូរចាក់ហៅថា( ហួយណយ ) ចំងាយ១០ម ពីអន្លង់ មូលហេតុដែលគេហៅឈ្មោះអន្លង់នេះថា តាភីឡា ពីព្រោះតាំងពីយូរលង់មកហើយមានលោកតាម្នាក់ឈ្មោះភីឡា គាត់បានមករស់នៅទល់មុខចំណុចអន្លង់នោះប្រជាជនក៏បានហៅឈ្មោះអន្លង់នេះទៅតាមឈ្មោះរបស់គាត់តៗគ្នាមក ប៉ុន្តែអន្លង់នេះមិនសូវសំបូរត្រីដូចជាអន្លង់ដទៃៗនោះទេ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៨៧២៨
- អរដោនេ =១៩៧០៨០៦
- រយៈកំពស់ =៦១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៦ម ឆ្នាំ ២០០៦ = ៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០ម x ១០ម ឆ្នាំ ២០០៦ = ១០ម x ១០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : យើងអាចមើលឃើញមានល្បាក់ថ្មដែលនៅជាប់ច្រាំងទន្លេ ជិត-អន្លង់តែប៉ុណ្ណោះ រីឯផ្ទៃមាត់អន្លង់ គឺយើងមើលមិនឃើញទេព្រោះមានទឹកនៅពាសពេញ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ហើយនៅរដូវវស្សាចាប់ពីខែ សីហា ដល់ ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០មទៅ ១៣ម ។



**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប ល្មូន និង សត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីឆ្កោក, ត្រីព្រួល, ខ្ជៅ ( បច្ចុប្បន្នសំបូរ ) ។
- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ស្រុក និង អាអូដ ។
- ប្រភេទល្មូន : ពស់, បង្កួយ និង កន្ទ្រង ។
- ប្រភេទសត្វផ្សេងៗ : ជ្រូក និង គោ ។

**ង. ប្រភេទរុក្ខជាតិ :**

ដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមស្វាយ, ដើមដូង, ដើមថ្កូវ, ដើមឫស្សី, ដើមរាំងទឹក, ដើមល្វា, ដើមក្តុល និង ដើមជន្លា ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ ។

- ការនេសាទអន្លង់នេះ គឺមានតែប្រជាជនក្នុងភូមិញ៉ាងស៊ុំ ជាអ្នកមកនេសាទ ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ទៅ ១២ស.ម នេសាទនៅរដូវប្រាំង
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែ លេខ ១ ទៅ លេខ ១៤ ។
  - មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡា២ហ៊ុន- ១៤ហ៊ុន ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ

- តុំ : ដាក់ប្រចាំ

- ប៉ោង : ដាក់ពីខែ មិថុនា ដល់ខែ កក្កដា

## ៣.១.៨ អន្លង់អូរទុងលុង

**ក. ទីតាំង :**

អន្លង់អូរទុងលុង ស្ថិតនៅក្រោយជាប់ច្រាំងខាងលិចទល់មុខភូមិញ៉ាំងស៊ុំដែរ ។ ហេតុដែលគេហៅឈ្មោះអន្លង់នេះថា អន្លង់អូរទុងលុង គឺគេហៅទៅតាមអូរមួយដែលនៅជិតនោះ កាលពីមុនអូរនេះហូរចាក់ទៅអន្លង់ និងមានរាងជារណ្ដៅទឹកហូរចាក់ដោយមានទឹកចេញដូចអណ្ដូង ដូចនេះហើយទើបពួកគេហៅអូរនេះថាអូរទុងលុង ចំណែកឯឈ្មោះអន្លង់វិញ គេក៏ហៅទៅតាមអូរនេះត១គ្នាទៅតាមលក្ខណៈសណ្ឋានរណ្ដៅរបស់អូរនោះ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៨៧២៨
- អរដោនេ = ១៥៧០៨០៦
- រយៈកំពស់ = ៦១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៦ម ឆ្នាំ ២០០៦ = ៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០ម x ១០ម ឆ្នាំ ២០០៦ = ១០ម x ១០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅរដូវប្រាំង ពេលដែលទឹករីងអស់យើងអាចមើលឃើញមានខ្សាច់នៅមាត់អូរទុងលុងនៅប៉ែកខាងកើត ។

♦ រដូវវស្សា :រីឯនៅរដូវវស្សាវិញកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ហើយនៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០មទៅ ១៣ ម



**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេង១ទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្ដង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីពោ, ត្រីឆ្លាំង, ត្រីក្អែក, ត្រីឆ្ពិន, ត្រីឆ្ដោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីឆ្កោក, ត្រីព្រួល, ខ្ជៅ ( បច្ចុប្បន្នសំបូរ ) ។
- ប្រភេទសត្វស្លាបរួមមាន : កុក,មាន់ស្រុក និង មាន់ទឹក ។
- ប្រភេទល្មូន : ពស់, បង្កួយ និង កន្ធ្រូង ។
- ប្រភេទសត្វផ្សេង១ : ជ្រូក, គោ និង ក្របី ។

**ង. ប្រភេទរុក្ខជាតិ :**

ដើមរំ ដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឬស្សី, ដើមរាំងទឹក, ដើមល្វា, ដើមក្ដុល, ដើមជន្លា, ដើមស្វាយ, ដើមគគីរ, ដើមអំពិល ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ ។

- ការនេសាទអន្លង់នេះអ្នកដែលមកនេសាទ គឺមានតែប្រជាជនក្នុងភូមិញ៉ាំងស៊ុំទេ ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ទៅ ១២ស.ម នេសាទនៅរដូវប្រាំង
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែ លេខ ១ ទៅ លេខ ១៤ ។
  - មង : មងបណ្ដែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡា ២ហ៊ុន- ១៤ហ៊ុន ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ ធ្នូ ។

- តុំ : នេសាទជាប្រចាំ

- ប៉ោង : ដាក់ពីខែ មិថុនា ដល់ខែ កក្កដា

## ៣.២ ភូមិអូរចាយ ឃុំសន្តិភាព

ភូមិអូរចាយ ស្ថិតនៅក្នុងឃុំសន្តិភាព ស្រុកសៀមប៉ាង មានចំងាយប្រមាណ ១៣គ.ម ភាគខាងជើងនៃទីរួមស្រុក (ស្ថិតនៅផ្នែកខាងលើនៃខ្សែទឹក) ។ ជាភូមិជនជាតិដើមភាគតិចរស់នៅ(ជនជាតិកាវ៉ែត)ការប្រើប្រាស់ភាសាប្រចាំថ្ងៃ គឺភាសាជនជាតិរបស់គាត់ តែគាត់ចេះនិយាយភាសាឡាវ និងភាសាខ្មែរបានខ្លះៗដែរ ។

ការធ្វើដំណើររបស់ប្រជាជននៅក្នុងតំបន់នេះជាសំខាន់ គឺផ្លូវទឹកដែលមានទូកជាមធ្យោបាយ និងរដូវប្រាំងអាចធ្វើដំណើរតាមផ្លូវគោក ព្រោះទឹកស្រកផុតពីអូររស់ ។ ប្រជាជននៅក្នុង ភូមិសរុបចំនួន១៦៦គ្រួសារ មានប្រជាជនសរុបចំនួន ៦៤៧ នាក់ ស្រី៣៤៣នាក់ (ទិន្នន័យភូមិ ២០០៦) ។

អន្លង់នៅក្នុងភូមិមានចំនួន ០១ កន្លែងគត់ គឺ : អន្លង់វ៉ាយ៉ាំ ។





តារាង២ ឈ្មោះអន្លង់នៅក្នុងភូមិអូរចាយ ឃុំសន្តិភាព

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំអន្លង់បច្ចុប្បន្ន (ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្ដោយ | ទទឹង | បណ្ដោយ | ទទឹង | អាប់ស៊ីស | អរដោនេ |
| ១ | អន្លង់ វ៉ាយ៉ាំ | ១០ | ៧ | ៥០ | ៣០ | ៥០ | ៣០ | | |

### ៣.២.១ អន្លង់រ៉ាយាំ

**ក. ទីតាំង**

អន្លង់រ៉ាយាំ មានចំងាយ ៣០០ម ពីភូមិអូរចាយស្ថិតនៅជាប់ច្រាំងទន្លេខាងកើត បើនិយាយតាមខ្សែទឹកមកលើ[១] ។ កាលពីដើមមានឈ្មោះតាយាក់កន្ទើយ បានទៅអង្គុយស្ទូចត្រីនៅមាត់អូរ ហើយក៏បានសំរាកនៅទីនោះ ទើបគេហៅឈ្មោះអន្លង់តាមនោះរហូតមក ។ ក្រោយមកដល់ជំនាន់សម្តេចឪ ទីនោះក៏បានឃើញមានដើមឫស្សីពីរគុម្ព ដុះត្រង់ស្លូតដោយគ្មានមែកអ្វីឡើយ ទេរទៅរកទន្លេរាងដូចដងសន្ទូចដែលកាលពីមុនតាកន្ទើយ គាត់ស្ទូចត្រីទើបមានឫស្សីដុះ ដូច្នេះ គេហៅឈ្មោះអន្លង់នេះថា អន្លង់រ៉ាយាំ តរៀងមក។

**<u>ចំនុចនៅលើ GPS :</u>**

- អាប់ស៊ីស =
- អរដោនេ =
- រយៈកំពស់ =

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៧ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៥០ម x ៣០ម ឆ្នាំ ២០០៦ = ៥០ម x ៣០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ នៅរដូវប្រាំង : មានកោះមួយនៅខាងលើមាត់អន្លង់ ទំហំបណ្តោយ ២០ម និងទទឹង ៥ម និងមានថ្មប៉ប្រះទឹកច្រើន ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញថ្មប៉ប្រះទឹក និងកោះនៅជិតមាត់អន្លង់បានឡើយ ។ រដូវវស្សាចាប់ពីខែសីហា ដល់ខែវិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០មទៅ ១៣ម ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប ល្មូន និង សត្វ



ផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីថ្ម, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្ទាន់, ត្រីរ៉ស់, ត្រីចេកទុំ, , ត្រីបបែល, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីអណ្តែង, ត្រីផ្ទោង, ត្រីកាដនជ័យ, ត្រីក្រាញ់, ត្រីក្រពើ, ត្រីឫសចេក, ត្រីអាចម៍កុក, ខ្ជៅ, គ្រំ និង ក្តាម ។
- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, ក្អែកទឹក, មាន់ទឹក, រំពេ, កាឡុង, មាន់ព្រៃ និង ត្រដេវវិច ។
- ប្រភេទសត្វល្មូន : កន្ធាយ, បង្កួយ, ពស់, ត្រកួត និង កន្ទ្រង ។
- ប្រភេទ សត្វផ្សេងៗ : ជ្រូកព្រៃ, ប្រម៉ា, ខ្លាត្រី, ប្រើស, សំពោច, កំប្រុក, ក្របី, កណ្តុរ, ឆ្កែព្រៃ ដង្កែ ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី, ដើមល្វា, ដើមរាំងទឹក, ដើមក្តុល, ដើមព្រីង ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និង ផ្គាំរុក្ខជាតិជាបន្លែ។

- ការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និងប្រជាជនដែលមកពីភូមិខាងក្រៅដូចជា ភូមិឡាក់កាយ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

-សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា៥ ស.មទៅ ១០ស.មនេសាទនៅរដូវប្រាំង

- សន្ទូច :នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅលេខ ១២ ( នេសាទគ្រប់រដូវ) ។

- មង : មងបណ្តែត : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡាលេខ ៦-១០ស.ម

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែតុលា

- តុំ : នេសាទចាប់ពីខែ សីហា ដល់ខែតុលា



ទិដ្ឋភាពចំការស្រូវរបស់អ្នកស្រុកសេកុង



## ៣.៣ ភូមិសៀមប៉ាង ឃុំសេកុង

តារាង៣ ឈ្មោះអន្លង់នៅក្នុងភូមិសៀមប៉ាង ឃុំសេកុង

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំអន្លង់បច្ចុប្បន្ន (ម) | | កូរអរដោនេ ( GPS ) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់ តាកាឡាំង | ២០ | ១៥ | ៥០ | ៤០ | ៥០ | ៤០ | ១៥៦០០១១ | ០៦៤៩៨៨៩ |
| ២ | អន្លង់អូរសែ | ១២ | ៨ | ៧០ | ១០ | ៧០ | ១០ | | |

ភូមិសៀមប៉ាង ស្ថិតនៅក្នុងឃុំសេកុង ទីរួមស្រុកសៀមប៉ាង មានចំងាយប្រមាណ ៩៩គ.ម ចំពោះផ្លូវទឹក ឯផ្លូវគោកចំងាយប្រមាណ ១០៤គ.មពីទីរួមខេត្តស្ទឹងត្រែង (ស្ថិតនៅផ្នែកខាងលើនៃខ្សែទឹក ) ។ ការធ្វើដំណើររបស់ប្រជាជននៅក្នុងតំបន់នេះជាសំខាន់ គឺផ្លូវទឹកដែលមានទូកជាមធ្យោបាយ និងរដូវប្រាំងអាចធ្វើដំណើរបានតាមផ្លូវគោក ព្រោះទឹកអូរស្រកផុតអស់ ។ ប្រជាជននៅក្នុងភូមិសរុបចំនួន១៩៦គ្រួសារ មានប្រជាជនសរុប ១០៧៨ នាក់ ស្រី៥៩៦នាក់ (ទិន្នន័យភូមិ ២០០៦) ។

អន្លង់នៅក្នុងភូមិសរុបចំនួន ០២ គឺ : អន្លង់តាកាឡាំង និង អន្លង់អូរសៃ ។ អន្លង់ទាំងពីរនេះមានជំរៅមិនស្មើគ្នាទេ ក្នុងនោះអន្លង់ដែលមានជំរៅជ្រៅជាងគេ គឺអន្លង់តាកាឡាំង (១៥ម) ។

### ៣.៣.១ អន្លង់តាកាឡាំង

**ក. ទីតាំង :**

អន្លង់តាកាឡាំង នៅជាប់កន្ទុយភូមិផ្នែកខាងក្រោម ស្ថិតនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើង ហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា និងវិលយឺតនៅរដូវប្រាំង ។ ឈ្មោះតាកាឡាំងមានតាំងពីយូរលង់ណាស់មកហើយ ដោយកាលពីមុនមានតាចាស់ម្នាក់ឈ្មោះតាកាឡាំង គាត់ចេះបំបាំងខ្លួន ចេះជួយដល់ប្រជាពលរដ្ឋពេលមានឧបសគ្គ ។ គាត់នឹងផ្តល់ដំណឹងដល់យើងដើម្បីប្រុងប្រយ័ត្នទុកជាមុន ។ បច្ចុប្បន្នប្រជាពលរដ្ឋមានជំនឿថា គាត់ជាស្តេចខ្មោចព្យាបាលជំងឺមនុស្សបាន ហើយតែងតែធ្វើការបែបន់សុំសេចក្តីសុខជារៀងរាល់ឆ្នាំ ក្រៅពីនោះនៅមានក្រពើដែលរស់នៅក្នុងអន្លង់អោយតែមានអ្នកណាចង់ឃើញក្រពើនោះស្រែកសុំចំនួន ៥ដងក្រពើ ក៏ផុសឱ្យឃើញ(១៩៩៣-១៩៩៤) ។



អន្លង់តាកាឡាំង កាលពីមុនគេទំលាក់ដូងចូលទៅហើយដូងនោះទៅផុសនៅវឺនខាម ប្រទេសឡាវ ។ ម្យ៉ាងទៀតអ្នកភូមិឈ្មោះ( ថង ផុន) ធ្លាប់ជ្រមុជយកសន្ទូច ឃើញព្រះនៅក្នុងទឹកមួយអង្គធំ ភ្នែកខៀវ នៅមុខទ្វារដែលគេទំលាក់ដូង( ឆ្នាំ ២០០៥ ) ។ នៅខាងក្រោមមានអូរមួយហៅថាអូរតាកាឡាំង ។ នៅឆ្នាំ ១៩៧៩ រហូតមកដល់ ឆ្នាំ ១៩៨៧ នៅមានសត្វផ្សោត និងត្រីប្រម៉ា ត្រីផ្ទក់ធំៗ ។

**<u>ចំនុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៩៨៨៩
- អរដោនេ =១៥៦០០១១
- រយៈកំពស់ =៦១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២០ម ឆ្នាំ ២០០៦ = ១៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៥០ម x ៤០ម ឆ្នាំ ២០០៦ = ៥០ម x ៤០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ នៅរដូវប្រាំង : មានថ្មផ្ទាំងធំៗនៅខាងលើមាត់អន្លង់ និងមានថ្មប៉ប្រះទឹកនៅតាមច្រាំងទន្លេជាប់មាត់អន្លង់ នៅផ្នែកខាងក្រោមឆ្វេងដៃ បើនិយាយតាមខ្សែទឹកឡើង ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញផ្ទាំងថ្ម និងថ្មប៉ប្រះទឹកបានឡើយ ។ រដូវវស្សាចាប់ពីខែ សីហា ដល់ខែតុលា កំពស់ទឹកឡើងរហូតដល់ ១១ម ទៅ ១៥ម ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

-ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជាត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស,

ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ប៉ាវ៉ា, ត្រីស្លឹកឫស្សី, ត្រីខ្ទាន់, ត្រីចេកទុំ, ត្រីផ្ទក់, ត្រីបំពែល, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល,ប៉ាស៊ីអ៊ី, ត្រីឆ្កោក, ត្រីប្រា, បង្កង, ត្រីក្លាំងហាយ ។

-ប្រភេទសត្វស្លាបរួមមានៈ កុក, កដប, មាន់ទឹក, មាន់ព្រៃ, អាអូដ, រំពេ, មាន់ស្រុក

-ប្រភេទល្មូន : ពស់, ត្រកួត, កន្ធ្រង (ត្រង), កន្ធាយ ។

-ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ក្របី, គោ, ស្វា ជ្រូកស្រុក ។

**ង. ប្រភេទរុក្ខជាតិ :**

ដើមរៃនៅដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី, រាំងទឹក, ដើមល្វា, ដើមក្តុល, ដើមស្លែង, ដើមបេង, ដើមឈើទាល និង ដើមស្រឡៅ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកិរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពី ភូមិខាងក្រៅដូចជា បានមួង, កែងព្នៅ, ចន្ទរតូច និងសម្ទ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

  - សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា ៥ ស.មទៅ ១០ស.ម នេសាទចាប់ពីខែវិច្ឆិកា ដល់ខែ មិថុនា ។
  - សន្ទូច :នេសាទនៅខែ សីហា ដល់ខែ កុម្ភៈ ដោយប្រើផ្លែលេខ ៨ ទៅ ១២
  - មង : នេសាទចាប់ពីខែ ធ្នូ ដល់ខែ មិថុនា ដោយប្រើក្រឡាលេខ ៥ ទៅ ៨ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ កុម្ភៈ
  - ស្ទូចោក : នៅរដូវប្រាំង (ចាប់ពីខែ តុលា ដល់ខែ ឧសភា)
  - លប : ដាក់ខែ សីហា ដល់ខែ តុលា



### ៣.៣.២ អន្លង់អូរសែ

**ក. ទីតាំង :**

អន្លង់អូរសែ នៅជាប់ក្បាលភូមិផ្នែកខាងលើ ស្ថិតនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើង ហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា និងវិលយឺតនៅរដូវប្រាំង ។ ឈ្មោះអូរសែ មានតាំងពីយូរលង់ណាស់មកហើយ ដោយកាលពីមុនមានតាចាស់ម្នាក់ឈ្មោះតាសែ គាត់ជាអង្គរក្សរបស់តាកាឡាំង ។ តាសែគាត់មិនមែនស្លាប់ដោយសារឈឺទេ គឺស្លាប់ដោយគេសំលាប់គាត់ព្រោះកាលនោះមានគេកប់កំណប់នៅចំនុចនោះ ហើយតាកាឡាំងបានសួរថាអ្នកណាចង់ថែរក្សាទ្រព្យសម្បត្តិទាំងនេះ គេនឹងសង់ផ្ទះឱ្យមួយពេលនោះតាសែក៏បានឆ្លើយថាទុកឱ្យខ្ញុំជាអ្នកថែរក្សា (គាត់មិនបានដឹងខ្លួនថាគេសំលាប់ដើម្បីការពារកំណប់ដែលគេកប់នោះទេ) ទើបគាត់ឆ្លើយបែបនេះ ។ បន្ទាប់ពីគាត់យល់ព្រម គេក៏កាប់សំលាប់គាត់ស្លាប់ហើយកប់គាត់នៅជិតកន្លែងកំណប់នោះទៅ ហើយក៏ធ្វើជាខ្ទមតូចមួយសំរាប់គាត់ ។ បន្ទាប់ពីនោះមកប្រជាជនក៏បានហៅឈ្មោះអូរទៅតាមឈ្មោះរបស់គាត់ ចំណែកអន្លង់នៅជិតអូរក៏ហៅដូចនេះតរៀងរហូតមកដល់សព្វថ្ងៃនេះ ។

**ចំនុចនៅលើ GPS : (មិនបានបញ្ចូលទៅក្នុងប្រព័ន្ធ GPS)**

- អាប់ស៊ីស =
- អរដោនេ =
- រយៈកំពស់ =

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១២ម ឆ្នាំ ២០០៦ = ៨ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៧០ម x ១០ម ឆ្នាំ ២០០៦ = ៧០ម x ១០ម

គ. មជ្ឈដ្ឋានជុំវិញ :

♦ រដូវប្រាំង :មានថ្មប៉ប្រះទឹក និងនៅខាងលើអន្លង់ចំងាយ ២០មមានជួរថ្មតូច១ល្មម

♦ រដូវវស្សា : កំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញជួរថ្ម និងថ្មប៉ប្រះទឹកបានឡើយ ។ រដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា កំពស់ទឹកឡើងរហូតដល់ ១១ម ទៅ ១៩ម ។

ឃ.ប្រភេទសត្វ :

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប ល្មូន និង សត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីឆ្តិន, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីបំពែល, ត្រីថ្ម, ត្រីច្រកែង, ត្រីកញ្ចុះ, ត្រីក្រពើ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, មាន់ទឹក, មាន់ព្រៃ, អាអូដ, រំពេ, មាន់ស្រុក ។

- ប្រភេទល្មូន : ពស់, ត្រកួត, កន្ធេង (ត្រង), កន្ធាយ ។

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ក្របី, គោ, ស្វា, ជ្រូកស្រុក ។

ង. ប្រភេទរុក្ខជាតិ :

មានដើមរៃ ដុះតាមច្រាំងក្បែរអន្លង់ ហើយនៅតាមច្រាំងជាប់អន្លង់មាន ដើមចំបក់, ដើមឫស្សី, ដើមល្វា, ដើមពោធិ៍, ដើមផ្តៅ, ដើមចេកទុំ, ដើមឈើទាល, ដើមស្វាយ ។

ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

ទំនាក់ទំនងរវាងអន្លង់ទៅនឹង ប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្ការរុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺ ប្រជាជនក្នុងភូមិ និងប្រជាជនដែលមកពីភូមិខាងក្រៅដូចជា ផាបាំង, សៀមប៉ាង, ចន្ទរតូច, សម្ពុ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :



- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៥ ស.មទៅ ១០ស.ម នេសាទចាប់ ពី ខែ វិច្ឆិកា-ខែ មិថុនា ។

- សន្ទូច : នេសាទនៅខែ សីហា ដល់ ខែ កុម្ភៈ ដោយប្រើផ្លែលេខ ៨ ទៅ លេខ១២ ។

-មង : នេសាទចាប់ពីខែ ធ្នូ ដល់ខែ មិថុនា ដោយប្រើក្រឡាលេខ ៥ ទៅ ៨ស.ម ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ ខែកុម្ភៈ

- ស្ទូចចាក់ : នៅរដូវប្រាំង (ចាប់ពីខែ តុលា ដល់ ខែ ឧសភា)

- លប : ដាក់ខែ សីហា ដល់ ខែ តុលា

## ៣.៤ ភូមិបានមួង ឃុំសេកុង

ភូមិបានមួងស្ថិតនៅខាងក្រោមស្រុកសៀមប៉ាងមានព្រំប្រទល់ជាប់និង ភូមិសៀមប៉ាងចំងាយ ២គ.ម មានប្រជាពលរដ្ឋរស់នៅចំនួន ៨៩គ្រួសារ ប្រជាពលរដ្ឋសរុប៤៦៦នាក់ ស្រី២៤១នាក់ ភូមិនេះពុំមានអន្លង់ទេ តែគាត់ទៅនេសាទនៅចំណុចអន្លង់ក្នុងភូមិដទៃៗទៀត ហើយស្ថិតនៅក្នុងឃុំសេកុងនៅម្ខាងទន្លេម្ខាក់នៃភូមិកែងញ៉ៃ ស្រុកសៀមប៉ាង ។

## ៣.៥ ភូមិកែងញ៉ៃ ឃុំសេកុង

ភូមិកែងញ៉ៃ ស្ថិតនៅក្នុងឃុំសេកុង ស្រុកសៀមប៉ាង ដែលមានបណ្តោយ ២គ.ម និងទទឹង ២០០ម ភូមិនេះស្ថិតនៅខាងក្រោមទីរួមស្រុកសៀមប៉ាងចំងាយ ១,៥គ.ម នៅជាប់ច្រាំងទន្លេខាងស្តាំដៃបើនិយាយតាមខ្សែទឹកមកលើទល់មុខភូមិបានមួង ។

តារាង ៤ អន្លង់នៅក្នុងភូមិកែងញៀ

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំពីមុន(ម) | | ទំហំបច្ចុប្បន្ន(ម) | | កូអរដោនេ(G P S) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្ដោយ | ទទឹង | បណ្ដោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់ គគីរ | ១២ | ៩ | ២៥ | ២០ | ២៥ | ២០ | ១៩៥៨៥៧៣ | ០៦៥០០២៣ |
| ២ | អន្លង់កែងញៀ | ៨ | ៨ | ៥០ | ២០ | ៥០ | ២០ | ១៩៥៨០៩១ | ០៦៤៩៩៦៥ |
| ៣ | អន្លង់ខាន់ទីមូន | ១៥ | ៦ | ១៥ | ១៥ | ១៥ | ១៥ | ១៩៥៧១៨៤ | ០៦៤៩៧៩៤ |
| ៤ | អន្លង់ហ្វាកផា | ១៣ | ៧ | ៨០ | ៥០ | ៨០ | ៥០ | ១៩៥៦២៥៦ | ០៦៤៩៤៥៤ |



ការធ្វើដំណើររបស់ប្រជាជននៅក្នុងតំបន់នេះជាសំខាន់ គឺផ្លូវទឹក ដែលមានទូកជាមធ្យោបាយ និងរដូវប្រាំងអាចធ្វើដំណើរបានតាមផ្លូវគោក ព្រោះទឹកហូរផុតអូររអស់ ។ ប្រជាជននៅក្នុងភូមិសរុបចំនួន ១២៦គ្រួសារ មានប្រជាជនសរុបចំនួន ៦៧៧នាក់ ស្រី៣៣៩នាក់ (ទិន្នន័យភូមិ ២០០៦ ) ។ ចំពោះការប្រើប្រាស់ភាសានៅក្នុងមូលដ្ឋានវិញ គឺប្រជាពលរដ្ឋទាំងនេះនិយាយជាភាសាឡាវក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ។

អន្លង់នៅក្នុងភូមិនេះសរុបចំនួន ៤ គឺ អន្លង់គគីរ, អន្លង់កែងញៀ, អន្លង់ខាន់ទីមូន និងអន្លង់ហ្វាកផា ។ អន្លង់ទាំងនេះមានជំរៅមិនស្មើគ្នាទេ ក្នុងនោះអន្លង់ដែលមានជំរៅជ្រៅជាងគេ គឺអន្លង់គគីរ (៩ ម) និងអន្លង់មានជំរៅរាក់ជាងគេ គឺអន្លង់ខាន់ទីមូន (៦ម) ។

### ៣.៥.១ អន្លង់គគីរ

**ក. ទីតាំង :**

អន្លង់គគីរ នៅជាប់ក្បាលភូមិផ្នែកខាងលើ ស្ថិតនៅខាងស្ដាំដៃបើនិយាយតាមខ្សែទឹកឡើង[1] ។ ឈ្មោះគគីរ នេះកាលពីមុនមានដើមគគីរមួយដើមធំដុះនៅជិតនោះ តែឆ្នាំនេះដើមគគីរក៏បាក់ច្រាំងធ្លាក់ចូលទៅក្នុងអន្លង់ ។ ដល់នៅរដូវប្រាំងទើបគេអាចមើលឃើញគល់គគីរនោះ ដោយហេតុដូច្នោះទើបប្រជាជននៅក្នុងភូមិនាំគ្នាហៅថា អន្លង់គគីរ តៗគ្នារៀងមករហូតដល់ សព្វថ្ងៃនេះ នៅក្នុងអន្លង់នេះប្រជាជនធ្លាប់ឃើញក្រពើ យូរៗម្ដង ។

នៅក្បាលអន្លង់ផ្នែកខាងលើមានអូរមួយហូរចាក់ហៅថា អូរតាវ៉ឺន មានចំងាយ ៣០០ម ពីអន្លង់ ។

**<u>ចំនុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥០០២៣
- អរដោនេ= ១៩៥៨៥៧៣
- រយៈកំពស់ = ៦១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១២ម ឆ្នាំ ២០០៦ = ៩ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ២៥ម x ២០ម ឆ្នាំ ២០០៦ = ២៥ម x ២០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : មានជួរដុះកាត់ និងថ្មប៉ប្រះទឹកនៅខាងលើមាត់អន្លង់ និងនៅតាមច្រាំងទន្លេខាងស្តាំ នៅចំអន្លង់គេពិបាកនេសាទណាស់ ដោយនៅក្នុងអន្លង់ មានដើមគគីរធំមួយធ្លាក់ចូលក្នុងនោះ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញផ្ទាំងថ្ម និងជួរបានឡើយ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០មទៅ ១៣ម ។

**ឃ .ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្ពោ, ត្រីកែស,ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្មាន់, ត្រីចេកទុំ, ត្រីផ្ទក់, ត្រីបបែល, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីប្រម៉ា, ត្រីត្រសក់, ត្រីឆ្លូញ, ត្រីកញ្ជ្រូក, ត្រីកំពត, ត្រីស្រកាក្តាម, ត្រីអាចម៏កុក, ត្រីខ្លា, ត្រីកន្ទ្រប់, ត្រីក្រោស, ត្រីលលកស, ត្រីកញ្ចាញ់ច្រាស់, ត្រីរ៉ស, ត្រីកញ្ចុះ, ត្រីក្របី( ត្រីក្រពើ), ត្រីអំបូង, ត្រីឫសចេក,ត្រីចង្វា, ត្រីដឺរី, ខ្ទៅ, លៀស, គ្រុំ, ក្តាមថ្ម ។
- ប្រភេទសត្វស្លាបរួមមាន : កុក, ខ្លែង, និង សត្វរំពេ, ចាប,
- ប្រភេទល្មូន : កន្ធាយ
- ប្រភេទសត្វផ្សេងៗ : ក្របី, គោ, ជ្រូក



**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, គុម្ពឫស្សី, ប្រមាត់ដី។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្ការុក្ខជាតិ-ជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពី ភូមិខាងក្រៅដូចជា បានមួង ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២ហ៊ុនទៅ ១៣ហ៊ុន នេសាទនៅរដូវប្រាំង ( ខែធ្នូ ដល់ខែ មិថុនា) ។
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១២ ( នេសាទគ្រប់រដូវ) ។
  - សន្ទូចពន្លិច :នេសាទនៅខែ ឧសភា
  - មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ ខែ មិនា ដោយប្រើក្រឡាលេខ ២- ១២ ស.ម ។
  - ចាន់ : នេសាទនៅរដូវទឹកស្រក

### ៣.៥.២ អន្លង់ជ្រូរធំ (វ៉ឺនកែងញ៉ៅ)

**ក .ទីតាំង :**

អន្លង់ជ្រូរធំ (វ៉ឺនកែងញ៉ៅ) ស្ថិតនៅទល់មុខភូមិជាប់ច្រាំងទន្លេខាងកើតបើនិយាយតាមខ្សែទឹកឡើង។ ឈ្មោះជ្រូរធំនេះមានតាំងពីយូរលង់ណាស់មកហើយ ដែលត្រូវបានប្រជាជនក្នុងភូមិហៅតាមចាស់បុរាណត។គ្នា រហូតមកដល់សព្វថ្ងៃនេះដោយហៅទៅតាមឈ្មោះជ្រូរនៅជិតអន្លង់ព្រោះនៅក្បាលអន្លង់មានជ្រូរធំ និងនៅខាងក្រោមអន្លង់មានជ្រូរតូច ។ នៅកន្ទុយអន្លង់ផ្នែកខាងក្រោមមានអូរមួយហូរចាក់ ហៅថាអូរកែងញ៉ៅ ចំងាយ ១០ម ពីអន្លង់ប្រជាពលរដ្ឋមួយចំនួនបានហៅអន្លង់នេះ តាមឈ្មោះអូរ ខ្លះទៀតហៅតាមជ្រូរ ។

**<u>ចំនុចនៅលើ GPS :</u>**

- អាប់ស៊ីស = 0៦៤៩៩៦៥
- អរដោនេ = ១៥៥៨0៩១
- រយៈកំពស់ = ៥៩ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៨ម ឆ្នាំ ២00៦ = ៨ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៥0ម x ២0ម ឆ្នាំ ២00៦ = ៥0ម x ២0ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : មានថ្មធំៗជុំវិញមាត់អន្លង់ និងនៅតាមច្រាំងទន្លេជាប់មាត់អន្លង់នៅផ្នែកខាងលើ ចំណែកឯខាងក្រោមអន្លង់មើលឃើញជ្រូរថ្មទាំងពីរព្រមទាំងមានថ្មប៉ប្រះទឹកពាសពេញផ្ទៃទន្លេ និងមានកោះដុះជិតអន្លង់នៅបញ្ចិតខាងភូមិបានមួយ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិន-អាចមើលឃើញផ្ទាំងថ្ម កោះ ជ្រូរថ្ម និងថ្មប៉ប្រះទឹកបានឡើយ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០ម ទៅ ១៤ម។



**ឃ .ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ស្លឹកឫស្សី ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីឆ្តោក ត្រីប្រា, ត្រំ, លៀស, ក្តាមថ្ម, ខ្ចៅ ។
- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, អាអួង, កេងកង, មាន់ព្រៃ, មាន់ទឹក, រំពេ, ពពេច, ចាប ។
- ប្រភេទល្មូន : ពស់, កន្ត្រង (ត្រង), អន្សង, ត្រកួត, ថ្លែន
- ប្រភេទសត្វផ្សេងៗ : ក្របី, គោ, ជ្រូក

**ង. ប្រភេទរុក្ខជាតិ :**

ដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឈើ-ទាល, ដើមល្វា, ដើមក្តុល, សារាយ, ស្លែ, ដើមផ្តៅ, ដើមបន្លាស្អិត, ដើមស្តៅទឹក, ដើមប្រមាត់ដី, ដើមរាំង, ដើមឫស្សី ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយការិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្ការុក្ខជាតិ-ជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពី ភូមិខាងក្រៅដូចជា បានមួង ចន្ទ្រតូច សៀមប៉ាង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៥ ស.មទៅ ១០ស.ម នេសាទនៅរដូវប្រាំង ។

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១២ ( នេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡាលេខ ៦- ១០ស.ម ។

- ចាន់ : នេសាទនៅរដូវទឹកស្រក

- ស្ទូចាក់( ច្បូក ) :នៅរដូវប្រាំង ( ចាក់បានតែប្រភេទត្រីឆ្តោ និង ត្រីរ៉ស)

### ៣.៥.៣ អន្លង់ខាន់នីមួន (ជ្រូវខាន់នីមួន )

**ក ទីតាំង :**

អន្លង់ខាន់នីមួន នៅជាប់កន្ទុយភូមិផ្នែកខាងក្រោមស្ថិតនៅខាងស្តាំដៃ បើនិយាយតាមខ្សែ-ទឹកឡើង គឺនៅ(ខាងកើត) ហើយទឹកហូរខ្លាំងវិលនៅរដូវវស្សា ។ អន្លង់នេះកាលពីមុនមានភូមិមួយនៅទីនេះមានចំនួន ៥គ្រួសារ នៅក្នុងភូមិនេះមានយាយចាស់ម្នាក់ឈ្មោះថា យាយមួន ដែលអន្លង់នេះស្ថិតនៅត្រង់កំពង់ទឹករបស់គាត់ ហេតុនេះហើយទើបគេហៅអន្លង់នេះថា ខាន់នីមួនទៅតាមឈ្មោះរបស់គាត់ ។ កាលពីមុនធ្លាប់មានក្រពើទៅមក ប៉ុន្តែបច្ចុប្បន្ននេះធ្លាប់ឃើញម្តងៗ ។ នៅផ្នែកខាងក្រោមអន្លង់មានអូរមួយហៅថា អូរហ៊ីនពូន (ថ្មកំបោរ) មានចំងាយប្រវែង ១៥០ម អន្លង់នេះសំបូរ ត្រីក្អែក និងត្រីក្រាយ ជាងអន្លង់ ដទៃ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៩៧៩៤

- អរដោនេ =១៥៩៧១៤៤

- រយៈកំពស់ =៦២ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៦ម

- ទំហំ : មុនឆ្នាំ ១៩៩៥ = ១៥ម x ១៥ម ឆ្នាំ ២០០៦ = ១៥ម x ១៥ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : មានផ្ទាំងថ្មធំៗនៅក្បាលអន្លង់ និងនៅកន្ទុយអន្លង់ មានថ្មប៉ប្រះទឹក និងនៅតាមច្រាំងទន្លេជាប់មាត់អន្លង់ ក៏មានផ្ទាំងថ្មធំៗដែរ ។ ប៉ុន្តែអន្លង់នេះខុសពីអន្លង់ដទៃទៀត ដោយវាគ្មានខ្សាច់ដុះទេនៅរដូវប្រាំង ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញផ្ទាំងថ្ម និងថ្មប៉ប្រះទឹកបានទេ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ ខែវិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០ម ទៅ ១៥ម ។

**ឃ .ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីក្រហែ, ស្លឹកឫស្សី, ត្រីខ្លាន់, ត្រីចេកទុំ, ត្រីផ្ទក់, ត្រីបបែល, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រំ, លៀស, ក្តាមថ្ម, ខ្ចៅ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអូដ, ក្អែកគោក ។

- ប្រភេទល្មូន : ពស់, ត្រកួត, កន្ទ្រង( ត្រង ), អន្សង, អណ្តើក, កន្ធាយ

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ក្របី, គោ, ស្វា

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី ដើមល្វា, ដើមរាំងទឹក, ដើមក្តុល, ដើមសង្កែ, ដើមស្លែង, ដើមបន្លាស្អិត, ដើមថ្វាន់, ដើមជន្លា, ស្មៅ, ដើមប្រមាត់ដី, ដើមផ្តៅ ដើមស្តែទឹក ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា បានហួយ សៀមប៉ាង សាម៉ង ចន្ទុរតូច ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា ២ហ៊ុនទៅ ១៣ហ៊ុន នេសាទនៅរដូវប្រាំង (ខែធ្នូ ដល់ខែ មិថុនា ) ។

- សន្ទូច :នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ទៅ១២ (នេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២-៥ ហ៊ុន ។

- ចាន់ : នេសាទនៅរដូវទឹកស្រក

- ស្ទូរចាក់( ច្បូក ) : នៅរដូវប្រាំង( ចាក់បានតែប្រភេទត្រីឆ្តោ និង ត្រីរ៉ស )



**៣.៥.៤ អន្លង់រន្ទះបាញ់ (កែងហ្វាកផា)**

**ក. ទីតាំង :**

អន្លង់រន្ទះបាញ់ (កែងហ្វាកផា) ស្ថិតនៅខាងក្រោមភូមិ ចំងាយ៨00មពីកន្ទុយភូមិ នៅផ្នែកខាងស្តាំដៃ បើនិយាយតាមខ្សែទឹកឡើងហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា ។ នៅចំណុចអន្លង់មានថ្មមិនខ្ពស់ទេ កាលពីមុនអន្លង់នេះមានរន្ទះបាញ់ថ្មនៅចំណុចនោះនៅផ្នែកខាងក្បាលអន្លង់មានជួរថ្មធំមួយវែង និងខាងក្រោមមានជួរដែរ ហៅថាខាន់ណៃចាប( កាំងណៃចាប) ។ ឈ្មោះអន្លង់នេះគេហៅតៗគ្នាមក ដោយសារកាលនោះមានរន្ទះបាញ់ថ្មនៅទីនោះទើបគេហៅតាមរន្ទះបាញ់នោះទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = 0៦៤៩៤៥៤
- អរដោនេ = ១៥៥៦២៥៦
- រយៈកំពស់ = ៦0ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៣ម ឆ្នាំ ២00៦ = ៧ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៨0ម x ៥0ម ឆ្នាំ ២00៦ = ៨0ម x ៥0ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : មានផ្ទាំងថ្មធំវែងនៅក្បាលអន្លង់ រីឯផ្នែកខាងក្រោមអន្លង់មានជួរហៅថាកាំងណៃចាប និងជាពិសេស គឺមានថ្មប៉ប្រះទឹកច្រើន ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ មិនអាចមើលឃើញផ្ទាំងថ្ម ជួរថ្ម និងថ្មប៉ប្រះទឹកបានទេ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១0ម ទៅ ១៤ម ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្ដោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, ត្រីថ្ម, ត្រីអណ្ដាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្ដាយ, ត្រីព្រួល, ប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, គ្រុំ, លៀស, ក្ដាមថ្ម, ខ្ចៅ ។

- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអួដ, ខ្លែង, រំពេ, កេងកង, ពពេច, ក្ងោក ។

- ប្រភេទល្មូន : ពស់, ត្រកួត, កន្ត្រង ( ត្រង ), អណ្ដើក, អន្សង, កន្ធាយ

-ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ក្របី, គោ, ស្វា, ប្រើស

**ង. ប្រភេទរុក្ខជាតិ :**

ដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី, ដើមរាំងទឹក, ដើមល្វា, ដើមក្ទុល, ដើមឈើទាល, ដើមពង្រ, ដើមពោន, ដើមផ្ទីក, ដើមត្បែង, ដើមធ្នង់, ស្លែ, ដើមផ្កាអំណ្ដែង ដើមរៃទឹក ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា បានមួង សៀមប៉ាង សាម៉ង ចន្ទរតូច ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា ២ ហ៊ុនទៅ ១០ហ៊ុន នេសាទនៅរដូវប្រាំង

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ទៅ១២ (នេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ដោយប្រើក្រឡា លេខ ៦-១០ហ៊ុន ។



- ចាន់ : នេសាទនៅរដូវទឹកស្រក

- ស្ទរចាក់( ច្បូក ): នៅរដូវប្រាំង ( ចាក់បានតែប្រភេទត្រីឆ្ដោ និង ត្រីរ៉ស )

## ៣.៦ ភូមិពាមខិៈ ឃុំស្រែសំបូរ

ភូមិពាមខិៈនៅផ្នែកខាងក្រោមនៃស្រុកសៀមប៉ាងមានចំងាយ៨៧គ.ម ពីទីរួមខេត្តស្ទឹងត្រែង ស្ថិតនៅច្រាំងទន្លេខាងឆ្វេងបើនិយាយតាមខ្សែទឹកឡើង ភូមិនេះបានកកើតឡើងនៅក្នុងឆ្នាំ ១៩៦៥ បច្ចុប្បន្នមានប្រជាពលរដ្ឋរស់នៅចំនួន ៩២គ្រួសារ ប្រជាពលរដ្ឋសរុប ៥៧៦នាក់ ស្រីមានចំនួន ២៧២នាក់ ប្រជាពលរដ្ឋនៅភូមិនេះគេនិយាយភាសាខ្មែររាងរដឹនៗដែលហៅថា ខ្មែរខិៈ ។ ហើយការប្រើប្រាស់ទឹកពឹងផ្អែកទៅលើទឹកទន្លេទាំងស្រុង ដោយគាត់ផ្អែកទៅតាមទំលាប់របស់គាត់ ។ ភូមិនេះមានអន្លង់មួយកន្លែងស្ថិតនៅទល់មុខភូមិឈ្មោះថា អន្លង់ជួរពាមខិៈ។ កាលពីមុននៅចំណុចនេះគេហៅថា កំពង់ស្ដេច ដោយកាលនោះគេបណ្ដែតកូនមក ហើយក៏បានស្លាប់នៅត្រង់នេះ ទើបគេហៅថាកំពង់ស្ដេចតៗគ្នាមក តែមួយរយៈក្រោយមក ដោយនៅ ឆ្នាំ ១៩៦៨ គេក៏ហៅថាពាមខិៈវិញ ។



ស្ថានភាពបាក់ច្រាំងទន្លេតាមដងទន្លេសេកុងក្នុងឆ្នាំ ២០០៧

តារាង ៥ អន្លង់នៅក្នុងភូមិពាមខិ:

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំអន្លង់មុន(ម) | | ទំហំអន្លង់បច្ចុប្បន្ន (ម) | | កូអរដោនេ ( GPS) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្ដោយ | ទទឹង | បណ្ដោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់ជូរពាមខិ: | ១៥ | ៦ | ២០០ | ៥០ | ២០០ | ៥០ | ១៥៥០៧២៦ | ០៦៤៥២៤៨ |



## ៣.៦.១ អន្លង់ជួរពាមខិ: (គែខប៉ាខិ:)

**ក ទីតាំង :**

អន្លង់ជួរពាមខិ: ស្ថិតនៅទល់មុខភូមិពាមខិ:ជាប់ច្រាំងទន្លេខាងឆ្វេង នៅរដូវប្រាំងមានថ្មប៉ប្រះទឹក និងនៅខាងលើមានជួរនៅខាងក្រោមក៏មានជួរថ្មដែរ ហើយមានគុម្ពរៃតិចតួចនៅតាមជួរថ្ម ។ នៅផ្នែកខាងជើងមានខ្សាច់ដុះច្រើន នៅផ្នែកខាងលើអន្លង់មានអូរមួយហៅថាអូរពាមខិ: ហើយគេក៏ហៅអន្លង់ទៅតាមឈ្មោះរបស់អូរនោះតៗគ្នារហូតមកដល់បច្ចុប្បន្ននេះ

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៥២៤៨
- អរដោនេ = ១៥៥០៧២៦
- រយៈកំពស់ = ៥៨ម

**ខ. លក្ខណ:រូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៦ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ២០០ម x ៥០ម ឆ្នាំ ២០០៦ = ២០០ម x ៥០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅក្បាលអន្លង់យើងអាចមើលឃើញមានជួរ និងថ្មប៉ប្រះទឹក រីឯនៅផ្នែកខាងក្រោមអន្លង់ក៏មានជួរ និងថ្មប៉ប្រះទឹកច្រើនដែរ ដោយហេតុនេះហើយទើបស្ថានភាពទឹកនៅត្រង់អន្លង់នោះហូរកួចខ្លាំង ទោះជានៅរដូវប្រាំងក៏ដោយ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញជួរនិងថ្មប៉ប្រះទឹកបានឡើយ ទឹកមានលក្ខណ:កួចខ្លាំង ។ នៅរដូវវស្សាចាប់ពីខែសីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១៥ម ទៅ ២០ម ។

**ឃ .ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជាត្រី សត្វស្លាប លូន និង សត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, (ត្រីក្រសេក ), ត្រីឆ្ពោ, ត្រីកែស, ត្រីអំបូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីក្រុស, ត្រីថ្ម(ត្រីប៉ាកក ឬត្រីសេះ ), ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីផ្ទក់, បបែល, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ប៉ាវ៉ា, ត្រីខ្ទីង, ត្រីកាហែ, ត្រីឆ្ពួញ, ត្រីឈ្វាត, ត្រីក្រពើ, ត្រីកំពត, ត្រីកំផ្លេវ, ត្រីផ្ទោង, ត្រីប្រាក់(កញ្ជាញ់ច្រាស ), ត្រីស្រកាក្តាម ត្រីអណ្តែង, ត្រីកញ្ជ្រូក, ត្រីកន្ត្រប់, ត្រីកញ្ចុះ, ត្រីក្អែក, គ្រំ, ត្រីត្រស់, ត្រីខ្លា, ត្រីចង្វា, ត្រីឆ្មា (ប៉ាម៉ែវ ភាសាលាវ), ត្រីឆ្កោក, ត្រីចេកទុំ, ត្រីឫសចេក, ប៉ាស៊ីអ៊ី, កំពីស, ក្តាមថ្ម, ខ្ចៅ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, កងប, មាន់ទឹក, មាន់ស្រុក
- ប្រភេទលូន : ពស់, កន្ធ្រេង(ត្រង), កន្ធាយ
- ប្រភេទសត្វផ្សេងៗ : ជ្រូក, ក្របី, គោ

**ង. ប្រភេទរុក្ខជាតិ :**

ដើមរំដេះតាមថ្មក្បែរអន្លង់ និងរំដេះមាត់អន្លង់ នៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមរាំងទឹក,ដើមល្វា, ដើមក្តុល ដើមឈើទាល, ដើមស្រឡៅ, ដើមស្លែង, ដើមកំបៅ, ស្មៅ, ដើមប្រមាត់ដី, ដើមស្តែទឹក ដើមត្រចៀកក្រាញ់ និងដើមស្បាំង ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្កាវុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា បានហួយ សាមឃួយ ដនឡូង ប្រជាជនវៀតណាមនៅស្ទឹងត្រែង ។



- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
- សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា ២ ហ៊ុនទៅ ១២ហ៊ុន នេសាទនៅរដូវប្រាំង
- សន្ទូច :នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១៣ (នេសាទគ្រប់រដូវ) ។
- មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២ - ៨ហ៊ុន ។
- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែតុលា (រដូវវស្សា)
- លប : នេសាទចាប់ពីខែសីហា ដល់ខែតុលា (រដូវវស្សា)

## ៣.៧ ភូមិកេតមឿង ឃុំស្រែសំបូរ

ភូមិកេតមឿង នៅផ្នែកខាងក្រោមភូមិពាមខិៈ និងមានចំងាយ ៨៦គ.ម ពីទីរួមខេត្តស្ទឹងត្រែងស្ថិតនៅច្រាំងទន្លេខាងឆ្វេងបើនិយាយតាមខ្សែទឹកឡើង ។ ដំបូងឡើយមានគ្រួសារចំនួន ១០គ្រួសារ ហើយមិនទាន់មានឈ្មោះដាក់ឱ្យភូមិនេះទេ ប៉ុន្តែក្រោយមកគ្រួសារចេះតែកើនច្រើនឡើងៗ ដោយនៅក្នុងភូមិនោះមានលោកតាចាស់ម្នាក់ គាត់ក៏បានដាក់ឈ្មោះឱ្យថា កេតមឿង ហេតុដូចនេះហើយទើបគេហៅថាភូមិកេតមឿង តៗគ្នាមកដល់សព្វថ្ងៃនេះ ។ បច្ចុប្បន្នមានប្រជាពលរដ្ឋរស់នៅចំនួន ៥៧គ្រួសារ មានប្រជាពលរដ្ឋសរុប ៣៣៦នាក់ ស្រី ១៦៣ នាក់ ស្ត្រីមេម៉ាយចំនួន ៨នាក់ ហើយគាត់ទាំងអស់គ្នាជាជនជាតិខ្មែរខិៈភូមិនេះបានកកើតតាំងពីដូនតាមកម្លេះ ។

តារាង ៦ អន្លង់នៅក្នុងភូមិកេតមឿង

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំអន្លង់មុន(ម) | | ទំហំអន្លង់បច្ចុប្បន្ន(ម) | | កូអរដោនេ (GPS ) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អាប់ស៊ីស | អរដោនេ |
| ១ | អន្លង់អូរតាឡូន | ១៥ | ១០ | ២០០ | ១០០ | ២០០ | ១០០ | | |
| ២ | អន្លង់អូរក្រឡាក់ | ២៥ | ៧ | ១៥០ | ១០០ | ១០០ | ៧០ | | |



សព្វថ្ងៃគាត់ទាំងអស់គ្នានៅតែរក្សា និងប្រើប្រាស់ភាសាដើមរបស់គាត់ គឺភាសាខ្មែរខិះជាប្រចាំ ។

អន្លង់នៅក្នុងភូមិមានចំនួន ២កន្លែង គឺ អន្លង់អូរតាឡូន និងអន្លង់អូរការឡាក់ ដែលអន្លង់អូរតាឡូន មានជំរៅជ្រៅជាងអន្លង់អូរក្រឡាក់ ។

### ៣.៧.១ អន្លង់អូរតាឡូន

**ក. ទីតាំង :**

អន្លង់អូរតាឡូន នៅក្បាលភូមិស្ថិតនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើង ហើយនៅរដូវវស្សាទឹកមានលក្ខណៈហូរវិលខ្លាំង ។ អន្លង់នេះកាលពីមុនមានតាចាស់ម្នាក់ឈ្មោះ តាឡូន ធ្វើដំណើរមកពីឆ្ងាយហើយគាត់ គឺជាក្រុមចោរប្លន់ដែលបានរស់នៅអូរក្បែរអន្លង់នេះ ហើយនៅពេលដែលគាត់ស្លាប់គេបានយកគាត់ទៅកប់នៅត្រង់អូរនោះ គេក៏ហៅឈ្មោះ អន្លង់អូរតាឡូន រហូតមកដល់សព្វថ្ងៃនេះ ។ កាលពីខែ សីហា ឆ្នាំ ២០០៥ ប្រជាពលរដ្ឋបានឃើញក្រពើនៅក្នុងអន្លង់នេះ ។

**ចំណុចនៅលើ GPS :( មិនបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ** GPS )

- អាប់ស៊ីស =
- អរដោនេ =
- រយៈកំពស់ =

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ១០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ១០០ម ឆ្នាំ ២០០៦ = ២០០ម x ១០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : អន្លង់នេះនៅរដូវប្រាំងយើងមើលឃើញថ្មដុះជុំវិញមាត់អន្លង់ និងមានខ្សាច់ដុះក្បែរអន្លង់នៅខាងស្តាំ បើគិតតាមខ្សែទឹកឡើង ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិន-អាចមើលឃើញផ្ទាំងថ្មដុះ និងខ្សាច់ដែលមាននៅជុំវិញមាត់អន្លង់បានទេ ចំណែកឯទឹកមានលក្ខណៈគួចខ្លាំង ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០ម ទៅ ១៤ម ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្ទាន់, ត្រីផ្ទក់, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីក្រាយ, ត្រីឫសចេក, ត្រីត្រសក់, ត្រីខ្លា, ត្រីដំរី, ត្រីខ្ទឹង, បបែល, កន្ធាយ, ត្រីប៉ាសុីអុិ, ត្រីស្លាបមាន់, ត្រីក្បាន, ត្រីស្រកាក្តាម, ត្រីក្រឹម, ត្រីកន្ធរ, ត្រីឆ្នា (ប៉ាម៉ែរ), ត្រីកំភ្លាញ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, ក្អែកទឹក, មាន់ព្រៃ, អក, អាអូដ, ប្រវឹក, ក្ងោក, ត្មាត, ក្លែង, ទិទុយ, មៀម, សត្វក.ស, ត្រយ៉ង, សេក, ចាប, សារិកាកែវ, តាវ៉ៅ, គ្រលីងគ្រលោង, ត្រដៀវរិច, ត្រចៀកកាំ, ទទា, ក្រៀល, កេងកង, កំពូល, ព្រាប, ត្រដក់, លលក, អាឡ, ខ្វែក, ស្មោញ, កុកសរទាល, មាន់ទរ, ក្លែងមាន់, ក្លែងក្ងោក, ក្រួច ។

- ប្រភេទល្មូន : ពស់,កន្ទ្រង(ត្រង),អន្សង,ទន្សោង,អណ្តើក,ពង្រូល, ត្រកួត, តុកកែ, ឈ្លូស,ជន្លេន, ថ្លែន ។

- ប្រភេទសត្វផ្សេងៗ :ជ្រូកព្រៃ, ស្វា, ប្រើស, ក្តាន់, ឈ្លូស, ចចក, សំពោច, ខ្ទីងដូង, ប្រម៉ា, កំប្រុក, ស្កាវ, ឆ្មាព្រិច, ឆ្កែព្រៃ, ខ្លាឃ្មុំ, ខ្លាត្រី, ជ្រូកទេស (ខ្លួនជ្រូក ជើងឆ្កែ) រឺជ្រូកពោន, ដំរី, ខ្ទីង, សងទីង, គោ, ខ្វែកត្រួក, កណ្តុរ, ក្របី, គោ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមឫស្សី, ដើមរាំងទឹក ដើមល្វា, ដើមក្ទុល, ដើមសង្កែ, ដើមជន្លា, ដើមស្តែទឹក, ដើមស្លែង, ដើមសេរ, ដើមរកា, ដើមខ្លែ, ដើមប្រមាត់ដី ដើមត្រចៀកក្រាញ់, ដើមស្បាំង និងដើមច្រកែង។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភេទគឺ ប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា ពាមខិៈ បានហួយ កញ្ចាញទឹក សាមឃួយ ហាង្សាវ៉ាត ស្ពោ សៀមប៉ាង បានមួង កែងញ៉ៃ និងប្រជាជនវៀតណាមនៅស្ទឹងត្រែង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា ២ ហ៊ុនទៅ ៣ហ៊ុន នេសាទនៅរដូវប្រាំង (ខែធ្នូ ដល់ខែ កុម្ភៈ) ។

- សន្ទូច :នេសាទនៅខែមិថុនា ដល់ខែ តុលា ដោយប្រើផ្លែលេខ ៥ ទៅ១២

- មង : នេសាទចាប់ពីខែ តុលា ដល់ ខែ មករាដោយប្រើក្រឡាលេខ ៣ - ៥ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ ខែ កក្កដា

- លប : ដាក់ពីខែ ឧសភា ដល់ កក្កដា

### ៣.៧.២ អន្លង់អូរក្រឡាក់ (អន្លង់អូរតាឡាក់ )

**ក. ទីតាំង :**

អន្លង់អូរក្រឡាក់( អន្លង់អូរកាឡាក់) ស្ថិតនៅក្បាលភូមិលើអន្លង់អូរតាឡួនខាងឆ្វេងដៃ បើនិយាយតាមខ្សែទឹកឡើង អន្លង់នេះមានចំងាយ ៣00ម ពីភូមិព្រមទាំងមានថ្មច្រើន ហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា ។ តាមការនិយាយរបស់អ្នកភូមិបានបញ្ជាក់ថា កាលពីមុនមានចោរប្លន់យកមាសប្រាក់ ហើយបានវៃគ្នាទៅវិញទៅមកប្រឡូកប្រឡាក់ពាសពេញទីនោះ ទើបគេហៅអន្លង់នោះថា អូរក្រឡាក់ តៗគ្នារហូតមកដល់សព្វថ្ងៃនេះ ។ លក្ខណៈពិសេសរបស់អន្លង់នេះ គឺមានត្រីផ្សោត ប៉ុន្តែត្រូវបាត់បង់ ពីឆ្នាំ ( ១៩៧៣-១៩៧៩ ) ។

<u>**ចំណុចនៅលើ GPS : (មិនបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ** GPS )</u>

- អាប់ស៊ីស =
- អរដោនេ =
- រយៈកំពស់ =

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២៥ម ឆ្នាំ ២00៦ = ៧ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១៥0ម x ១00ម ឆ្នាំ ២00៦ = ១00ម x ៧0ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : អន្លង់នេះនៅរដូវប្រាំងមើលឃើញថ្មដុះជុំវិញអន្លង់ ចំណែកនៅកណ្តាលអន្លង់មានគល់ឈើដែលគេទំលាក់ នៅទីនោះតាមសំដីរបស់អ្នកភូមិបាននិយាយថាមានអ្នកមកកាប់ឈើដឹកតាមទូក តែដល់ធ្ងន់ពេកក៏ទំលាក់ចោល នៅក្នុងអន្លង់នោះទៅ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់បានឡើយ ចំណែកទឹកហូរក្តួចខ្លាំងព្រមទាំងមានថ្មប៉ប្រះទឹក ។ នៅរដូវវស្សាចាប់ពីខែសីហា ដល់ ខែវិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១0ម ដល់ ១៣ម ។



**ឃ .ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្នាន់, ត្រីក្លាំងហាយ, ត្រីផ្ទក់, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្តោក ត្រីប្រា, ត្រីកន្ទ្រប់, ត្រីកន្ត្រងប្រេង, ត្រីចង្វាមូល, ត្រីក្រាញ់ ,ត្រីឈ្វាត, ត្រីកៃ, ត្រីខ្ទីង, ត្រីប៉ាស៊ីអុី, ត្រីកញ្ជ្រូក ត្រីឫសចេក, ត្រីកំពត, ត្រីក្រពើ, បបែល, ត្រីឆ្លូញ, ត្រីកញ្ចាញ់ច្រាស់, ត្រីស្លាបមាន់, ត្រីក្បាន, ត្រីក្រឹម, ត្រីផ្ទោង, ត្រីឆ្នា( ប៉ាម៉េវ ), ត្រីថ្ម( ប៉ាកក ), ត្រីត្រសក់, និងត្រីកំភ្លាញ ។
- ប្រភេទសត្វស្លាបរួមមាន : កុក កដប មាន់ទឹក ប្រវឹក អក រនាល សត្វជើងក្អែកទឹក មាន់ព្រៃ អាអូដ ប្រវឹក ក្ងោក ត្មាត ក្លែង ទីទុយ មៀម សត្វកស ត្រយ៉ង សេក ចាប សារិកាកែវ តាវ៉ៅ គ្រលីងគ្រលោង ត្រដេវវិច ត្រចៀកកាំ ទទា គ្រៀល កេងកង កំពូលក្លែងក្ងោក ព្រពូ ត្រដក់ លលក អាឡ ខ្វែក ស្មោញ កុកស មាន់ទរ ក្លែងមាន់ ក្រួច អណ្តើក សត្វរំពេ ពពេច និងពង្រូល ។
- ប្រភេទល្មូន : ពស់, កន្ទ្រង( ត្រង ), អន្សង, អណ្តើក, ត្រកួត, កន្ធាយ
- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ប្រើស, ស្វា, សំពោច, ស្កា, ប្រម៉ា, កំប្រុក, ក្របី និងគោ ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី ដើមល្វា, ដើមរាំងទឹក, ដើមក្តុល, ដើមសង្កែ, ដើមទន្លា, ស្មៅ, ដើមប្រមាត់ដី, ដើមស្តៅទឹក, ដើមផ្កាអណ្តែង, ដើមក្លែ ដើមត្រចៀកក្រាញ់, ដើមស្បាំង, ដើមស្វាយព្រៃ, ដើមស្វាយស្រុក, ដើមផ្តៅ, ដើមពង្រ, ដើមធ្មេញត្រី, ដើមក្របៅ ដើមរកា, ដើមគគីរ, ដើមសេវ, ដើមត្រឡក,

ដើមក្រឡាញ់, ដើមប្រមោយដំរី, ដើមច្រកែង, ដើមញទឹក, ដើមត្រែង, ដើមស្រឡៅ, ដើមជ្រៃ, ដើមផ្ទី, ដើមមនទឹក និងដើមឈើទាល ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភេទ គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា ពាមខិៈ បានហួយ កញ្ចាញទឹក សាមឃួយ ហាង្សាវ៉ាត ស្ពៅ សៀមប៉ាង បានមួង កែងញ៉ៃ និងប្រជាជនវៀតណាមនៅស្ទឹងត្រែង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២ ហ៊ុនទៅ ៣ហ៊ុន នេសាទនៅរដូវប្រាំង (ពីខែ ធ្នូ ដល់ខែ កុម្ភៈ) ។

- សន្ទូច :នេសាទនៅរដូវវស្សាពីខែមិថុនា ដល់ខែ តុលា ដោយប្រើផ្លែលេខ ៥- ១២ ។

- មង : នេសាទនៅរដូវប្រាំងចាប់ពីខែ តុលា ដល់ខែ មករា ដោយប្រើក្រឡាលេខ ៣-៥ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ខែ កក្កដា

- លប : ដាក់ពីខែ ឧសភា ដល់ខែ កក្កដា



## ៣.៨ ភូមិកញ្ចាញទឹក ឃុំស្រែសំបូរ

ភូមិកញ្ចាញទឹក ស្ថិតនៅចំងាយប្រហែល ៨០គ.ម ពីទីរួមខេត្តស្ទឹងត្រែង ភូមិនេះធ្វើដំណើរទៅមកភាគច្រើនតាមផ្លូវទឹកហើយនៅរដូវប្រាំងក៏អាចធ្វើដំណើរតាមផ្លូវគោកបានដែរ ។ ភូមិនេះនៅជាប់ច្រាំងទន្លេខាងឆ្វេង បើនិយាយតាមខ្សែទឹកឡើង និងមានប្រជាពលរដ្ឋរស់នៅចំនួន ១៧៥គ្រួសារ មានប្រជាពលរដ្ឋសរុប ៧៤៣នាក់ ស្រី ៣៥៦នាក់ ភូមិនេះភាគច្រើនគេនាំគ្នានិយាយភាសាឡាវ ហើយការរស់នៅ គឺត្រូវពឹងផ្អែកទៅលើធនធាននៅក្នុងទន្លេ និងធនធាននៅក្នុងព្រៃ ។ អន្លង់នៅតាមចំណុចភូមិមានចំនួន ៧កន្លែង គឺ អន្លង់កំពង់ថ្ម អន្លង់ប៉ាតង អន្លង់តៃ អន្លង់ហ៊ីនដាង អន្លង់អូរគាន អន្លង់ខាន់ដាយនាងនាត និងអន្លង់វ៉ឺនតាញូង ហើយនៅក្នុងអន្លង់ទាំងនោះមានជំរៅមិនស្មើគ្នាទេ ក្នុងនោះអន្លង់ដែលមានជំរៅជ្រៅជាងគេ គឺ អន្លង់ខាន់ដាយនាងនាត (១៣,៣ ម) និងអន្លង់កំពង់ថ្ម (៦ ម) ។

### ៣.៨.១ អន្លង់កំពង់ថ្ម (ថាហ៊ីន)

**ក.ទីតាំង :**

អន្លង់កំពង់ថ្ម នៅកណ្តាលភូមិផ្នែកខាងក្រោមស្ថិតនៅខាងឆ្វេងដៃ បើនិយាយតាមខ្សែទឹកឡើងហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា ។ ប្រជាជននៅក្នុងភូមិបាននិយាយថា កាលពីមុនអន្លង់នេះធ្លាប់មានត្រីរាជ និងសត្វផ្សោត ។ នៅជាប់ច្រាំងខាងឆ្វេងមានផ្ទាំងថ្មធំៗ តែនៅរដូវប្រាំងយើងមើលឃើញថ្មប៉ប្រះទឹកតិចតួចណាស់ ហើយអន្លង់នេះសំបូរត្រីឆ្លាំងជាងគេ ។ ដោយសារមានផ្ទាំងថ្មធំៗជាច្រើននៅតាមអន្លង់ ទើបប្រជាជននាំគ្នាហៅអន្លង់នោះថា អន្លង់កំពង់ថ្ម រហូតមកដល់សព្វថ្ងៃនេះ ។ ប៉ុន្តែនៅឆ្នាំ (២០០៥)នេះ មានប្រភេទត្រីម៉្យាងដែលគេមិនស្គាល់ឈ្មោះបានខាំមនុស្ស តាមសំដីរបស់អ្នកនេសាទម្នាក់ឈ្មោះ នាងហួត ត្រីនោះរូបរាងវាខ្លីតែធំ ។

តារាង ៧ អន្លង់នៅក្នុងភូមិកញ្ចាញទឹក

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ ( ម ) | | ទំហំអន្លង់ពីមុន ( ម ) | | ទំហំអន្លង់បច្ចុប្បន្ន ( ម ) | | កូអរដោនេ ( GPS ) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់ កំពង់ថ្ម | ១៥ | ៦ | ៥០ | ៣០ | ៥០ | ៣០ | ១៥៤៧១១៨ | ០៦៤០៨៥៦ |
| ២ | អន្លង់ប៉ាតង | ១៥ | ៧ | ៥០ | ៣០ | ៥០ | ៣០ | ១៥៤៥៩៥៦ | ០៦៤០២៨៩ |
| ៣ | អន្លង់តៃ | ១៦ | ៧ | ៥៥ | ៣៥ | ៥៥ | ៣៥ | ១៥៤៥៨៨២ | ០៦៤០២៤៤ |
| ៤ | អន្លង់ហ៊ុនដាង | ២០ | ៧.៥ | ១០០ | ៨០ | ១០០ | ៨០ | ១៥៤៣២៤៨ | ០៦៤១០៥៧ |
| ៥ | អន្លង់អូរគៀន | ១២ | ១១.៥ | ២០០ | ៨០ | ១០០ | ៨០ | ១៥៤២៨៧២ | ០៦៤១៦៩៦ |
| ៦ | ខាន់ដាយនាងនាគ | ៣០ | ១៣.៣ | ២០០ | ១៥០ | ២០០ | ១៥០ | ១៥៣៩៨៩៦ | ០៦៤០១៣៩ |
| ៧ | អន្លង់តាញ៉ូង | ៤០ | ៣៥ | ៣០០ | ១៨០ | ៣០០ | ១៨០ | ១៥៣៩៣៨៣ | ០៦៣៨៩៧០ |



**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤០៨៥៦
- អរដោនេ = ១៥៤៧១១៨
- រយៈកំពស់ =

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៦ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៥០ម x ៣០ម ឆ្នាំ ២០០៦ = ៥០ម x ៣០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : អន្លង់នេះមើលឃើញផ្ទាំងថ្មធំៗល្អមនៅតាមច្រាំងទន្លេ ដោយស្ថានភាពទន្លេនៅចំណុចនោះល្អ គឺទឹកទន្លេនៅពេញបាតនៃទន្លេទាំងអស់ ដោយមើលមិនឃើញថ្មទេ តែមានថ្មនៅបាតទន្លេ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០ម ទៅ ១៤ម ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវវិនាសផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្ទាន់, ត្រីក្លាំងហាយ, ត្រីផ្ទក់, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា ត្រីឆ្តោក និងត្រីប្រា ។

- ប្រភេទសត្វស្លាបរួមមាន : កុក, កដប(សត្វងារកក), ក្អែកទឹក, មាន់ទឹក, រំពេ, និងក្អែកខ្មៅ ។

- ប្រភេទល្ហូន : ពស់,កន្ត្រង(ត្រង)

- សត្វផ្សេងៗ : ជ្រូក, ក្របី, គោ, មនុស្ស, មាន់ និងឆ្កែ ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់ ដើមឫស្សី, ដើមរាំងទឹក ដើមល្វា, ដើមក្តុល, ដើមសង្កែ, ដើមជន្លា (កុកហែ), ដើមឆ្កែង, ដើមប្រមាត់ដី, ដើមត្រចៀកក្រាញ់ និងវល្លិ៍ត្រដិត ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្តារុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា អ្នកមកពីស្ទឹងត្រែង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១- ២ហ៊ុនឬ ១តឹក២ ទៅ១តឹក៣ នេសាទនៅរដូវប្រាំង ។

  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ ទៅ ៩ (នេសាទគ្រប់រដូវ) ។

  - មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២-១៥ហ៊ុន ។

  - ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ ខែ មិថុនា និងនេសាទម្តងទៀតពី ខែតុលា ដល់ខែ វិច្ឆិកា ។

  - លប. សៃយឺន :នេសាទពីខែឧសភា ដល់ខែមិថុនា ។



### ៣.៨.២ អន្លង់ប៉ាតង (ត្រីក្រាយ)

**ក. ទីតាំង :**

អន្លង់ប៉ាតង ស្ថិតនៅផ្នែកខាងក្រោមជិតផុតកន្ទុយភូមិ នៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើងហើយ ទឹកហូរវិលខ្លាំងនៅរដូវវស្សា ។ កាលពីមុនអន្លង់នេះសំបូរទៅដោយត្រីក្រាយជាងអន្លង់ដទៃៗ ហេតុនេះហើយទើបគេហៅឈ្មោះអន្លង់ទៅតាមឈ្មោះត្រីក្រាយនេះ ហើយនៅផ្នែកខាងកើតអន្លង់មានខ្សាច់ដុះ ។

<u>**ចំណុចនៅលើ GPS :**</u>

- អាប់ស៊ីស = ០៦៤០២៨៩
- អរដោនេ = ១៥៤៥៩៥៦
- រយៈកំពស់ = (មិនបានបញ្ចូលទិន្នន័យ)

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៧ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៥០ម x ៣០ម ឆ្នាំ ២០០៦ = ៥០ម x ៣០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : អន្លង់នេះនៅរដូវប្រាំងមើលឃើញផ្ទាំងថ្មនៅក្បាលអន្លង់ មានថ្មប៉ប្រះទឹក និងនៅតាមច្រាំងទន្លេជាប់មាត់អន្លង់មានដើមរុក្ខជាតិតូចៗ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ដុះបានឡើយ ។ នៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០ម ទៅ ១៤ម។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្ហូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា

ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្ពោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្នាន់, ត្រីក្លាំងហាយ, ត្រីផ្ទក់, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក ត្រីប្រា, ត្រីក្រពើ និងត្រីខ្ទឹង ។

- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, ក្អែកទឹក, មាន់ទឹក និងពពេច
- ប្រភេទលូន : ពស់, កន្ធ្រង(ត្រង)
- សត្វផ្សេងៗ : ជ្រូក, ក្របី និងគោ

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, គុម្ពឫស្សី, ដើមរាំងទឹក ដើមល្វា, ដើមក្តុល, ដើមសង្កែ,ដើមស្លែង និងដើមជន្លា។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភពគឺ ប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជាភូមិ ហាងឃោ តាដែត ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១-២ ហ៊ុនឬ ១តឹក២ទៅ១តឹក៣ នេសាទនៅរដូវប្រាំង ។
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ ទៅ ៩(នេសាទគ្រប់រដូវ) ។
  - មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២- ១៥ហ៊ុន ។



- ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ ខែ មិថុនា និងនេសាទម្តងទៀតពី ខែ តុលា ដល់ខែ វិច្ឆិកា ។
- លប. សៃយឺន : នេសាទពីខែ ឧសភា ដល់ខែ មិថុនា ។

**៣.៨.៣ អន្លង់តែ(សង្កែ)**

**ក. ទីតាំង :**

អន្លង់តែ ស្ថិតនៅផ្នែកខាងក្រោមភូមិនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើង ហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា ។ កាលពីមុនអន្លង់នេះសំបូរទៅដោយត្រីប៉ាតែ (ត្រីកែ)ជាងអន្លង់ដទៃៗទៀត ហេតុនេះហើយទើបគេហៅឈ្មោះអន្លង់ទៅតាមឈ្មោះត្រីប៉ាតែនេះ តែបច្ចុប្បន្នគេហៅថា អន្លង់សង្កែ ដោយមានដើមសង្កែដុះច្រើននៅតាមច្រាំងទន្លេ ចំណុចអន្លង់នេះទើបតែហៅនាពេលបច្ចុប្បនេះ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៨០២៨៤
- អរដោនេ =១៥៤៥៨៨២
- រយៈកំពស់ =៥៩ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៦ម ឆ្នាំ ២០០៦ = ៧ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៥៥ម x ៣៥ម ឆ្នាំ ២០០៦ = ៥៥ម x៣៥ម

**គ. មជ្ឈដ្ឋានជុំវិញ :**

- ♦ រដូវប្រាំង : អន្លង់តែនេះ គឺខុសពីអន្លង់ដទៃ ដោយនៅរដូវប្រាំងក៏យើង មិន-អាចមើលឃើញផ្ទាំងថ្មធំៗដែរ យើងអាចមើលឃើញផ្ទៃទឹកតែប៉ុណ្ណោះ ។
- ♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ ទាំងអស់មិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ជុំវិញមាត់អន្លង់បានឡើយ ។ នៅរដូវវស្សា ចាប់ពីខែ

សីហា ដល់ខែវិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០មទៅ ១៣ម ដោយប្រែប្រួលទៅតាមឆ្នាំ ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប លូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្អិន, ត្រីឆ្ពោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីប្រកែង, ត្រីក្រពាត់ ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក,ត្រីប្រា (រកមិនបានឆ្នាំនេះ) និងត្រីខ្ទឹង ។
- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, ក្អែកទឹក, មាន់ទឹក,មាន់ព្រៃ និងសត្វអាអួដ
- ប្រភេទលូន : ពស់, កន្ត្រង
- ប្រភេទសត្វផ្សេងៗ : ក្របី, គោ និងមនុស្ស

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរំដេះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, គុម្ពឫស្សី, ដើមរាំងទឹក ដើមល្វា, ដើមក្តុល, ដើមសង្កែ និងដើមស្លែង (ក្រចៅ) ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្កាវុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជាភូមិ កន្ទុយគោ ស្តៅ តាកដែត ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១-២ហ៊ុនឬ ១តឹក២ទៅ១តឹក៣ នេសាទនៅរដូវប្រាំង ។
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ ទៅ៩ (នេសាទគ្រប់រដូវ) ។
  - មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២- ១៥ហ៊ុន ។
  - ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ខែមិថុនា និង នេសាទម្តងទៀតពីខែ តុលា ដល់ខែ វិច្ឆិកា ។
  - លប. សៃយឺន :នេសាទពីខែ ឧសភា ដល់ ខែ មិថុនា



**៣.៨.៤ អន្លង់ហ៊ិនដាង (ថ្មពពាល)**

**ក. ទីតាំង :**

អន្លង់ហ៊ិនដាង ស្ថិតផ្នែកខាងក្រោមភូមិចំងាយ ៣,៥គ.ម ស្ថិតនៅខាងឆ្វេងដៃ បើនិយាយតាមខ្សែទឹកឡើងហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា ។ អន្លង់នេះកាលពីមុនមានថ្មអណ្តែតមួយគូមកជាប់នៅចំណុចអន្លង់ ហើយជារៀងរាល់ឆ្នាំតែងតែមានត្រីត្រសក់មកលេងថ្មនេះរហូតមកដល់សព្វថ្ងៃនេះ គឺនៅក្នុងខែ កត្តិក ត្រូវនឹងខែ វិច្ឆិកា ។ នៅផ្នែកខាងឆ្វេងមានថ្មដុះពណ៌ពពាល និងនៅកន្ទុយអន្លង់មានថ្មដុះប៉ប្រះទឹកច្រើន ហើយនៅក្បាលអន្លង់មានអូរមួយហូរចាក់ឈ្មោះថា អូរថ្មពពាល និងមានថ្មប្រភេទនេះនៅចំក្បាលអន្លង់តែម្តងហេតុនេះហើយគេក៏ហៅអន្លង់នេះទៅតាមសណ្ឋាននៃថ្មនោះតែម្តងទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = 0៦៤១0៥៧
- អរដោនេ =១៥៤៣២៤៨
- រយៈកំពស់ =៥៧ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២០ម ឆ្នាំ ២00៦ = ៧,៥ម

- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០០ម x ៨០ម ឆ្នាំ ២០០៦ = ១០០ម x ៨០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : មើលឃើញផ្ទាំងថ្មនៅជុំវិញអន្លង់ និងមានដើមរំដេះនៅតាមថ្ម ហ៊ុំព័ទ្ធជាង ស្ថិតនៅជាប់ច្រាំងខាងឆ្វេង និងមានថ្មដុះប៉ប្រះទឹកនៅច្រើននៅផ្នែកខាងក្រោមអន្លង់

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ ទាំងអស់មិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ជុំវិញមាត់អន្លង់បានឡើយ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០មទៅ ១៤ម ប្រែប្រួលតាមឆ្នាំ ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្កោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្មាន់, ត្រីចេកទុំ, ត្រីផ្ទក់, បំពេល, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា និងត្រីខ្ទឹង ។

- ប្រភេទសត្វស្លាបរួមមាន : កុក, កដប(ងាវកក), ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ និងសត្វអាអូដ ។

- ប្រភេទល្មូន : ពស់, កន្ត្រង (ត្រង) និងកន្ធាយ

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ស្វា



**ង. ប្រភេទរុក្ខជាតិ :**

មានដើមរំដេះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, គុម្ពឫស្សី ដើមរាំងទឹក ដើមល្វា, ដើមក្តុល និងដើមស្តៅទឹក ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជាភូមិ កន្ទុយគោ ស្តៅ បាឌើម តាកដែត និងសៃឃួន ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១-២ ហ៊ុនឬ ១តឹក២ទៅ១តឹក៣ នេសាទនៅរដូវប្រាំង ។

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ ទៅ ៩ (នេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២- ១៥ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ខែ មិថុនា និងនេសាទម្តងទៀតពី ខែតុលា ដល់ ខែវិច្ឆិកា ។

- លប. សៃយ៉ឺន :នេសាទពីខែ ឧសភា ដល់ ខែ មិថុនា ។

### ៣.៨.៥ អន្លង់អូរគៀន (អូររទេះ)

**ក. ទីតាំង :**

អន្លង់អូរគៀន ស្ថិតនៅចំងាយ ៤,៥ គ.មពីភូមិកញ្ជាញទឹក ផ្នែកខាងក្រោមស្ថិតនៅខាងស្តាំដៃបើនិយាយតាមខ្សែទឹកឡើង ហើយទឹកហូរវិលខ្លាំងនៅរដូវវស្សា ។ នៅក្បាលអន្លង់ត្រើយខាងកើតមានអូរមួយហូរចាក់ឈ្មោះថា អូរគៀន(អូររទេះ)បើនិយាយតាមខ្សែទឹកមកលើ គឺនៅខាងស្តាំដោយកាលពីមុនមានរទេះកង់ដែកទៅដឹកឈើហើយឆ្លងកាត់អូរនេះក៏បានបាក់កង់រទេះនៅចំណុចនោះទើបបានគេហៅថាអូរគៀន ហើយឈ្មោះអន្លង់ក៏គេហៅទៅតាមនោះទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤១៦៩៦
- អរដោនេ = ១៩៤២៨៧២
- រយៈកំពស់ = ៥៨ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១២ម ឆ្នាំ ២០០៦ = ១១,៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ២០០ម x ៨០ម ឆ្នាំ ២០០៦ = ១០០ម x ៨០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : គឺយើងមើលឃើញផ្ទាំងថ្មធំៗនៅក្បាលអន្លង់ និងនៅកន្ទុយអន្លង់មានថ្មប៉ប្រះទឹក ហើយនៅតាមច្រាំងទន្លេជាប់មាត់អន្លង់មានផ្ទាំងថ្មតូចធំ ឯនៅផ្ទៃទន្លេមានថ្មទាំងខាងក្បាល និងខាងកន្ទុយអន្លង់កាត់ទទឹងទន្លេជាជួរដូចស្ពាន។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ។ កំពស់ទឹកនៅរដូវទឹកឡើងមាន ១០ទៅ ១៥ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប លូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឬស្សី ត្រីខ្មាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីត្រសក់, ត្រីក្លាំងហាយ និងត្រីខ្ទឹង ។
- ប្រភេទសត្វស្លាបរួមមាន : កុក,កដប,ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ និងសត្វអាអួដ
- ប្រភេទលូន : ពស់, ត្រកួត, កន្ត្រង, អន្សង និងកន្ធាយ
- ប្រភេទសត្វផ្សេងៗ :ជ្រូកព្រៃ, ឈ្លូស, ស្វា និងប្រើស

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរំដេះតាមថ្មក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, គុម្ពឬស្សី, ដើមរាំងទឹក, ដើមល្វា, ដើមក្ទុល, ដើមសង្កែ, ដើមស្លែង, ដើមកកោះ, ដើមជន្លា, ដើមស្រឡៅ និងដើមក្បៀរ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការរុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភពគឺ ប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជាភូមិ កន្ទុយគោ ស្តៅ សៀមប៉ាង តាកដែត សាឃួន ញ៉ឹន កេតមឿង ពាមខិៈ ផាបាំង និងភូមិចាន់តាង៉យ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១- ២ហ៊ុនឬ ១តឹក២ទៅ១ តឹក ៣ នេសាទនៅរដូវប្រាំង ។
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ទៅ៩ (នេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២-១៥ ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ខែមិថុនា និងនេសាទម្តងទៀតពីខែតុលា ដល់ ខែវិច្ឆិកា ។

- លប. សៃយ៉ឺន :នេសាទពីខែឧសភា ដល់ខែ មិថុនា ។

### ៣.៨.៦ អន្លង់ខាន់ដាយនាងនាគ (ជណ្តើរនាងនាគ )

**ក. ទីតាំង :**

អន្លង់ខាន់ដាយនាងនាគ ស្ថិតនៅចំងាយ ៦គ.មពីភូមិផ្ទែកខាងក្រោមស្ថិតនៅច្រាំងទន្លេ ខាងស្តាំដៃបើនិយាយតាមខ្សែទឹកឡើង(ខាងកើត) ហើយទឹកហូរខ្លាំងវិលនៅរដូវវស្សា និងរដូវប្រាំង ។ អន្លង់នេះកាលពីមុនមាននាគមកលេងទឹករៀងរាល់ថ្ងៃសីល ហើយសំបូរទៅដោយប្រភេទត្រីធំៗដូចអន្លង់តាញូងដែរ ។ ដោយនៅតាមច្រាំងទន្លេជាប់មាត់អន្លង់មានរូប សំណាកថ្ម ដូចជាជណ្តើរមានរាងស្រទាប់ៗចាប់ពីបាតអន្លង់រហូតឡើងមកដល់ មាត់ច្រាំងទន្លេខាងលើមាននាគមកលេងនៅតាមកាំជណ្តើរចំណុចអន្លង់ ដោយហេតុនេះហើយទើបគេហៅឈ្មោះអន្លង់តាមសណ្ឋានថ្មនេះ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤០១៣៩
- អរដោនេ =១៥៣៩៨៥៦
- រយៈកំពស់ =៦០ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៣០ម ឆ្នាំ ២០០៦ = ១៣,៣ម
- ទំហំ :មុនឆ្នាំ១៩៩៥ = ២០០ម x ១៥០ម ឆ្នាំ ២០០៦ = ២០០ម x ១៥០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅរដូវប្រាំងមានថ្មផុសជាជួរនៅក្បាលអន្លង់ប្រវែង ១០ម



ពីច្រាំង និងមានកោះមួយដុះនៅចំហៀងអន្លង់ប៉ែកខាងលិច ហៅថាកោះគ្រួសនៅរដូវប្រាំង និងមានខ្សាច់នៅច្រាំងខាង ឆ្វេងបើនិយាយ(តាមខ្សែទឹកមកលើ) ឯព្រៃនៅតាមច្រាំងទន្លេជាប្រភេទព្រៃក្រាស់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ ដុះនៅជុំវិញមាត់អន្លង់បានឡើយ ។ នៅរដូវវស្សាចាប់ពីខែសីហា ដល់ខែ វិច្ឆិកា កំពស់ទឹកឡើងរហូតដល់ ១០ម ទៅ ១៥ម ប្រែប្រួលទៅតាមឆ្នាំ ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្ននេះមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្ពោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្តោក និងត្រីប្រា ។
- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ និងអាអូដ
- ប្រភេទល្មូន : ពស់, ត្រកួត, កន្ធ្រង
- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស និងខ្លាឃ្មុំ

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមថ្មជាប់មាត់អន្លង់មាន ដើមត្រស់, ដើមល្វា, ដើមឫស្សី, ដើមរាំងទឹក, ដើមក្តុល, ដើម សង្កែ, ដើមស្លែង, ដើមស្ពៃទឹក និងដើមប្រមាត់ដី ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្កាវរុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភេទគឺ ប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជា ភូមិកន្ទុយគោ ស្ដៅ តាកដែត សៀមប៉ាង សាឃួន ញ៉ឺន កេតមឿង ពាមខិៈ ផាប៉ាង និងភូមិចាន់តាង៉យ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១-២ ហ៊ុនឬ ១តឹក២ទៅ១ តឹក ៣ នេសាទនៅរដូវប្រាំង ។

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ទៅ៩ (នេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២- ១៥ហ៊ុន ។

- ចាន់ : នេសាទចាប់ពីខែ ឧសភា ដល់ខែ មិថុនា និងនេសាទម្ដងទៀត ពីខែ តុលា ដល់ខែ វិច្ឆិកា ។

- លប. សៃយ៉ឺន : នេសាទពីខែ ឧសភា ដល់ខែ មិថុនា ។

### ៣.៨.៧ អន្លង់រ៉ឺនតាញ៉ូង

**ក. ទីតាំង :**

អន្លង់រ៉ឺនតាញ៉ូង ស្ថិតនៅជាប់កន្ទុយអន្លង់ខាន់ដាយនាងនាគនៅផ្នែកខាងក្រោម ស្ថិតនៅខាងឆ្វេងដៃបើនិយាយតាមខ្សែទឹកឡើង (ខាងលិច) ហើយទឹកហូរកួចនៅរដូវវស្សា ។ អន្លង់នេះកាលពីដើមជាជម្រកសត្វ ក្រពើ ផ្សោត និងបបែល ។ កាលពីដើមមានតាចាស់ម្នាក់ឈ្មោះតាញ៉ូង គាត់ទៅជ្រមុជទឹកនៅចំណុចអន្លង់នោះ បន្ទាប់ពីជ្រមុជទឹកក៏បានបាត់ខ្លួនទៅក្រោយមក ទើបគាត់ត្រឡប់មកផ្ទះវិញ ហើយគាត់ប្រាប់ថាទៅផុសនៅរ៉ឺនខាមប្រទេសឡាវក្រោយមកគេក៏ហៅអន្លង់នេះទៅតាមឈ្មោះរបស់គាត់រហូតមកដល់សព្វថ្ងៃ ។



**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = ០៦៣៨៩៧០
- អរដោនេ =១៥៣៩៣៨៣
- រយៈកំពស់ =៥៧ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៤០ម ឆ្នាំ ២០០៦ = ៣៥ម
- ទំហំ :មុនឆ្នាំ ១៩៩៥ = ៣០០ម x ១៨០មឆ្នាំ ២០០៦ = ៣០០ម x១៨០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅរដូវប្រាំងមានថ្មាំងថ្មនៅខាងក្រោមជាប់មាត់អន្លង់ ចំណែកកណ្ដាលអន្លង់វិញជាប់នឹងកន្ទុយកោះដែលគេហៅឈ្មោះថា កោះគ្រួស ដែលភាសាឡាវហៅថា (ហាតហ៊ៃ) ហើយនៅត្រើយខាងកើតមានឆ្នេរខ្សាច់ដុះចេញហៅថា កោះល្វា ភាសាឡាវហៅ (ហាតដឿ) ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញថ្មាំងថ្ម និងខ្សាច់ជុំវិញមាត់អន្លង់បានឡើយ ។ នៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា កំពស់ទឹកឡើងដល់ ១០មទៅ ១៥ម ដោយមានការប្រែប្រួលទៅតាមឆ្នាំ ។

**ឃ.ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះត្រូវបានថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្ដង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបាននាពេលបច្ចុប្បន្នមានដូចជា ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី ត្រីខ្នាន់,ត្រីចេកទុំ,ត្រីផ្ទក់, បបែល, ត្រីថ្ម, ត្រីអណ្ដាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្ដាយ, ត្រីប្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក និង ត្រីប្រា ។

- ប្រភេទសត្វស្លាបរួមមាន ៖កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអូដ, ក្ងោក, ក្អែកខ្មៅ, រំពេ សេក និងសត្វលលក ។

- ប្រភេទល្មូន ៖ ពស់, ត្រកួត, កន្ធ្លង, អន្សោង និងកន្ធាយ ។

- ប្រភេទសត្វផ្សេងៗ ៖ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស និងខ្លាឃ្មុំ ។

**ង. ប្រភេទរុក្ខជាតិ ៖**

មានដើមរៃ ដើមផ្កាអណ្ដែង ដុះតាមថ្មក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមឫស្សី ដើមរាំងទឹក, ដើមល្វា, ដើមក្ដុល, ដើមសង្កែ, ដើមស្លែង, ដើមស្ដៅទឹក, ដើមត្រចៀកក្រាញ់, ដើមប្រមាត់ដី, ដើមផ្ដៅ, ដើមត្រែង និងលក្ខណៈជាប្រភេទព្រៃស្ដុក ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភពគឺ ប្រជាជនក្នុងភូមិ និង ប្រជាជនដែលមកពីភូមិខាងក្រៅដូចជាភូមិស្ដៅ តាកដែត សៀមប៉ាង សាឃួន ញ៉ីន ហ្វៃងម៉ា ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា ៖

- សំណាញ់ ៖ គឺប្រើប្រាស់ចាប់ពីក្រឡា ១-២ ហ៊ុនឬ ១តឹក២ទៅ១តឹក៣ នេសាទនៅរដូវប្រាំង ។

- សន្ទូច ៖ នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ ទៅ ៩ (នេសាទគ្រប់រដូវ) ។

- មង ៖ នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ២- ១៥ហ៊ុន ។

- ចាន់ ៖ នេសាទចាប់ពីខែ ឧសភា ដល់ខែមិថុនា និងនេសាទម្ដងទៀតពីខែតុលា ដល់ខែវិច្ឆិកា ។



- លប. សៃយឺន ៖នេសាទពីខែ ឧសភា ដល់ខែ មិថុនា

## លទ្ធផលនៃការសិក្សាស្រាវជ្រាវទន្លេស្រែពក

***អន្លង់តាមបណ្ដោយទន្លេស្រែពក***

### ៣.៩ ភូមិស្រែស្រណុក ឃុំក្បាលរមាស

ភូមិស្រែស្រណុក ជាភូមិដែលស្ថិតនៅតាមបណ្ដោយដងទន្លេស្រែពក ក្នុងស្រុកសេសាន ដែលមានចំងាយ ៦៧គ.ម (តាមផ្លូវគោក)ពីទីរួមខេត្តស្ទឹងត្រែង យើងអាចធ្វើដំណើរបានទាំងផ្លូវគោក និងផ្លូវទឹក ។ ចំនួនប្រជាពលរដ្ឋរស់នៅមាន ៩១គ្រួសារ ប្រជាពលរដ្ឋសរុប ៤២៦នាក់ ស្រី ២១២នាក់ ហើយគាត់ទាំងអស់គ្នាភាគច្រើនជាជនជាតិព្រៅ ការប្រកបមុខរបរគឺ ពឹងផ្អែកទៅលើស្រែ ចំការ និងធនធានធម្មជាតិ ។

អន្លង់នៅក្នុងភូមិនេះសរុបមានចំនួន ៤កន្លែង គឺអន្លង់កោះអណ្ដែត អន្លង់កំពង់ជ្រៃ អន្លង់ពាមអូរសួរ និងអន្លង់កំពង់ទឹក ។ អន្លង់នីមួយៗមានជំរៅមិនស្មើគ្នាទេ ក្នុងនោះអន្លង់ដែលមានជំរៅជ្រៅជាងគេគឺ អន្លង់កោះអណ្ដែត (១០ម) និងអន្លង់មានជំរៅរាក់ជាងគេគឺអន្លង់ពាមអូរសួ(៥ម) ចំពោះលក្ខណៈអន្លង់ទាំងនេះនៅមានជំរៅជ្រៅ២ ដែលជាជម្រកត្រីដ៏ពិសេស។

តារាង ៨ អន្លង់នៅក្នុងភូមិស្រែស្រណុក

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំពីមុន(ម) | | ទំហំបច្ចុប្បន្ន(ម) | | កូអរដោនេ (GPS) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់កោះអណ្តែត | ២៧ | ១០ | ២០០ | ១០០ | ១៥០ | ៨០ | ១៤៨៨៤៧៩ | ០៦៥៣១២១ |
| ២ | អន្លង់ពក់ព្រៀ | ១៥ | ៨ | ១០០ | ៥០ | ១០០ | ៥០ | ១៤៨៨៧៥៧ | ០៦៥៤១៥២ |
| ៣ | អន្លង់ ពាមអស្សូ | ១៨ | ៩ | ២០០ | ១៥០ | ២០០ | ១៥០ | ១៤៨៥៦១៤ | ០៦៥៨៥៨ |
| ៤ | អន្លង់ពក់ទឹក | ១៥ | ៨ | ៣៥០ | ១៥០ | ៣៥០ | ១៥០ | | |



### ៣.៩.១ អន្លង់កោះអណ្តែត

**ក ទីតាំង :**

អន្លង់កោះអណ្តែត ស្ថិតនៅផ្នែកខាងក្រោមភូមិចំងាយ ២គ.ម ហើយមានកោះមួយស្ថិតនៅជិតនោះឈ្មោះថា កោះអណ្តែត ដោយសារតែកោះនេះវារសាត់ចុះឡើងៗម្តងខាងនេះម្តងខាងនោះទើបគេហៅថា អន្លង់កោះអណ្តែត នេះទៅតាមលក្ខណៈនៃកោះនោះ ។ បើយើងមកពីខាងលើនៃខ្សែទឹកចុះ គឺអន្លង់នេះស្ថិតនៅផ្នែកខាងស្តាំដៃតាមការកត់សំគាល់របស់បងប្អូន យើងនៅក្នុងភូមិ ថានៅពេលមានទឹកលិចកោះនេះ គឺច្បាស់ជាមានទឹកធំនៅរដូវវស្សា ។

សព្វថ្ងៃសហគមន៍នៅភូមិស្រែស្រណុកបានឯកភាពគ្នា និងសហការស្រុះស្រួលមតិគ្នាដើម្បីធ្វើការអភិរក្សអន្លង់កោះអណ្តែតនេះឡើងវិញក្រោមការឧបត្ថម្ភរបស់អង្គការ ស្ត្រីសន្តិភាពដើម្បីបរិស្ថាន (SSP) និងសហការជាមួយការិយាល័យជលផលខេត្តស្ទឹងត្រែង ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥៣១២១
- អរដោនេ =១៤៨៨៤៧៩
- រយៈកំពស់ =៦៣ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២៧ម ឆ្នាំ ២០០៦ = ១០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ២០០ម x ១០០ម ឆ្នាំ ២០០៦ = ១៥០ម x ៨០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ នៅរដូវប្រាំង : មានផ្ទៃព័ទ្ធជុំវិញអន្លង់មានរាងទ្រវែង (ពងក្រពើ) និងមានកូនឈើដុះជុំវិញនៅផ្នែកជុំវិញមាត់អន្លង់ មើលឃើញថ្មប៉ប្រះទឹក ដើមផ្កាអណ្តែង ដើមរំពៃនៅកណ្តាលអន្លង់មានកោះមួយឈ្មោះថាកោះ អណ្តែតមានរាងមូលទ្រវែងវាអណ្តែតទៅមកៗ និងនៅខាងលើច្រាំងមានដើមឈើច្រើនចំណែកស្ថានភាពទឹកគឺក្ងួចវិលទាំងរដូវប្រាំង និងរដូវវស្សា

♦ រដូវវស្សា ៖ នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទាំងនោះទេ ។ នៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ តុលា កំពស់ទឹកឡើងរហូតដល់ ១០ ទៅ១៤ ម៉ែត្រ និងអាចមានការប្រែប្រួលទៅតាមឆ្នាំ។

**ឃ ប្រភេទសត្វ ៖**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី ៖ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីលលកស, ត្រីផ្ទោង, ត្រីអំបូង, គ្រុំ, ត្រីកន្ធ, ត្រីកន្ត្រប់, ត្រីក្រាញ់, ត្រីក្របី, ត្រីដំរី, ត្រីគល់រាំង, បបែល, ត្រីខ្ទីង, ត្រីកញ្ចុះ, ត្រីក្អាន, ត្រីអណ្តែង, ត្រីប្រាកណ្តុរ, ត្រីស្លាបមាន់, ត្រីឆ្លូញ, ត្រីកញ្ជ្រូក, ត្រីឬសចេក, ត្រីប៉ាស៊ីអ៊ិ, ត្រីលេញ, ត្រីបង្កួយ, ត្រីប៉ាភៀន (ត្រីខ្យល់), ត្រីននោងល្វីង, ត្រីអាចម៍កុក, ត្រីអន្ទ័យ, ត្រីល្មិច, ត្រីស្លឹកក្ដួច, ត្រីផ្កាគរ និងត្រីកំពត ។

- ប្រភេទសត្វស្លាបរួមមាន ៖កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអូដ, ក្លែង, ពពូល, សេក, ចាប, សារិកាកែវ, កេងកង, ត្រយង, អក, ត្មាត, លលក, ក្ងោក, ត្រដក់, ក្រៀល, ទីទុយ, មៀម, គ្រលីងគ្រលោង, ឪឡ, ទទា, តាវ៉ៅ, ផ្តោក, កែវលើក, កុកគ្រោង, និងត្រសេះ ។

- ប្រភេទល្មូន ៖ ពស់, ត្រកួត, កន្ធ្រង, អណ្តើក, អន្សង, កន្ធាយ, កំប្រុក, និងក្រពើ(ឃើញម្តងៗ) ។

- ប្រភេទសត្វផ្សេងៗ ៖ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស, ខ្លាឃ្មុំ, ឆ្កែព្រៃ និងខ្លាខ្មៅ



**ង. ប្រភេទរុក្ខជាតិ ៖**

មានដើមរៃនៅដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមល្វាដើមឫស្សី, ដើមរាំងទឹក, ដើមក្តុល, ដើមសុក្រំ, ដើមឈ្លីច, ដើមឆ្កែង, ដើមត្រែង, ដើមត្រាច, ដើមខ្លុង, ដើមស្រឡៅ, ដើមផ្ទីក, ដើមពពេល, ដើមគគីរ, ដើមកកោះ, ដើមផ្តៀក, ដើមញ, ដើមស្វាយព្រៃ, ដើមជន្លា, ដើមមៀនទឹក, ដើមខ្វាវ, ដើមព្រីង, ដើមប្រាំដំឡឹង, ដើមសង្កែ, ដើមឆ្កែស្រែង, ដើមអង្រ្កង, ដើមតង្កៀបក្តាម, ដើមជើងគោ, ដើមធ្នង់, ហើយនៅមាត់អន្លង់មាន ដើមស្លែទឹក, ដើមប្រមាត់ដី និង កំប្លោក និងមានចកដុះនៅពាសពេញទឹក។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្កាវុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺ ប្រជាជនក្នុងភូមិស្រែស្រណុក និងប្រជាជនដែលមកពីមកពីភូមិខាងក្រៅដូចជាភូមិភ្លុក កំភុន សេសានសាមឃួយ ហាងសាវ៉ាត បាដើម កំផាន់ ស្តៅ កោះស្នែង ក្បាលរមាស និងភូមិក្របីជ្រុំ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា ៖

- សំណាញ់៖ គឺប្រើប្រាស់ចាប់ពីក្រឡា ៥ស.មទៅ ១២ស.ម នេសាទនៅរដូវប្រាំង

- សន្ទូច ៖ នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ទៅ១០ (នេសាទគ្រប់រដូវ) ។

- មង ៖ នេសាទចាប់ពីខែ ធ្នូ ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៤-១០ស.ម

- ចាន់ ៖ នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ។

## ៣.៩.២ អន្លង់កំពង់ជ្រៃ

### ក ទីតាំង :

អន្លង់កំពង់ជ្រៃ នេះស្ថិតនៅផ្នែកខាងក្រោមភូមិចំងាយ ២គ.ម បើយើងមកពីខាងលើនៃខ្សែទឹកចុះ គឺអន្លង់នេះស្ថិតនៅផ្នែកខាងឆ្វេងដៃ ដោយនៅជិតអន្លង់នេះមានដើមជ្រៃជាច្រើនដុះនៅតាមច្រាំងមាត់ទឹក និងច្រាំងទន្លេខាងលើ ហេតុនេះហើយទើបគេហៅទៅតាមស្ថានភាពដើមជ្រៃនោះ ។

**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = ០៦៥៤១៥២
- អរដោនេ = ១៤៨៨៧៥៧
- រយៈកំពស់ = ៦២ម

### ខ. លក្ខណៈរូប :

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៨ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០០ម x ៥០ម ឆ្នាំ ២០០៦ = ១០០ម x ៥០ម

### គ. មជ្ឈដ្ឋានជុំវិញ :

♦ រដូវប្រាំង : មានថ្មប៉ប្រះទឹកព័ទ្ធជុំវិញនៅជាប់គ្នានឹងអន្លង់កោះអណ្តែត ប៉ុន្តែមានអន្លង់ទំហំតូចៗជាងអន្លង់កោះអណ្តែត និងមានកូនឈើដុះជុំវិញ ។ នៅរដូវប្រាំងយើងឃើញមាត់អន្លង់ចាប់ពី ខែវិច្ឆិកា ដល់ខែឧសភា ផ្នែកជុំវិញមាត់អន្លង់មើលឃើញថ្មប៉ប្រះទឹក ដើមផ្កាអណ្តែង ដើមរ៉ៃ នៅកណ្តាលអន្លង់មានទឹកហូរខ្លាំង និងកួចនៅខាងលើច្រាំងមានដើមឈើច្រើនជាពិសេសដើមជ្រៃ ។

♦ រដូវវស្សា : នៅរដូវវស្សាទឹកលិចមាត់អន្លង់ចាប់ពី ខែមិថុនា ដល់ខែវិច្ឆិកា ចំនែកកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ។ នៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ តុលា កំពស់ទឹកឡើងរហូតដល់១០ ទៅ ១៤ម៉ែត្រ ដោយមានការប្រែប្រួលទៅតាមឆ្នាំ។



### ឃ ប្រភេទសត្វ :

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្ជាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, ត្រីថ្ម,ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្តោក, ត្រីប្រា, ត្រីលលក ស, ត្រីផ្ទោង, ត្រីអំបូង, គ្រំ, ត្រីកន្ធរ, ត្រីកន្ត្រប់, ត្រីក្រាញ់, ត្រីក្របី, ត្រីដឺរ, ត្រីគល់រាំង, ត្រីខ្ទឹង, ត្រីកញ្ចុះ, ត្រីក្មោន, ត្រីអណ្តែង, ត្រីប្រាកណ្តុរ, ត្រីស្លាបមាន់, ត្រីឆ្លូញ, ត្រីកញ្ជ្រូក, ត្រីឫសចេក, ត្រីកំពត, ត្រីប៉ាស៊ីអ៊ី, ត្រីលេញ, ត្រីបង្កួយ, ត្រីប៉ាភៀន(ត្រីខ្យល់), ត្រីននោងល្វីង, ត្រីអាចម៍កុក, ត្រីអន្ទ័យ, ត្រីល្វិច, ត្រីស្លឹកក្លូច និងត្រីផ្កាគរ ។
- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអូដ, ខ្លែង, ពពូល, សេក, ចាប, សារិកាកែវ, កេងកង, ត្រយង, អក, ត្មាត, លលក, ក្ងោក, ត្រដក់, ក្រៀល, ទិទុយ, មៀម, គ្រលីងគ្រលោង, ឪឡ, ទទា,តាវ៉ៅ, ផ្តោក, កែវលើក, កុកគ្រោង, និងត្រសេះ ។
- ប្រភេទល្មូន : ពស់,ត្រកួត, កន្ធ្លង, អណ្តើក, អន្ទ្យង និងកន្ធាយ
- ប្រភេទសត្វផ្សេងៗ :ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស និងខ្លាឃ្មុំ

### ង. ប្រភេទរុក្ខជាតិ :

មានដើមរ៉ៃនៅដុះតាមច្រាំងក្បែរអន្លង់និងនៅតាមច្រាំងជាប់អន្លង់មានដើមជ្រៃ, ដើមត្រស់, គុម្ពឫស្សី, ដើមល្វា, ដើមរាំងទឹក, ដើមក្តុល, ដើមសុក្រំ, ដើមឈ្លីច, ដើមឆ្អែង , ដើមត្រែង, ដើមត្រាច, ដើមខ្លុង, ដើមស្រឡៅ, ដើមធ្នឹក, ដើមពពេល, ដើមគគីរ, ដើមកកោះ, ដើមផ្តៀក, ដើមញ, ដើមស្វាយព្រៃ, ដើមជន្លា , ដើមមៀនទឹក, ដើមខ្វាវ, ដើមព្រីង,

ដើមប្រាំដំឡឹង, ដើមសង្កែ, ដើមឆ្កែស្រែង, ដើមអង្រ្កង, ដើមតង្កៀបក្ដាម, ដើមជើងគោ, ដើមធ្នង់ ហើយនៅមាត់អន្លង់មានស្ពៃទឹក, ដើមប្រមាត់ដី និង កំប្លោក និងចកពាសពេញទឹក។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភេទ គឺ ប្រជាជនក្នុងភូមិស្រែស្រណុក និងប្រជាជនដែលមកពីភូមិខាងក្រៅដូចជា ភូមិភ្លុក និងកំភុន ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៥ ស.មទៅ ១២ស.ម នេសាទនៅរដូវប្រាំង ។

- សន្ទូច :នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៥ទៅ១០ (នេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែធ្នូ ដល់ខែឧសភា ដោយប្រើក្រឡាលេខ ៤-១០ស.ម ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ។



**៣.៩.៣ អន្លង់ពាមអូរស្វ**

**ក ទីតាំង :**

អន្លង់ពាមអូរស្វ ស្ថិតនៅផ្នែកខាងលើភូមិចំងាយ ២គ.ម មានកោះតូចមួយស្ថិតនៅជិតនោះជាប់មាត់អន្លង់ ជាប់នឹងពាមអូរស្វដែលហូរចូលមកនៅផ្នែកខាងក្រោមនៃអន្លង់ដោយសារតែមានពាមមួយនៅជាប់អន្លង់នេះហើយ ទើបគេហៅអន្លង់ពាមអូរស្វនេះទៅតាមឈ្មោះរបស់ពាមនោះតែម្ដងទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៩៨៥៩៨
- អរដោនេ = ១៤៨៥៦១៤
- រយៈកំពស់ = ៥១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៨ម ឆ្នាំ ២០០៦ = ៥ម
- ទំហំ :មុនឆ្នាំ១៩៩៥ =២០០ម x ១៥០ម ឆ្នាំ២០០៦ = ២០០ម x ១៥០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ នៅរដូវប្រាំង : មានថ្មព័ទ្ធជុំវិញអន្លង់មានរាងបួនជ្រុងទ្រវែង និងមានកូនឈើដុះនៅជុំវិញមាត់អន្លង់ ហើយយើងក៏មើលឃើញថ្មប៉ប្រះទឹក ខាងត្បូងមានថ្ម ខាងជើងមានខ្សាច់ដុះ និងខាងលិចជាប់ច្រាំងទន្លេនៅក្បែរនោះមានកូនកោះមួយជាប់នឹង កាំងជាប់មាត់អន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ។ កំពស់ទឹកនៅរដូវវស្សា ទឹកឡើងមាន ១០ ទៅ ១៤ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ តុលា។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប លូន និងសត្វផ្សេងៗទៀត។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីខ្ទឹង, ត្រីកញ្ចុះ, ត្រីក្មោន, ត្រីអណ្តែង, ត្រីប្រាកណ្តុរ, ត្រីស្លាបមាន់, ត្រីឆ្លូញ, ត្រីកញ្ជ្រូក, ត្រីឫសចេក, ត្រីគល់រាំង, ត្រីប៉ាស៊ីអ៊ី, ត្រីលេញ, ត្រីបង្កួយ, ត្រីប៉ាភៀន(ត្រីខ្យល់), ត្រីនាងល្វិង, ត្រីអាចម៍កុក, ត្រីអន្ទ័យ, ត្រីល្ពិច ត្រីស្លឹកក្លួច, ត្រីផ្កាគរ និងត្រីកំពត ។

- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អារូដ, ខ្លែង, ពពូល, សេក, ចាប, សារិកាកែវ, កេងកង, ត្រយង, អក, ត្មាត, លលក, ក្ងោក, ត្រដក់, ក្រៀល, ទីទុយ, មៀម, គ្រលីងគ្រលោង, ឪឡ, ទទា, តាវ៉ៅ, ផ្តោក, កែវលើក, កុកគ្រោង, និងត្រសេះ ។

- ប្រភេទលូនៈ ពស់, ត្រកួត, កន្ធ្រង, អណ្តើក, អន្សង, កន្ធាយ និងកំប្រុក

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស, ខ្លាឃ្មុំ, ឆ្កែព្រៃ, ខ្លាខ្សែន

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃ ដើមផ្កាអណ្តែងដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមល្វា ដើមឫស្សី, ដើមរាំងទឹក, ដើមក្តុល, ដើមសង្កែ, ដើមស្លែង និងមានជាប្រភេទព្រៃស្តុក។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្គារុក្ខជាតិជាបន្លែ។



-ចំពោះការនេសាទអន្លង់នេះមានអ្នកមកនេសាទពីពីរប្រភព គឺប្រជាជនក្នុងភូមិស្រែស្រណុក និងប្រជាជនដែលមកពីខាងក្រៅភូមិដូចជាភូមិភ្លុក កំភុន សេសាន សាមឃួយ ហាងសាវ៉ាត បាដើម កំផាន់ ស្តៅ កោះស្នែង ក្បាលរមាស និងភូមិក្របីជ្រុំ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៥ ស.មទៅ ១២ស.ម នេសាទនៅរដូវប្រាំង ។

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១០ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។

- មង :នេសាទចាប់ពីខែ តុលា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៤-១០ស.ម ។

- ចាន់ :នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ។

### ៣.៩.៤ អន្លង់កំពង់ទឹក

**ក ទីតាំង :**

អន្លង់កំពង់ទឹកស្ថិតជាប់ច្រាំងនៅខាងឆ្វេងដៃទន្លេស្របភូមិស្រែស្រណុកតែម្តង បើនិយាយ-តាមខ្សែទឹកចុះក្រោមនៅតាមច្រាំងក្បែរអន្លង់នេះមានតែគុម្ពឫស្សី និងមានកូនរុក្ខជាតិជា-បន្លែប៉ុណ្ណោះ។

<u>ចំណុចនៅលើ GPS : (មិនបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធGPS)</u>

- អាប់ស៊ីស =
- អរដោនេ =
- រយៈកំពស់ =

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៨ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៣៥០ម x១៥០ម ឆ្នាំ ២០០៦ = ៣៥០ម x ១៥០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅផ្នែកជុំវិញមាត់អន្លង់មើលឃើញថ្មប៉ប្រះទឹក និងឃើញមានព្រៃឬស្សីនៅត្រើយខាងកើតទន្លេ ម្យ៉ាងវិញទៀតយើងក៏អាចឃើញខ្សាច់នៅរដូវប្រាំងដែរ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញថ្មប៉ប្រះ ទឹក និងខ្សាច់ទេ ។ កំពស់ទឹកនៅ រដូវទឹកឡើងមានកំពស់...... ។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីខ្ទឹង, ត្រីកញ្ចុះ, ត្រីក្អាន, ត្រីអណ្តែង, ត្រីប្រាកណ្តុរ, ត្រីស្លាបមាន់, ត្រីឆ្លូញ, ត្រីកញ្រ្ជូក, ត្រីឫសចេក, ត្រីគល់រាំង, ត្រីប៉ាស៊ីអ៊ី, ត្រីលេញ, ត្រីបង្គួយ, ត្រីប៉ាភៀន(ត្រីខ្យល់), ត្រីននោងល្វឹង, ត្រីអាចម៏កុក, ត្រីអន្ទ័យ, ត្រីល្វិច ត្រីស្លឹកក្ដួច, ត្រីផ្កាគរ និងត្រីកំពត ។

- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអួដ, ខ្លែង, ពពូល, សេក, ចាប, សារិកាកែវ, កេងកង, ត្រយង, អក, ត្មាត, លលក, ក្ងោក, ត្រដក់, ក្រៀល, ទីទុយ, មៀម, គ្រលីងគ្រលោង, ឪឡ, ទទា, តាវ៉ៅ, ផ្តោក, កែវលើក, កុកគ្រោង, និងត្រសេះ ។



- ប្រភេទល្មូន : ពស់, ត្រកួត, កន្ទ្រង, អណ្តើក, អន្សង, កន្ធាយ, កំប្រុក និងក្រពើ
- ប្រភេទសត្វផ្សេងៗ :ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស, ខ្លាឃ្មុំ, ឆ្កែព្រៃ, ខ្លាខ្មៅ

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរំ ដើមផ្កាអណ្តែង ដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមប្រមាត់ដី ដើមក្រសាំងទាប ដើមស្លឹកងប់ និង មានគុម្ព និងឫស្សីដុះតាមច្រាំងទន្លេ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះ គឺមានតែប្រជាជនក្នុងភូមិ ភូមិស្រែស្រណុកទេ ព្រោះអន្លង់នេះមិនសូវសំបូរ ត្រីដូចអន្លង់កោះអណ្តែត អន្លង់កំពង់ជ្រៃ អន្លង់ពាមអូរស្វ ទេ ។

- ការប្រើប្រាស់ឧបករណ៏នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៥ ស.មទៅ ១២ស.ម នេសាទនៅរដូវប្រាំង ។
- សន្ទូច :នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១០ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។
- មង : នេសាទចាប់ពីខែ តុលា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៤-១០ស.ម ។
- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ។

## ៣.១០ ភូមិក្បាលរមាស ឃុំក្បាលរមាស

ភូមិក្បាលរមាស ស្ថិតនៅភាគខាងលើនៃភូមិស្រែស្រណុកមានចំងាយ ៨គ.ម ស្ថិតនៅតាមដងទន្លេស្រែពក និងមានចំងាយ ៧៥គ.ម ពីខេត្តស្ទឹងត្រែង គេអាចធ្វើដំណើរបានទាំងផ្លូវគោក និងផ្លូវទឹក ។ មានប្រជាពលរដ្ឋរស់នៅចំនួន ៩៧គ្រួសារ និងមានប្រជាជនចំនួន ៤៣២នាក់ ស្រី ២២៧នាក់ ហើយគាត់ទាំងអស់គ្នាជាជនជាតិដើមភាគតិច គឺជនជាតិព្នង ការប្រកបរបរចិញ្ចឹមជីវិតរបស់គាត់ គឺការធ្វើស្រែ ចំការ និងការពឹងផ្អែកលើធនធានធម្មជាតិ ។ អន្លង់ទាំងនេះមានលក្ខណៈអំណោយផលល្អណាស់សំរាប់មច្ឆាជាតិរស់នៅ ហើយសព្វថ្ងៃសហគមន៍គាត់បានពិភាក្សាគ្នាយកអន្លង់ពក និងអន្លង់កុតប៊ូ ធ្វើជាអន្លង់សំរាប់ធ្វើការអភិរក្ស ។

អន្លង់នៅភូមិនេះមានសរុបចំនួន ៤កន្លែង គឺអន្លង់កុតប៊ូ អន្លង់កណ្តាលភូមិ អន្លង់ក្បាលភូមិ និងអន្លង់ពក ។ អន្លង់នីមួយៗមានជំរៅមិនស្មើគ្នា ក្នុងនោះអន្លង់ដែលមានជំរៅជ្រៅជាងគេគឺ អន្លង់កុតប៊ូ (២១,៥ម) និងអន្លង់មានជំរៅរាក់ជាងគេគឺ អន្លង់ពក (៨ម) ចំពោះលក្ខណៈអន្លង់ទាំងនេះ នៅមានជំរៅជ្រៅៗដែលជាជំរកត្រីដ៏ពិសេស ។



ព្រៃ និងស្ថានភាពទន្លេស្រែពកក្នុងភូមិក្បាលរមាស



| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំពីមុន(ម) | | ទំហំបច្ចុប្បន្ន(ម) | | កូអរដោនេ (GPS) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់ ពក | ១៤ | ៨ | ១៥០ | ៧០ | ១៥០ | ៧០ | ១៤៩៤៤៧៣ | ០៦៥៩៩៧ ៣ |
| ២ | អន្លង់ក្បាលភូមិ | ២៥ | ១០ | ២០០ | ១០០ | ២០០ | ១០០ | ១៤៩២៦៤៤ | ០៦៦១៨១ ៨ |
| ៣ | អន្លង់កណ្តាលភូមិ | ២៥ | ១៩ | ១០០ | ៥០ | ១០០ | ៥០ | ១៤៩២១៤០ | ០៦៦១៧០ ០ |
| ៤ | អន្លង់ កុតប៊ូ | ៣៤ | ២១.៥ | ៤០០ | ១០០ | ៤០០ | ១០០ | ១៤៨៩៦១៦ | ០៦៥៨៧០ ៣ |

### ៣.១០.១ អន្លង់ពក

**ក ទីតាំង :**

អន្លង់ពក ស្ថិតនៅផ្នែកខាងលើភូមិក្បាលរមាស ចំងាយ ៣គ.ម នៅត្រើយខាងកើត ខាងស្តាំដៃបើនិយាយតាមខ្សែទឹកឡើងលើ ហើយមានជួរមួយនៅក្បាលអន្លង់ហៅថា ជួរពក នៅជ្រុងខាងលិចមានខ្សាច់ដុះ ។ នៅរដូវប្រាំងនៅផ្នែកខាងក្បាលអន្លង់មានថ្មដែរដាសលំបាកក្នុងការធ្វើដំណើរ ។ នៅពេលដែលមានជួរដុះកាត់ទន្លេជិតអន្លង់ដូចនេះហើយទើបប្រជាពលរដ្ឋគាត់នាំគ្នាហៅអន្លង់នេះទៅតាមជួរ រហូតរៀងមកដល់សព្វថ្ងៃនេះ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥៩៧៣
- អរដោនេ = ១៤៩៤៤៧
- រយៈកំពស់ = ៦៩ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៤ម ឆ្នាំ ២០០៦ = ៨ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១៥០ម x ៧០ម ឆ្នាំ ២០០៦ = ១៥០ម x ៧០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅផ្នែកមាត់អន្លង់ខាងលើមើលឃើញថ្មប៉ប្រះទឹក និងនៅខាងក្រោមក៏មើលឃើញជួរថ្មដែរ មានខ្សាច់ដុះនៅផ្នែកខាងលិច ជាប់ច្រាំងទន្លេក្បែរនោះមានថ្មខ្លះៗ និងមានដើមឈើតូចៗ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ចំណែកទឹកវិញមានលក្ខណៈកួចខ្លាំង និងមានពពុះពាសពេញផ្ទៃទឹកតាមអន្លង់នោះ ។ កំពស់ទឹកនៅរដូវទឹកឡើងមាន ១០ទៅ ១៤ម៉ែត្រ ចាប់ពីខែ សីហា ដល់ ខែ តុលា ។



**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីក្លាំងហាយ, ត្រីសូវៀត, ត្រីអំបូង, ត្រីក្រាយ, ត្រីកញ្ចុះ, បបែល, កន្ធាយ, ត្រីកញ្ជ្រូក, ត្រីកន្ទ្រប់, ត្រីរមាស, ត្រីប៉ាស៊ីអ៊ី, ត្រីក្រាញ់, ត្រីអណ្តែង, ត្រីខ្ជឹង និងត្រីឆ្លូញ ។

- ប្រភេទសត្វស្លាបរួមមាន :កុក, កងប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអូដ, ត្រដក់, ត្មាត, ខ្លែង, ពពេច, ពពូកចាប, ប្រវឹក និងមៀម ។

- ប្រភេទល្មូន : ពស់, ត្រកួត, កន្ទ្រង, អន្ទ្បង (រយ៉ា), អន្ទង់

- ប្រភេទសត្វផ្សេងៗ :ជ្រូកព្រៃ, ឈ្លូស, ស្វា និងប្រើស

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី, ដើមរាំងទឹក, ដើមល្វា,ដើមក្តុល, ដើមត្រែង ដើមផ្កាអណ្តែង, ដើមសង្កែ និងជាប្រភេទព្រៃស្ដុក

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះ គឺមានប្រជាជនក្នុង ភូមិក្បាលរមាស និងប្រជាជនដែលមកពីភូមិក្របីជ្រុំ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៣ហ៊ុន ទៅ១៥ហ៊ុន ( នេសាទរដូវប្រាំង គឺ ចាប់ពីខែ ធ្នូ ដល់ខែ មិថុនា ) ។

- សន្ទូច :នេសាទនៅខែ កក្កដា ដល់ខែ តុលា ដោយប្រើផ្លែលេខ ៨ ទៅ ៩ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ដោយប្រើក្រឡាលេខ ៣ - ១១ ស.ម ។

- ចាន់ : នេសាទចាប់ពីខែ កក្កដា ដល់ខែ តុលា ។

### ៣.១០.២ អន្លង់ក្បាលភូមិ

**ក ទីតាំង :**

អន្លង់ក្បាលភូមិ ស្ថិតនៅជាប់ក្បាលភូមិផ្នែកខាងលើភូមិ ហើយមានថ្មប៉ប្រះទឹកនៅក្បែរអន្លង់នៅខាងស្តាំដៃជាប់ច្រាំងទន្លេខាងកើត(បើនិយាយតាមខ្សែទឹកឡើង) ។ នៅផ្នែកខាងក្បាលអន្លង់មានអូរមួយហូរចាក់ហៅថា អូរបែកកាំភ្លើង ដោយកាលពីមុនមានគេបាញ់កាំភ្លើងហើយគាប់ជួនកាំភ្លើងវាបែកកាណុងគេក៏ហៅទៅតាមនោះទៅ ។ រីឯអន្លង់ដែលគេនាំគ្នាហៅថា អន្លង់ក្បាលភូមិ ព្រោះអន្លង់នេះស្ថិតនៅជាប់នឹងក្បាលភូមិទើបគេក៏បានហៅដូច្នេះទៅឈ្មោះនេះហៅតាំងពីបានកកើតភូមិមកម្ល៉េះ គឺនៅឆ្នាំ ១៩៧០ ដែលអ្នកភូមិបាននាំគ្នាមករស់នៅទីនេះ ។ អន្លង់នេះនៅឆ្នាំ ២០០៣ មានគេបានឃើញសត្វក្រពើមួយក្បាល ហើយនៅឆ្នាំ ២០០៤ អ្នកភូមិក៏បានមើលឃើញសត្វក្រពើម្តងទៀត ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៦១៨១៨
- អរដោនេ =១៤៩២៦៤៤
- រយៈកំពស់ =៦៧ម



**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២៥ម ឆ្នាំ ២០០៦ = ១០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ២០០ម x ១០០ម ឆ្នាំ ២០០៦ = ២០០ម x ១០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅផ្នែកជុំវិញមាត់អន្លង់មើលឃើញថ្មបប្រះទឹក នៅក្បាលអន្លង់ និងនៅតាមច្រាំងនៅខាងលើអន្លង់មានកោះ ថ្ម ហើយមានចំការនៅខាងឆ្វេងនៃអន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ចំណែកទឹកវិញមានលក្ខណៈកួចខ្លាំង និងមានពពុះពាសពេញផ្ទៃទឹកតាមអន្លង់នោះ។ កំពស់ទឹកនៅរដូវទឹកឡើងមានកំពស់ចាប់ពី ១០ ទៅ ១៤ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ តុលា។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្អិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្តោក, ត្រីប្រា, ត្រីក្លាំងហាយ, ត្រីសូវៀត, ត្រីអំបូង, ត្រីក្រាយ, ត្រីកញ្ចុះ, បបែល, ត្រីកញ្ជ្រូក, ត្រីកន្ធ្រប, ត្រីរមាស, ត្រីក្រាញ់, ត្រីប៉ាស៊ីអ៊ី , ត្រីអណ្ដែង, ត្រីខ្ញឹង និងត្រីឆ្លូញ ។

- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអូដ, ត្រដក់, ត្មាត, ខ្លែង, មៀម, ពពេច, ពពួកចាប និងប្រវឹក ។

- ប្រភេទល្មូន : ពស់, ត្រកួត, កន្ធ្រង, អន្សង (រយ៉ា) និងអន្ទង់ ។

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ស្វា, គោ និងក្របីរបស់អ្នកភូមិ ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរំដេះតាមច្រាំងក្បែរអន្លង់ និង នៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមឫស្សី, ដើមរាំងទឹក ដើមល្វា, ដើមក្តុល, ដើមត្រែង, ដើមផ្កាអណ្តែង និងដើមសង្កែ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និងផ្ការុក្ខជាតិជាបន្លែ ។

- ចំពោះការនេសាទអន្លង់នេះគឺមានប្រជាជនក្នុងភូមិក្បាលរមាស
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ :ប្រើប្រាស់ចាប់ពីក្រឡា ៣ ហ៊ុនទៅ ១៥ហ៊ុន នេសាទនៅរដូវប្រាំង
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១០ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។
  - មង : នេសាទចាប់ពីខែ តុលា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៣- ១១ស.ម ។
  - ចាន់ :នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ។



## ៣.១០. ៣ អន្លង់កណ្តាលភូមិ

**ក ទីតាំង :**

អន្លង់កណ្តាលភូមិ ស្ថិតនៅផ្នែកខាងក្រោមអន្លង់ក្បាលភូមិ មានរាងបួនជ្រុងទ្រវែងនៅជាប់ច្រាំងទន្លេខាងកើត (ខាងស្តាំតាមខ្សែទឹកមកលើ) ។ ជារៀងរាល់ឆ្នាំអ្នកភូមិយើងតែងតែមើលឃើញមេទឹកទំហំប៉ុនធុងសាំង ហើយក្នុងមួយឆ្នាំគេអាចមើលឃើញម្តង ឬពីរដង ។ ដោយអន្លង់នេះនៅត្រង់កណ្តាលភូមិ ទើបអ្នកភូមិយើងហៅអន្លង់នេះថា អន្លង់កណ្តាលភូមិទៅតាមស្ថានភាពនៃអន្លង់នោះ គេទើបតែហៅនៅពេលដែលកកើតភូមិនៅឆ្នាំ ១៩៧០ តែប៉ុណ្ណោះ ។ នៅខាងក្រោមអន្លង់មានអូរមួយឈ្មោះថា អូរព្រះផ្ទែក ចំងាយ៥០ម ហេតុដែលគេហៅថា អូរព្រះផ្ទែក ដោយកាលពីមុនមានស្តេចធ្វើដំណើរ ដោយមិនមានអ្នកហែហមជាមួយ មានតែញាតិវង្សស្តេចដូចគ្នា លុះដល់ពេលបាយក៏អត់មានអ្នកដាំបាយហូប ពេលនោះស្តេចទាំងអស់នោះក៏ហេវបាយ ហើយនាំគ្នាដាក់គូថអង្គុយផ្ទែកមើលមុខគ្នានៅចំណុចអូរនោះទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៦១៧០០
- អរដោនេ = ១៤៩២១៤០
- រយៈកំពស់ = ៦៩ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២៥ម ឆ្នាំ ២០០៦ = ១៩ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០០ម x ៥០ម ឆ្នាំ ២០០៦ = ១០០ម x ៥០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅផ្នែកជុំវិញមាត់អន្លង់មើលឃើញថ្មប៉ប្រះទឹក ខាងត្បូងមានថ្មខាងជើងមានខ្សាច់ដុះ និងខាងលិចជាប់ច្រាំងទន្លេនៅក្បែរនោះមានកូនកោះមួយជាប់នឹងកាំងជាប់មាត់អន្លង់ ។

♦ រដូវវស្សា ៖ នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ចំណែកទឹកវិញមានលក្ខណៈកួចខ្លាំង និងមានពពុះពាសពេញផ្ទៃទឹកតាមអន្លង់នោះ។ កំពស់ទឹកនៅរដូវទឹកឡើងមានពី ១០ ទៅ ១៥ម៉ែត្រ ចាប់ពីខែ សីហា ដល់ ខែ តុលា។

**ឃ. ប្រភេទសត្វ ៖**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី ៖ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្កោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីក្លាំងហាយ, ត្រីសូវៀត, ត្រីអំបូង, ត្រីក្រាយ, ត្រីកញ្ចុះ,បបែល, កន្ធាយ, ត្រីកញ្ជ្រូក, ត្រីកន្ត្រប់, ត្រីរមាស, ត្រីប៉ាស៊ីអ៊ុ, ត្រីក្រាញ់, ត្រីអណ្តែង, ត្រីខ្ទឹង និងត្រីឆ្លូញ ។

- ប្រភេទសត្វស្លាបរួមមាន ៖កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអូដ, ត្រដក់, ត្មាត, ខ្លែង, មៀម, ពពេច, ពពួកចាប និងប្រវឹក ។

- ប្រភេទល្មូន ៖ពស់, ត្រកួត, កន្ធ្រង, អន្សង (រយ៉ា) និងអន្ទង់ ។

- ប្រភេទសត្វផ្សេងៗ ៖ជ្រូកព្រៃ, ឈ្លូស និងស្វា ។

**ង. ប្រភេទរុក្ខជាតិ ៖**

មានដើមរំដេះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី, ដើមល្វា, ដើមរាំងទឹក, ដើមក្តុល, ដើមត្រែង, ដើមផ្កាអណ្តែង, ដើមសង្កែ, ដើមស្លែង និងជាប្រភេទព្រៃស្តុក។



**ច. ទំនាក់ទំនងរវាងអន្លង់ ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និង ផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះ គឺមានប្រជាជនក្នុង ភូមិក្បាលរមាស

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា ៖

- សំណាញ់ ៖ប្រើប្រាស់ចាប់ពីក្រឡា ៥ស.មទៅ ១២ស.ម នេសាទនៅរដូវប្រាំង

- សន្ទូច ៖នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ១០ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។

- មង ៖ នេសាទចាប់ពីខែ តុលា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៤-១០ស.ម ។

- ចាន់ ៖នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ។



ស្ថានភាពសត្វស្លាប និងអន្លង់ក្នុងទន្លេស្រែពក

### ៣.១០. ៤ អន្លង់កុតប៊ូ (អន្លង់ត្រីដីរ៍)

**ក ទីតាំង :**

អន្លង់កុតប៊ូ ស្ថិតនៅផ្នែកខាងក្រោមភូមិចំងាយ៣គ.មនៅជាប់ច្រាំងខាងលិច បើនិយាយតាមខ្សែទឹកមកលើ អន្លង់នេះមានរាងទ្រវែងហើយមានជួររំពេនៅអមសងខាងអន្លង់ ។ នៅឆ្នាំ ១៩៩២ គេឃើញមាននាគមួយគួបពណ្ណែតខ្លួនតែបច្ចុប្បន្ននេះបាត់លែងមើលឃើញ ហើយនៅឆ្នាំ ២០០៤ គេបានឃើញពស់វែកមួយហែលចុះឡើង១លុះដល់ពេលគេទៅបង់យកពស់នោះស្រាប់តែមានផុសដីឡើងផុរ១ធ្វើអោយអ្នកទាំងនោះភ័យខ្លាច ។ នៅចំណុចជួររំពេមានដើមឈើទាលធំមួយនៅដើមនោះគេព្យួរស្នូរបំពេរកូនជាវៀងរាល់ឆ្នាំដែលគេហៅថា អារក្សព្រាយ។ ម្យ៉ាងទៀតហេតុដែលគេហៅអន្លង់នេះថា **កុតប៊ូ** ដោយនៅខាងលើជិតនោះមានត្រពាំងមួយសំបូរទៅដោយត្រីដីរ៍ ដែលភាសាឡាវហៅថា ប៉ាប៊ូ ឈ្មោះនេះជាឈ្មោះដែលហៅតាមឡាវតាំងពីបុរាណមក ហើយយើងក៏ហៅត១គ្នារហូតមកដល់សព្វថ្ងៃនេះ ។ បច្ចុប្បន្ននេះសហគមន៍បាននាំគ្នារៀបចំបង្កើតអន្លង់នេះអោយធ្វើជាអន្លង់អភិរក្សទុក សំរាប់ក្មេង១ជំនាន់ក្រោយ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥៨៧០៣
- អរដោនេ = ១៤៨៩៦១៦
- រយៈកំពស់ = ៦៧ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៣៤ម ឆ្នាំ ២០០៦ = ២១,៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៤០០ម x ១០០ម ឆ្នាំ ២០០៦ = ៤០០ម x ១០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅផ្នែកមាត់អន្លង់មើលឃើញថ្មប៉ប្រះទឹកនៅអមសងខាងអន្លង់ ហើយមើលឃើញដើម គ្រោះ ដើមរៃ គុម្ពព្រៃង និងមានថ្ម ជួរច្រើនអមសងខាងទន្លេ ។



♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ចំណែកទឹកវិញមានលក្ខណៈកួចខ្លាំង និងមានពពុះពាសពេញផ្ទៃទឹកតាមអន្លង់នោះ។ កំពស់ទឹកនៅរដូវទឹកឡើងមាន ១០ទៅ ១៤ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ តុលា។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេង១ទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្ទាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក, ត្រីប្រា, ត្រីក្លាំងហាយ, ត្រីសូវៀត, ត្រីអំបូង, ត្រីក្រាយ, ត្រីកញ្ចុះ, ត្រីកញ្ជ្រូក, ត្រីកន្ធប់, ត្រីរមាស, ត្រីប៉ាស៊ីអ៊ី, ត្រីក្រាញ់, ត្រីអណ្តែង, ត្រីខ្ទឹង និងត្រីឆ្លូញ ។
- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, អាអួង, ត្រដក់, ត្មាត, ខ្លែង, មៀម, ពពេច, ពពួកចាប និងប្រវឹក ។
- ប្រភេទល្មូន :ពស់ ត្រកួត កន្ទ្រង អន្សង (រយ៉ា) និងអន្ទង់ ។
- ប្រភេទសត្វផ្សេង១ :ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស និងខ្លាឃ្មុំ ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរំដេះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមឫស្សី, ដើមល្វា, ដើមរាំងទឹក, ដើមក្កុល, ដើមព្រៃង, ដើមផ្កាអណ្តែង, ដើមសង្កែ, ដើមស្លែង និងជាប្រភេទព្រៃស្តុក។

### ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះ គឺមានប្រជាជនក្នុងភូមិក្បាលរមាស
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា ៣ហ៊ុន ទៅ១៥ហ៊ុន នេសាទនៅរដូវប្រាំង
  - សន្ទូច :នេសាទចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ទៅ១០ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។
  - មង : នេសាទចាប់ពីខែ តុលា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៤-១០ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ តុលា ។


ស្ថានភាពទន្លេស្រែពកនៅផ្នែកខាងក្រោមនៃភូមិស្រែស្រណុក



## ៣.១១ ភូមិក្របីជ្រុំ

ភូមិក្របីជ្រុំ ស្ថិតនៅឃុំក្បាលរមាសតាមដងទន្លេស្រែពក នៅផ្នែកខាងលើគេបង្អស់នៃឃុំក្បាលរមាស មានប្រជាជនរស់នៅចំនួន ១៤៦គ្រួសារ ស្មើនឹងប្រជាជនសរុប៦៥៦នាក់ ស្រី ៣៥៧នាក់។ ប្រជាជនភូមិនេះភាគច្រើនគេប្រើភាសាឡាវ ប៉ុន្តែគេអាចនិយាយ និងស្តាប់ភាសាខ្មែរបានដែរ ។ ចំពោះមុខរបររបស់ប្រជាពលរដ្ឋ គឺធ្វើស្រែចំការ ចិញ្ចឹមសត្វ ដាំដំណាំ និងនេសាទត្រី ។ កាលពីមុនភូមិនេះមានអ្នកមករស់នៅតែ ១៥គ្រួសារទេ ហើយអ្នកទាំងនោះប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែចំការ និងនេសាទត្រី។ លុះក្រោយមកប្រជាពលរដ្ឋមានការកើនឡើងជាបន្តបន្ទាប់ ហើយអ្នកភូមិដែលនៅជិតនោះតែងតែយកក្របីមកឃ្វាលនៅចំណុចភូមិនេះជាប្រចាំ ។ដោយសារតែហេតុនេះហើយទើបគេបានហៅឈ្មោះភូមិនេះ ថាភូមិក្របីជ្រុំតៗគ្នារហូតមកដល់សព្វថ្ងៃនេះ ។

បច្ចុប្បន្ននេះដោយមានការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅប្រទេសវៀតណាម បានធ្វើឱ្យការបង្កបង្កើនផលរបស់ប្រជាជនទទួលរងនូវគ្រោះទឹកជំនន់ជាប្រចាំចាប់ពីឆ្នាំ២០០៣ រហូតមកនិងបង្កការភ័យខ្លាចដល់ការរស់នៅរបស់គាត់ ។

ស្ថានភាពទន្លេ និងទឹកទន្លេចាប់ផ្តើមមានការប្រែប្រួលទន្ទឹមគ្នានឹងការសាងសង់ទំនប់វារីអគ្គិសនី ហើយធនធានទឹក វារីជាតិ ប្រព័ន្ធអេកូឡូស៊ីទន្លេក៏ចាប់ផ្តើមមានការប្រែប្រួលដែរ ។ ទាក់ទងនឹងបញ្ហាទាំងនេះវាបានបង្កផលប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតាមដងទន្លេស្រែពកទាំងអស់ផងដែរ ។

អន្លង់នៅភូមិនេះមានសរុបចំនួន ៣កន្លែង គឺ អន្លងកាំងតាយោក អន្លង់លុងម៉ាតាយ និងអន្លង់ហ៊ិនឡាត់ ។ អន្លង់នីមួយៗមានជំរៅមិនស្មើគ្នា ក្នុងនោះអន្លង់ដែលមានជំរៅជ្រៅជាងគេគឺអន្លង់លុងម៉ាតាយ (៤០ម) និងអន្លង់មានជំរៅរាក់ជាងគេគឺអន្លង់ហ៊ិនឡាត់ (១២ម) ចំពោះលក្ខណៈអន្លង់ទាំងនេះ នៅមានជំរៅជ្រៅៗដែលជាជម្រកត្រីដ៏ពិសេស ។

តារាង ៩ អន្លង់នៅក្នុងភូមិក្របីជ្រុំ

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំអន្លង់ពីមុន(ម) | | ទំហំអន្លង់បច្ចុប្បន្ន (ម) | | កូអរដោនេ(GPS) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | បច្ចុប្បន្ន | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់កាំងតាយោក | ២0 | ១៥ | ១00 | ៨0 | ១00 | ៨0 | ១៤៩៨៤៤១ | 0៦៦៧១ ៩៩ |
| ២ | អន្លង់លុងម៉ាតាយ | ៤0 | ៤0 | ២00 | ១៥0 | ២00 | ១៥0 | ១៤៩៨៥៥៩ | 0៦៦៥៥ ៥0 |
| ៣ | អន្លងហ៊ីនឡាត់ | ១៥ | ១២ | ១៥0 | ៥0 | ១៥0 | ៥0 | ១៤៩៨៤៤0 | 0៦៦៣៨ ៨១ |



## ៣.១១.១ អន្លង់កាំងតាយោក

ក ទីតាំង :

អន្លង់កាំងតាយោក ស្ថិតនៅផ្នែកខាងលើភូមិចំងាយ ១,៥គ.ម នៅក្បែរអន្លង់មានកោះមួយនៅខាងឆ្វេងដៃតាមខ្សែទឹកឡើងលើ កោះនេះទំហំទទឹង ២0ម និងបណ្តោយ ៣0ម ឈ្មោះថា កោះតាយោក នៅលើកោះមានដើមឈើមួយចំនួន ហើយអន្លង់នេះស្ថិតនៅចំកណ្តាលទន្លេមានកាំងអមសងខាង (ជួរថ្ម) ឈ្មោះថា កាំងតាយោក និងមានកូនឈើដុះអមជុំវិញ ដោយសារតែមានជួរនេះហើយទើបគេហៅឈ្មោះអន្លង់ទៅតាមជួរនោះតែម្តងទៅ (មានឈ្មោះបែបនេះតាំងពីដូនតាមកម្លេះ) និងលក្ខណៈល្អរបស់អន្លង់នេះគឺ សំបូរត្រីកែសជាងគេ ។

**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = 0៦៦៧១៩៩
- អរដោនេ = ១៤៩៨៤៤១
- រយៈកំពស់ = ៧៨ម

ខ. លក្ខណៈរូប :

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២0ម ឆ្នាំ ២00៦ = ១៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៨0ម x ១00ម ឆ្នាំ ២00៦ = ៨0ម x ១00ម

គ. មជ្ឈដ្ឋានជុំវិញ :

♦ រដូវប្រាំង : នៅផ្នែកជុំវិញមាត់អន្លង់មើលឃើញថ្មប៉ប្រះទឹកធំ តូច និងមានដើមផ្កាអំពៅ្លង ដើមរៃ ដុះពាសពេញអន្លង់ ហើយមានខ្សាច់នៅជ្រោយកោះខាងឆ្វេងដៃ ទឹកនៅរដូវប្រាំងហូរខ្លាំងមានលក្ខណៈស្អុគស្មាញច្រើន ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ។ កំពស់ទឹកនៅរដូវទឹកឡើងមាន ១0ទៅ ១៥ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ តុលា ។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប លូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមានត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីក្រាយ, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល,កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីប៉ាផាំង, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្តោក និងត្រីប្រា ។

- ប្រភេទសត្វស្លាបរួមមាន :កុក, ត្រយង, ត្រដក់, ក្ងោក, ប្រវឹក, ក្អែកទឹក, មាន់ទឹក, មាន់ព្រៃ, ទិទុយ, និងសត្វអក ។

- ប្រភេទលូន :ពស់, ត្រកួត, កន្ធ្រង និងសត្វបង្កួយ ។

- ប្រភេទសត្វផ្សេងៗ : ជ្រូកព្រៃ, ឈ្លូស, ទោច, ស្វា, ប្រើស និងខ្លាឃ្មុំ ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មាន ដើមត្រស់, ដើមឫស្សី, ដើមល្វា, ដើមរាំងទឹក, ដើមក្តុល, ដើមគគីរ, ដើមឈើទាល និងដើមក្រថៅ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និង ផ្កាវុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះ គឺមានប្រជាជនក្នុងភូមិក្របីជ្រុំ

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៥ ស.មទៅ ១៣ស.ម នេសាទនៅរដូវប្រាំង (ខែមករា ដល់ខែ មិថុនា) ។

- សន្ទូច : នេសាទនៅខែ សីហាដល់ខែ វិច្ឆិកាដោយប្រើផ្លែលេខ ៧ ទៅ១៣ និង ១១ ដល់ ១២ (ជា ទូទៅគេនេសាទគ្រប់រដូវ) ។

- មង : នេសាទចាប់ពីខែ មករា ដល់ខែ មិថុនា ដោយប្រើក្រឡាលេខ ៨-១៣ស.ម ។

**៣.១១. ២ អន្លង់លុងម៉ាតាយ(អន្លង់ធ្លាក់ឆ្កែងាប់)**

**ក ទីតាំង :**

អន្លង់លុងម៉ាតាយ (ធ្លាក់ឆ្កែងាប់) ស្ថិតនៅទល់មុខភូមិក្របីជ្រុំនៅផ្នែកខាងស្តាំនៃច្រាំងទន្លេបើនិយាយតាមខ្សែទឹកឡើងអន្លង់នេះសំបូរត្រីជាងគេ និងមានជំរៅជ្រៅ ។ នៅជិតអន្លង់មានកូនកោះតូចមួយឈ្មោះថា កោះម៉ាតាយ នៅផ្នែកខាងស្តាំដៃនៃអន្លង់មានគុម្ពព្រៃងជាច្រើន ។ មូលហេតុដែលគេនាំគ្នាហៅថា អន្លង់ម៉ាតាយ គឺដោយសារកាលពីមុនគេកាប់ដើមឈ្លើកសង្កត់ឆ្កែងាប់ហើយដើមឈ្លើកនោះបានក្លាយទៅជាថ្មដោយមានព្រឹត្តិការណ៍ចំឡែក ដូច្នេះហើយទើបប្រជាពលរដ្ឋ នាំគ្នាហៅអន្លង់នេះថា អន្លង់ម៉ាតាយ តៗគ្នារៀងមកដល់បច្ចុប្បន្ននេះ ។

**<u>ចំណុចនៅលើ GPS</u> :**

- អាប់ស៊ីស = ០៦៦៥៥០
- អរដោនេ = ១៤៩៨៥៩៩
- រយៈកំពស់ = ៧៤ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៤០ម ឆ្នាំ ២០០៦ = ៤០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១៥០ម x ២០០ម ឆ្នាំ ២០០៦ = ១៥០ម x ២០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅផ្នែកជុំវិញមាត់អន្លង់មើលឃើញថ្មប៉ប្រះទឹកខ្លះៗ និងនៅក្បាលអន្លង់មានផ្ទាំងថ្មធំមួយនៅផ្នែកខាងឆ្វេងដៃមានកោះតូចមួយដែលមានដុះដើមរៃនៅតាមប្រលោះថ្ម ហើយមានខ្សាច់ដុះធំនៅផ្នែកខាងក្រោម និងស្ថានភាពទឹកនៅចំណុចអន្លង់ គឺហូរ

កួចខ្លាំង ដែលធ្វើអោយមានការលំបាកខ្លាំងក្នុងការធ្វើដំណើរនៅចំណុចអន្លង់នេះ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ។ កំពស់ទឹកនៅរដូវទឹកឡើងមាន ១០ទៅ ១៥ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ តុលា។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី : ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្អិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្នាន់, ត្រីចែកទុំ, ត្រីផ្ទក់, បបែល,កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា, ត្រីឆ្កោក និងត្រីប្រា ។
- ប្រភេទសត្វស្លាបរួមមាន :កុក, កដប, មាន់ទឹក និងមាន់ ។
- ប្រភេទល្មូន : ពស់, កន្ទ្រង ។
- ប្រភេទសត្វផ្សេងៗ : ជ្រូកស្រុក, គោ និងក្របី ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរវែដុះតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមឫស្សី, ដើមរាំងទឹក ដើមល្វា, ដើមក្តុល, ដើមគគីរ, ដើមឈើទាល និងដើមក្របៅ ។

**ច. ទំនាក់ទំនងរវាង អន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់ គឺការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះ គឺមានប្រជាជនក្នុងភូមិក្របីជ្រុំ



- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៣ ស.មទៅ ១៣ស.ម នេសាទនៅរដូវប្រាំង (ខែ មករា ដល់ខែ មិថុនា) ។
- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១០ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។
- មង : នេសាទចាប់ពីខែ តុលា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៨-១៣ ស.ម ។
- ចាន់ : នេសាទចាប់ពីខែ កក្កដា ដល់ខែ តុលា ។
- លប : នេសាទ ពីខែ កក្កដា ដល់ខែ កញ្ញា ។

**៣.១១.៣ អន្លង់ហ៊ីនឡាត់ (អន្លង់ថ្មលាត)**

**ក. ទីតាំង :**

អន្លង់ហ៊ីនឡាត់ ស្ថិតនៅផ្នែកខាងក្រោមភូមិក្របីជ្រុំ (កន្ទុយភូមិ) មានថ្មប៉ប្រះទឹកជុំវិញអន្លង់មានរាងទ្រវែង និងមានកូនផ្កាអណ្តែង និងគុម្ពរវែដុះជុំវិញ អន្លង់នេះស្ថិតនៅទល់មុខសាលារៀននៅត្រើយខាងស្តាំដៃ បើនិយាយតាមខ្សែទឹកចុះក្រោម ។ មូលហេតុដែលគេហៅថាអន្លង់ហ៊ីនឡាត់ ដោយសារតែនៅជិតអន្លង់មានថ្មធំ តូច ជាច្រើននៅពាសពេញទីនោះ ហើយគេចូលចិត្តទៅលេងនៅលើថ្មនោះ ព្រោះវាមានលក្ខណៈល្អស្រួលអង្គុយលេង ទើបបានគេហៅអន្លង់នេះទៅតាមលក្ខណៈថ្មនោះគឺ ហ៊ីនឡាត់ ។

<u>ចំណុចនៅលើ GPS :</u>

- អាប់ស៊ីស = ០៦៦៣៨៨១
- អរដោនេ = ១៤៩៨៤៤០
- រយៈកំពស់ = ៧១ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ១២ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១៥០ម x ៥០ម ឆ្នាំ ២០០៦ = ១៥០ម x ៥០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : នៅផ្នែកជុំវិញមាត់អន្លង់មើលឃើញដើមរុក្ខជាតិមួយចំនួនថ្មប៉ប្រះទឹក និងមានជួរថ្មនៅផ្នែកខាងស្តាំដៃ លាតសន្ធឹងមកលើ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងកូនរុក្ខជាតិទេ ។ កំពស់ទឹកនៅរដូវទឹកឡើងមាន ១០ទៅ ១៤ម៉ែត្រចាប់ពីខែ សីហា ដល់ខែ តុលា ។

**ឃ. ប្រភេទសត្វ :**

នៅជុំវិញអន្លង់ និងក្នុងអន្លង់មានសត្វជាច្រើនប្រភេទដូចជា ត្រី សត្វស្លាប ល្មូន និងសត្វផ្សេងៗទៀត ។ ប៉ុន្តែនាពេលបច្ចុប្បន្នប្រភេទសត្វខ្លះត្រូវបាត់បង់ ថយចុះ និងខ្លះទៀតត្រូវផុតពូជអស់តែម្តង ។

- ប្រភេទសត្វត្រី :ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីពោ, ត្រីឆ្កិន, ត្រីឆ្តោ, ត្រីកែស, ត្រីព្រលូង, ត្រីរមាស, ត្រីត្រនេល, ត្រីខ្យា, ត្រីតាសេក, ត្រីកាហែ, ត្រីស្លឹកឫស្សី, ត្រីខ្មាន់, ត្រីចេកទុំ, ត្រីផ្ទក់, បបែល, កន្ធាយ, ត្រីថ្ម, ត្រីអណ្តាតឆ្កែ, ត្រីច្រកែង, ត្រីក្រពាត់, ត្រីសណ្តាយ, ត្រីព្រួល, ត្រីប៉ាវ៉ា និងត្រីឆ្កោក ។
- ប្រភេទសត្វស្លាបរួមមាន : កុក, កដប, មាន់ទឹក និងសត្វអាអូដ
- ប្រភេទល្មូន : ពស់, កន្ធ្រង
- ប្រភេទសត្វផ្សេងៗ : គោ, ក្របី និងជ្រូក ។

**ង. ប្រភេទរុក្ខជាតិ :**

មានដើមរៃ ដើមផ្កាអណ្តែង ដុះនៅតាមច្រាំងក្បែរអន្លង់ និងនៅតាមច្រាំងជាប់អន្លង់មានដើមត្រស់, ដើមឫស្សី, ដើមរាំងទឹក, ដើមល្វា, ដើមក្តុល, ដើមសង្កែ និងដើមរាំង ។



**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

ទំនាក់ទំនងរវាងអន្លង់ទៅនឹងប្រជាជននៅក្នុងតំបន់ជាសំខាន់គឺ ការនេសាទ និងផ្ការុក្ខជាតិជាបន្លែ។

- ចំពោះការនេសាទអន្លង់នេះ គឺមានប្រជាជនក្នុងភូមិក្របីជ្រុំ
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៣ ស.មទៅ ១៣ស.ម នេសាទនៅរដូវប្រាំង (ខែ មករា ដល់ខែ មិថុនា) ។
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ដោយប្រើផ្លែលេខ ៨ ទៅ ១០ (ជាទូទៅគេនេសាទ គ្រប់រដូវ) ។
  - មង : នេសាទចាប់ពីខែ តុលា ដល់ខែ ឧសភា ដោយប្រើក្រឡាលេខ ៨-១៣ ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ កក្កដា ដល់ខែ តុលា ។
  - លប :នេសាទ ពីខែ កក្កដា ដល់ខែកញ្ញា ។

## ៣.១២ ភូមិសាមឃួយ ឃុំសាមឃួយ

ភូមិសាមឃួយ ជាភូមិមួយស្ថិតនៅតាមបណ្ដោយដងទន្លេសេសានមានចំងាយប្រហែល ៩គីឡូម៉ែត្រពីទីរួមខេត្តស្ទឹងត្រែង មានប្រជាជនសរុបចំនួន ៩៦គ្រួសារ ប្រជាពលរដ្ឋសរុប ៤៧៣ នាក់ ស្រី ២៤៣ នាក់ ផ្ទះ ៨៣ខ្នង មានអន្លង់សរុបចំនួន ៥ គឺ : អន្លង់សាម៉ាខយតូច អន្លង់សាម៉ាខយធំ អន្លង់តាហ៊ិង អន្លង់យាយសាត់ និងអន្លង់យាយផានី ក្នុងនោះអន្លង់ ២ គឺ អន្លង់យាយសាត់ និងអន្លង់យាយផានី ត្រូវបានខ្សាច់ហូរលប់រាក់ស្មើនឹងបាតទន្លេ ។ នៅពេល នេសាទ ការប្រើប្រាស់ឧបករណ៍ និងពេលវេលារវាងអន្លង់នីមួយៗ នៅក្នុងភូមិមានលក្ខណៈ ដូចគ្នា ។


ស្ថានភាពទន្លេសេសាននៅភាគខាងក្រោមនៃចំនុចប្រសព្វរវាងទន្លេស្រែពក



| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំ ២០០៦ (ម) | | កូអរដោនេ (GPS) | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្ដោយ | ទទឹង | បណ្ដោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | សាម៉ាខយតូច | ៨ | ២ | ១២ | ៦ | ១៥ | ១០ | ១៤៩៨០៧២ | ០៦១១៤២៣ |
| ២ | សាម៉ាខយធំ | ៩ | ៣ | ៥០ | ៣០ | ២០ | ១៥ | ១៤៩៧៩៧២ | ០៦១១៩៨១ |
| ៣ | តាហ៊ិង | -[១] | ៤,២០ | - | - | ៣៥ | ៣០ | ១៤៩៧៥៨៥ | ០៦១២៥៦០ |
| ៤ | យាយសាត់ | ៥ | ០[២] | - | - | ១៥ | ៨ | ១៤៩៧៤៩៧ | ០៦១២៩៩៦ |
| ៥ | យាយផានី | ៥ | ០ | ៨ | ៦ | - | - | ១៤៩៧៣៤១ | ០៦១៣១៨៥ |

[១] = មិនដឹងជំរៅ, [២] =ជំរៅស្មើបាតទន្លេ

### ៣.១២.១ អន្លង់សាម៉ាខយតូច (អន្លង់ជំរាលថ្មតូច)

#### ក. ទីតាំង

អន្លង់សាម៉ាខយតូច មានចំងាយ ៧00ម៉ែត្រ ពីភូមិសាមឃួយ ឃុំសាមឃួយ នៅភាគខាងក្រោមខ្សែទឹកនៃភូមិ ហើយប្រជាពលរដ្ឋតែងតែហៅត១គ្នារៀងមកដោយមានលក្ខណៈសំគាល់មួយ គឺមានថ្មជំរាលតូចមួយនៅមាត់អន្លង់នេះ (មានឈ្មោះពីដូនតាមក) នៅខែ តុលា ឆ្នាំ ២00៥ ប្រជាជនឃើញសត្វរាងដូចពស់មានសិរលើក្បាល មកកៀងទូក។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = 0៦១១៤២៣
- អរដោនេ = ១៤៩៨0៧២
- រយៈកំពស់ = ៤៣ ម

#### ខ. លក្ខណៈរូប

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៨ម ឆ្នាំ ២00៦ = ២ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៦ម x ១២ម ឆ្នាំ ២00៦ = ១0ម x ១៥ម

#### គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធជុំវិញទៅដោយផ្ទាំងថ្ម និងខ្សាច់ ។ មាត់អន្លង់គែមខាងត្បូងនៅជាប់នឹងច្រាំងទន្លេមានជំរាលថ្មទេរទៅរកបាតអន្លង់ ផ្នែកខាងកើតបាំងទៅដោយផ្ទាំងថ្មទំហំ ៥ម៉ែត្រ គុណនឹង ៦ម៉ែត្រ ផ្នែកខាងជើង និងផ្នែកខាងលិចត្រូវបានខ្សាច់ហូរមកគរ និងលុបអន្លង់ជារៀងរាល់ឆ្នាំ ។ ចាប់ពីខែមករា ដល់ខែ ឧសភា ផ្ទៃទឹកកំពស់ ១ ម៉ែត្រពីលើមាត់អន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មើលមិនឃើញផ្ទាំងថ្ម និងខ្សាច់ ។ កំពស់ទឹកនៅរដូវទឹកឡើងកំពស់ ១0ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ។



#### ឃ. ប្រភេទសត្វ

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីប៉ាមូក, ត្រីឆ្ពិន, ត្រីប៉ាញ៉ូន, ត្រីប៉ាវ៉ា, ត្រីប៉ាស៊ីអុី, ត្រីឆ្កោ , ត្រីអណ្តែង , ត្រីផ្ទក់ និងត្រីកែស ។
- ប្រភេទសត្វស្លាបរួមមាន : ព្រាបព្រៃ , កុក និងក្អែកទឹក ។
- ប្រភេទល្មូន : អណ្តើក , កន្ធាយ ។

#### ង. ប្រភេទរុក្ខជាតិ

- ដើមរៃ ដើមផ្កាអណ្តែង ។

#### ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឡឺម ដុងតាដាំ ស្រែ-ពាធី និងតាដែក ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា
  - សំណាញ់ : ប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៤ ស.ម ។
    - ♦ ក្រឡា២,៥ -៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)
    - ♦ ក្រឡា៨-១៤ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា (រដូវទឹកឡើង)
  - សន្ទូច នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១0-១២-១៤ វិញ ។
  - មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៦ -១0ស.ម ។
  - ចាន់ នេសាទចាប់ពីខែ កញ្ញា ដល់ខែ កុម្ភៈ (អ្នកមកពីភូមិដុងតាដាំ និង ភូមិ-ស្រែពោធិ៍) ។

*(កាលបរិច្ឆេទ ២១ មេសា ២00៦)*

### ៣.១២.២ អន្លង់សាម៉ាខយធំ (អន្លង់ជំពលថ្មធំ)

**ក. ទីតាំង**

អន្លង់សាម៉ាខយធំ មានចំងាយ ៤00ម៉ែត្រ ពីភូមិសាមឃួយ ឃុំសាមឃួយ ដែលស្ថិតនៅភាគខាងក្រោមនៃខ្សែទឹកក្នុងភូមិ ហើយប្រជាពលរដ្ឋតែងតែហៅត។គ្នារៀងមកដោយមានលក្ខណៈសំគាល់មួយ គឺមានថ្មជំរាលធំមួយនៅមាត់អន្លង់នេះ ( មានឈ្មោះពីដូនតាមក) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = 0៦១១៥៨១
- អរដោនេ = 0១៤៩៧៩៧២
- រយៈកំពស់ = ៤0 ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៩ម ឆ្នាំ ២00៦ = ៣ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៣0ម x ៥0ម ឆ្នាំ ២00៦ = ១៥ម x ២0ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធជុំវិញទៅដោយផ្ទាំងថ្ម និងខ្សាច់ ។ មាត់អន្លង់តែមខាងត្បូងនៅជាប់នឹងច្រាំងទន្លេមានជំរាលថ្មទេរទៅរកបាតអន្លង់ ផ្នែកខាងកើតមានថ្មប៉ប្រះទឹក ល្បាក់ទឹកហូរ ផ្នែកខាងលិច និងខាងត្បូងមានថ្ម និងខ្សាច់ដុះជារៀងរាល់ឆ្នាំ ។ នៅរដូវប្រាំងចាប់ពីខែមករា ដល់ខែ ឧសភា ពីលើផ្ទៃអន្លង់ទឹកមានកំពស់ 0,៥ម៉ែត្រ ទៅ ២ម៉ែត្រ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងខ្សាច់ ។ នៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ទឹកមានកំពស់ ១0ម៉ែត្រ។



**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីប៉ាមូក, ត្រីឆ្ពិន, ត្រីប៉ាញ៉ន,ត្រីប៉ាវ៉ា, ត្រីប៉ាស៊ីអ៊ី, ត្រីឆ្តោ ,ត្រីអណ្តែង ,ត្រីផ្ទក់ និងត្រីកែស ។
- ប្រភេទសត្វស្លាបរួមមាន : ព្រាបព្រៃ ,កុក និងក្អែកទឹក ។
- ប្រភេទល្មូន : អណ្តើក កន្ធាយ និងល្មិចមានដោយកំរ ។

**ង. ប្រភេទរុក្ខជាតិ :**

- ដើមរៃ ដើមអណ្តែង និងនៅតាមច្រាំងទន្លេ មានគុម្ពឫស្សី ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឡើម ដុងតាដំ ស្រែពោធិ៍ និងភូមិតាដែក ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា
- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៤ ស.ម ។

♦ ក្រឡា ២,៥-៤ស.ម ប្រើប្រាស់ចាប់ពីខែវិច្ឆិកា ដល់ខែមិថុនា ( រដូវទឹកស្រក)

♦ ក្រឡា ៨ - ១៤ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ( រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១0-១២-១៤ វិញ ។
- មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៥-១0 ស.ម ។
- ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ វិច្ឆិកា ( អ្នកមកពីភូមិដុងតាដំ និងភូមិ-ស្រែពោធិ៍) ។

*( កាលបរិច្ឆេទ ២១ មេសា ២00៦)*

### ៣.១២.៣ អន្លង់តាហិង

**ក. ទីតាំង**

អន្លង់តាហិង មានទីតាំងជាប់នឹងភូមិសាមឃួយ ឃុំសាមឃួយ ហើយប្រជាពលរដ្ឋតែងតែហៅត១គ្នាតាំងពីដូនតាមក និងមានលក្ខណៈសំគាល់ដោយអន្លង់នេះស្ថិតនៅត្រង់កំពង់ទឹកតាហិង ។

**<u>ចំណុចនៅលើ GPS :</u>**

**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីប៉ាមូក, ត្រីឆ្កិន, ត្រីប៉ាញ៉ន,ត្រីប៉ាវ៉ា, ត្រីប៉ាសុីអុី, ត្រីឆ្តោ,ត្រីអណ្តែង, ត្រីផ្ទក់ និងត្រីកែស ។
- ប្រភេទសត្វស្លាបរួមមាន : ព្រាបព្រៃ, កុក និងក្អែកទឹក ។
- ប្រភេទល្មូន : អណ្តើក,កន្ធាយ ។

**ង. ប្រភេទរុក្ខជាតិ :**

- មិនមានដើមរៃ ឫផ្កាអណ្តែងដុះទេ នៅតាមមាត់អន្លង់ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឌើម ដុងតាដំ ស្រែពោធិ៍ និងភូមិតាដែក ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៤ ស.ម
  - ◆ ក្រឡា ២,៥- ៤ ស.ម ប្រើចាប់ពីខែវិច្ឆិកា ដល់ខែមិថុនា (រដូវទឹកសម្រក)
  - ◆ ក្រឡា៨-១៤ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា(រដូវទឹកឡើង)
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្ន ប្រើលេខ ១០-១២-១៤ វិញ ។
  - មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៤ - ១០ ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែតុលា ។

*(កាលបរិច្ឆេទ ២១ មេសា ២០០៦)*

### ៣.១២.៤ អន្លង់យាយសាត់

**ក. ទីតាំង**

អន្លង់យាយសាត់ ស្ថិតនៅជាប់នឹងភូមិសាមឃួយ ឃុំសាមឃួយ ហើយប្រជាពលរដ្ឋតែងតែហៅអន្លង់នេះត១គ្នារៀងមក និងមានលក្ខណៈសំគាល់ដោយអន្លង់នេះស្ថិតនៅត្រង់កំពង់យាយសាត់( មានឈ្មោះពីដូនតាមក) ។ បច្ចុប្បន្នអន្លង់នេះនៅស្មើនឹងបាតទន្លេ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១២៩៩៦
- អរដោនេ = ១៤៩៧៤៩៧
- រយៈកំពស់ = ៤២ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ =៥ម ឆ្នាំ ២០០៦ = ០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ម x ម ឆ្នាំ ២០០៦ = ១៥ម x ៨ម

ដោយអន្លង់នេះសព្វថ្ងៃត្រូវខ្សាច់ហូរលុបបាត់បង់ស្ថានភាពអស់ទៅហើយធ្វើអោយយើងមិនអាចបរិយាយបានក្បោះក្បាយឡើយ ។

### ៣.១២.៥ អន្លង់យាយផានី

**ក. ទីតាំង**

អន្លង់យាយផានី ស្ថិតនៅជាប់នឹងភូមិសាមឃួយ ឃុំសាមឃួយ ហើយប្រជាពលរដ្ឋតែងតែហៅត។គ្នារៀងមក(ដោយមានឈ្មោះតាំងពីដូនតាមក) និងមានលក្ខណៈសំគាល់ដោយអន្លង់នេះស្ថិតនៅត្រង់កំពង់យាយផានី បច្ចុប្បន្នអន្លង់នេះជម្រៅស្មើនឹងបាតទន្លេ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១៣១៨៥
- អរដោនេ = ១៤៩៧៣៤១
- រយៈកំពស់ = ៤២ ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៥ម ឆ្នាំ ២០០៦ = ស្មើបាតទន្លេ
- ទំហំ : មុនឆ្នាំ ១៩៩៥ = ៨ម x ៦ម ឆ្នាំ ២០០៦ = បាត់ស្ថានភាពអន្លង់

អន្លង់នេះសព្វថ្ងៃត្រូវខ្សាច់ហូរលុបបាត់បង់ស្ថានភាពអស់ទៅហើយ ធ្វើអោយយើងមិនអាចបរិយាយបានក្បោះក្បាយឡើយ ។

*(កាលបរិច្ឆេទ ២១ មេសា ២០០៦)*



## ៣.១៣ ភូមិបាឌើម ឃុំសាមឃួយ

ភូមិបាឌើម ជាភូមិមួយស្ថិតនៅតាមបណ្តោយដងទន្លេសេសាន មានចំងាយ៩,៥គ.ម ពីទីរួមខេត្តស្ទឹងត្រែង។ ខាងកើតជាប់នឹងភូមិសេសាន, ខាងលិចជាប់នឹងភូមិសាមឃួយ និងខាងជើងជាប់នឹងភូមិហាងសាវ៉ាត។ ភូមិបាឌើម មានប្រជាជនចំនួន ១១៩គ្រួសារ ស្មើនឹង ៥៥៦នាក់ ស្រី ២៦៩ នាក់ និងមានផ្ទះចំនួន ៩៥ ខ្នង ។ នៅតាមបណ្តោយដងទន្លេមានអន្លង់សរុបចំនួន ២កន្លែងគឺ : អន្លង់ហ៊ីនឡាត និងអន្លង់កំពង់វត្តបាឌើម ។ ក្នុងនេះមានអន្លង់មួយ គឺអន្លង់កំពង់វត្តត្រូវបានខ្សាច់ហូរលុបរាក់ស្មើនឹងបាតទន្លេ នៅពេលនេសាទការប្រើប្រាស់ឧបករណ៍ និងពេលវេលារវាងអន្លង់នីមួយ។នៅក្នុងភូមិមានលក្ខណៈដូចគ្នា គ្រប់រដូវកាលទាំងអស់ ។

### ៣.១៣.១ អន្លង់ហ៊ីនឡាត (អន្លង់ថ្មលាត)

**ក. ទីតាំង**

អន្លង់ហ៊ីនឡាត មានទីតាំងជាប់នឹងភូមិបាឌើម ឃុំសាមឃួយ តែមមាត់អន្លង់ខាងត្បូងជាប់នឹងច្រាំងទន្លេខាងត្បូង ហើយមានផ្ទាំងថ្មធំបណ្តោយប្រវែង ១០ម និងទទឹង ៥ម ព្រមទាំងមានថ្មតូច។នៅបាតអន្លង់ ។ នៅផ្នែកខាងជើងនៃមាត់អន្លង់មានខ្សាច់ដុះគរ លើគ្នាជាថ្នាក់។ យ៉ាងច្រើន ហើយប្រជាពលរដ្ឋតែងតែហៅត។គ្នារៀងមកទៅតាមស្ថានភាពថ្មនោះ (មានឈ្មោះតាំងពីដូនតាមកម្លេះ) ។

<u>ចំណុចនៅលើ GPS :</u>

- អាប់ស៊ីស = ០៦១៤២២៨
- អរដោនេ = ១៤៩៦៩៥៧
- រយៈកំពស់ = ៤៥ ម

តារាង ២ ឈ្មោះអន្លង់ភូមិបាឌើម ឃុំសាមឃួយ

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំ ២០០៦ (ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្ដោយ | ទទឹង | បណ្ដោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | ហ៊ិនឡាត | ៦ | ១,៨ | ១០០ | ២៥ | ៨០ | ២០ | ១៤៩៦៩៥៧ | ០៦១៤២២៨ |
| ២ | កំពង់វត្ត | - | ០ | ១០០ | ៣០ | - | - | ១៤៩៦៨៩១ | ០៦១៤៥០៥ |

[១] = មិនដឹងជំរៅ, [២] =ជំរៅស្មើបាតទន្លេ



ខ. លក្ខណៈរូប

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៦ម ឆ្នាំ ២០០៦ = ១,៨ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០០ម x ២៥ម ឆ្នាំ ២០០៦ = ៨០ម x ២០ម

គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធជុំវិញទៅដោយផ្ទាំងថ្ម និងខ្សាច់ពុំមានរុក្ខជាតិដុះទេ ។ នៅមាត់អន្លង់ផ្នែកខាង លើល្បាក់ទឹកហូរខ្លាំងល្មម ។ រដូវប្រាំងចាប់ពីខែមករា ដល់ខែ ឧសភា លើផ្ទៃអន្លង់ទឹកមានកំពស់ពី ០,៥ម ទៅ ១,៥០ម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើលមិនឃើញផ្ទាំងថ្ម និងខ្សាច់ ។ កំពស់ទឹកនៅរដូវទឹកឡើងកំពស់ ១០,២០ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ។

ឃ.ប្រភេទសត្វ

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីប៉ាមូក, ត្រីឆ្កិន, ត្រីប៉ាញ៉ន, ត្រីផ្ទក់, ត្រីប៉ាស៊ីអ៊ី, ត្រីឆ្តោ , ត្រីអណ្ដែង , ត្រីកែស , ត្រីប៉ាវ៉ា, ត្រុំ និង ខ្ទៅ ។
- ប្រភេទសត្វស្លាបរួមមាន ព្រាបព្រៃ, កុក ,ក្អែកទឹក, មាន់ស្រុក និងទា ។
- ថនិកសត្វ : គោ, ក្របី, ជ្រូក
- ប្រភេទល្មូន : អណ្ដើក , កន្ធាយ ។

ង. ប្រភេទរុក្ខជាតិ (គ្មាន)

ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

- ប្រជាជននៅក្នុងភូមិតែងតែនាំគ្នាមកប្រមូលថ្ម និងខ្សាច់យកទៅធ្វើជើងសសរផ្ទះ
- ប្រភពអ្នកនេសាទ : មកពីភូមិសាមឃួយ ហាងសាវ៉ាត បាឌើម តាដុងតាដាំ និងភូមិស្រែពោធិ៍ ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៤ ស.ម

- ក្រឡា ២.៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក)

- ក្រឡា ៨ - ១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ( រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។

- មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៤ស.ម ទៅ ១០ស.ម ។

- ចាន់ : នេសាទចាប់ពីខែមិថុនា ដល់ខែ តុលា ។

*(កាលបរិច្ឆេទ ២២ មេសា ២០០៦)*

### ៣.១៣.២ អន្លង់កំពង់វត្តបាឌើម

**ក. ទីតាំង**

អន្លង់កំពង់វត្ត មានទីកន្លែងជាប់នឹងភូមិបាឌើម ឃុំសាមឃួយ ទល់មុខវត្តបាឌើមផ្នែកច្រាំងទន្លេខាងត្បូង នៅបាតអន្លង់មានខ្សាច់ដុះយ៉ាងច្រើន ។ ប្រជាពលរដ្ឋតែងតែហៅឈ្មោះអន្លង់នោះតាមស្ថានភាពជាក់ស្តែង ព្រោះថាវានៅទល់មុខវត្តទើបគេនាំគ្នាហៅថា អន្លង់កំពង់វត្ត តៗគ្នារៀងមក ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១៤៥០
- អរដោនេ = ១៤៩៦៨៩១
- រយៈកំពស់ = ៥៧ ម

**ខ.លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ម ឆ្នាំ ២០០៦ = ស្មើបាតទន្លេ
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០០ម x ៣០មឆ្នាំ ២០០៦ = បាត់ស្ថានភាព

*(កាលបរិច្ឆេទ ២២ មេសា ២០០៦)*



## ៣.១៤ ភូមិហាងសាវ៉ាត ឃុំសាមឃួយ

ភូមិហាងសាវ៉ាត ជាភូមិមួយស្ថិតនៅតាមបណ្តោយដងទន្លេសេសាន ឃុំសាមឃួយ នៅច្រាំងទន្លេផ្នែកខាងជើង មានចំងាយផ្លូវគោក៩ គ.ម និងផ្លូវទឹក៩គ.ម ពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅប្រមាណ ១១១គ្រួសារ និងមាន ៩០ខ្នងផ្ទះដែលមានប្រជាពលរដ្ឋសរុប ៥២២នាក់ ស្រី២៤៤នាក់ ។ ភូមិនេះមានអន្លង់ចំនួន ៤កន្លែង បើយើងរាប់ពីខ្សែទឹកខាងក្រោមឡើងមកលើ ។ អន្លង់ទាំងនោះមានដូចជា អន្លង់ចឹកស៊ុី អន្លង់ណោយ៉ាក់ អន្លង់ហ៊ិនស៊ូងក្រោម និង អន្លង់ហ៊ិនស៊ូងលើ ។ ក្នុងចំណោមអន្លង់ទាំង ៤នេះមានអន្លង់ពីរកន្លែងត្រូវបានរាក់អស់ស្មើនឹងបាតទន្លេគឺ អន្លង់ចឹកស៊ុី និងអន្លង់ណោយ៉ាក់ ឯអន្លង់ដទៃៗទៀតក៏ត្រូវរាក់អស់មួយចំនួនដែរដោយសារតែខ្សាច់ហូរលុប ។

### ៣.១៤.១ អន្លង់ចឹកស៊ុី

**ក. ទីតាំង**

អន្លង់ចឹកស៊ុី មានចំងាយ ១គ.ម ពីភូមិហាងសាវ៉ាត ឃុំសាមឃួយ ផ្នែកទន្លេខាងលិចភូមិ នៅបាតអន្លង់មានខ្សាច់ដុះយ៉ាងច្រើន ។ ប្រជាពលរដ្ឋតែងតែហៅតាមស្ថានភាពអន្លង់នោះតៗគ្នាមកដល់សព្វថ្ងៃនេះ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១២៣៦៩
- អរដោនេ = ១៤៩៧៩៤៧
- រយៈកំពស់ = ៣២ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ម ឆ្នាំ ២០០៦ =ស្មើបាតទន្លេ
- ទំហំ : មុនឆ្នាំ ១៩៩៥ = ម x ម ឆ្នាំ ២០០៦ = បាត់ស្ថានភាព

ដោយអន្លង់នេះសព្វថ្ងៃត្រូវខ្សាច់ហូរលុបបាត់បង់ស្ថានភាពអស់ទៅហើយ ធ្វើអោយយើងមិន-អាចបរិយាយបានក្បោះក្បាយឡើយ ។ *(កាលបរិច្ឆេទ ២៣ មេសា ២០០៦)*

តារាង ៣ ឈ្មោះអន្លង់ភូមិហាងសាវ៉ាត ឃុំសាមឃួយ

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំ ២០០៦ (ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | ចឹកស៊ី | - | 0 | - | - | 0 | 0 | ១៤៩៧៩៤៧ | ០៦១២៣៦៩ |
| ២ | ណាយ៉ាក់ | - | 0 | ១០០ | ៣០ | 0 | 0 | ១៤៩៨២៤៣ | ០៦១១៩១៨ |
| ៣ | ហ៊ុនស៊ួងក្រោម | ១៥ | ៣ | ១០០ | ៥០ | ១០០ | ៣០ | ១៤៩៧៩០៦ | ០៦១២៦០៧ |
| ៤ | ហ៊ុនស៊ួងលើ | ១៥ | ៤,៥ | ២០០ | ១៥០ | ២០០ | ១០០ | ១៤៩៧៣៨៥ | ០៦១៤៩៣៨ |

[១]= មិនដឹងជំរៅ, [២]=ជំរៅស្មើបាតទន្លេ



## ៣.១៤.២ អន្លង់ណាយ៉ាក់

**ក. ទីតាំង**

អន្លង់ណាយ៉ាក់ មានចំងាយ ៧០០ម ពីភូមិហាងសាវ៉ាត ឃុំសាមឃួយ នៅតាមដងទន្លេភាគខាងក្រោមភូមិនៅបាតអន្លង់មានខ្សាច់ដុះយ៉ាងច្រើន ។ ប្រជាពលរដ្ឋតែងតែហៅតាមស្ថានភាពអន្លង់នោះត១ មកដល់សព្វថ្ងៃនេះដោយហេតុថាអន្លង់នោះមានរាងដូចមុខយក្ស។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១១៩១៨
- អរដោនេ = ១៤៩៨២៤៣
- រយៈកំពស់ = ៤១ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ម x ម ឆ្នាំ ២០០៦ =ស្មើបាតទន្លេ
- ទំហំ : មុនឆ្នាំ ១៩៩៥ = ១០០ម x ៣០ម ឆ្នាំ ២០០៦ = បាត់ស្ថានភាព

ដោយអន្លង់នេះសព្វថ្ងៃត្រូវខ្សាច់ហូរលុបបាត់បង់ស្ថានភាពដើមអស់ទៅហើយ ធ្វើអោយយើងមិនអាចបរិយាយបានក្បោះក្បាយឡើយ ។

*(កាលបរិច្ឆេទ ២៣ មេសា ២០០៦)*

### ៣.១៤.៣ អន្លង់ហ៊ិនស្ទ៊ងក្រោម (ផ្ទខ្ពស់ក្រោម)

**ក. ទីតាំង**

អន្លង់ហ៊ីនស្ទ៊ីងក្រោម មានចំងាយប្រហែល២០០ម ពីភូមិហាងសាវ៉ាត ឃុំសាមឃួយ នៅភាគខាងក្រោមខ្សែទឹកនៃភូមិ (បើគិតតាមខ្សែទឹកពីក្រោមមកលើ) ។ ប្រជាពលរដ្ឋតែងតែហៅត១គ្នាពីដូនតារៀងមក ដោយមានលក្ខណៈសំគាល់ទៅតាមថ្មធំមួយដែលនៅជាប់អន្លង់នេះ ផ្នែកខាងជើងជាប់នឹងច្រាំង រីឯផ្នែកខាងត្បូងមានខ្សាច់ដុះច្រើន និងមានរាងទ្រវែង ។

**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = ០៦១២៦០៧
- អរដោនេ = ១៤៩៧៩០៦
- រយៈកំពស់ = ៣២ ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៣ម
- ទំហំ : មុន ១០០ម x ៥០ម ឆ្នាំ២០០៦=១០០ម x ៣០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធទៅដោយផ្ទាំងថ្ម និងមានខ្សាច់ដុះនៅមាត់អន្លង់ខាងកើតឆៀងខាងត្បូង ។ កាលពីមុនអន្លង់នេះមានរាងមូល ប៉ុន្តែសព្វថ្ងៃនេះមាត់អន្លង់មានរាងទ្រវែងផ្នែកខាងកើត និងទទឹងមានទំហំតូចជាងមាត់អន្លង់ផ្នែកខាងលិច រីឯនៅបាតអន្លង់មានថ្មនៅខាងក្រោម ។ ចាប់ពីខែមករា ដល់ខែឧសភា ទឹកមានកំពស់ចាប់ពី ១ម ទៅ ២ម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ដោយមិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់បានទៀតឡើយ ។ នៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែវិច្ឆិកា ទឹកមានកំពស់ ១០ ម៉ែត្រ ។

**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីប៉ាមូក, ត្រីឆ្អិន, ត្រីប៉ាញ៉ន,ត្រីប៉ាវ៉ា, ត្រីប៉ាស៊ីអ៊ី, ត្រីប៉ាផ្ទង, ត្រីប៉ាស៊ីកាង, ត្រីប៉ាកក់ និងត្រីកែស ។



- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក និងលលកទឹក ។
- ប្រភេទល្មូន : ពស់

**ង. ប្រភេទរុក្ខជាតិ** : មានដើមផ្កាអណ្ដែង ដុះបន្តិចបន្តួច ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិសាមឃួយ ហាងសាវ៉ាត បាឌើម ដុងតាដំ សាឃួន និងភូមិតាដែក ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៤ ស.ម

♦ ក្រឡា ២,៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)

♦ ក្រឡា ៨ -១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា រដូវទឹកឡើង

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្ន ប្រើលេខ ១០-១២-១៤ វិញ ។
- មងបណ្ដែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៤-១០ស.ម ។
- ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ កញ្ញា (អ្នកមកពីភូមិដុងតាដាំ និង ភូមិសាឃួន) ។
- ឆក់ : ចាប់ពីខែមិនា ដល់ខែ ឧសភា ។

*(កាលបរិច្ឆេទ ២៣ មេសា ២០០៦)*

### ៣.១៥.៤ អន្លង់ហ៊ិនស៊ូងលើ (ថ្មខ្ពស់លើ)

**ក. ទីតាំង**

អន្លង់ហ៊ិនស៊ូងលើ មានចំងាយ១,៥០គ.ម ពីភូមិហាងសាវ៉ាត ឃុំសាមឃួយ នៅភាគខាងលើនៃខ្សែទឹកភូមិ ។ ប្រជាពលរដ្ឋតែងតែហៅត១គ្នាពីដូនតារៀងមកដោយមានលក្ខណៈសំគាល់ទៅតាមថ្មធំៗនៅជាប់នឹងអន្លង់នេះផ្នែកខាងជើងជាប់នឹងច្រាំង ឯផ្នែកខាងត្បូងមានខ្សាច់ដុះច្រើន និងមានរាងទ្រវែង ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = 0៦១៤៩៣៨
- អរដោនេ = ១៤៩៧៣៨៥
- រយៈកំពស់ = ៤0 ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២00៦ = ៤,៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ = ២00ម x ១៥0មឆ្នាំ ២00៦ = ២00មx ១00ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : មានផ្ទាំងថ្មនៅព័ទ្ធជុំវិញមាត់អន្លង់ ហើយអន្លង់មានរាងទ្រវែង ។ រីឯផ្នែកខាងកើតមានផ្ទាំងថ្មធំៗទំហំ ៥-១0ម x ១0ម និង នៅបាតអន្លង់មានថ្ម ដែលផ្នែកខាងលើមានទំហំធំជាងផ្នែកខាងក្រោម ។ នៅផ្នែកខាងជើងជាប់នឹងច្រាំងទន្លេចាប់ពី ខែមករាដល់ខែ ឧសភា ផ្ទៃទឹកកំពស់ ១ម ទៅ ២ម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់ អន្លង់ទាំងអស់ដោយមិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ដែលដុះដូចមុនបានឡើយ ។ នៅរដូវវស្សាចាប់ពីខែសីហា ដល់ខែ វិច្ឆិកា ទឹកមានកំពស់ពី ៩ម-១0 ម ។



**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្កិន, ត្រីឆ្លួញ, ត្រីប៉ាវ៉ា, ត្រីប៉ាកក់ , ត្រីប៉ាស៊ីអ៊ី, ត្រីប៉ាផ្ទង, ត្រីប៉ាស៊ីកាង, ត្រីកែស, ត្រីពោ, ត្រីឈ្វាត និងត្រីកញ្ចុះក្តោង ។
- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក និងលលកទឹក ។
- ប្រភេទល្មូន : ពស់ ។

**ង. ប្រភេទរុក្ខជាតិ :** មានដើមផ្កាអណ្តែង ដុះបន្តិចបន្តួច ដើមកុកហែ និងដើមរៃ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រជាជនតែងតែយកថ្មមកចាក់ធ្វើជើងសសរផ្ទះ គ្រឹះ ចាក់អាងទឹក និងចាក់សាប ។
- ប្រភពអ្នកនេសាទ :មកពីភូមិសាមឃួយ ហាងសាវ៉ាត បាឌើម សេសាន បានម៉ៃ សាឃួន និងភូមិតាដែក ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៤ ស.ម
  - ក្រឡា ២,៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក)
  - ក្រឡា៨ - ១៤ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែ វិច្ឆិកា ( រដូវទឹកឡើង
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្ន ប្រើលេខ ១0-១២-១៤ វិញ ។
  - មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ
  - ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ កញ្ញា
  - ឆក់ : ចាប់ពីខែមីនា ដល់ខែ ឧសភា ។

*( កាលបរិច្ឆេទ ២៣ មេសា ២00៦)*

## ៣.១៥ ភូមិសេសាន ឃុំកំភុន

ភូមិសេសាន ជាភូមិមួយស្ថិតនៅតាមបណ្តោយដងទន្លេសេសាន ឃុំកំភុន មានចំងាយផ្លូវគោក ១១ គ.ម និងផ្លូវទឹក ១១គ.ម ពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅប្រមាណ ៧៨គ្រួសារ និងមាន ៦១ ខ្នងផ្ទះមានប្រជាពលរដ្ឋសរុប ៣៤៨នាក់ ស្រី ១៧៦នាក់ ។ ភូមិនេះមានអន្លង់ចំនួន ៣កន្លែង បើយើងរាប់ពីក្រោមខ្សែទឹកឡើងទៅលើ ហើយអន្លង់ទាំងនេះរួមមាន: អន្លង់ហ៊ុីនស៊ូង អន្លង់ហ៊ុីនខៃ និងអន្លង់ខាន់ថានី ។ ក្នុងចំណោមអន្លង់ទាំង ៣ កន្លែងនេះមានអន្លង់មួយត្រូវបានរាក់អស់ស្ទើនឹងបាតទន្លេ គឺអន្លង់ខាន់ថានី ឯអន្លង់ដទៃៗទៀតក៏រាក់អស់មួយចំនួនដែរ ដោយសារតែមានខ្សាច់ហូរលុប ។

### ៣.១៥.១ អន្លង់ខាន់ថានី

#### ក.ទីតាំង

អន្លង់ខាន់ថានី មានទីតាំងស្ថិតនៅក្នុងភូមិសេសាន ឃុំកំភុន នៅភាគខាងលើគេបើប្រៀបធៀបទៅនឹងអន្លង់ទាំងបីនេះ ។ អន្លង់នេះខណ្ឌដោយថ្មអមសងខាងផ្នែកខាងកើតនិងផ្នែកខាងលិច ឯតែមខាងត្បូងជាប់នឹងច្រាំងទន្លេ ។ ប្រជាពលរដ្ឋតែងតែហៅតៗគ្នារៀងមក និងមានលក្ខណៈសំគាល់មួយគឺ ( មានឈ្មោះពីដូនតាមក) ។

<u>ចំណុចនៅលើ GPS :</u>

- អាប់ស៊ីស = ០៦១៦៣៦៦
- អរដោនេ = ១៤៩៧៩០៣
- រយៈកំពស់ = ៣៧ម

ខ លក្ខណៈរូប

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ឆ្នាំ ២០០៦ = ស្ទើបាត

-ទំហំ :មុនឆ្នាំ ១៩៩៥ =១០០ម x ៥០០ម ឆ្នាំ ២០០៦ = បាត់ស្ថានភាព



តារាងទី ៤ ឈ្មោះអន្លង់នៅភូមិសេសាន ឃុំកំភុន

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ ( ម) | | ទំហំអន្លង់ពីមុន ( ម) | | ទំហំ ២០០៦ ( ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុនឆ្នាំ ១៩៩៥ | ២០០៦ | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | ខាន់ ថានី | | | ៥០០ | ១០០ | បាត់បង់ស្ថាន ភាព អន្លង់ | | ១៤៩៧៩០៣ | ០៦១៦៣៦៦ |
| ២ | ហ៊ុីនខៃ | ៥ | ១,៥ | ១៥០ | ១០០ | ៥០ | ៣០ | ១៤៩៧៨២៨ | ០៦១៦១៤៥ |
| ៣ | ហ៊ុីនស៊ូង | ៨ | ១,៥០ | ១០០ | ១០០ | ៥០ | ៣០ | ១៤៩៧២៣០ | ០៦១៩៥៤៦ |

## គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធជុំវិញទៅដោយផ្ទាំងថ្ម អមសងខាងអន្លង់រាងទ្រវែងកាត់ទទឹងទន្លេ ។ កាលពីមុនមានរន្ធមេទឹកដែលមានប្រភពមកពីត្រពាំងពើក អូរឃ្លៃ វាលរំពេ និងមានមេទឹក (នាគ) ។ ចំណែកបាតអន្លង់មានថ្មជាច្រើន ហើយចាប់ពីខែមករា ដល់ខែ ឧសភា ផ្ទៃទឹកមាន កំពស់ ១ម ទៅ ២ម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ដោយមិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់បានឡើយ។ នៅរដូវវស្សាចាប់ពីខែសីហា ដល់ខែ វិច្ឆិកា ទឹកមានកំពស់ ១០ម៉ែត្រដោយអន្លង់នេះសព្វថ្ងៃត្រូវខ្សាច់ហូរលុបបាត់បង់ស្ថានភាព អស់ទៅធ្វើ អោយយើងមិនអាចបរិយាយបានក្បោះក្បាយឡើយ ។

*(កាលបរិច្ឆេទ ២៤ មេសា ២០០៦)*



**ការភ្ជួរស្រែចំការរបស់អ្នកស្រុកសេសាននារដូវវស្សាឆ្នាំ ២០០៨**



## ៣.១៥.២ អន្លង់ហ៊ីនខែ (អន្លង់ថ្មក្រពើ)

### ក.ទីតាំង

អន្លង់ហ៊ីនខែ មានទីតាំងនៅក្នុងភូមិសេសាន ឃុំកំភុន ។ អន្លង់នេះស្ថិតនៅត្រង់ចំណុចកណ្តាលគេក្នុងចំណោមអន្លង់ទាំងបីនេះ ហើយនៅគែមមាត់អន្លង់ខាងត្បូងមានខ្សាច់ដុះគ្រប ចំងាយ ១៥ម ពីមាត់ទន្លេនៅផ្នែកខាងក្រោមមានផ្ទាំងថ្មមួយសណ្ឋានបណ្តោយទន្លេដែលមានរាងដូចក្រពើ មានបណ្តោយប្រវែង២០ម និងទទឹងប្រវែង ៥ម ។ ប្រជាពលរដ្ឋតែងតែហៅតៗគ្នារៀងមកទៅតាមស្ថានភាពនៃលក្ខណៈរបស់ថ្ម (មានឈ្មោះ ពីដូនតាមក) ។

**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = ០៦១៦១៤៩
- អរដោនេ = ១៤៩៧៨២៨
- រយៈកំពស់ = ៤០ម

### ខ. លក្ខណៈរូប

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៥ម ឆ្នាំ ២០០៦ = ១,៥០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =១៥០ម x ១០០ម ឆ្នាំ ២០០៦ =៥០ x ៣០ម

### គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : នៅក្បែរមាត់អន្លង់ព័ទ្ធជុំវិញទៅដោយផ្ទាំងថ្មអមសងខាង និង-មាន ខ្សាច់ដុះ ប៉ុន្តែពុំមានរុក្ខជាតិដុះទេ ។ រីឯល្បឿនទឹកនៅត្រង់ចំណុចអន្លង់នេះ គឺមិនសូវហូរលឿនប៉ុន្មានដែរ ។ ប្រជាពលរដ្ឋមួយចំនួនតែងចាប់អារម្មណ៍ទៅ លើថ្មដែលដុះនោះ ដោយ-វាមានរាង ដូចក្រពើណាស់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ដោយ មិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់បានទៀតទេ ។ នៅរដូវវស្សាចាប់ពីខែ សីហា ដល់ ខែ វិច្ឆិកា ទឹកមានកំពស់ ១០ម៉ែត្រ ។

ឃ. ប្រភេទសត្វ

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្ពិន, ត្រីឆ្លូញ, ត្រីប៉ាវ៉ា, ត្រីស្លឹកឫស្សី, ត្រីប៉ាថុង, ត្រីប៉ាស៊ីកាង,ត្រីប៉ាកក់,ត្រីកែស,ត្រីពោ, ត្រីឈ្វាត និងត្រីកញ្ចុះភ្លោង ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក,លលកទឹក, ខ្វែកទឹក ,សត្វសំណាញ់ចិន, និងសត្វគ្រួចទឹក ។

- ប្រភេទល្មូន : ពស់ ។

- ប្រជាពលរដ្ឋចូលចិត្តទៅរាវ ខ្យង, ខ្ចៅ និងគ្រុំនៅទីនោះ ។

ង. ប្រភេទរុក្ខជាតិ : នៅចំណុចអន្លង់នេះគ្មានដើមផ្កាអណ្តែង ដើមកុកហែ ដើមរៃដុះទេ ។

ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

- ប្រជាជននៅក្នុងភូមិតែងតែយកថ្មដែលមាននៅជិតអន្លង់នោះមកចាក់ធ្វើជើងសសរផ្ទះ គ្រឹះ ចាក់អាងទឹក និងចាក់សាបជាដើម ។

- ប្រភពអ្នកនេសាទ :មកពីភូមិសាមឃួយ ហាងសាវ៉ាត បាឡើម សេសាន បានម៉ៃ កំភុន។ ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៤ ស.ម ក្រឡា ២,៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក) ក្រឡា ៨ - ១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា(រដូវទឹក ឡើង) ។

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤វិញ ។

- មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ៦-១០ស.ម ។

- ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ កញ្ញា

- មានអ្នកលួចឆក់ចាប់ពីខែ មីនា ដល់ខែ ឧសភា

*(កាលបរិច្ឆេទ ២៤ មេសា ២០០៦)*



៣.១៥.៣ អន្លង់ហ៊ីនស៊ូង (អន្លង់ថ្មខ្ពស់)

ក. ទីតាំង

អន្លង់ហ៊ីនស៊ូង មានទីតាំងស្ថិតនៅក្នុងភូមិសេសាន ឃុំកំភុន នៅខ្សែទឹកខាងក្រោមបើប្រៀបធៀបទៅនឹងអន្លង់ទាំងបីនេះ ចំណែកនៅគែមមាត់អន្លង់ខាងត្បូងជាប់នឹងច្រាំងទន្លេ ។ ហើយនៅត្រង់ចំណុចអន្លង់មានថ្មដុះឡើងមួយផ្ទាំងធំខ្ពស់ជាងគេ ។ ប្រជាពលរដ្ឋតែងតែហៅតៗគ្នារៀងមកទៅតាមស្ថានភាពនៃលក្ខណៈរបស់ថ្មថា ហ៊ីនស៊ូង រហូតមកដល់សព្វថ្ងៃនេះ (មានឈ្មោះពីដូនតាមក) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១៩៥៤៦
- អរដោនេ = ១៥៩៧២៣០
- រយៈកំពស់ = ៣៧ម

ខ. លក្ខណៈរូប

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ៨ម ឆ្នាំ ២០០៦ = ១,៥០ម
- ទំហំ :មុនឆ្នាំ ១៩៩៥ =១០០ម x ១០០ម ឆ្នាំ ២០០៦ =៥០ x ៣០ម

គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : នៅក្បែរមាត់អន្លង់ព័ទ្ធជុំវិញទៅដោយផ្ទាំងថ្មអមសងខាង និងខ្សាច់ដុះជាច្រើនពុំមានរុក្ខជាតិដុះទេ ។ រីឯល្បឿនទឹកហូរលឿនមធ្យមនៅត្រង់ចំណុចអន្លង់នោះ ។ ប្រជាពលរដ្ឋមួយចំនួនតែងចាប់អារម្មណ៍ទៅលើថ្មដែលមានកំពស់ខ្ពស់ជាងគេនោះណាស់។

♦ រដូវវស្សា :

រដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ដែលមិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ដែលដុះនៅត្រង់នោះបានទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ ខែ វិច្ឆិកា ១០ម ។

ឃ. ប្រភេទសត្វ

-ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្ពិន, ត្រីឆ្លូញ, ត្រីប៉ាវ៉ា, ត្រីស្លឹកឫស្សី,ត្រីកព្រួក, ត្រីប៉ាកក់,ត្រីកែស, ត្រីពោ, ត្រីឈ្វាត និង ត្រីកញ្ចុះក្តោង ។

- ប្រភេទសត្វស្លាបរួមមាន : កុក, លលកទឹក និងខ្វែកទឹក ។

- ប្រភេទល្អូន : ពស់ ។

- ប្រជាពលរដ្ឋចូលចិត្តទៅរាវ ខ្យង ខ្ចៅ គ្រំនៅទីនោះណាស់

**ង. ប្រភេទរុក្ខជាតិ :** នៅចំណុចអន្លង់នេះគ្មាន ដើមផ្កាអំណ្តែង ដើមកុកហែ និងដើមរំដេះ ឡើយ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រជាជននៅក្នុងភូមិតែងតែយកថ្មមកចាក់ធ្វើជើងសសរផ្ទះ គ្រឹះ ចាក់អាងទឹក និង-ចាក់សាបជាដើម ។

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឌើម សេសាន បានម៉ៃ និងភូមិកំភុន ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១០ ស.ម
 ក្រឡា ២,៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសំរក)
 ក្រឡា ៨ - ១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា (រដូវទឹកឡើង

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។

- មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៦-៩ស.ម ។

- ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ កញ្ញា ។

- មានអ្នកលួចឆក់ចាប់ពីខែ មិនា ដល់ខែ ឧសភា ពេលទឹកស្រកនៅរាក់ ។

*(កាលបរិច្ឆេទ ២៤ មេសា ២០០៦)*



## ៣.១៦ ភូមិបានម៉ៃ

ភូមិបានម៉ៃ ជាភូមិមួយស្ថិតនៅតាមបណ្តោយដងទន្លេសេសាន ឃុំកំភុន មានចំងាយផ្លូវគោក ប្រហែល ១៣ គ.ម និងផ្លូវទឹក ១៣គ.ម ពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅ ប្រមាណ ៨៣ គ្រួសារ និងមាន ៧៤ខ្នងផ្ទះ ប្រជាពលរដ្ឋសរុប ៣៩២នាក់ ស្រី ១៨៤នាក់ ។ ភូមិនេះមានអន្លង់ចំនួន ៣កន្លែង បើយើងរាប់ពីក្រោមខ្សែទឹក ឡើងទៅលើ ហើយអន្លង់ទាំង នោះរួមមាន អន្លង់យាយមីត អន្លង់យាយហៅ និងអន្លង់សាលា ។ ក្នុងចំណោមអន្លង់ទាំង ៣ នេះមានអន្លង់មួយត្រូវបានរាក់អស់ស្មើនឹងបាតទន្លេ គឺអន្លង់សាលា ឯអន្លង់ដទៃៗទៀត ក៏ត្រូវរាក់អស់មួយចំនួនដែរ ដោយសារតែខ្សាច់ហូរចាក់លុប ។

### ៣.១៦.១ អន្លង់យាយមីត ឬអន្លង់តាឡិត

**ក.ទីតាំង**

អន្លង់យាយមីត មានទីតាំងក្នុងភូមិបានម៉ៃ ឃុំកំភុន ស្ថិតនៅភាគខាងក្រោមនៃខ្សែទឹកពីក្រោមមកលើ បើប្រៀបធៀបទៅនឹងអន្លង់ទាំងបីនេះ ។ នៅត្រង់ទីតាំងអន្លង់មានថ្មប៉ប្រះទឹក នៅគែមអន្លង់ខាងកើត មាត់អន្លង់ខាងត្បូងជាប់នឹងច្រាំងទន្លេខាងត្បូង ចំណែកនៅមាត់អន្លង់ ខាងជើងមានថ្ម និងខ្សាច់ដុះឡើងខ្ពស់ ។ ប្រជាពលរដ្ឋតែងតែហៅតៗគ្នារៀងមកទៅតាម ឈ្មោះកំពង់ ព្រោះអន្លង់នេះស្ថិតនៅចំមុខកំពង់យាយមីត ទើបគេហៅដូច្នេះ ។ ប៉ុន្តែក្រោយ មកគេបានហៅថាអន្លង់តាឡិកវិញ ដោយសារតាឡិកគាត់បានស្លាប់នៅត្រង់ចំណុចអន្លង់នេះ ។ សព្វថ្ងៃបើយើងប្រើឈ្មោះទាំងពីរនេះអ្នកភូមិដែលរស់នៅទីនោះស្គាល់ទាំងអស់គ្នា ព្រោះបច្ចុប្បន្ន នេះប្រជាពលរដ្ឋនិយមហៅ ឈ្មោះទាំងពីរ ។

តារាង ៥ឈ្មោះអន្លង់ភូមិបានម៉ៃ ឃុំកំភុន

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំ ២០០៦ (ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុនឆ្នាំ ១៩៩៩ | ២០០៦ | បណ្ដោយ | ទទឹង | បណ្ដោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | យាយមីត | ៦ | ២.៦ | ៣០០ | ១០០ | ៣០០ | ១០០ | ១៤៩៨១២៤ | ០៦១៦៨៣៦ |
| ២ | យាយហៅ | ៦ | ៣ | ២២០ | ១០០ | ២២០ | ១០០ | ១៤៩៨៥០៦ | ០៦១៦៧៧០ |
| ៣ | សាហោ | ៦ | ស្មើបាត | ៦០ | ៤០ | បាត់បង់ស្ទើរភាព | | ១៤៩៧២៥១ | ០៦១៧២៦១ |



## ចំណុចនៅលើ GPS :

- អាប់ស៊ីស = ០៦១៦៨៣៦
- អរដោនេ = ១៤៩៨១២៤
- រយៈកំពស់ = ៤៥ម

### ខ. លក្ខណៈរូប

- ជំរៅ : មុនឆ្នាំ ១៩៩៩ = ៦ម ឆ្នាំ ២០០៦ = ២,៦០ម
- ទំហំ : មុនឆ្នាំ ១៩៩៩ =៣០០ម x ១០០ម ឆ្នាំ ២០០៦ =៣០០ x ១០០ម

### គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង :

នៅក្បែរមាត់អន្លង់ព័ទ្ធជុំវិញទៅដោយផ្ទាំងថ្ម និងខ្សាច់ដុះច្រើន តែពុំមានរុក្ខជាតិដុះទេ ។ ហើយល្បឿនទឹកហូរលឿនមធ្យមនៅត្រង់ចំណុចអន្លង់តែម្ដងវាមានទីតាំងស្ថិតនៅខាងក្រោមអន្លង់យាយហៅ តែក្បាលអន្លង់ យាយមីត ជាប់នឹងកន្ទុយអន្លង់ យាយហៅ ។

♦ រដូវវស្សា :

នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញផ្ទាំងថ្ម និង ខ្សាច់ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងពី ៩ម -១០ម ។

### ឃ. ប្រភេទសត្វ

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្ពិន, ត្រីឆ្ពួញ, ត្រីប៉ាវ៉ា, ត្រីស្លឹកឫស្សី, ត្រីកញ្ជ្រូក, ត្រីប៉ាកក់, ត្រីកែស, ត្រីពោ, ត្រីឈ្វាត និង កញ្ចុះក្ដោង ។
- ប្រភេទសត្វស្លាបរួមមាន : កុក, លលកទឹក, ខ្វែកទឹក
- ប្រភេទល្មូន : ពស់

**ង. ប្រភេទរុក្ខជាតិ**

នៅចំណុចអន្លង់ច្រាំងទន្លេមាន ដើមផ្កាអណ្តែង, ដើមកុកហែ, ដើមរំរៃ, ដើមរាំងទឹក, ដើមថ្វាន់=កុកគុមគេយកវាទៅធ្វើជ្រក់ហូប, ដើមក្តុលគេយកទៅធ្វើថ្នាំលឿង លាបពេលរលាកភ្លើង,ល្វាគេយកទងល្វាទៅស្ងោរទឹកផឹកដើម្បីឱ្យ ចេញទឹកដោះ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឌើម សេសាន បានម៉ៃ កំភុន និងភូមិកន្ទុយគោ ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១០ ស.ម
    ក្រឡា ២.៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក)
    ក្រឡា ៨ - ១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា រដូវទឹកឡើង ។
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។
  - មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៦ -១០ ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ តុលា
  - មានអ្នកលួចឆក់ចាប់ពីខែ មិនា ដល់ខែ ឧសភា ពេលទឹកស្រកខ្លាំង



**៣.១៦.២ អន្លង់យាយហៅ**

**ក. ទីតាំង**

អន្លង់យាយហៅ មានទីតាំងក្នុងភូមិបានម៉ៃ ឃុំកំភុន ដែលស្ថិតនៅចន្លោះកណ្តាលនៃខ្សែទឹកពីក្រោមឡើងមកលើបើប្រៀបធៀបទៅនឹងអន្លង់ទាំងបីដែលមាននៅក្នុងភូមិ ។ ហើយនៅត្រង់ទីតាំងនៃអន្លង់មានថ្មប៉ប្រះទឹក និងមានថ្មដុះឡើងខ្ពស់នៅកណ្តាលអន្លង់ ។ ចំណែកឯនៅគែមអន្លង់ខាងជើងជាប់ច្រាំងទន្លេមានថ្មដុះជាជួរជាប់ទៅនឹងកូនកោះមួយតូចហៅថា កោះយាយមីត គេនាំគ្នាហៅអន្លង់យាយហៅ ទៅតាមទីតាំងអន្លង់ ព្រោះអន្លង់នេះស្ថិតនៅចំណុចកំពង់យាយហៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១៦៧៧០
- អរដោនេ =១៤៩៨៥០៦
- រយៈកំពស់ = ៤១ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៦ម ឆ្នាំ ២០០៦ = ៣ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២២០ម x ១០០ម ឆ្នាំ ២០០៦ =២២០x ១០០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង :

នៅច្រាំងទន្លេខាងជើងក្បែរមាត់អន្លង់មានផ្ទាំងថ្ម និងជ្រុងខាងត្បូងមានខ្សាច់ដុះច្រើន តែពុំ-មានរុក្ខជាតិដុះច្រើនណាស់ណាទេ ។ អន្លង់នេះមានទីតាំងនៅខាងលើអន្លង់យាយមីត តែកន្ទុយអន្លង់យាយហៅ និងក្បាលអន្លង់យាយមីតនៅជាប់គ្នា ហើយអន្លង់នេះមានអូរមួយទៀតហូរចាក់ហៅថា អូរផាកកាញូន ( អូរម្អម) និងមានល្បឿនទឹកហូរលឿនមធ្យមត្រង់អន្លង់ ។

♦ រដូវវស្សា :

នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចឱ្យយើងមើលឃើញផ្ទាំងថ្ម និងខ្សាច់បានឡើយ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ១០ ម៉ែត្រ ។

**ឃ. ប្រភេទសត្វ**

-ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង,ត្រីក្អែក,ត្រីកាហែ,ត្រីឆ្ពិន, ត្រីឆ្ដូញ, ត្រីកញ្ជ្រូក, ត្រីស្លឹកឫស្សី, ត្រីប៉ាកក់,ត្រីកែស, ត្រីពោ, កូនត្រីខ្យា ,កូនត្រីខ្នាន់, ត្រីត្រសក់, ត្រីកញ្ចុះក្ដោង ,ត្រីប៉ាវ៉ា និងមានប្រភេទត្រីខ្ទីងចំឡែក ។

- ប្រភេទសត្វស្លាបរួមមាន : កុក, លលកទឹក, ប្រវឹក និងទាទឹក ។
- ប្រភេទល្មូន : ពស់,អណ្ដើក, កន្ធាយ និងអន្សង ។
- ប្រជាពលរដ្ឋចូលចិត្តទៅរាវ ខ្យង , ខ្ចៅ និងគ្រំនៅទីនោះ ។

**ង. ប្រភេទរុក្ខជាតិ**

នៅចំណុចអន្លង់ច្រាំងទន្លេមានដើមកុកហែ ដើមរៃ,ត្រស់,ដើមរាំងទឹក,ដើមថ្វាន់=កុកគុម្ព គេយកវាទៅធ្វើជ្រក់ហូប,ដើមក្ដុលគេយកទៅធ្វើថ្នាំលឿង លាបពេលរលាកភ្លើង, ល្វាគេយកទងល្វា ទៅស្ទោទឹកជីកដើម្បីអោយចេញទឹក ដោះ និងដើមឫស្សី ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រជាជនតែងតែនាំគ្នាទៅប្រមូលយកថ្ម និងខ្សាច់មកចាក់ធ្វើជើងសសរផ្ទះ គ្រឹះ ចាក់អាងទឹក និងចាក់សាប ។
- ប្រភពអ្នកនេសាទ: មកពីភូមិសាមឃួយ ហាងសារ៉ាត បាឌើម សេសាន បានម៉ៃ និងភូមិកំភុន ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១០ ស.ម
    - ក្រឡា ២,៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក) ។
    - ក្រឡា ៨ - ១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា (រដូវទឹកឡើង) ។
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។
  - មងបណ្ដែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើ ក្រឡាលេខ៦ -១០ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែតុលា ។



**៣.១៦.៣ អន្លង់សាលា**

**ក.ទីតាំង**

អន្លង់សាលា មានទីតាំងក្នុងភូមិបានម៉ៃ ឃុំកំភុន នៅជាប់ច្រាំងទន្លេខាងត្បូងបើប្រៀបធៀបទៅនឹងអន្លង់យាយហៅ គឺនៅត្រើយម្ខាងម្នាក់ហើយខណ្ឌដោយខ្សាច់នៅចំកណ្ដាល ។ ប្រជាពលរដ្ឋតែងតែហៅត១គ្នារៀងមកទៅតាមលក្ខណៈ និងទីតាំងរបស់អន្លង់ដែលនៅទល់មុខសាលា

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១៧២៦១
- អរដោនេ = ១៤៩៨២៥១
- រយៈកំពស់ = ៤៦ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ =៦ម ឆ្នាំ ២០០៦ = ស្មើបាត
- ទំហំ : មុនឆ្នាំ ១៩៩៥ =៦០ម x ៤០ម ឆ្នាំ ២០០៦ = បាត់ស្ថានភាព

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធទៅដោយខ្សាច់ និងមានដើមឈើដុះមួយចំនួននៅតាមច្រាំងទន្លេ ។

នៅក្បាលអន្លង់មានអូរមួយហូរចាក់ហៅថា អូរតាសិង ចាប់ពីខែមករា ដល់ខែ ឧសភា ផ្ទៃទឹក កំពស់ ១ ម ទៅ ២ ម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ធ្វើឱ្យយើងមិនអាចមើលឃើញខ្សាច់ដែលដុះនៅជុំវិញមាត់អន្លង់ ។ កំពស់ទឹកនៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើង ដល់ ១០ម៉ែត្រ ។ ដោយអន្លង់នេះសព្វថ្ងៃត្រូវខ្សាច់ហូរលប់បាត់បង់ស្ថានភាពអស់ទៅធ្វើអោយយើងមិនអាចបរិយាយបានក្បោះក្បាយឡើយ ។

*(កាលបរិច្ឆេទ ២៤ មេសា ២០០៦)*

## ៣.១៧ ភូមិកំភុន ឃុំកំភុន

ភូមិកំភុន ជាភូមិមួយស្ថិតនៅតាមបណ្តោយដងទន្លេសេសាន ឃុំកំភុន មានចំងាយផ្លូវគោក ១៦គ.ម ផ្លូវ ទឹក១៦គ.ម ពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅប្រមាណ ៣១០ គ្រួសារមាន ៣០៤ខ្នងផ្ទះ ចំនួនប្រជាពលរដ្ឋសរុប ១៥៧៧នាក់ ស្រី៨២៨នាក់ ។ ភូមិនេះមានអន្លង់ចំនួន ៤កន្លែងបើយើងរាប់ពីក្រោមខ្សែទឹកឡើងទៅលើ ហើយអន្លង់ទាំងអស់នោះមានអន្លង់កំពង់ចំឡង អន្លង់យាយឡិក អន្លង់តាម៉ៅ និងអន្លង់ចាប ។ ក្នុងចំណោមអន្លង់ទាំងបួននេះពុំមានការបាត់បង់ស្ថានភាពអន្លង់ទេ តែត្រូវបានបាត់បង់ជំរៅអស់មួយចំនួន ។



**តារាង ៦ ឈ្មោះអន្លង់ភូមិកំភុន ឃុំកំភុន**

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំ ២០០៦ (ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | កំពង់ចំឡង | ៨ | ៤.៨ | ១០០ | ៥០ | ៨០ | ៥០ | ១៤៩៩១៨២ | ០៦១៨០៧០ |
| ២ | យាយលិក | ៣០ | ៣.២ | ២០០ | ១០០ | ២០០ | ៨០ | ១៤៩៩៦០៣ | ០៦១៩០៧៧ |
| ៣ | តាម៉ៅ | ២០ | ៣.២ | ៨០ | ៦០ | ៨០ | ២៥ | ១៤៩៩១៩២ | ០៦២០៦១៩ |
| ៤ | អូរចាប | ៣០ | ១២.៥ | ២០០ | ១៥០ | ១៥០ | ៥០ | ១៤៩៩០០៧ | ០៦២១២៦៩ |

### ៣.១៧.១ អន្លង់កំពង់ចំឡង (ថាខាម)

**ក. ទីតាំង**

អន្លង់កំពង់ចំឡង មានទីតាំងស្ថិតនៅទល់មុខភូមិកំភុន ឃុំកំភុន នៅផ្នែកខាងក្រោមនៃខ្សែទឹកពីក្រោមទៅលើបើប្រៀបធៀបទៅនឹងអន្លង់ទាំងបួននេះ ។ ត្រង់ទីតាំងអន្លង់មានផ្ទាំងថ្មនៅមាត់អន្លង់ផ្នែកខាងកើត ហើយតែមអន្លង់ខាងជើងជាប់ច្រាំងទន្លេ និងមានថ្មដុះជាជួរ ។ គេតែងនាំគ្នាហៅអន្លង់កំពង់ចំឡង (ថាខាម) ទៅតាមទីតាំងអន្លង់ ព្រោះអន្លង់នេះស្ថិតនៅចំណុចកំពង់ចំឡងត្រើយខាងជើងឆ្លោះទៅឃុំស្ដៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១៨០៧០
- អរដោនេ =១៤៩៩១៨២
- រយៈកំពស់ =៣៧ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៨ម ឆ្នាំ ២០០៦ = ៤,៨ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =១០០ម x ៥០ម ឆ្នាំ ២០០៦ =៨០ x ៥០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : មានថ្មប៉ប្រះទឹកនៅក្បែរមាត់អន្លង់ ច្រាំងទន្លេខាងជើង និងមានខ្សាច់ដុះច្រើននៅជ្រុងខាងត្បូង តែពុំមានរុក្ខជាតិដុះទេ ។ អន្លង់នេះស្ថិតនៅខាងក្រោមអន្លង់យាយលិក តែកន្ទុយអន្លង់ និងក្បាលអន្លង់ជាប់គ្នា ។ ហើយអន្លង់នេះមានអូរតាខាំហូរកាត់ ជាពិសេសខាងកន្ទុយអន្លង់មានថ្មបាយក្រៀមផងដែរ ហើយល្បឿនទឹកហូរល្បឿនមធ្យម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មើលមិនឃើញផ្ទាំងថ្ម និងខ្សាច់ដែលដុះនោះទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែតុលា មានកំពស់ពី ៩-១០ ម៉ែត្រ ។



**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្ពិន, ត្រីឆ្លូញ, ត្រីប៉ាវ៉ា, ត្រីស្លឹកឫស្សី, ត្រីកញ្ជ្រូក, ត្រីប៉ាកក់, ត្រីកែស, ត្រីពោ, កូនត្រីខ្យា, កូនត្រីខ្ទាន់, ត្រីត្រសក់ និងត្រីកញ្ចុះក្ដោង ។
- ប្រភេទសត្វស្លាបរួមមាន : កុក, លលកទឹក, ប្រវឹក, ទាទឹក, អញ្ចាត និងកដប ។
- ប្រភេទល្មូន : ពស់, អណ្ដើក, កន្ធាយ , អន្សង, ខ្មៅ និងគ្រំ ។

**ង. ប្រភេទរុក្ខជាតិ :** នៅច្រាំងទន្លេជិតអន្លង់មានដើម កុកហែ, ដើមរៃ, ដើមត្រស់, ដើម-រាំងទឹក, ដើម ថ្វាន់(កុកគុម្ព), ដើមក្ដុល, ល្វា និងដើមឫស្សីអង្កោល ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឌើម បានម៉ៃ កំភុន ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១០ ស.ម
  - ក្រឡា ២,៥ -៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)
  - ក្រឡា៨ -១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែវិច្ឆិកា(រដូវទឹកឡើង)
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។
  - មង : ក្រឡា ២ស.ម ទៅ ៦ស.ម ចាប់ពីខែធ្នូ ទៅខែឧសភា ។
  - មងបណ្ដែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡា លេខ ៦-១០ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ ខែតុលា ។

### ៣.១៧.២ អន្លង់យាយលិត

**ក. ទីតាំង**

អន្លង់យាយលិក មានទីតាំងក្នុងភូមិកំភុន ឃុំកំភុន នៅខាងលើអន្លង់កំពង់ចំឡង (បើគិតតាមខ្សែទឹកពីក្រោមឡើងទៅលើ) ខាងជើងស្ថិតនៅជាប់ច្រាំងទន្លេ ។ អន្លង់នេះខុសពីអន្លង់ផ្សេងទៀតដែលនៅក្នុងភូមិជាមួយវាត្រង់អត់មានរុក្ខជាតិ អត់មានថ្មនៅចំណុចអន្លង់ទេ ប៉ុន្តែមានខ្សាច់ដុះនៅខាងត្បូងឆៀងខាងកើតអន្លង់។ ចំពោះប្រវត្តិរឿងរបស់អន្លង់នេះគ្មានអ្នកភូមិណាម្នាក់បានដឹងទេ ដូចនេះគេគ្រាន់តែនាំគ្នាហៅឈ្មោះអន្លង់នេះតៗគ្នារហូត មកដល់សព្វថ្ងៃ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦១៩០៧៧
- អរដោនេ =១៤៩៩៦០៣
- រយៈកំពស់ = ៤៥ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៣០ម ឆ្នាំ ២០០៦ = ៣.២ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ១០០មឆ្នាំ ២០០៦ = ២០០ x ៨០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅច្រាំងទន្លេខាងជើងក្បែរមាត់អន្លង់មានគុម្ពឬស្សីជាច្រើន និងនៅជ្រុងខាងត្បូងមានខ្សាច់ដុះច្រើនហើយមានចរន្តទឹកហូរលឿនមធ្យមជាប់អន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ដោយមិនអាចមើលឃើញខ្សាច់ដែលដុះទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា ឡើងដល់ ១០ម៉ែត្រ ។

**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្កិន, ត្រីឆ្លូញ, ត្រីប៉ាវ៉ា, ត្រីស្លឹកឫស្សី,ត្រីកញ្រ្ជូក, ត្រីប៉ាកក់, ត្រីកែស,ត្រីពោ, កូនត្រីខ្យា, កូនត្រីខ្មាន់, ត្រីត្រសក់ និងត្រីកញ្ចុះក្តោង ។
- ប្រភេទសត្វស្លាបរួមមាន : កុក, លលកទឹក,ប្រវឹក និងទាទឹក ។
- ប្រភេទល្មូន : ពស់, អណ្តើក, កន្ធាយ, អន្សង , ខ្ចៅ និងគ្រំ ។

**ង. ប្រភេទរុក្ខជាតិ**

នៅចំណុចអន្លង់ច្រាំងទន្លេមានដើមកុកហែ ដើមរៃ, ដើមត្រស់, ដើមរាំងទឹក, ដើមថ្ងាន់ = កុកគុម្ព, ដើមក្តុល, ល្វា, ដើមឫស្សី និងដើមស្រឡៅ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឡើម បានម៉ៃ កំភុន ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១០ ស.ម
  - ក្រឡា ២.៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)
  - ក្រឡា៨-១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា(រដូវទឹកឡើង)
  - សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។
  - មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡា លេខ៤-៩ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ តុលា ។

### ៣.១៧.៣ អន្លង់តាម៉ៅ

**ក. ទីតាំង**

អន្លង់តាមៅ មានទីតាំងនៅក្នុងភូមិកំភុន ឃុំកំភុន មានចំងាយ ៣គ.ម ពីភូមិ ។ នៅត្រង់ទីតាំងអន្លង់មានថ្មប៉ប្រះទឹក និងផ្ទាំងថ្មដុះឡើងខ្ពស់ស្មេកស្មះ រីឯនៅតែមអន្លង់ខាងត្បូងមានកូនកោះដុះជាប់ទីនោះ ។ កាលពីមុនមានតាម្នាក់ឈ្មោះ តាម៉ៅគាត់បានមករស់នៅក្បែរអន្លង់នឹងជួយថែរក្សាព្រៃដែលដុះក្បែរនោះទើបប្រជាជននាំគ្នា ហៅទៅតាមឈ្មោះរបស់តាម៉ៅនោះរៀងរហូតមក ។ តាមសំដីរបស់អ្នកភូមិថានៅចំណុចអន្លង់នោះប្រកាន់ណាស់ បើមានអ្នកថតរូបភាពមិនសុំម្ចាស់ទឹកដី គឺថតមិនជាប់ទេដេរក៏មិនបានដែរធ្វើឱ្យឮសូរឃ្លង១ដែលធ្វើអោយប្រជាជនមួយចំនួនខ្លាច និងមានថ្មធំនៅក្រោមដើមឈើទាលសំរាប់គេអង្គុយលេង ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦២០៦១៩
- អរដោនេ = ១៤៩៩១៩២
- រយៈកំពស់ = ៤៤ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ២០ម ឆ្នាំ ២០០៦ = ៣.២ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =៨០ម x ៦០ម ឆ្នាំ ២០០៦ =៨០ x ២៥ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅក្បែរមាត់អន្លង់ជ្រុងខាងជើងមានផ្ទាំងថ្មធំ១ និងនៅជ្រុងខាងត្បូងមានខ្សាច់ខ្លះ១ ជាពិសេសមានផ្ទាំងថ្មដេរដាស និងមានរុក្ខជាតិដុះច្រើន ហើយត្រង់ចំណុចអន្លង់ចរន្តទឹកហូរលឿន ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិន អាចមើលឃើញផ្ទាំងថ្ម និងខ្សាច់បានទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ១០ម៉ែត្រ ។



**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្កិន, ត្រីឆ្ពួញ, ត្រីប៉ាវ៉ា, ត្រីស្លឹកឫស្សី,ត្រីកញ្ជ្រូក, ត្រីប៉ាកក់ , ត្រីកែស, ត្រីពោ, កូនត្រីខ្យា, កូនត្រីខ្ទាន់, ត្រីត្រសក់,ត្រីកញ្ចុះក្តោង និងមានប្រភេទត្រីខ្ចឹងចំឡែក ។
- ប្រភេទសត្វស្លាបរួមមាន : កុក , លលកទឹក ,ប្រវឹក, ទាទឹក និងមាន់ទឹក ។
- ប្រភេទល្មូន : ពស់, អណ្តើក, កន្ធាយ, អន្សង, ខ្យង, ខ្ចៅ និងគ្រំ ។
- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ និងសត្វស្វា ។

**ង. ប្រភេទរុក្ខជាតិ**

នៅច្រាំងទន្លេក្បែរអន្លង់មានដើមកុកហែ ដើមរៃ,ដើមត្រស់,ដើមរាំងទឹក,ដើមថ្វាន់=កុកគុម្ព, ដើមក្តុល,ល្វា, ដើមឫស្សី, ឈើទាល, ផ្ដៀក, ពពែល, គគីរ, ចំបក់, កកោះ, បេង, ស្តៅ និង ដើមក្រឡាញ់ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឌើម សេសាន បានម៉ៃ កំភុន បានប៊ុង ភ្លុក ហាងឃោសួន និងភូមិហាងឃោបាន ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១៣ ស.ម
  - ក្រឡា ២.៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក )
  - ក្រឡា ៨-១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា( រដូវទឹកឡើង)
- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។
- មង : ក្រឡា ២.ស.មទៅ ៦ស.ម ប្រើនៅ រដូវសម្រក ។
- មងបណ្តែត :នេសាទចាប់ពីខែកញ្ញា ដល់ខែវិច្ឆិកា ដោយប្រើក្រឡាលេខ៤-១០ស. ម
- ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ តុលា ។

### ៣.១៧.៣ អន្លង់អូរចាប

**ក. ទីតាំង**

អន្លង់អូរចាប មានទីតាំងនៅក្នុងភូមិកំភុន ឃុំកំភុន ចំងាយ ៤គ.ម ពីភូមិ ។ អន្លង់នេះនៅឆ្ងាយ និងមានជំរៅជ្រៅជាងគេបើប្រៀបធៀបទៅនឹងអន្លង់ទាំងបួននៅក្នុងភូមិ ។ នៅត្រង់អន្លង់មានថ្មប៉ប្រះទឹក និងនៅគែមអន្លង់ខាងជើងមានថ្មធំៗ ដុះជាជួរឡើងខ្ពស់រដិបរដុបច្រើនប្រៀបដូចជាកូនកោះ និងមានចរន្តទឹកហូរខ្លាំងនៅរដូវសម្រក ។ ដោយសារអន្លង់នេះស្ថិតនៅជាប់នឹងអូរចាបគេនាំគ្នាហៅអន្លង់នេះទៅតាមឈ្មោះអូរនោះត។ គ្នារហូតមកដល់បច្ចុប្បន្ន ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦២១២៦៩
- អរដោនេ =១៤៩៩០០៧
- រយៈកំពស់ = ៤៤ម

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៣០ម ឆ្នាំ ២០០៦ = ១២,៥ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ១៥០ម ឆ្នាំ ២០០៦ =១៥០ម x ៥០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅច្រាំងទន្លេក្បែរមាត់អន្លង់ខាងជើង និងខាងត្បូងមានផ្ទាំងថ្មធំៗ និងនៅកន្ទុយអន្លង់ប៉ែកខាងជើងមានខ្សាច់ និងរុក្ខជាតិដុះច្រើនហើយមានល្បឿនទឹកហូរលឿននៅរដូវសម្រក ។

♦ រដូវវស្សា : កំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ ។ កំពស់ទឹកនៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ១០ ម៉ែត្រ ពីមាត់អន្លង់ ។



**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីកាហែ, ត្រីឆ្កិន, ត្រីឆ្ពួញ, ត្រីប៉ាវ៉ា, ត្រីស្លឹកឫស្សី, ត្រីកញ្រ្ជូក, ត្រីប៉ាកក់, ត្រីកែស, ត្រីពោ, កូនត្រីខ្យា, កូនត្រីខ្នាន់, ត្រីត្រសក់ និងត្រីកញ្ចុះក្តោង ។
- ប្រភេទសត្វស្លាបរួមមាន :កុក, លលកទឹក, ប្រវឹក, ទាទឹក, ក្អែកទឹក, សេក ។ ល ។
- ប្រភេទល្មូន : ពស់, អណ្តើក, កន្ធាយ, អន្សង, ខ្យង, ខ្ទៅ និងគ្រំ ។
- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ ។

**ង. ប្រភេទរុក្ខជាតិ**

នៅច្រាំងទន្លេត្រង់អន្លង់ មានដើមរាំងភ្នំ, ដើមរ៉ៃ, ដើមត្រស់, ដើមរាំងទឹកគេយកវាទៅធ្វើ-អន្ទក់, ដើមក្តុល គេយកទៅធ្វើថ្នាំលឿងលាបរលាកភ្លើង, ល្វាគេយកទងល្វាទៅស្ងោរទឹកផឹកដើម្បីអោយចេញទឹកដោះ, ដើម ឫស្សី, ដើមត្បែង, ដើមស្រឡៅ, ដើមស្តៅ, ដើមកកោះ និងដើមពពេល ។ ល ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឌើម សេសាន បានម៉ៃ កំភុន បានប៊ុង និងភូមិហាងឃោសួន ។ ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១០ ស.ម
  - ក្រឡា ២,៥ - ៤ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)
  - ក្រឡា ៨- ១៤ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា(រដូវទឹកឡើង)
- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។
- មង : ក្រឡា២ ស.ម ទៅ ៦ស.ម ចាប់ពីខែ ធ្នូ ទៅ ខែឧសភា
- មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ៦-១០ស.ម
- ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ តុលា

*(កាលបរិច្ឆេទ ១៧ ឧសភា ២០០៦)*

## ៣.១៨ ភូមិបានប៉ុង ឃុំភ្លុក

ភូមិបានប៉ុង ស្ថិតនៅឃុំភ្លុក តាមបណ្តោយដងទន្លេសេសានមានចំងាយទាំងផ្លូវគោក និងផ្លូវទឹកប្រមាណ ២៤គ.ម ពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅ ៥៦គ្រួសារ ស្មើនឹងផ្ទះ ៤៦ ខ្នង មានប្រជាពលរដ្ឋសរុប ២៤៩នាក់ ស្រី ១៣១នាក់ *(ទិន្នន័យភូមិភ្លុក, ២០០៥)* ។ នៅក្នុងភូមិមានអន្លង់ចំនួន ៤កន្លែង ។ បើយើងរាប់ពីក្រោមខ្សែទឹកឡើងទៅលើមាន អន្លង់ផ្តៅ អន្លង់ថ្ពុះ អន្លង់ក្លែងពណិ និងអន្លង់អ្នកតា ។ ក្នុងចំណោមអន្លង់ទាំង ៤ នេះមិនមានអន្លង់ណាមួយរាក់អស់ស្ទើបាតទន្លេនោះទេ គ្រាន់តែរាក់អស់មួយចំនួនប៉ុណ្ណោះ ។

### ៣.១៨.១ អន្លង់ផ្តៅ (ប៉ុងខាយ)

**ក. ទីតាំង**

អន្លង់ផ្តៅ មានទីតាំងក្នុងភូមិបានប៉ុង ឃុំភ្លុកនៅជាប់កន្ទុយភូមិ បើគិតតាមខ្សែទឹកហូរពីក្រោមឡើងមកលើ ។ ស្ថិតនៅភាគខាងក្រោមនៃខ្សែទឹក និងមានជំរៅបច្ចុប្បន្ន ៣,៥ម មានល្បឿនទឹកហូរខ្លាំងនៅរដូវសម្រក ហើយនៅត្រង់ទីតាំងអន្លង់មានថ្មប៉ប្រះទឹកខាងជើងជាប់នឹងច្រាំងទន្លេ (ព្រោះអន្លង់នេះនៅជាប់នឹងច្រាំងទន្លេ) ។ ប្រជាជននៅក្នុងភូមិតែងតែហៅត។គ្នាមកដល់បច្ចុប្បន្នថា អន្លង់ផ្តៅ គឺដោយសារមានដើមផ្តៅដែលដុះនៅតាមច្រាំងទន្លេច្រើន ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦២២៤៨៥
- អរដោនេ = ១៤៩៩៥៧៤
- រយៈកំពស់ =

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៥ម ឆ្នាំ ២០០៦ = ៣,៥ ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ២០០ ឆ្នាំ ២០០៦ = ២០០ម x ១០០ម



តារាង៧ ឈ្មោះអន្លង់នៅភូមិបានប៉ុង ឃុំភ្លុក

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំ ២០០៦ (ម) | | ភូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | ផ្តៅ | ៥ | ៣.៥ | ២០០ | ២០០ | ២០០ | ១០០ | ១៤៩៩៥៧៤ | ០៦២២៤៨៥ |
| ២ | ថ្ពុះ | ២០ | ១៣ | ៣០០ | ១០០ | ២០០ | ៧០ | ១៤៩៩៥០៤ | ០៦២៣០៩១ |
| ៣ | អ្នកតា | ១៥ | ៧.៥ | ២០០ | ១៥០ | ២០០ | ១៥០ | ១៤៩៩៥០៩ | ០៦២៣៣៩៥ |
| ៤ | ក្លែងពណិ | ២០ | ០.៧ | ១០០ | ៥០ | ៥០ | ៣០ | ១៤៩៩៥២៣ | ០៦២៤០០៧ |

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅច្រាំងទន្លេខាងលិចក្បែរមាត់អន្លង់មានថ្មប៉ប្រះទឹក និងមានរុក្ខជាតិដុះខ្លះៗនៅកន្ទុយអន្លង់ ហើយចរន្តទឹកហូរលឿន ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញផ្ទាំងថ្មបានទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងរហូតដល់ទៅ ១០ម៉ែត្រ ។

**ឃ. ប្រភេទសត្វ**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល,ត្រីឆ្លាំង, ត្រីក្អែក, ត្រីលេញ, ត្រីឆ្កិន, ត្រីឆ្ពួញ, ត្រីក្រាយ, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, កូនត្រីខ្យា, កូនត្រីខ្មាន់, ត្រីត្រសក់, ត្រីត្រនេល, ត្រីឆ្តោ និងត្រីក្រពើ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ប្រវឹក, ទាទឹក, ក្អែកទឹក, ក្អែក, មាន់ទឹក ។ ល ។

- ប្រភេទល្មូន : ពស់, អណ្តើក, អន្សង, ខ្យង, ខ្ចៅ និងគ្រុំ ។

- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ

**ង. ប្រភេទរុក្ខជាតិ**

នៅចំណុចអន្លង់ពុំមានរុក្ខជាតិដុះច្រើនទេ តែនៅច្រាំងទន្លេជាប់អន្លង់មានដើមរាំងភ្នំ, ដើមរៃ ដើមត្រស់, ដើមក្តុល ដើមរាំងទឹក, ដើមល្វា, ដើមឫស្សី, ដើមត្បែង, ដើមស្រឡៅ, ដើមស្តៅ, ដើមផ្តៅ, ដើមកកោះ, ដើមពពេល និងដើមពង្រ ។ ល ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ មកពីភូមិ សាមឃួយ ហាងសាវ៉ាត បាឡើម កំភុន បានប៊ុង ស្រែពោ និងភូមិហាងឃោសួន ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ១.៥ ស.ម រហូតទៅដល់ ១០ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

-ក្រឡា២,៥-៤ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា( រដូវទឹកសម្រក)



- ក្រឡា៨-១៤ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា( រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា ។ កាលពីមុនសន្ទូចប្រើប្រាស់ផ្លែលេខ ៥ ទៅលេខ ៨ ប៉ុន្តែបច្ចុប្បន្នប្រើលេខ ១០-១២-១៤ វិញ ។

- មង : ក្រឡា ២ស.ម ទៅ ៦ស.ម ចាប់ពីខែ ធ្នូ ដល់ខែ ឧសភា

- មងបណ្តែត : នេសាទចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ដោយប្រើក្រឡាលេខ ៦ - ១០ស.ម ។

- ចាន់ : នេសាទចាប់ពីខែ មិថុនា ដល់ខែ តុលា ។

**៣.១៨.២ អន្លង់ថ្មពុះ**

**ក. ទីតាំង**

អន្លង់ថ្មពុះ ស្ថិតនៅជាប់នឹងភូមិបានប៊ុង ឃុំភ្លុក ។ អន្លង់នេះមានថ្មមួយដុំនៅកណ្តាលព័ទ្ធជុំវិញទៅដោយទឹក ។ អន្លង់នេះនៅចំកណ្តាលទន្លេហើយមានជំរៅបច្ចុប្បន្ន ១៣ម ។ អន្លង់ថ្មពុះសំបូរត្រីជាងគេតាំងពីមុនរហូតដល់បច្ចុប្បន្ននេះ ព្រោះប្រជាពលរដ្ឋគាត់នាំគ្នាថែរក្សាអន្លង់នេះមិនអោយអ្នកណាមកនេសាទនៅចំណុចអន្លង់នេះឡើយ ។ ឈ្មោះអន្លង់ថ្មពុះ គឺគេហៅទៅតាមចរន្តទឹកហូរតែប៉ុណ្ណោះ ព្រោះនៅត្រង់អន្លង់នេះទឹកហូរព្រួស្នូរខ្លាំងនៅរដូវវស្សា ទើបប្រជាជនហៅទៅតាមលក្ខណៈនៃស្នូរទឹករហូតមកដល់បច្ចុប្បន្ន ។

**<u>ចំណុចនៅលើ GPS :</u>**

- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ២០ម ឆ្នាំ ២០០៦ = ២០០ម x ២០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : យើងអាចមើលឃើញថ្មខ្លះៗ និងកោះតូចៗនៅជុំវិញនៃអន្លង់ ។ ក្រៅពី-នោះនៅជុំវិញអន្លង់ក៏មាន ដើមរំ និងដើមផ្កាអំណ្ដែងមួយៗនៅតាមច្រាំងអន្លង់ដែរ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញថ្ម និងអ្វីផ្សេងៗទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា ឡើងដល់ ៩,៣០ម៉ែត្រ ( ឡើងលើជំរៅអន្លង់ ) ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្កិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, ត្រីឆ្ពោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ,ត្រីរមាស, ត្រីប៉ាវ៉ា ត្រីក្រាយ, ត្រីប៉ាញ៉ន, ត្រីព្រួល, ខ្យង, ខ្ចៅ និងគ្រំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និង សេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្រង, ថ្លែន, បង្កួយ, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស និងឆ្កែព្រៃ ។

**ង. ប្រភេទរុក្ខជាតិ :**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអំណ្ដែង គុម្ពរំ ហើយនៅច្រាំងទន្លេទាំងសងខាង-មានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរំ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្ពៅ, ដើមផ្តៅ, ដើមកកោះ, ដើមពពេល, ដើមពង្រ និងដើមឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិភ្លុក ភូមិបានប៊ុង ភូមិសាមឃួយ ភូមិហាងសាវ៉ាត ភូមិកំភុន ភូមិបាចុង ភូមិស្រែពោធិ៍ ភូមិស្រែឫស្សី ភូមិហាងឃោសួន ស្រែគរ១ និងភូមិស្រែគរ២ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

-ក្រឡា ៨ -១២ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ( រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង : ក្រឡា ៧ ស.ម ទៅ ៨ ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា គប់គ្រាប់ និងឆក់ ។

**៣.២០.៤ អន្លង់តាលី**

**ក. ទីតាំង**

អន្លង់តាលី ស្ថិតនៅខាងក្រោមភូមិស្រែគរ១ ចំងាយ ៤ គ.ម ពីភូមិ និងមានល្បឿនទឹកហូរខ្លាំងនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងទ្រវែងនៅតាមបណ្តោយទន្លេ បើនិយាយតាមខ្សែទឹកពីក្រោមទៅលើ ហើយដែលនៅចំកណ្តាលទន្លេ ។ នៅរដូវប្រាំង មានលក្ខណៈស្មុគស្មាញលំបាកក្នុងការធ្វើដំណើរទៅមក ដោយសារមានផ្ទាំងថ្មធំៗដេរដាសពាសពេញផ្ទៃទន្លេ ។ តាមសំដីរបស់អ្នកភូមិដែលរស់នៅទីនោះបាននិយាយថា កាលពីដើមតាលីគាត់បានទៅធ្វើស្រែនៅត្រង់ចំណុចអន្លង់នេះ និងនៅខាងក្បាលអន្លង់មានជួរមួយដែលមានឈ្មោះថា ជួរតាលី ចំណែកនៅកន្ទុយអន្លង់ក៏មានជួរដែរ គឺជួរព្រះស្គ ។ ដោយសារមានដំណើររឿង និងលក្ខណៈពីធម្មជាតិរបស់វា ជាហេតុធ្វើអោយប្រជាពលរដ្ឋនាំគ្នាហៅអន្លង់នេះទៅឈ្មោះនោះ តរៀងមកដល់បច្ចុប្បន្ននេះ ។



**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤២៦៥៣
- អរដោនេ =១៥០៤១១៧
- រយៈកំពស់ = ៥៧,១ម

**ខ. លក្ខណៈរូប**

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ៨ម ឆ្នាំ ២០០៦ = ៤,៥ម
- ទំហំ :មុនឆ្នាំ ១៩៩៥ =១៥០ម x ៥០ម ឆ្នាំ ២០០៦ = ១៥០ម x ៥០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : មានថ្មធំៗនៅខាងស្តាំ ហើយជួរនៅខាងក្បាល និងខាងកន្ទុយនៃអន្លង់ ។ នៅជុំវិញអន្លង់មានដើមរៃ និងផ្កាអណ្តែងមួយៗនៅតាមច្រាំងអន្លង់ និងមានថ្មរដិបរដុបច្រើន

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញថ្ម និងអ្វីផ្សេងៗទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា ឡើងដល់ ៩,៣០ម៉ែត្រ ( ឡើងលើជំរៅអន្លង់) ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្កិន, ត្រីស្លឹកឫស្សី, ត្រីកែស,ត្រីពោ, ត្រីឆ្ពោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ត្រីប៉ាញ៉ន, ត្រីព្រួល, ខ្យង, ខ្ចៅ និងគ្រុំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និងសេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្រូង, ថ្លែន, បង្កួយ, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស និងឆ្កែចចក ។

**ង. ប្រភេទរុក្ខជាតិ :**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអណ្ដែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាង-មានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមដើមក្ដុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្ដៅ, ដើមផ្ដៅ, ដើមកកោះ, ដើម-ពពេល, ដើមពង្រ និងដើមឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិភ្លុក ភូមិសាមឃួយ ភូមិកំភុន ភូមិបានប៊ុង ស្រែគរ១ ភូមិស្រែពោធិ៍, ភូមិបាចុង ភូមិស្រែឫស្សី ភូមិហាងឃោសួន ស្រែគរ២ និងភូមិ-ហាងសាវ៉ាត ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

-ក្រឡា ៨ -១២ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ( រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង : ក្រឡា ៧ ស.ម ទៅ ៨ ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា គប់គ្រាប់បែក និងឆក់ ។

**៣.២០.៥ អន្លង់សាលា**

**ក. ទីតាំង :**

អន្លង់សាលា ស្ថិតនៅខាងក្រោមភូមិស្រែគរ១ ចំងាយ ៣ គ.មពីភូមិ និងមានល្បឿនទឹកហូរលឿនមធ្យមនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងមូលនៅជិតច្រាំងទន្លេខាងស្ដាំ



បើនិយាយតាមខ្សែទឹកពីក្រោមឡើងទៅលើនិងមានថ្មជុំវិញ ។ នៅរដូវប្រាំងមានលក្ខណៈស្មុគស្មាញលំបាកក្នុងការធ្វើដំណើរទៅមកព្រោះមានផ្ទាំងថ្មធំៗ ដេរដាសពាសពេញផ្ទៃទន្លេ ។ ប្រជាពលរដ្ឋតែងនាំគ្នាហៅអន្លង់នេះទៅតាមលក្ខណៈពីធម្មជាតិដូចជា មានជួរមួយនៅខាងក្បាលដែលមានឈ្មោះថា ជួរប៉ាកាន់ និងនៅកន្ទុយអន្លង់មានជួរតាលី ។ ដោយហេតុនេះហើយទើបគេហៅបែបនេះរៀងមកដល់បច្ចុប្បន្ននេះ ( ហៅពីដូនតាមកមិនចាំប្រវត្តិច្បាស់ ) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៤០៣៤

- អរដោនេ = ១៥០៤១៦៥

- រយៈកំពស់ = ៥៧ម

**ខ. លក្ខណៈរូប**

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៦ម

- ទំហំ :មុនឆ្នាំ ១៩៩៥ =១៥០ម x ១៥០ម ឆ្នាំ ២០០៦ = ១៥០ម x ១៥០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : យើងអាចមើលឃើញមានថ្មដេរដាសពេញផ្ទៃទន្លេ និងនៅជុំវិញអន្លង់មានដើមរៃ ផ្កាអណ្ដែងមួយៗនៅតាមច្រាំងអន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិនអាចមើលឃើញថ្ម និងអ្វីផ្សេងៗទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែសីហា ដល់ខែ តុលាឡើងដល់ ៩,៣០ម៉ែត្រ ( ឡើងលើជំរៅអន្លង់) ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្ពិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, ត្រីឆ្ដោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ត្រីប៉ាញ៉ែន, ត្រីព្រួល, ខ្យង, ខ្ចៅ និងគ្រំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និង សេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្លង, ថ្លែន, បង្កួយ, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស និងឆ្កែចចក ។

**ង. ប្រភេទរុក្ខជាតិ :**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអណ្តែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាងមានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្តៅ, ដើមផ្តៅ, ដើមកកោះ, ដើមពពេល, ដើមពង្រ និងឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិភ្លុក ភូមិសាមឃួយ ភូមិហាងសារ៉ាត ភូមិកំភុន ភូមិបានប៉ុង ភូមិបាចុង ភូមិស្រែពោធិ៍ ភូមិស្រែឫស្សី ភូមិហាងឃោសួន ស្រែគរ១ និងភូមិស្រែគរ២។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

- ក្រឡា ២,៥ - ៦ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក)

- ក្រឡា ៨ -១២ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ ខែវិច្ឆិកា ( រដូវទឹកឡើង

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង : ក្រឡា ៧ ស.មទៅ ៨ ស.មគ្រប់រដូវ

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា គប់គ្រាប់បែក និងឆក់ ។



**៣.២០.៦ អន្លង់ប៉ាកាន់**

**ក. ទីតាំង**

អន្លង់ប៉ាកាន់ ស្ថិតនៅខាងក្រោមភូមិស្រែគរ១ ចំងាយ២ គ.មពីភូមិ និងមានល្បឿនទឹកហូរមធ្យមនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងការ៉េ នៅជិតច្រាំងទន្លេខាងឆ្វេងបើនិយាយតាមខ្សែទឹកពីក្រោមទៅលើ និងមានថ្មដុះជុំវិញ ។ នៅរដូវប្រាំងមានលក្ខណៈស្មុគស្មាញលំបាកក្នុងការធ្វើដំណើរទៅមក ដោយសារមានផ្ទាំងថ្មធំៗដេរដាសពាសពេញផ្ទៃទន្លេ ។ ប្រជាពលរដ្ឋតែងនាំគ្នាហៅអន្លង់នេះទៅតាមលក្ខណៈពិធម្មជាតិដូចជា មានជួរមួយនៅខាងកន្ទុយដែលមានឈ្មោះថា ជួរប៉ាកាន់ និងមានអូរមួយហូរចាក់ហៅថាអូរប៉ាកាន់ ទើបគេហៅតាមឈ្មោះអូរនេះរៀងមកដល់បច្ចុប្បន្ននេះ ( ហៅពីដូនតាមក ) ។ លក្ខណៈពិសេសរបស់អន្លង់នេះគឺសំបូរត្រីជាងអន្លង់ដទៃៗទៀត ហើយបទល្មើសនេសាទក៏សំបូរដែរ ។

**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = ០៦៤៥០៦១
- អរដោនេ =១៥០៤២១៩
- រយៈកំពស់ = ៦១,៩ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ១០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ២០០ម ឆ្នាំ ២០០៦ = ២០០ម x ២០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : យើងអាចមើលឃើញមានថ្មធំ តូចដេរដាសជុំវិញ ។ ក្រៅពីថ្មនៅជុំវិញអន្លង់មានដើមរៃ និងដើមផ្កាអណ្តែងមួយៗនៅតាមច្រាំងអន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មិនអាចមើលឃើញថ្ម និងអ្វីផ្សេងៗទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា ឡើង ៩.៣០ម៉ែត្រ ( ឡើងលើជំរៅអន្លង់) ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្ពិន, ត្រីស្លឹកឬស្សី, ត្រីកែស, ត្រីពោ, ត្រីឆ្តោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ត្រីប៉ាញ៉ន, ត្រីព្រួល, ខ្សង, ខ្ចៅ និងគ្រំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និងសេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្រង, ថ្លែន, បង្កួយ, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស និងឆ្កែចចក ។

**ង. ប្រភេទរុក្ខជាតិ :**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជា ដើមផ្កាអណ្តែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាង-មានដើមឈើដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឬស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្តៅ, ដើមផ្តៅ, ដើមកកោះ, ដើមពពេល, ដើមពង្រ និងឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិភ្លុក ភូមិសាមឃួយ ភូមិហាងសាវ៉ាត ភូមិបានប៊ុង ភូមិស្រែគរ១ ស្រែគរ២ និងភូមិកំភុន ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

- ក្រឡា ៨ - ១២ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា (រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣

- មង : ក្រឡា ៧ ស.ម ទៅ ៨ ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា គប់គ្រាប់បែក និង ឆក់ ។



**៣.២០.៧ អន្លង់ផាស៊ី**

**ក. ទីតាំង :**

អន្លង់ផាស៊ី ស្ថិតនៅខាងក្រោមភូមិស្រែគរ១ ចំងាយ ១គ.មពីភូមិ និងមានល្បឿនទឹកហូរមធ្យមនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងទ្រវែងនៅជិតច្រាំងទន្លេខាងស្តាំបើនិយាយតាមខ្សែទឹកពីក្រោមទៅលើ និងមានថ្មជុំវិញ ។ នៅរដូវប្រាំងមានលក្ខណៈស្មុគស្មាញលំបាកក្នុងការធ្វើដំណើរទៅមក ដោយសារមានកាំងធំៗដេរដាសពាសពេញផ្ទៃទន្លេ ។ ប្រជាពលរដ្ឋតែង នាំគ្នាហៅអន្លង់នេះទៅតាមលក្ខណៈពីធម្មជាតិដូចជា មានជួរមួយនៅក្បាលអន្លង់ដែលមាន ឈ្មោះថា ជួរសាំងសឿ និងហៅតាមឈ្មោះអូរដែរតាមប្រវត្តិរឿងនាយធុនមកដល់បច្ចុប្បន្ន នេះ (ហៅពីដូនតាមក មិនចាំប្រវត្តិច្បាស់លាស់) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៤៧០២៧
- អរដោនេ = ១៥០៤៣៨៩
- រយៈកំពស់ = ៦២,៦ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៦,៨០ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ១០០ម ឆ្នាំ ២០០៦ = ២០០ម x ១០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : យើងអាចមើលឃើញមានថ្មខ្លះៗ និងខ្សាច់ដុះនៅខាងឆ្វេងអន្លង់ ។ ចំណែកនៅជុំវិញអន្លង់មាន ដើមរៃ ផ្កាអណ្តែងមួយៗនៅតាមច្រាំងអន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ មិន-អាច មើលឃើញថ្ម និងខ្សាច់ដែលដុះបានទៀតទេ ។ កំពស់ទឹកនៅរដូវវស្សាចាប់ពី ខែសីហា ដល់ខែ តុលា ឡើងដល់ ៩,៣០ម៉ែត្រ (ឡើងលើជំរៅអន្លង់) ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្ពិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ខ្យង, ខ្ចៅ និងគ្រុំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និង សេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្រង, ថ្លែន, បង្កួយ, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស និងឆ្កែចចក ។

**ង. ប្រភេទរុក្ខជាតិ :**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជា ដើមផ្កាអណ្តែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាង-មានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្តៅ, ដើមផ្តៅ, ដើមកកោះ, ដើមពពេល, ដើមពង្រ និងដើមឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិភ្លុក ភូមិសាមឃួយ ភូមិហាងសាវ៉ាត ភូមិកំភុន ភូមិបានប៊ុង ភូមិស្រែគរ១ ភូមិស្រែគរ២ ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

- ក្រឡា ៨ - ១២ ស.ម ប្រើប្រាស់ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា (រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣



- មង : ក្រឡា ៧ ស.មទៅ ៨ ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា គប់គ្រាប់បែក និង ឆក់ ។

*(កាលបរិច្ឆេទថ្ងៃទី ១៦ មិថុនា ឆ្នាំ២០០៦)*

## ៣.២១ ភូមិស្រែគរ២ ឃុំស្រែគរ

ភូមិស្រែគរ២ ស្ថិតនៅតាមបណ្តោយដងទន្លេសេសាន ឃុំស្រែគរ មានចំងាយផ្លូវគោក ៧០គ.ម និងផ្លូវទឹក ៦៨ គ.មពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅប្រមាណ ១៤៨ គ្រួសារ និងមាន ១១០ខ្នងផ្ទះ មានប្រជាពលរដ្ឋសរុប ៦៤៩នាក់ ស្រី៣៦១នាក់។ ភូមិនេះមាន អន្លង់ចំនួន ៥កន្លែង បើយើងរាប់ពីក្រោមខ្សែទឹកឡើងមកលើ គឺអន្លង់ត្រី អន្លង់ឃ្នួន អន្លង់ពោន អន្លង់ហាតស៊ែង និងអន្លង់ពន្លាក ។ ក្នុងចំណោមអន្លង់ទាំងនេះបានបាត់បង់ជំរៅ អស់មួយចំនួនដែរដោយសារខ្សាច់ហូរលុប។



**អ្នកស្រុកសេសាន និងបុគ្គលិកអង្គការសេប៉ាកំពុងរៀបចំអាំងត្រីប៉ាវ៉ាមុខពីរ**

តារាង ១០

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់ (ម) | | ទំហំអន្លង់ពីមុន (ម) | | ទំហំ ២០០៦ (ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់ត្រី | ១៥ | ៨.៨ | ១០០ | ១០០ | ១០០ | ១០០ | ១៥០៦០២០ | ០៦៤៩៤៤៨ |
| ២ | អន្លង់ឃ្មួន | ៨ | ៥ | ១០០ | ១០០ | ១០០ | ១០០ | ១៥០៦០១២ | ០៦៥០៧៩៧ |
| ៣ | អន្លង់ពោន | ១០ | ៧ | ៣០ | ៣០ | ៣០ | ៣០ | ១៥០៨៧៤០ | ០៦៥២៤៤៦ |
| ៤ | ហាតសើង | ៦ | ៤ | ១០០ | ១០០ | ១០០ | ១០០ | ១៥០៨៩២៧ | ០៦៥២៨២៣ |
| ៥ | អន្លង់ពន្លាក | ១០ | ៣.៥ | ១០០០ | ១០០ | ១០០០ | ១០០ | ១៥០៨៨៩២ | ០៦៥៣៨៣៤ |



### ៣.២១.១ អន្លង់ត្រី(អន្លង់ប៉ា)

**ក. ទីតាំង**

អន្លង់ត្រី ស្ថិតនៅជាប់ក្បាលភូមិខាងលើ ដែលមានល្បឿនទឹកហូរលឿនមនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងទ្រវែង ដែលមានលក្ខណៈស្មុគស្មាញលំបាកក្នុងការធ្វើដំណើរទៅមកសំរាប់មនុស្សគ្រប់គ្នា ព្រោះនៅគែមខាងៗសុទ្ធតែថ្មាំងថ្មដេរដាស ពាសពេញផ្ទៃទន្លេនៅខាង ឆ្វេង ផ្នែកខាងក្រោមមានខ្សាច់ដុះច្រើន ។ ប្រជាពលរដ្ឋតែងនាំគ្នាហៅ អន្លង់នេះទៅតាមលក្ខណៈធម្មជាតិ ដូចជាអន្លង់មានត្រីច្រើនដែលប្រជាពលរដ្ឋយើងងាយស្រួលនេសាទជាងអន្លង់ផ្សេងៗ ដោយសារតែហេតុនេះហើយទើបប្រជាពលរដ្ឋគាត់នាំគ្នាហៅថាអន្លង់ប៉ា (ត្រី) ដល់បច្ចុប្បន្ននេះទៅ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស =០៦៤៩៤៤៨
- អរដោនេ =១៥០៦០២០
- រយៈកំពស់ = ៦៣ម

**ខ. លក្ខណៈរូប :**

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ១៥ម ឆ្នាំ ២០០៦ = ៨.៨០ម
- ទំហំ :មុនឆ្នាំ ១៩៩៥ =១០០ម x ១០០ម ឆ្នាំ ២០០៦ = ១០០ម x ១០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : យើងអាចមើលឃើញមានថ្មខ្លះៗ និងខ្សាច់ដុះនៅកន្ទុយអន្លង់ខាងឆ្វេង។ ចំណែកនៅជុំវិញអន្លង់មានដើមរ៉ៃ និងដើមផ្កាអណ្តែងមួយៗនៅតាមច្រាំងអន្លង់ ។

♦ រដូវវស្សា ៖ នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់មើល មិន-ឃើញថ្ម និងអ្វីផ្សេងៗទេ ។ កំពស់ទឹកនៅរដូវទឹកឡើងកំពស់ ៩,៣០ម៉ែត្រ ចាប់ពីខែ សីហា ដល់ខែ តុលា ( ឡើងលើជំរៅអន្លង់) ។

**ឃ. ប្រភេទសត្វ ៖**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្កិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, ត្រីឆ្តោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ត្រីប៉ាញ៉ន, ត្រីព្រួល, ខ្យង, ខ្ចៅ និងគ្រំ ។

- ប្រភេទសត្វស្លាបរួមមាន៖ កុក, មាន់ទឹក,មាន់ស្រុក, ទា, លលក និងសេក ។ល។

- ប្រភេទល្មូន ៖ ពស់, កន្ធ្រង, ថ្លែន និងបង្កួយ ។

- ថនិកសត្វ ៖ ជ្រូកស្រុក, គោ, ក្របី និងឆ្កែស្រុក ។

**ង. ប្រភេទរុក្ខជាតិ ៖**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអណ្ដែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាងមានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្ដៅ, ដើមផ្ដៅ, កកោះ, ដើមពពេល, ដើមពង្រ និងដើមឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រជាជនភាគច្រើននាំគ្នាទៅប្រមូលខ្សាច់ គ្រួស ថ្ម យកទៅចាក់ជើងតាង គ្រឹះសាលា និងចាក់សាបគ្រឹះវត្ត ។

- ប្រភពអ្នកនេសាទ ៖ មកពីភូមិស្រែគរ១ និងភូមិស្រែគរ២ ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា ៖

  - សំណាញ់ ៖ គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

  - ក្រឡា ២,៥ - ៦ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក)



  -ក្រឡា ៨ -១២ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ( រដូវទឹកឡើង)

- សន្ទូច ៖ នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង ៖ក្រឡា៧ ស.ម ទៅ ៨ ស.មគ្រប់រដូវ និងមងក្រឡា ២,៥ ស.ម ទៅ ៦ ស.ម ( រដូវទឹកឡើង) ។

**៣.២១.២ អន្លង់ឃ្លួន**

**ក. ទីតាំង**

អន្លង់ឃ្លួន ស្ថិតនៅខាងភូមិស្រែគរ២ ចំងាយ ២គ.ម ពីភូមិ និងមានល្បឿនទឹកហូរមធ្យម នៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងការ៉េ នៅជិតច្រាំងទន្លេខាងស្ដាំបើនិយាយតាមខ្សែទឹកពីក្រោមទៅលើ និងមានថ្មជុំវិញ ។ នៅរដូវប្រាំងមានលក្ខណៈស្មុគស្មាញលំបាកក្នុងការធ្វើដំណើរទៅមកខ្លាំងណាស់ ដោយសារមានកាំងធំៗដេរដាសពាសពេញផ្ទៃទន្លេ ។ ប្រជាពល-រដ្ឋតែងនាំគ្នាហៅអន្លង់នេះទៅតាមលក្ខណៈពិធម្មជាតិ ដូចជាមានអូរមួយហូរចាក់ដែលមានឈ្មោះថា អូរឃ្លួន គេហៅតាមឈ្មោះអូរនេះតៗគ្នាមកដល់បច្ចុប្បន្ននេះ ( ហៅពីដូនតាមក ) ។

**<u>ចំណុចនៅលើ GPS ៖</u>**

- អាប់ស៊ីស = ០៦៥០៧៩៧
- អរដោនេ = ១៥០៦០១២
- រយៈកំពស់ = ៦៣,៨ម

**ខ. លក្ខណៈរូប**

- ជំរៅ ៖មុនឆ្នាំ ១៩៩៥ = ៨ម ឆ្នាំ ២០០៦ = ៥ម
- ទំហំ ៖មុនឆ្នាំ ១៩៩៥ =១០០ម x ១០០ម ឆ្នាំ ២០០៦ = ១០០ម x ១០០ម

គ. មជ្ឈដ្ឋានជុំវិញ ៖

♦ រដូវប្រាំង ៖ មានថ្មប៉ប្រះៗទឹកច្រើនពេញផ្ទៃទន្លេ នៅជុំវិញអន្លង់មានដើមរៃ និងផ្កាអំណ្ដែងមួយៗដុះនៅតាមច្រាំងអន្លង់ ។

♦ រដូវវស្សា ៖ នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ យើងមិន-អាចមើលឃើញថ្ម និងអ្វីផ្សេងៗទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា ឡើងដល់ ៩,៣០ម៉ែត្រ (ឡើងលើជំរៅអន្លង់) ។

ឃ. ប្រភេទសត្វ ៖

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្ពិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ខ្សង, ខ្ចៅ និងគ្រុំ ។

- ប្រភេទសត្វស្លាបរួមមាន ៖ កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និង សេក ។ល។

- ប្រភេទល្មូន ៖ ពស់, កន្ធ្រង, ថ្លែន, បង្កួយ, ត្រកួត និងអណ្ដើក ។

- ថនិកសត្វ ៖ ជ្រូកព្រៃ, ឈ្លូស និងឆ្កែចចក ។

ង. ប្រភេទរុក្ខជាតិ ៖

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអំណ្ដែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាងមានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្ដុល, ដើមល្វាទឹក, ដើមគុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្ដៅ, ដើមផ្ដៅ, ដើមកកោះ, ដើមពពេល, ដើមពង្រ និងឈើទាល ។ល។

ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

- ប្រភពអ្នកនេសាទ ៖ មកពីភូមិ ខ្សាច់ថ្មី ភូមិស្រែគរ១ និងភូមិស្រែគរ២ ។



- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា ៖

- សំណាញ់ ៖ គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

-ក្រឡា ៨ -១២ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ ខែវិច្ឆិកា (រដូវទឹកឡើង)

- សន្ទូច ៖ នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង ៖ ក្រឡា ៧ ស.ម ទៅ ៨ ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា ឆក់ ។

### ៣.២១.៣ អន្លង់ពោន

ក. ទីតាំង

អន្លង់ពោន ស្ថិតនៅខាងលើភូមិស្រែគរ២ ចំងាយ ២,៥គ.មពីភូមិ និងមានល្បឿនទឹកហូរខ្លាំងហើយកួចនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងការ៉េនៅកណ្ដាលទន្លេ និងមានថ្មប៉ប្រះទឹកជុំវិញ ។ នៅរដូវប្រាំងមានលក្ខណៈស្មុគស្មាញពិបាកក្នុងការធ្វើដំណើរទៅមកដោយសារមានកាំងធំៗដេរដាសពាសពេញផ្ទៃទន្លេ ។ ប្រជាពលរដ្ឋតែងនាំគ្នាហៅ អន្លង់នេះទៅតាមលក្ខណៈពីធម្មជាតិដូចជា មានជួរពោននៅក្បាលអន្លង់ និងដើមពោនច្រើន ទើបគេហៅតាមឈ្មោះជួរ និងដើមពោននេះតៗមកដល់បច្ចុប្បន្ននេះ (ហៅពីដូន តាមក) ។

**ចំណុចនៅលើ GPS ៖**

- អាប់ស៊ីស = ០៦៥២៤៤៦
- អរដោនេ =១៥០៨៧៤០
- រយៈកំពស់ = ៦២ម

ខ. លក្ខណៈរូប

- ជំរៅ ៖ មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៧ម

- ទំហំ : មុនឆ្នាំ ១៩៩៥ =៣០ម x ៣០ម ឆ្នាំ ២០០៦ = ៣០ម x ៣០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : យើងឃើញមានថ្មប៉ប្រះទឹកស្មេកស្តុះពេញផ្ទៃទន្លេ នៅជុំវិញអន្លង់វិញមាន ដើមរៃ និងផ្កាអណ្តែងមួយៗ នៅតាមច្រាំងអន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ធ្វើឱ្យយើង មិនអាចមើលឃើញថ្ម និងអ្វីផ្សេងៗបានទៀតទេ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ តុលា ឡើងដល់ ៩,៣០ម៉ែត្រ(ឡើងលើជំរៅអន្លង់ ) ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្កិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ខ្សង, ខ្ចៅ និងគ្រំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និង សេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្រង, ថ្លែន, បង្កួយ, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស និងឆ្កែចចក ។

**ង. ប្រភេទរុក្ខជាតិ :**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអណ្តែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាង មានដើមឈើដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្តៅ, ដើមផ្តៅ, ដើមកកោះ, ដើម-ពពេល, ដើមពង្រ និងដើមឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ ខ្សាច់ថ្មី ភូមិស្រែគរ១ ភូមិស្រែគរ២ ភូមិក្រឡា ពុះ និងភូមិស្វាយរៀង។



- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

-ក្រឡា ៨ -១២ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា (រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង : ក្រឡា ៧ ស.ម ទៅ ៨ ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា ឆក់ ។

### ៣.២១.៤ អន្លង់ហាតសេីង

**ក. ទីតាំង**

អន្លង់ហាតសេីង ស្ថិតនៅខាងលើភូមិស្រែគរ២ ចំងាយ ៣គ.ម ពីភូមិ និងមានល្បឿនទឹកហូរ មធ្យមនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងការ៉េនៅរដូវប្រាំងមានលក្ខណៈ ស្មុគស្មាញលំបាកក្នុងការធ្វើដំណើរទៅមក ព្រោះមានកាំងធំៗដេរដាសពាសពេញផ្ទៃទន្លេជាប់ គែមអន្លង់ប្រជាពលរដ្ឋតែងនាំគ្នាហៅអន្លង់នេះទៅតាមលក្ខណៈធម្មជាតិដូចជា មានដើមស្លែង ដុះច្រើននៅតាមច្រាំង និងចំណុចអន្លង់មានជួរឈ្មោះថា ជួរបាយលាក់។ តាមសំដីរបស់អ្នក ភូមិដែលរស់នៅទីនោះបាននិយាយថា កាលពីដើមអ្នកភូមិយើងធ្លាប់យកបាយទៅលាក់ទុកនៅ តាមជួរ មុននឹងចេញទៅនេសាទ (ហៅពីដូនតាមក) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥២៨២៣

- អរដោនេ =១៥០៨៩២៧

- រយៈកំពស់ = ៦៤,៨ម

ខ. លក្ខណៈរូប :

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៦ម ឆ្នាំ ២០០៦ = ៤ម

- ទំហំ : មុនឆ្នាំ ១៩៩៥ =១០០ម x ១០០ម ឆ្នាំ ២០០៦ =១០០ម x ១០០ម

គ. មជ្ឈដ្ឋានជុំវិញ :

♦ រដូវប្រាំង : យើងអាចមើលឃើញមានកាំងថ្ម និងថ្មប៉ប្រះទឹកស្មោកស្មុះនៅពាសពេញផ្ទៃទន្លេ និងគែមអន្លង់ ។ ក្រៅពីនោះនៅជុំវិញអន្លង់ក៏មានដើមរៃ ផ្កាអណ្តែងមួយៗនៅតាមច្រាំងអន្លង់ផងដែរ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ដោយមិនអាចមើលឃើញថ្ម និងអ្វីផ្សេងៗទៀតបានទេ ។ កំពស់ទឹកនៅរដូវវស្សាចាប់ពីខែសីហា ដល់ខែ តុលា ឡើងដល់ ៩,៣០ម៉ែត្រ ( ឡើងលើជំរៅអន្លង់) ។

ឃ. ប្រភេទសត្វ :

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្កិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ, ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ខ្យង, ខ្ចៅ និងគ្រុំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និងសេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្រង, ថ្លែន, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស, ឆ្កែចចក និងជ្រូកពោន ។

ង. ប្រភេទរុក្ខជាតិ :

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអណ្តែង គុម្ពរៃ ហើយនៅច្រាំងទន្លេទាំងសងខាង-មានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្មៅ, ដើមផ្តៅ, ដើមកកោះ, ដើមពពេល, ដើមពង្រ, ដើមឈើទាល និងត្រាច ។ល។



ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

- ប្រភពអ្នកនេសាទ : មកពីភូមិស្រែគរ១ ភូមិស្រែគរ២ ភូមិខ្សាច់ថ្មី ភូមិក្រឡាពុះ និងភូមិស្វាយរៀង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

-ក្រឡា៨ - ១២ ស.ម ប្រើប្រាស់ចាប់ពីខែសីហាដល់ខែវិច្ឆិកា ( រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង :ក្រឡា ៧ ស.ម ទៅ ១០ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា ឆក់ ។

**៣.២១.៥ អន្លង់ពន្លាត**

**ក. ទីតាំង**

អន្លង់ពន្លាកស្ថិតនៅខាងលើភូមិស្រែគរ២ ចំងាយ ៥គ.មពីភូមិ និងមានល្បឿនទឹកហូរមធ្យមនៅរដូវសម្រក ។ អន្លង់នេះមានទ្រង់ទ្រាយរាងទ្រវែងនៅជិតច្រាំងទន្លេខាងស្តាំ បើនិយាយតាមខ្សែទឹកពីក្រោមទៅលើ និងមានថ្មជុំវិញ ។ នៅរដូវប្រាំងត្រង់អន្លង់នេះ មានលក្ខណៈស្មុគស្មាញ លំបាកក្នុងការធ្វើដំណើរទៅមក ដោយសារមានកាំងធំៗដេរដាសពាសពេញផ្ទៃទន្លេ និងអន្លង់។ ប្រជាពលរដ្ឋតែងនាំគ្នាហៅអន្លង់នេះទៅតាមលក្ខណៈធម្មជាតិ ដោយហេតុថាវាមានអូរមួយហូរចាក់ឈ្មោះថាអូរពន្លាកទើបគេហៅតៗគ្នាមកដល់បច្ចុប្បន្ននេះ( ហៅពីដូនតាមក) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥៣៤៣៤

- អរដោនេ = ១៥០៨៨៩២

- រយៈកំពស់ = ៦៥,៦ម

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៣,៥ម

- ទំហំ : មុនឆ្នាំ ១៩៩៥ =១០០០ម x ១០០ម ឆ្នាំ ២០០៦ = ១០០០ម x ១០០ម

**គ. មជ្ឈដ្ឋានជុំវិញ :**

♦ រដូវប្រាំង : មានថ្មដេរដាសពាសពេញផ្ទៃអន្លង់ ហើយនៅជុំវិញអន្លង់មានដុះ ដើមរ៉ៃ និងដើមផ្កាអណ្តែងមួយៗនៅតាមច្រាំងអន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ដែលធ្វើឱ្យយើងមិនអាចមើលឃើញថ្ម និងអ្វីផ្សេងៗទៀតបានទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែសីហា ដល់ខែតុលា ឡើងដល់៩,៣០ម៉ែត្រ( ឡើងលើជំរៅអន្លង់) ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីលេញ, ត្រីឆ្កិន, ត្រីស្លឹកឫស្សី, ត្រីកែស, ត្រីពោ ត្រីក្រពើ, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីរមាស, ត្រីប៉ាវ៉ា, ត្រីក្រាយ, ខ្យង, ខ្ចៅ និងគ្រុំ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, មាន់ទឹក, មាន់ព្រៃ, ក្អែកទឹក, លលក និង សេក ។ល។

- ប្រភេទល្មូន : ពស់, កន្ធ្រង, ថ្លែន, បង្កួយ, ត្រកួត និងអណ្តើក ។

- ថនិកសត្វ : ជ្រូកព្រៃ, ឈ្លូស និងឆ្កែចចក ។

**ង. ប្រភេទរុក្ខជាតិ :**

នៅចំណុចអន្លង់មានរុក្ខជាតិដូចជាដើមផ្កាអណ្តែង គុម្ពរ៉ៃ ហើយនៅច្រាំងទន្លេទាំងសងខាង-មានដើមឈើ ដូចជា ដើមរាំងភ្នំ, ដើមរ៉ៃ, ដើមត្រែង, ដើមត្រស់, ដើមរាំងទឹក, ដើមក្តុល, ដើមល្វាទឹក, គុម្ពឫស្សី, ដើមរំដេញ, ដើមស្រឡៅ, ដើមស្មៅ, ដើមផ្តៅ, ដើមកកោះ,



ដើមពពេល, ដើមពង្រ និងដើមឈើទាល ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពី ភូមិស្រែគរ១ ភូមិស្រែគរ២ និងភូមិខ្សាច់ថ្មី ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ៧ ស.ម រហូតទៅដល់ ១២ ស.ម ប្រើប្រាស់ប្រចាំរដូវ ។

-ក្រឡា៨ - ១២ ស.ម ប្រើប្រាស់ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ( រដូវទឹកឡើង)

- សន្ទូច : នេសាទនៅខែ សីហា ដល់ខែ វិច្ឆិកា សន្ទូចប្រើប្រាស់ផ្លែលេខ ៨ ទៅ ១៣ ។

- មង : ក្រឡា ៧ ស.ម ទៅ ១០ស.មគ្រប់រដូវ ។

- ចំណុចនេះសំបូរអ្នកប្រព្រឹត្តបទល្មើសនេសាទដូចជា គប់គ្រាប់ និងឆក់

*( កាលបរិច្ឆេទថ្ងៃទី ១៦ មិថុនា ឆ្នាំ២០០៦)*

## ៣.២២ ភូមិខ្សាច់ថ្មី ឃុំតាឡាត

ភូមិខ្សាច់ថ្មី ជាភូមិមួយស្ថិតនៅតាមបណ្តោយដងទន្លេសេសាន ក្នុងឃុំតាឡាត ។ ដែលមានប្រជាពលរដ្ឋរស់នៅអមច្រាំងទន្លេទាំងសងខាង មានចំងាយផ្លូវគោក ៨៤ គ.ម និងផ្លូវទឹក ៨២គ.ម ពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅប្រមាណ ២៤៧គ្រួសារ ហើយមានផ្ទះ២០៥ខ្នង ស្មើនឹងប្រជាពលរដ្ឋសរុប ១០៨៧ នាក់ស្រី ៦២១ នាក់។ ភូមិនេះមានអន្លង់ចំនួន ៦ កន្លែង បើយើងរាប់ពីខ្សែទឹកក្រោមទៅលើគឺ អន្លងកន្ទក់ អន្លង់ជជូរ អន្លង់តាសួស អន្លង់ក្រពើ អន្លង់អង់កូ និងអន្លង់កំបោរ។ ក្នុងចំណោមអន្លង់ទាំង ៦នេះ មានអន្លង់មួយត្រូវបានរាក់អស់ គឺអន្លង់អង់កូរស្មើនឹងបាតទន្លេ ឯអន្លង់ដទៃៗទៀតក៏បានបាត់បង់ជំរៅអស់មួយចំនួនដែរ ដោយសារតែខ្សាច់ហូរលុប។

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំអន្លង់ ពីមុន(ម) | | ទំហំបច្ចុប្បន្ន(ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៥ | ២០០៦ | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | អន្លង់ កន្ទក់ | ៥ | ៤,១០ | ២០០ | ៥០ | ២០០ | ៥០ | ១៥១២៤៣៩ | ០៦៥៤៧២៦ |
| ២ | អន្លង់ជជូរ | ៥ | ២,៧០ | ៣០០ | ៣០ | ១១០ | ៣០ | ១៥១២៩៧១ | ០៦៥៦១១ |
| ៣ | អន្លង់តាសួស | ៦ | ២,៥០ | ១០០ | ៣០ | ១០០ | ៣០ | ១៥១៣១៧០ | ០៦៥៨៥១១ |
| ៤ | អន្លង់ក្រពើ | ៧ | ៣ | ១០០ | ៣០ | ១០០ | ៣០ | ១៥១២៩៧១ | ០៦៥៦១១ |
| ៥ | អន្លង់អង់កូ | ៥ | ០ | ១០០ | ៣០ | ស្មើទន្លេ | | ១៥១២៩៧១ | ០៦៥៦១១ |
| ៦ | អន្លង់កំបោរ | ១០ | ៨,៨ | ៣០០ | ១៥០ | ៣០០ | ៦០ | ១៥១១១០៤ | ០៦៦១៨០៥ |



តារាង១១ ឈ្មោះអន្លង់ ភូមិខ្សាច់ថ្មី ឃុំតាឡាត

## ៣.២២.១ អន្លង់កន្ទក់

### ក. ទីតាំង

អន្លង់កន្ទក់ មានចំងាយ ៦គ.មពីភូមិខ្សាច់ថ្មី ឃុំតាឡាត នៅភាគខាងក្រោមខ្សែទឹកនៃភូមិ ហើយប្រជាពលរដ្ឋតែងតែហៅតៗគ្នារៀងមកតាមលក្ខណៈសំគាល់មួយគឺ មានអូរមួយហូរ-កាត់អន្លង់នេះហៅថា អូរកន្ទក់ ដែលមានឈ្មោះពីដូនតាមក ។ ហើយអន្លង់នេះមានល្បឿនទឹកហូរមធ្យមនៅរដូវប្រាំង ។

**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = ០៦៥៤៧២៦
- អរដោនេ =១៥១២៤៣៩
- រយៈកំពស់ =

### ខ. លក្ខណៈរូប

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៥ម ឆ្នាំ ២០០៦ = ៤,១០ ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =២០០ម x ៥០ម ឆ្នាំ ២០០៦ = ២០០ម x ៥០ម

### គ. មជ្ឈដ្ឋានជុំវិញ

◆ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធដោយជួរថ្មជាច្រើន ចំណែកបាតអន្លង់មានថ្មច្រើនដែរ ហើយនៅមាត់អន្លង់ជាប់ច្រាំងទន្លេខាងស្តាំមានថ្មប៉ប្រះទឹក និងល្បាក់ទឹកហូរមានថ្ម ។ លើសពីនេះមានខ្សាច់ដុះនៅកន្ទុយអន្លង់ផ្នែកខាងក្រោមនៃខ្សែទឹក ព្រមទាំងមានដើមរៃដុះជាច្រើនផងដែរ ។ កំពស់ទឹកនៅខែប្រាំង ចាប់ពីខែមករា ដល់ខែ ឧសភា ពីលើផ្ទៃអន្លង់កំពស់ ០,៥-១ម ។ ជាពិសេសអន្លង់កន្ទក់នេះ សំបូរត្រីជាងគេ ។

◆ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ដោយមិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ដែលដុះនៅរដូវប្រាំងទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពី ខែសីហា ដល់ខែ តុលា ឡើងដល់ ៩,៣៥ ម៉ែត្រ ។

ឃ. ប្រភេទសត្វ

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីប៉ាមូក, ត្រីឆ្ពិន, ត្រីប៉ាញ៉ន, ត្រីប៉ាវ៉ា, ត្រីប៉ាស៊ីអ៊ី, ត្រីឆ្ដោ, ត្រីព្រួល, ត្រីផ្ទក់, ត្រីចង្វា, ត្រីណាក, ត្រីកែស, ត្រីរាហូ, ត្រីតាសេក, ត្រីខ្យា, ត្រីខ្ទាន់, បបែល, គ្រំ និងខ្ចៅ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ពពូល, រំពេ, ត្រដេវវិច, ត្រសេះ, លលក, មាន់ព្រៃ និងអក។

- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ, ប្រើស និងសត្វស្វា ។

- ប្រភេទល្មូន : អណ្តើក, កន្ធាយ, ពស់, រមិច និងត្រកួត ។

ង. ប្រភេទរុក្ខជាតិ

នៅក្នុងទន្លេមានដើមរៃ ដើមផ្កាអណ្តែង ហើយនៅតាមច្រាំងទន្លេនៃអន្លង់មានប្រភេទរុក្ខជាតិដូចជា ដើមស្ដី, គុម្ពឫស្សី, ដើមគគីរ, ដើមពពេល, ដើមត្រស់, ដើមដៃញទួយ, ដើម-ល្វា, ដើមសាខ័រ, ដើមតាំងទឹក, ដើមសណ្តាន់ , ដើមក្តុល, ដើមក្បៀ, ដើមឈើទាល, ដើមចំបក់, ដើមស្រឡៅ, ដើមព្រីងទឹក និងរំដេញ ។

ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

- ប្រភពអ្នកនេសាទ : មកពីភូមិ ស្រែគរ១ ស្រែគរ២ ខ្សាច់ថ្មី ក្រឡាពុះ និង-ភូមិស្វាយរៀង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២.0 ស.ម រហូតទៅដល់ ១០ ស.ម ។

- ក្រឡា ២,00 - ១០ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)

- សន្ទូច : នេសាទនៅ ខែមិថុនា ដល់ខែធ្នូ។ សន្ទូចប្រើប្រាស់ផ្លែបច្ចុប្បន្ន ប្រើលេខ ៨ - ១០ ។



- មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅតាមរដូវកាលដូចជានៅរដូវប្រាំង ប្រើក្រឡា ២,៥0 ទៅ ៦ស.ម និងនៅរដូវវស្សា ៤ ទៅ ១០ ស.ម

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ។

៣.២២.២ អន្លង់ជជួរ

ក. ទីតាំង

អន្លង់ជជួរ មានចំងាយ៥ គ.មពីភូមិខ្សាច់ថ្មី ឃុំតាឡាតនៅភាគខាងក្រោមខ្សែទឹកនៃភូមិ ហើយប្រជាពលរដ្ឋតែងតែហៅត១គ្នារៀងមកដោយមានលក្ខណៈសំគាល់ គឺមានជួរថ្មវែងលាតសន្ធឹងពីច្រាំងទន្លេម្ខាងទៅច្រាំងទន្លេម្ខាងទៀតនៅក្បាលអន្លង់ និងកន្ទុយអន្លង់ ហើយនឹងមាន-អូរមួយហូរចាក់ចូលអន្លង់នេះ គឺអូរជជួរ។ កាលពីដើមមានជនជាតិភាគតិចធ្លាប់បានរស់នៅជិតអន្លង់នេះ រីឯល្បឿនទឹកហូរលឿនល្មម។

**<u>ចំណុចនៅលើ GPS :</u>**

-អាប់ស៊ីស = 0៦៥៦១១

- អរដោនេ =១៥១២៩៧១

- រយៈកំពស់ = (មិនបានវាស់)

ខ. លក្ខណៈរូប :

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៥ម ឆ្នាំ ២00៦ = ២,៧0ម

- ទំហំ : មុនឆ្នាំ ១៩៩៥ =៣00ម x ៣0ម ឆ្នាំ ២00៦ = ១១0ម x ៣0ម

គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធដោយជួរថ្ម និងមាត់អន្លង់ជាប់ច្រាំងទន្លេទាំងសងខាងមានថ្មប៉ប្រះទឹក ឯបាតអន្លង់ក៏មានថ្មច្រើនដែរ ។ ជាពិសេសអន្លង់ជជួរនេះសំបូរត្រីដូចអន្លង់កន្ទក់ដែរ ដោយវាមានទីតាំងមិនសូវឆ្ងាយប៉ុន្មានពីអន្លង់កន្ទក់ ហើយមានដើមរៃជាច្រើនដែលដុះនៅជិតនោះ ។ កំពស់ទឹកនៅខែប្រាំងចាប់ពីខែមករា ដល់ខែ ឧសភា ឡើងដល់

០,១-២ម (ពីលើផ្ទៃអន្លង់) ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃអន្លង់ទាំងអស់ ដែលមើលមិន-ឃើញផ្ទាំងថ្ម ជួរថ្ម និងអ្វីផ្សេងទៀតបានទេ ។ ហើយកំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ៩,៣៥ ម៉ែត្រ ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីឆ្ពិន, ត្រីប៉ាវ៉ា, ត្រីប៉ាស៊ីអ៊ី, ត្រីឆ្តោ, ត្រីព្រួល, ត្រីថ្កក់, ត្រីចង្វា, ត្រីណាក, ត្រីកែស, ត្រីរាហូ, បបែល, ត្រីតាសេក, ត្រីខ្យា, ត្រីខ្នាន់, ត្រំ និងខ្ចៅ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ពពូល, រំពេ, ត្រដេវវិច, ត្រសេះ, លលក, មាន់ព្រៃ និងអក ។

- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ, ប្រើស និងសត្វស្វា ។

- ប្រភេទល្មូន : អណ្តើក, កន្ធាយ, រមិច, ត្រកួត និងពស់ ។

**ង. ប្រភេទរុក្ខជាតិ**

ដើមរៃ ដើមផ្កាអណ្តែងនៅក្នុងទន្លេ ហើយនៅតាមច្រាំងទន្លេនៃអន្លង់ជជួរ មានប្រភេទរុក្ខជាតិដូចជា ដើមគគីរ, គុម្ពឫស្សី, ដើមពពេល, ដើមត្រស់, ដើមដៃញទួយ, ដើមល្វា, ដើមសាខ័រ, ដើមរាំងទឹក, ដើមសណ្តាន់, ដើមក្តុល, ដើមក្បៀ, ដើមឈើទាល, ដើមចំបក់, ដើមស្រឡៅ, ដើមស្តី, ដើមព្រីងទឹក និងដើមរំដេញ ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ ស្រែគរ១ ស្រែគរ២ ខ្សាច់ថ្មី ក្រឡាពុះ និង-ភូមិស្វាយរៀង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២ស.ម រហូតទៅដល់ ១០ស.ម

  -ក្រឡា ២ - ១០ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)



- សន្ទូច : នេសាទនៅខែមិថុនា ដល់ខែ ធ្នូ ។ សន្ទូចប្រើប្រាស់ផ្លែបច្ចុប្បន្ន លេខ ៨-១០ ។

- មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅតាមរដូវកាលដូចជានៅរដូវប្រាំងប្រើក្រឡា ២,៥០ ទៅ ៦ស.ម និងនៅរដូវវស្សាក្រឡា ៤ ទៅ ១០ ស.ម ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ។

### ៣.២២.៣ អន្លង់តាសួស

**ក. ទីតាំង**

អន្លង់តាសួស មានចំងាយ ៤,៥០គ.ម ពីភូមិខ្សាច់ថ្មី ឃុំតាឡាត នៅភាគខាងក្រោមខ្សែទឹកនៃភូមិ ។ ហើយប្រជាពលរដ្ឋតែងតែហៅត១គ្នារៀងមក និងមានលក្ខណៈសំគាល់មួយគឺនៅខាងឆ្វេងមានអូរមួយហូរចាក់អន្លង់នេះហៅថា អូរតាសួស (បើចុះតាមខ្សែទឹក) ហើយនៅខាងក្រោមអន្លង់មានអូរមួយទៀតហៅថាអូរក្តុល ។ តាមសំដីរបស់អ្នកភូមិដែលរស់នៅទីនោះបាននិយាយថា កាលពីដើមមានជនជាតិដើមភាគតិចមករស់នៅតាមដងអូរ និងមាត់អន្លង់ ។ អន្លង់នេះមានល្បឿនទឹកហូរល្មម (មានឈ្មោះពីដូនតាមក) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥៨៥១១
- អរដោនេ =១៥១៣១៧០
- រយៈកំពស់ = (មិនបានវាស់)

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៦ម,    ឆ្នាំ ២០០៦ = ២,៩០ ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =១០០ម x ៣០ម    ឆ្នាំ ២០០៦ = ១០០ម x ៣០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ *រដូវប្រាំង* : នៅជុំវិញមាត់អន្លង់ព័ទ្ធដោយថ្មខ្លះៗហើយមានដើមរៃ និងផ្កាអំពៅ-ជាច្រើននៅមាត់អន្លង់ ។ នៅក្បាលអន្លង់មានជួរមួយឈ្មោះ ជួរតាសួស និងកន្ទុយអន្លង់មានជួរមួយឈ្មោះ ជួរផ្លុយ ។ នៅខាងឆ្វេងអន្លង់មានខ្សាច់ដុះ និងផ្នែកម្ខាងទៀតមានថ្មប៉ប្រះទឹកជាច្រើន (បើចុះតាមបណ្តោយខ្សែទឹកហូរ) ។ ម្យ៉ាងទៀតនៅបាតអន្លង់ក៏មានថ្មច្រើនដែរ ។ ចំពោះអន្លង់តាសួសនេះសំបូរត្រីដែរ តែមិនសូវដូចអន្លង់កន្ទក់ទេ ។ កំពស់ទឹកនៅខែប្រាំងចាប់ពីខែ មករា ដល់ខែ ឧសភា ពីលើផ្ទៃអន្លង់កំពស់ ០,៥- ១ម ។

♦ *រដូវវស្សា* : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ធ្វើឱ្យយើងមិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ដែលដុះទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ៩,៥០ម៉ែត្រ ។

**ឃ.ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមានត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីឆ្កិន,ត្រីប៉ាវ៉ា, ត្រីប៉ាសុីអ៊ី, ត្រីឆ្តោ ត្រីព្រួល, ត្រីផ្ទក់, ត្រីឆ្កោក, ត្រីចង្វា, ត្រីណាក, ត្រីកែស, ត្រីរាហូ, ត្រី-តាសេក, ត្រីខ្យា, ត្រីខ្មាន់, ត្រំ និងខ្ជៅ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ពពូល, រំពេ, ត្រដេវវិច, ត្រសេះ, លលក, មាន់ព្រៃ និងអក។

- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ, ប្រើស និងសត្វស្វា ។

- ប្រភេទល្មូន : អណ្តើក, កន្ធាយ, រមិច , ត្រកួត , បបែល និងពស់ ។

**ង. ប្រភេទរុក្ខជាតិ**

ដើមរៃ ដើមផ្កាអំពៅនៅក្នុងទន្លេ ហើយនៅតាមច្រាំងទន្លេនៃអន្លង់ មានប្រភេទរុក្ខជាតិដូចជា ដើមល្វា គុម្ពប្ញស្សី, ដើមគគីរ, ដើមពពេល, ដើមត្រស់, ដើមដៃញទួយ, ដើមសាខ័រ, ដើមរាំងទឹក, ដើមសណ្តាន់, ដើមក្តុល, ដើមក្បោ, ដើមឈើទាល, ដើមចំបក់, ដើម-ស្រឡៅ, ដើមស្តី, ដើមព្រីងទឹក និងរំដេញ ។



**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ ស្រែគរ១ ស្រែគរ២ ខ្សាច់ថ្មី ក្រឡាពុះ និង-ភូមិស្វាយរៀង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២ ស.ម រហូតទៅ ដល់ ១០ ស.ម

- ក្រឡា ២-១០ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)

- សន្ទូច : នេសាទនៅខែ មិថុនា ដល់ខែ ធ្នូ ។ បច្ចុប្បន្នសន្ទូចប្រើប្រាស់ផ្លែលេខ ១០- ១៤ ។

- មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅតាមរដូវកាលដូចជានៅរដូវប្រាំង ប្រើក្រឡា ២,៥០ ទៅ ៦ ស.ម និងនៅរដូវវស្សា ប្រើក្រឡា ៤ ទៅ ១០ស.ម ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ មករា ។

*(កាលបរិច្ឆេទ ថ្ងៃទី១២ ឧសភា ឆ្នាំ២០០៦)*

### ៣.២២.៤ អន្លង់ក្រពើ

**ក. ទីតាំង**

អន្លង់ក្រពើមានចំងាយ ៣,៥០គ.ម ពីភូមិខ្សាច់ថ្មី ឃុំតាឡាត នៅភាគខាងក្រោមខ្សែទឹកនៃភូមិហើយប្រជាពលរដ្ឋតែងតែហៅតៗគ្នារៀងមក និងមានលក្ខណៈសំគាល់ដោយអន្លង់នេះមានជួរថ្មនៅក្បាលអន្លង់ឈ្មោះថា ជួរផ្លុយ រីឯកន្ទុយអន្លង់ក៏មានជួរមួយដែរឈ្មោះថា ជួរតា-សួស (មានឈ្មោះពីដូនតាមក)។ ជាពិសេសអន្លង់ក្រពើនេះ កាលពីមុនសំបូរសត្វក្រពើ និង-បបែល។ កាលពីមុនអ្នកទៅនេសាទមិនហ៊ានចុះជ្រមុជទឹកនៅអន្លង់នេះទេ ដោយខ្លាចក្រពើ និងបបែល ហើយអន្លង់នេះមានទីតាំងមិនសូវឆ្ងាយពីអន្លង់តាសួសទេ ។

**ចំណុចនៅលើ GPS :**

- អាប់ស៊ីស = ០៦៥៦១១
- អរដោនេ =១៥១២៥៧១
- រយៈកំពស់ =

ខ. លក្ខណៈរូប :

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ៧ម ឆ្នាំ ២០០៦ = ៣,០០ ម
- ទំហំ :មុនឆ្នាំ ១៩៩៥ =១០០ម x ៣០ម ឆ្នាំ ២០០៦ = ១០០ម x ៣០ម

គ. មជ្ឈដ្ឋានជុំវិញ

♦ រដូវប្រាំង : មានជួរថ្ម ដែលជាថ្មពីមុនក្រពើធ្លាប់ឡើងមកសំងិលខ្លួនលេង និងដើមរៃជាច្រើននៅមាត់អន្លង់ខាងឆ្វេងជាប់ច្រាំងទន្លេ(បើចុះតាមខ្សែទឹកមកក្រោម) ឯផ្នែកម្ខាងទៀតមានថ្មប៉ប្រះទឹកហើយទឹកហូរខ្លាំង និងបាតអន្លង់ក៏មានថ្មច្រើនដែរ ។ កំពស់ទឹកនៅរដូវប្រាំង ចាប់ពីខែ មករា ដល់ខែ ឧសភា ផ្ទៃរាបស្មើទន្លេកំពស់ ០,៥- ១,៥០ម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃអន្លង់ទាំងអស់មិនអាចមើលឃើញផ្ទាំងថ្ម ជួរថ្ម និងរុក្ខជាតិផ្សេងៗទៀតទេ ។ ហើយកំពស់ទឹកនៅរដូវវស្សា ចាប់ពីខែសីហា ដល់ខែ វិច្ឆិកា ឡើងដល់ ៩,៣៥ ម៉ែត្រ ។

ឃ. ប្រភេទសត្វ :

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីឆ្កិន, ត្រីប៉ាវ៉ា , ត្រីប៉ាស៊ីអ៊ី, ត្រីឆ្តោ, ត្រីព្រួល, ត្រីផ្ទក់, ត្រីចង្វា, ត្រីណាក, ត្រីកែស, ត្រីរាហូ, ត្រីតាសេក, ត្រីខ្យា, ពស់, ត្រំ និងខ្មៅ ។

- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, ពពូល, រំពេ, ត្រដេវវិច, ត្រសេះ, លលក,មាន់ព្រៃ និងអក។

- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ, ប្រើស និងសត្វស្វា ។

- ប្រភេទល្មូន : អណ្តើក, កន្ធាយ, រមិច, ត្រកួត និងបបែល ។



ង. ប្រភេទរុក្ខជាតិ

ដើមរៃ ដើមផ្កាអណ្តែង នៅក្នុងទន្លេហើយនៅតាមច្រាំងទន្លេនៃអន្លង់ក្រពើមានប្រភេទរុក្ខជាតិមិនខុសពីអន្លង់តាសួស ទេដូចជា គុម្ពឫស្សី, ដើមគគីរ, ដើមពពេល, ដើមត្រស់, ដើមជ្រៃញទួយ, ដើមល្វា, ដើមសាខ័រ, ដើមរាំងទឹក, ដើមសណ្តាន់, ដើមក្តុល, ដើមក្បោ, ដើមឈើទាល, ដើមចំបក់, ដើមស្រឡៅ, ដើមស្តី, ដើមព្រីងទឹក និងដើមរំដេញ ។ល។

ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន

- ប្រភពអ្នកនេសាទ : មកពីភូមិ ស្រែគរ១ ស្រែគរ២ ខ្សាច់ថ្មី ក្រឡាពុះ និងភូមិស្វាយរៀង ។

- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :

- សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២.0 ស.ម រហូតទៅដល់ ១០ ស.ម

-ក្រឡា ២ - ១០ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក)

- សន្ទូច : នេសាទនៅខែមិថុនា ដល់ ខែ ធ្នូ ។ បច្ចុប្បន្នសន្ទូចប្រើប្រាស់ផ្លែលេខ ១០- ១៤ ។

- មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅតាមរដូវកាលដូចជា នៅរដូវប្រាំងប្រើក្រឡា ២,៥០ ទៅ ៦ស.ម និង នៅរដូវវស្សាប្រើក្រឡា ៤ ទៅ ១០ ស.ម ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ មករា

*( កាលបរិច្ឆេទ ថ្ងៃទី ១២ ឧសភា ឆ្នាំ២០០៦)*

**៣.២២.៥ អន្លង់អង់គូរ**

ក. ទីតាំង

អន្លង់អង់កូរ មានចំងាយ ២-៣គ.ម ពីភូមិខ្សាច់ថ្មី ឃុំតាឡាត នៅភាគខាងក្រោមខ្សែទឹកនៃភូមិ ហើយប្រជាពលរដ្ឋតែងតែហៅឈ្មោះតៗគ្នារៀងមកដោយមានលក្ខណៈសំគាល់អន្លង់

នេះគឺ មានជួរថ្មធំៗនៅចំណុចអន្លង់ និងដើមផ្កាអណ្តែងជាច្រើន (មានឈ្មោះពីដូនតាមក)។ ជាពិសេសអន្លង់អង់កូរកាលពីមុនសំបូរសត្វ និងត្រី ព្រោះមានទីតាំងមិនសូវឆ្ងាយពីអន្លង់ ក្រពើឡើយ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៥៦១១
- អរដោនេ =១៥១២៩៧១
- រយៈកំពស់ =

**ខ. លក្ខណៈរូប**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៥ម, ឆ្នាំ ២០០៦ = ០ ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =១០០ម x ៣០ម ឆ្នាំ ២០០៦ = ស្មើទន្លេ

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : មានជួរថ្ម ដែលជាថ្មកាលពីមុនក្រពើធ្លាប់ឡើងមកសំងិលខ្លួនលេង និង-មានដើមរៃជាច្រើននៅមាត់អន្លង់ ខាងឆ្វេងជាប់ច្រាំងទន្លេ (បើចុះតាមខ្សែទឹកមកក្រោម) រីឯផ្នែកម្ខាងទៀតមានថ្មប៉ប្រះទឹក ហើយបាតអន្លង់មានថ្មច្រើនចំណែកទឹកហូរខ្លាំងនៅត្រង់ចំណុចអន្លង់ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃអន្លង់ទាំងអស់ មើលមិនឃើញផ្ទាំងថ្ម ជួរថ្ម និងរុក្ខជាតិផ្សេងៗទៀតដែលនៅជុំវិញនោះឡើយ ។ ហើយកំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកាឡើង ៩,៣៥ម៉ែត្រ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីចង្វា, ត្រីលេញ និង ត្រីអាចម៍កុក ។
- ប្រភេទសត្វស្លាបរួមមាន : កុក, ពពូល, រំពេ, ត្រដេវរិច, ត្រសេះ, លលក និង មាន់ព្រៃ ។
- ថនិកសត្វ : គ្មាន
- ប្រភេទល្មូន : គ្មាន

**ង. ប្រភេទរុក្ខជាតិ**

ដើមរៃ ដើមផ្កាអណ្តែង នៅក្នុងទន្លេហើយនៅតាមច្រាំងទន្លេនៃអន្លង់អង់កូរមានប្រភេទរុក្ខជាតិមិនខុស ពីអន្លង់ក្រពើទេដូចជា គុម្ពឫស្សី, ដើមគគីរ, ដើមពពេល, ដើមត្រស់, ដើមជៃញទួយ, ដើមល្វា, ដើមសាខ័រ, ដើមរាំងទឹក, ដើមសណ្តាន់, ដើមក្តុល, ដើមក្បោ, ដើមឈើទាល, ដើមចំបក់, ដើមស្រឡៅ, ដើមស្តី, ដើមព្រីងទឹក និងដើមរំដេញ ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ ខ្សាច់ថ្មី ក្រឡាពុះ និងភូមិស្វាយរៀង ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២.០ ស.ម រហូតទៅដល់ ១០ ស.ម
  - ក្រឡា ២,០០ - ១០ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក) ។
  - សន្ទូច : នេសាទនៅខែ មិថុនា ដល់ខែ ធ្នូ ។ សន្ទូចប្រើប្រាស់បច្ចុប្បន្ន ប្រើផ្លែលេខ ១០- ១៤ ។
  - មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅតាមរដូវកាល ដូចជានៅរដូវប្រាំងប្រើក្រឡា ២,៥០ ទៅ ៦ ស.ម និងនៅរដូវវស្សាប្រើក្រឡា៤ ទៅ ១០ ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ មករា ។

**៣.២២.៦ អន្លង់កំបោរ**

**ក. ទីតាំង**

អន្លង់កំបោរ ស្ថិតនៅជាប់នឹងភូមិ (ទល់មុខភូមិ)ខ្សាច់ថ្មី ឃុំតាឡាតតែម្តង ។

ប្រជាពលរដ្ឋនាំគ្នា ហៅអន្លង់កំបោរតៗគ្នារៀងមក និងមានលក្ខណៈសំគាល់មួយគឺ មានអូរមួយហូរកាត់អន្លង់នេះហៅថា អូរកំបោរ អូរនេះពីមុនមានថ្មកំបោរហើយថ្មនេះ ប្រជាពលរដ្ឋយក ទៅដុតធ្វើជាកំបោរហូប ។ មិនតែប៉ុណ្ណោះនៅក្បាលអន្លង់ មានថ្មកាំង ហើយខាងកន្ទុយ-មានថ្មប៉ប្រះទឹក ( អន្លង់នេះមានឈ្មោះពីដូនតាមក គឺ១៩១៨) ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៦១៨០៥
- អរដោនេ =១៥១១១០៤
- រយៈកំពស់ =

**ខ. លក្ខណៈរូប :**

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ១០ម ឆ្នាំ ២០០៦ = ៨,៨០ ម
- ទំហំ :មុនឆ្នាំ ១៩៩៥ =៣០០ម x ១៥០ម ឆ្នាំ ២០០៦ = ៣០០ម x ៦០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : នៅជុំវិញមាត់អន្លង់ព័ទ្ធដោយជួរថ្មជាច្រើន គឺនៅច្រាំងទន្លេខាង ស្តាំ បើនិ-យាយតាមខ្សែទឹកឡើងពីក្រោមទៅលើ ។ នៅផ្នែកខាងឆ្វេងអន្លង់មានខ្សាច់ដុះច្រើន និង-មានរ៉ែមាសដែលកន្លងមកប្រជាពលរដ្ឋធ្លាប់បានជីកយក។ នៅក្នុងបាតអន្លង់មានថ្មច្រើនរីឯផ្នែកម្ខាងទៀតមានថ្មប៉ប្រះទឹក និងល្បាក់ទឹកហូរដោយមានថ្មលាយឡំផងដែរ ។ ជាពិសេសបច្ចុប្បន្នអន្លង់កំបោរនេះសំបូរត្រីជាងអន្លង់ដទៃៗទៀត ព្រោះមានទីតាំងនៅជិតភូមិដោយពុំ-មានការប្រព្រឹត្តបទល្មើសនេសាទទេ ។ កំពស់ទឹកនៅខែប្រាំងចាប់ពី ខែមករា ដល់ខែ ឧសភាគិតចាប់ពីលើផ្ទៃអន្លង់កំពស់ ០,៥-១,៥០ម ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃលើមាត់អន្លង់ទាំងអស់ ដែលធ្វើឱ្យយើងមិនអាចមើលឃើញផ្ទាំងថ្ម និងខ្សាច់ដែលដុះទៀតទេ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពីខែសីហា ដល់ខែ វិច្ឆិកា ប្រហែលជា ១០,០៥ម៉ែត្រ ។



**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីប៉ាមូក, ត្រីឆ្កិន, ត្រីប៉ាញ៉ន, ត្រីប៉ាវ៉ា, ត្រីប៉ាស៊ីអ៊ី, ត្រីឆ្តោ, ត្រីព្រួល, ត្រីផ្ទក់, ត្រីចង្វា, ត្រីណោក, ត្រីកែស, ត្រីរាហូ, ត្រីតាសេក, ត្រីខ្យា, ត្រំ និងខ្ចៅ ។
- ប្រភេទសត្វស្លាបរួមមាន : កុក, ពពូល, វំពេ, លលក, មាន់ស្រុក និងទា ។
- ថនិកសត្វ :គោ, ក្របី និងជ្រូកស្រុក ។
- ប្រភេទល្មូន : អណ្តើក, កន្ធាយ, រមិច, ពស់ និងបបែល ។

**ង. ប្រភេទរុក្ខជាតិ**

មានដើមរ៉ៃ ដើមផ្កាអណ្តែងនៅក្នុងទន្លេ ហើយនៅតាមច្រាំងទន្លេនៃអន្លង់មានប្រភេទរុក្ខជាតិដូចជា ដើមស្តី, ដើមត្រស់, គុម្ពឫស្សី, ដើមដៃញទួយ, ដើមល្វា, ដើមរំដេញ និងដើមស្វាយ ។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : ខ្សាច់ថ្មី ក្រឡាពុះ និងភូមិស្វាយរៀង ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២ ស.ម រហូតដល់ ១០ ស.ម ។
  - ក្រឡា ២ - ១០ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា ( រដូវទឹកសម្រក)
  - សន្ទូចៈ នេសាទនៅខែមិថុនា ដល់ ធ្នូ បច្ចុប្បន្នសន្ទូចប្រើប្រាស់ផ្លែលេខ៨- ១០
  - មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅ តាមរដូវកាលដូចជា នៅរដូវប្រាំងប្រើក្រឡា ២,៥០ ទៅ ៦ ស.ម និងនៅរដូវវស្សាប្រើក្រឡា ៤ ទៅ ១០ ស.ម ។
  - ចាន់ និងលប : នេសាទចាប់ពីខែ សីហា ដល់ខែ មករា ។
  - តុំ : នេសាទពីខែ មករា ទៅខែ ឧសភា

*( កាលបរិច្ឆេទ ថ្ងៃទី ១២ ឧសភា ឆ្នាំ២០០៦)*

## ៣.២៣ ភូមិក្រឡាពុះ ឃុំតាឡាត

ភូមិក្រឡាពុះ ជាភូមិមួយដែលស្ថិតនៅតាមបណ្តោយដងទន្លេសេសាន ឃុំតាឡាត នៅត្រើយម្ខាងនៃទន្លេទល់មុខ ភូមិស្វាយរៀង ។ តាមពិតភូមិនេះស្ថិតនៅក្នុងចំណុះភូមិស្វាយរៀង មានចំងាយផ្លូវទឹក ៨៨គ.ម ផ្លូវគោក ៩៩គ.មពីទីរួមខេត្តស្ទឹងត្រែង ។ មានប្រជាពលរដ្ឋរស់នៅចំនួន ៤៥ គ្រួសារ មាន៣០ខ្នងផ្ទះ ប្រជាពលរដ្ឋសរុប ២០០នាក់ ស្រី៩២នាក់ ។ ភូមិនេះមានអន្លង់ចំនួន ៣កន្លែងគឺ អន្លង់គែន អន្លង់ស្វាយ និងអន្លង់អូរក្រឡាពុះ។ ហើយក្នុងចំណោម-អន្លង់ទាំងនេះមានអន្លង់មួយហៅថា អន្លង់អូរក្រឡាពុះ ត្រូវរាក់ស្មើរស្មើបាតទន្លេ ដែលពីមុន-មានជំរៅ ៨ម បច្ចុប្បន្ននៅសល់ត្រឹមតែ ០,៥០ម ប៉ុណ្ណោះ ។ ហើយអន្លង់មួយចំនួនទៀតមានជំរៅ ១ម ទៅ ៣ម ប៉ុណ្ណោះ ។



អ្នកស្រុកសេសាន កំពុងអង្គុយពិភាក្សា អំពីអន្លង់ និងការហូរមិនទៀតទាត់នៃរបបទឹកទន្លេសេសានចាប់តាំងពីឆ្នាំ ១៩៩៦មក ហើយពួកគាត់កំពុងរិះរកមធ្យោបាយ ដើម្បីស្វែងរកដំណោះស្រាយសមស្របមួយ ដែលអាចទទួលយកបានទាំងអស់គ្នា



តារាង១២ ឈ្មោះអន្លង់ ភូមិក្រឡាពុះ ឃុំតាឡាត

| ល.រ | ឈ្មោះអន្លង់ | ជំរៅអន្លង់(ម) | | ទំហំអន្លង់ពីមុន(ម) | | ទំហំអន្លង់បច្ចុប្បន្ន(ម) | | កូអរដោនេ | |
|---|---|---|---|---|---|---|---|---|---|
| | | មុន១៩៩៦ | បច្ចុប្បន្ន | បណ្តោយ | ទទឹង | បណ្តោយ | ទទឹង | អរដោនេ | អាប់ស៊ីស |
| ១ | គែន | ៨ | ២ | ៣០០ | ២០០ | ៣០០ | ១៥០ | ១៥១៣៨០០ | ០៦៦៣៩១៦ |
| ២ | ស្វាយ | ៥ | ២ | ២៥០ | ២០០ | ២០០ | ២០០ | ១៥១៤៩៤៣ | ០៦៦៤២៣៨ |
| ៣ | អូរក្រឡាពុះ | ៨ | ០,៥០ | ២០០ | ២០០ | ១០០ | ១០០ | ១៥១៥៨៤៦ | ០៦៦៥៥២៨ |

### ៣.២៣.១ អន្លង់គែន

**ក. ទីតាំង**

អន្លង់គែន មានចំងាយ ២-៣គ.មពីភូមិក្រឡាពុះ ឃុំតាឡាត ស្ថិតនៅភាគខាងក្រោមខ្សែទឹកនៃភូមិ ។ ប្រជាពលរដ្ឋតែងតែហៅឈ្មោះអន្លង់គែនត១គ្នារៀងមក និងមានលក្ខណៈសំគាល់ដោយអន្លង់នេះមានថ្មនៅខាងក្បាលអន្លង់ និងដើមផ្កាអណ្ដែងជាច្រើន និងមានអូរមួយហូរចាក់ហៅថា អូរគែន ទើបគេហៅថាអន្លង់គែន (អន្លង់នេះមានឈ្មោះពីដូនតាមក)។ ជាពិសេសអន្លង់គែនកាលពីមុនសំបូរសត្វព្រៃចូលផឹកទឹក និងមានត្រីច្រើនប្រភេទ ដោយសារវាមានទីតាំងមិនសូវឆ្ងាយពីភូមិប៉ុន្មានទេ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៦៣៩១៦
- អរដោនេ =១៥១៣៨០០
- រយៈកំពស់ = (មិនបានវាស់)

**ខ. លក្ខណៈរូប :**

- ជំរៅ : មុនឆ្នាំ ១៩៩៥ = ៨ម, ឆ្នាំ ២០០៦ = ២ម
- ទំហំ : មុនឆ្នាំ ១៩៩៥ =៣០០ម x ២០០ម ឆ្នាំ ២០០៦ = ៣០០ម x ១៥០ម

**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : មានថ្មនៅក្បាលអន្លង់ និងមានដើមរៃ ដើមផ្កាអណ្ដែងខ្លះ១ នៅ-មាត់អន្លង់ជាប់ច្រាំងទន្លេទាំងសងខាង (បើចុះតាមខ្សែទឹកមកក្រោម) បាតអន្លង់មានថ្មច្រើន ហើយទឹកហូរល្មម ។ នៅខែប្រាំងចាប់ពី ខែមករា ដល់ខែឧសភា កំពស់ទឹកមានត្រឹមតែ ០,៥០-១,៥០ម ពីផ្ទៃរាបទឹកទន្លេ ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃអន្លង់ទាំងអស់ ហើយពុំអាចមើលឃើញផ្ទាំងថ្ម និងរុក្ខជាតិផ្សេង១ដែលដុះនៅទីនោះទៀតឡើយ ។ កំពស់ទឹក នៅរដូវវស្សាចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ៩,៣៥ម៉ែត្រ ។



**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីឆ្កិន, ត្រីឆ្ដោ, ត្រីព្រួល, ត្រីផ្ទក់, ត្រីចង្វា, ត្រីកែស, ត្រីតាសេក, ត្រីត្រនេល, ត្រំ និងខ្ចៅ ។
- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, រំពេ, ត្រដេវវិច, ត្រសេះ, លលក, មាន់ព្រៃ និងសត្វជើងទៀន ។
- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ និងសត្វស្វា ។
- ប្រភេទល្មូន : ត្រកួត, បបែល និងពស់ ។

**ង. ប្រភេទរុក្ខជាតិ**

ដើមរៃ ដើមផ្កាអណ្ដែងមានដុះនៅក្នុងទន្លេ ហើយនៅតាមច្រាំងទន្លេនៃអន្លង់គែន គឺពុំសូវមានប្រភេទរុក្ខជាតិដុះច្រើនទេដែលរុក្ខជាតិទាំងនោះមានដូចជា គុម្ពឫស្សី, ដើមគគីរ, ដើម-ពពេល, ដើមត្រស់, ដើមដែញទួយ, ដើមល្វា, ដើមសាខ័រ, ដើមសណ្ដាន់, ដើមក្តុល, ដើមឈើ-ទាល, ដើមស្រឡៅ, ដើមស្ដី និងរំដេញ ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយការរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ ខ្សាច់ថ្មី ក្រឡាពុះ និងភូមិស្វាយរៀង ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២.០ ស.ម រហូតទៅដល់ ១០ ស.ម ។
  - ក្រឡា ២ - ៨.០ ស.ម ប្រើចាប់ពីខែ វិច្ឆិកា ដល់ខែ មិថុនា (រដូវទឹកសម្រក)
  - សន្ទូច : នេសាទនៅខែ មិថុនា ដល់ខែ ធ្នូ ។ សន្ទូចប្រើប្រាស់ផ្លែបច្ចុប្បន្ន ប្រើលេខ ១០- ១២ ។
  - មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅតាមរដូវកាលដូចជានៅរដូវប្រាំង ប្រើក្រឡា ២,៥០ ទៅ ៦ស.ម និងនៅរដូវវស្សាប្រើក្រឡា ៤ ទៅ ១០ ស.ម ។
  - ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ មករា ។

### ៣.២៣.២ អន្លង់ស្វាយ

អន្លង់ស្វាយ មានចំងាយ១-២គ.ម ពីភូមិក្រឡាពុះ ឃុំតាឡាត ស្ថិតនៅភាគខាងក្រោមខ្សែទឹកនៃភូមិ ។ ប្រជាពលរដ្ឋតែងតែហៅឈ្មោះថា អន្លង់ស្វាយតៗគ្នារៀងមក ដោយពីមុន អន្លង់ស្វាយ និងអន្លង់ក្រឡាពុះនៅជាប់គ្នា ដល់ក្រោយមកទៀតមានដើមស្វាយព្រៃមួយដើមធំបានដុះនៅទីនោះ ទើបគេហៅចំណុចនេះថា អន្លង់ស្វាយតរៀងមក ។ ក្រៅពីចំណុចខាងលើនៅ-មានលក្ខណៈសំគាល់ផ្សេងទៀតដោយអន្លង់នេះមានថ្មនៅខាងក្បាលអន្លង់ និងនៅឯកន្ទុយអន្លង់ គឺនៅចំកណ្តាល និងមានដើមផ្កាអំណ្តែងដុះជាច្រើននៅទីនោះ ( អន្លង់នេះមានឈ្មោះពីដូនតាមកដែរ) ។ ជាពិសេសអន្លង់ស្វាយ កាលពីមុនសំបូរសត្វព្រៃចូលផឹកទឹក និងមានត្រីច្រើនប្រភេទ ដោយវាមានទីតាំងមិនសូវឆ្ងាយ ពីភូមិប៉ុន្មាន ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៦៤២៣៨
- អរដោនេ =១៥១៤៩៤៣
- រយៈកំពស់ =

**ខ. លក្ខណៈរូប**

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ៥ម បច្ចុប្បន្នខែ ឧសភាឆ្នាំ ២០០៦ = ២ម
- ទំហំ :មុនឆ្នាំ ១៩៩៥ =២៥០ម x ២០០ម បច្ចុប្បន្នខែ ឧសភា ឆ្នាំ ២០០៦ = ២០០ម x ២០០ម

**គ. មជ្ឍដ្ឋានជុំវិញ**

♦ រដូវប្រាំង : មានថ្មនៅក្បាលអន្លង់ និងបាតអន្លង់ក៏មានថ្មច្រើនដែរ ហើយ-មាត់អន្លង់ជាប់ច្រាំងទន្លេខាងស្តាំ មានដើមរៃ ដើមផ្កាអំណ្តែងដុះខ្លះៗ (បើចុះតាមខ្សែទឹកពីលើមកក្រោម) ដែលមានចរន្តទឹកហូរល្មមមិនបង្កការលំបាកដល់ការធ្វើដំណើរទេ ។ កំពស់ទឹកនៅខែប្រាំង ចាប់ពីខែមករា ដល់ខែ ឧសភា ( ០,៥០-១,៥០ម) ផ្ទៃរាបទឹកទន្លេ ។



♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃអន្លង់ទាំងអស់ ធ្វើឱ្យយើងមិនអាចមើលឃើញផ្ទាំងថ្ម និងរុក្ខជាតិ ដែលដុះនៅរដូវប្រាំងបានទៀតឡើយ ។ ហើយកំពស់ទឹកនៅរដូវវស្សា ចាប់ពីខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ៩,៣៥ ម៉ែត្រ ។

**ឃ. ប្រភេទសត្វ :**

- ត្រីដែលប្រជាជននេសាទបានរួមមាន ត្រីរៀល, ត្រីឆ្លាំង, ត្រីក្អែក, ត្រីឆ្ពិន, ត្រីឆ្តោ, ត្រីព្រួល, ត្រីផ្ទក់, ត្រីចង្វា, ត្រីកែស, ត្រីតាសេក, ត្រីត្រនេល, ត្រំ និងខ្ជៅ ។
- ប្រភេទសត្វស្លាបរួមមាន : កុក, ក្អែកទឹក, រំពេ, ត្រដេវិច, ត្រសេះ, លលក, មាន់ព្រៃ និង សត្វជើងទៀន ។
- ថនិកសត្វ : ឈ្លូស, ជ្រូកព្រៃ និងសត្វស្វា ។
- ប្រភេទល្មូន : ត្រកួត, បបែល និងពស់ ។

**ង. ប្រភេទរុក្ខជាតិ**

ដើមរៃ ដើមផ្កាអំណ្តែងដុះនៅក្នុងទន្លេ ចំណែកនៅតាមច្រាំងទន្លេនៃអន្លង់ស្វាយ គឺមិនសូវមានប្រភេទរុក្ខជាតិច្រើនទេ ។ រុក្ខជាតិដែលនៅតាមច្រាំងទន្លេមាន ដូចជា គុម្ពឫស្សី, ដើមគគីរ, ដើមពពេល, ដើមត្រស់, ដើមដែញទ្វយ, ដើមល្វា, ដើមសាខ័រ, ដើមសណ្តាន់, ដើមក្តុល, ដើមឈើទាល, ដើមស្រឡៅ, ដើមស្តី និងរំដេញ ។ល។

**ច. ទំនាក់ទំនងរវាងអន្លង់ជាមួយកំរិតជីវភាពរបស់ប្រជាជន**

- ប្រភពអ្នកនេសាទ : មកពីភូមិ ខ្សាច់ថ្មី ក្រឡាពុះ និងភូមិស្វាយរៀង ។
- ការប្រើប្រាស់ឧបករណ៍នេសាទ និង ពេលវេលា :
  - សំណាញ់ : គឺប្រើប្រាស់ចាប់ពីក្រឡា ២ ស.ម រហូតដល់ ១១ ស.ម ។
  - ក្រឡា ២ ទៅ ៨ ស.ម ប្រើចាប់ពី ខែវិច្ឆិកា ដល់ ខែមិថុនា ( រដូវទឹកសម្រក)
  - សន្ទូច : នេសាទនៅខែ មិថុនា ដល់ខែ ធ្នូ ។ បច្ចុប្បន្នសន្ទូចប្រើប្រាស់ផ្លែលេខ ១០ ទៅ លេខ ១២ ។
  - មង : ប្រើប្រាស់នៅគ្រប់រដូវ ហើយការប្រើប្រាស់ឧបករណ៍ទៅតាមរដូវកាល

របស់វាមានដូចជា នៅរដូវប្រាំងប្រើក្រឡា ២,៥០ ទៅ ៦ ស.ម និងនៅរដូវវស្សាប្រើក្រឡា ៤ ទៅ ១០ ស.ម ។

- ចាន់ : នេសាទចាប់ពីខែ សីហា ដល់ខែ មករា ។

**៣.២៣.៣ អន្លង់អូរក្រឡាពុះ:**

**ក. ទីតាំង**

អន្លង់ស្វាយ មានចំងាយ ៣០០ម ពីភូមិក្រឡាពុះ ឃុំតាឡាត ស្ថិតនៅភាគខាងក្រោមខ្សែទឹកនៃភូមិ (បើគិតខ្សែទឹកពីក្រោមឡើងទៅលើ) ។ ហើយប្រជាពលរដ្ឋតែងតែហៅឈ្មោះអន្លង់ក្រឡាពុះត១គ្នារៀងមក ដោយពីមុនអន្លង់អូរក្រឡាពុះ និងអន្លង់ស្វាយនៅជាប់គ្នា មិនតែប៉ុណ្ណោះអន្លង់នេះនៅមានអូរមួយហូរចាក់ គឺអូរក្រឡាពុះ ទើបគេហៅចំណុចនេះថា អន្លង់ក្រឡាពុះតរៀងមក ។ ម្យ៉ាងវិញទៀតមានលក្ខណៈសំគាល់ដោយអន្លង់នេះមិនមាន ថ្មដូចអន្លង់ដទៃ១ទេ គឺមានតែគុម្ពគ្រោះនៅខាងច្រាំងអន្លង់ និងដើមផ្កាអណ្ដែងបន្តិចបន្តួចប៉ុណ្ណោះ (អន្លង់នេះមានឈ្មោះពីដូនតាមកដែរ)។ ជាពិសេសអន្លង់នេះ កាលពីមុនសំបូរសត្វព្រៃចូលផឹកទឹក និងមានត្រីច្រើនប្រភេទ ដោយមានទីតាំងជាប់កន្ទុយភូមិមិនមានបទល្មើសនេសាទ ។

**<u>ចំណុចនៅលើ GPS :</u>**

- អាប់ស៊ីស = ០៦៦៤៥២៨
- អរដោនេ =១៥១៩៤៤៦
- រយៈកំពស់ = (មិនបានវាស់)

**ខ. លក្ខណៈរូប :**

- ជំរៅ :មុនឆ្នាំ ១៩៩៥ = ៨ម បច្ចុប្បន្នខែ ឧសភាឆ្នាំ ២០០៦ = ០,៥០ម
- ទំហំ :មុនឆ្នាំ ១៩៩៥ =២០០ម x ២០០ម បច្ចុប្បន្ន ខែ ឧសភា ឆ្នាំ ២០០៦ = ១០០ម x ១០០ម



**គ. មជ្ឈដ្ឋានជុំវិញ**

♦ រដូវប្រាំង : យើងអាចមើលឃើញមានតែដើមរៃ និង-ផ្កាអណ្ដែងខ្លះ១នៅមាត់ អន្លង់ជាប់ច្រាំងទន្លេខាងស្ដាំ (បើចុះតាមខ្សែទឹកពីលើមកក្រោម ) ហើយចរន្តទឹកហូរមិនសូវ ខ្លាំងទេ ។ កំពស់ទឹកនៅខែប្រាំងចាប់ពី ខែ មករា ដល់ខែ ឧសភា ០,៥០-១,៥០ម (ផ្ទៃរាប ទឹកទន្លេ) ។

♦ រដូវវស្សា : នៅរដូវវស្សាកំពស់ទឹកឡើងខ្ពស់លិចផ្ទៃអន្លង់ទាំងអស់ មើលមិនឃើញរុក្ខជាតិដែលដុះទៀតទេ ។ កំពស់ទឹកនៅរដូវវស្សា ចាប់ពី ខែ សីហា ដល់ខែ វិច្ឆិកា ឡើងដល់ ៩,៣០ម៉ែត្រ ។

**ឃ. ប្រភេទសត្វ :**

